# ព្រះ

# ត្រៃបិដកបាលី

នឹង

សេចក្ដីប្រែជាភាសាខ្មែរ

# សុត្តន្តបិដក

## មជ្ឈិមនិកាយ ឧបរិបណ្ណាសក

អដ្ឋមភាគ

# ២៧

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥០៥

# សុត្តន្តបិដក

## មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ

## អដ្ឋមភាគ

២៧

ព.ស. ២៥០៨

# សុត្តន្តបិដកេ មជ្ឈិមនិកាយស្ស

## ឧបរិបណ្ណាសកំ

## អដ្ឋមោ ភាគោ

---

## សុញ្ញតវគ្គោ

### បឋមំ ចូឡសុញ្ញតសុត្តំ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ ។ អថខោ អាយស្មា អានន្ទោ សាយណ្ហសមយំ បដិ-សល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគ-វន្តំ ឯតទវោច ឯកមិទំ ភន្តេ សមយំ ភគវា

# សុត្តន្តបិដក មជ្ឈិមនិកាយ

## ឧបរិបណ្ណាសកៈ

## អដ្ឋមភាគ

---

## សុញ្ញតវគ្គ

### ចូឡសុញ្ញតសូត្រទី ១

(១) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងប្រាសាទរបស់មិគារមាតា ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទមានអាយុ ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ គង់ក្នុងទីសមគួរហើយ ក៏ទូលសួរនឹងព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សម័យមួយ ព្រះមានព្រះភាគ

សក្កេសុ វិហរតិ នគរកំ នាម សក្យានំ និគមោ តត្ថ មេ ភន្តេ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ សុញ្ញតាវិហារេនាហំ អានន្ទ ឯតរហិ ពហុលំ វិហរាមីតិ កច្ចិ មេតំ ភន្តេ សុស្សុតំ សុគ្គហិតំ សុមនសិកតំ សុប្បធារិតន្តិ ។

(២) តគ្ឃ តេ ឯតំ អានន្ទ សុស្សុតំ សុគ្គហិតំ សុមនសិកតំ សុប្បធារិតំ ។ បុព្វេបាហំ អានន្ទ ឯតរហិ ច សុញ្ញតាវិហារេន ពហុលំ វិហរាមិ ។ សេយ្យថាបិ អានន្ទ[១] អយំ មិគារមាតុបាសាទោ សុញ្ញោ ហត្ថិគវស្សវឡវេន សុញ្ញោ ជាតរូបរជតេន សុញ្ញោ ឥត្ថីបុរិសសន្និបាតេន ។ អត្ថិ ចេវិទំ អសុញ្ញតំ យទិទំ ភិក្ខុសង្ឃំ បដិច្ច ឯកត្តំ ឯវមេវ ខោ អានន្ទ ភិក្ខុ អមនសិករិត្វា គាមសញ្ញំ អមនសិករិត្វា មនុស្សសញ្ញំ អរញ្ញសញ្ញំ បដិច្ច មនសិ ករោតិ ឯកត្តំ ។

១ ម. អានន្ទាតិ ន ទិស្សតិ ។



គង់ក្នុងនគរកៈ ជានិគមរបស់ពួកសក្យៈ ក្នុងសក្កជនបទ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានរៀនក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគក្នុងទីនោះថា ម្នាលអានន្ទ ឥឡូវនេះ តថាគតនៅច្រើន ដោយការនៅស្ងប់ស្ងាត់ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនុ៎ះ ឈ្មោះថាខ្ញុំព្រះអង្គ បានស្តាប់ដោយប្រពៃ បានរៀនដោយប្រពៃ បានធ្វើទុកក្នុងចិត្តដោយប្រពៃ បានចងចាំដោយប្រពៃហើយឬ ។

(២) ព្រះមានព្រះភាគត្រាស់ថា អើអានន្ទ ពាក្យនុ៎ះ ឈ្មោះថាអ្នកបានស្តាប់ដោយប្រពៃ រៀនដោយប្រពៃ ធ្វើទុកក្នុងចិត្តដោយប្រពៃ ចងចាំដោយប្រពៃហើយ ។ ម្នាលអានន្ទ កាលពីដើមក្តី ឥឡូវនេះក្តី តថាគតធ្លាប់នៅច្រើន ដោយការនៅស្ងប់ស្ងាត់ ។ ម្នាលអានន្ទ ប្រាសាទរបស់មិគារមាតានេះ សូន្យចាកដំរី គោ សេះ លា សូន្យចាកមាសនឹងប្រាក់ សូន្យចាកការជួបជុំស្រីនឹងប្រុសអស់ហើយ ។ តែទីនេះ មិនមែនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យភិក្ខុសង្ឃ មានឧបមាដូចម្តេចមិញ ម្នាលអានន្ទ មានឧបមេយ្យដូចជា ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវគាមសញ្ញា (សេចក្តីសំគាល់ថាស្រុក) មិនធ្វើទុកក្នុងចិត្តនូវមនុស្សសញ្ញា (សេចក្តីសំគាល់ថាមនុស្ស) ទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យអរញ្ញសញ្ញា (សេចក្តីសំគាល់ថាព្រៃ) ក៏ដូច្នោះដែរ ។

តស្ស អរញ្ញសញ្ញាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ[១] ។ សោ ឯវំ បជានាតិ យេ អស្សុ ទរថា គាមសញ្ញំ បដិច្ច តេធ ន សន្តិ យេ អស្សុ ទរថា មនុស្សសញ្ញំ បដិច្ច តេធ ន សន្តិ អត្ថិ ចេវាយំ ទរថមត្តា យទិទំ អរញ្ញសញ្ញំ បដិច្ច ឯកត្តន្តិ ។ សោ សុញ្ញមិទំ សញ្ញាគតំ គាមសញ្ញាយាតិ បជានាតិ សុញ្ញមិទំ សញ្ញាគតំ មនុស្សសញ្ញាយាតិ បជានាតិ ។ អត្ថិ ចេវិទំ អសុញ្ញតំ យទិទំ អរញ្ញសញ្ញំ បដិច្ច ឯកត្តន្តិ ។ ឥតិ យំ ហិ ខោ តត្ថ ន ហោតិ តេន តំ សុញ្ញំ សមនុបស្សតិ យំ បន តត្ថ អវសិដ្ឋំ ហោតិ តំ សន្តំ ឥទមត្ថីតិ បជានាតិ ។ ឯវម្បិស្ស ឯសា អានន្ទ យថាភុច្ចា អវិបល្លត្ថា បរិសុទ្ធា សុញ្ញតាវក្កន្តិ ភវតិ ។

១ ម. វិមុច្ចតិ ។



ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ស្ញើស៊ប់ ក្នុងអរញ្ញសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្ដីក្រវល់ក្រវាយ ទាំងឡាយណា នៅមាន ព្រោះអាស្រ័យគាមសញ្ញា សេចក្ដីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្ដីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យមនុស្សសញ្ញា សេចក្ដីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្ដីក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមានសភាពមួយ ព្រោះអាស្រ័យអរញ្ញសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសំគាល់ថាសូន្យ ចាកគាមសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសំគាល់ថាសូន្យ ចាកមនុស្សសញ្ញា ។ តែទីនេះ មិនមែនឈ្មោះថាសូន្យទេ គឺនៅមានសភាពមួយ ព្រោះអាស្រ័យអរញ្ញសញ្ញា ។ ព្រោះហេតុនោះ បើសេចក្ដីក្រវល់ក្រវាយណា មិនដែលមានក្នុងកន្លែងនោះ ភិក្ខុក៏ពិចារណាឃើញ នូវសេចក្ដីក្រវល់ក្រវាយនោះ ថាជារបស់សូន្យ ក្នុងកន្លែងនោះ បើសេចក្ដីក្រវល់ក្រវាយណានៅសេសសល់នៅ ក្នុងកន្លែងនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្ដីក្រវល់ក្រវាយដែលនៅមាននោះថា សេចក្ដីក្រវល់ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្ដីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្លះ ។

(៣) បុន ចបរំ អានន្ទ ភិក្ខុ អមនសិការិត្វា មនុស្សសញ្ញំ អមនសិការិត្វា អរញ្ញសញ្ញំ បឋវីសញ្ញំ បដិច្ច មនសិការោតិ ឯកត្តំ ។ តស្ស បឋវីសញ្ញាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ ។ សេយ្យថាបិ អានន្ទ អាសភចម្មំ[១] សង្កុសតេន សុវិហតំ វិគតវលិកំ ឯវមេវ ខោ អានន្ទ ភិក្ខុ យំ ឥមិស្សា បឋវិយា ឧក្កូលវិក្កូលំ[២] នទីវិទុគ្គំ ខាណុកណ្ដកដ្ឋានំ[៣] បព្វតវិសមំ តំ សព្វំ អមនសិការិត្វា បឋវីសញ្ញំ បដិច្ច មនសិការោតិ ឯកត្តំ ។ តស្ស បឋវីសញ្ញាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ ។ សោ ឯវំ បជានាតិ យេ អស្សុ ទរថា មនុស្សសញ្ញំ បដិច្ច តេធ ន សន្តិ យេ អស្សុ ទរថា អរញ្ញសញ្ញំ បដិច្ច

១ ម. ឧសភចម្មំ ។ ២ ម. ឧក្កូលវិក្កូលំ ។ ៣ ម. ខាណុកណ្ដកធានំ ទិស្សតិ ។ ម. ខាណុកណ្ដកដ្ឋានំ ។



(៣) ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវមនុស្សសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវអរញ្ញសញ្ញាទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យបឋវីសញ្ញា (សេចក្តីសំគាល់ថាដី) ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងបឋវីសញ្ញា ។ ម្នាលអានន្ទ ស្បែកគោ ដែលគេកាសតេស ដោយខ្នាស មានចេញផុតអំពីជ្រួញ ម្នាលអានន្ទ មានឧបមេយ្យដូចជាទីណា ខ្ពស់ ទាប ក្នុងទឹក ក្នុងភក់ មានដង្គត់និងបន្លាច្រូងច្រាង មានភ្នំរដិបរដុប ដែលមាននៅលើផែនដីនេះ ភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវទីទាំងអស់នោះទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យបឋវីសញ្ញា គឺផ្ទៃរាបផែ ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងបឋវីសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យមនុស្សសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យអរញ្ញសញ្ញា

ទេធ ន សន្តិ អត្ថិ ចេវាយំ ទរថមត្តា យទិទំ

បឋវីសញ្ញំ បដិច្ច ឯកត្តន្តិ ។ សោ សុញ្ញមិទំ

សញ្ញាគតំ មនុស្សសញ្ញាយាតិ បជានាតិ សុញ្ញមិទំ

សញ្ញាគតំ អរញ្ញសញ្ញាយាតិ បជានាតិ ។ អត្ថិ

ចេវិទំ អសុញ្ញតំ យទិទំ បឋវីសញ្ញំ បដិច្ច ឯកត្តន្តិ ។

ឥតិ យំ ហិ ខោ តត្ថ ន ហោតិ តេន

តំ សុញ្ញំ សមនុបស្សតិ យំ បន តត្ថ អវសិដ្ឋំ

ហោតិ តំ សន្តំ ឥទមត្ថីតិ បជានាតិ ។ ឯវម្បិស្ស

ឯសា អានន្ទ យថាភុច្ចា អវិបល្លត្ថា បរិសុទ្ធា

សុញ្ញតាវក្កន្តិ ភវតិ ។





សេចក្ដីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្ដី

ក្រវល់ក្រវាយនេះ ប៉ុណ្ណោះនៅមាន គឺនៅមានសភាវៈមួយ ព្រោះ

អាស្រ័យបឋវីសញ្ញា ។ ភិក្ខុនោះដឹងច្បាស់ថា ទីនេះ ជាលំនៅសេចក្ដី

សំគាល់ថាសូន្យ ចាកមនុស្សសញ្ញា ដឹងច្បាស់ថា ទីនេះ ជាលំនៅសេចក្ដី

សំគាល់ថាសូន្យ ចាកអរញ្ញសញ្ញា ។ តែទីនេះ មិនមែនឈ្មោះថាសូន្យ

ទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យបឋវីសញ្ញា ។ ព្រោះហេតុ

នោះ បើសេចក្ដីក្រវល់ក្រវាយណា មិនមានក្នុងទីនោះ ភិក្ខុពិចារណា

ឃើញនូវសេចក្ដីក្រវល់ក្រវាយនោះ ថាជារបស់សូន្យ ក្នុងទីនោះ

បើសេចក្ដីក្រវល់ក្រវាយណា សេសសល់នៅ ក្នុងទីនោះ ភិក្ខុក៏ដឹង

ច្បាស់នូវសេចក្ដីក្រវល់ក្រវាយ ដែលនៅមាននោះថា សេចក្ដីក្រវល់

ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការ

កើតឡើងនៃសេចក្ដីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល

បរិសុទ្ធស្អាត យ៉ាងនេះខ្លះ ។

(៦) បុន ចបរំ អានន្ទ ភិក្ខុ អមនសិការិត្វា អរញ្ញសញ្ញំ អមនសិការិត្វា បឋវីសញ្ញំ អាកាសានញ្ចាយតនសញ្ញំ បដិច្ច មនសិការោតិ ឯកត្តំ តស្ស អាកាសានញ្ចាយតនសញ្ញាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ ។ សោ ឯវំ បជានាតិ យេ អស្សុ ទរថា អរញ្ញសញ្ញំ បដិច្ច តេធ ន សន្តិ យេ អស្សុ ទរថា បឋវីសញ្ញំ បដិច្ច តេធ ន សន្តិ អត្ថិ ចេវាយំ ទរថមត្តា យទិទំ អាកាសានញ្ចាយតនសញ្ញំ បដិច្ច ឯកត្តន្តិ ។ សោ សុញ្ញមិទំ សញ្ញាគតំ អរញ្ញសញ្ញាយាតិ បជានាតិ សុញ្ញមិទំ សញ្ញាគតំ បឋវីសញ្ញាយាតិ បជានាតិ ។





(៦) ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុក ក្នុងចិត្ត នូវអរញ្ញសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវបឋវីសញ្ញាទេ តែធ្វើទុក ក្នុងចិត្ត នូវសភាវៈមួយ ព្រោះអាស្រ័យអាកាសានញ្ចាយតនសញ្ញា ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ស៊ប់ ក្នុង អាកាសានញ្ចាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់ យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យអរញ្ញសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមាន ក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យបឋវីសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមាន ក្នុងទីនេះទេ តែសេចក្តីក្រវល់ក្រវាយនេះ នៅតែមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអាកាសានញ្ចាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសំគាល់ថាសូន្យ ចាកអរញ្ញសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសំគាល់ថាសូន្យ ចាកបឋវីសញ្ញា ។

អត្ថិ ចេវាយំ អសុញ្ញតំ យទិទំ អាកាសានញ្ចាយ-តនសញ្ញំ បដិច្ច ឯកត្តំ ។ ឥតិ យំ ហិ ខោ តត្ថ ន ហោតិ តេន តំ សុញ្ញំ សមនុបស្សតិ យំ បន តត្ថ អវសិដ្ឋំ ហោតិ តំ សន្តំ ឥទមត្ថីតិ បជានាតិ ។ ឯវម្បិស្ស ឯសា អានន្ទ យថាភុច្ចា អវិបល្លត្ថា បរិសុទ្ធា សុញ្ញតាវក្កន្តិ ភវតិ ។

(៨) បុន ចបរំ អានន្ទ ភិក្ខុ អមនសិការិត្វា បឋវីសញ្ញំ អមនសិការិត្វា អាកាសានញ្ចាយតនសញ្ញំ វិញ្ញាណញ្ចាយតនសញ្ញំ បដិច្ច មនសិករោតិ ឯកត្តំ ។ តស្ស វិញ្ញាណញ្ចាយតនសញ្ញាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ ។ សោ ឯវំ បជានាតិ យេ អស្សុ ទរថា បឋវីសញ្ញំ បដិច្ច តេបិ ន សន្តិ យេ អស្សុ ទរថា អាកាសានញ្ចាយតនសញ្ញំ បដិច្ច



តែទីនេះមិនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអាកាសានញ្ចាយតនសញ្ញា ។ ព្រោះហេតុនោះ បើសេចក្តីក្រវល់ក្រវាយណា មិនមានក្នុងកន្លែងនោះទេ ភិក្ខុពិចារណាឃើញនូវសេចក្តីក្រវល់ក្រវាយនោះ ក្នុងកន្លែងនោះ ថាជារបស់សូន្យ បើសេចក្តីក្រវល់ក្រវាយណា សេសសល់នៅ ក្នុងកន្លែងនោះ ភិក្ខុដឹងច្បាស់នូវសេចក្តីក្រវល់ក្រវាយ ដែលនៅមាននោះថា សេចក្តីក្រវល់ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្តីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្លះ ។

(៨) ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវបឋវីសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវអាកាសានញ្ចាយតនសញ្ញាទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនសញ្ញា ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងវិញ្ញាណ-ញ្ចាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យបឋវីសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យអាកាសានញ្ចាយតនសញ្ញា

តេធ ន សន្តិ អត្ថិ ចេវាយំ ទរថមត្តា យទិទំ វិញ្ញាណញ្ចាយតនសញ្ញំ បដិច្ច ឯកត្តន្តិ ។ សោ សុញ្ញមិទំ សញ្ញាគតំ បឋវីសញ្ញាយាតិ បជានាតិ សុញ្ញមិទំ សញ្ញាគតំ អាកាសានញ្ចាយតនសញ្ញា-យាតិ បជានាតិ ។ អត្ថិ ចេវិទំ អសុញ្ញតំ យទិទំ វិញ្ញាណញ្ចាយតនសញ្ញំ បដិច្ច ឯកត្តន្តិ ។ ឥតិ យំ ហិ ខោ តត្ថ ន ហោតិ តេន តំ សុញ្ញំ សមនុបស្សតិ យំ បន តត្ថ អវសិដ្ឋំ ហោតិ តំ សន្តំ ឥទមត្ថីតិ បជានាតិ ។ ឯវម្បិស្ស ឯសា អានន្ទ យថាភុច្ចា អវិបល្លត្ថា បរិសុទ្ធា សុញ្ញតា-វក្កន្តិ ភវតិ ។



សេចក្ដីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្ដីក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសំគាល់ថាសូន្យ ចាកបឋវីសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសំគាល់ថាសូន្យ ចាកអាកាសានញ្ចាយតនសញ្ញា ។ តែទីនេះ មិនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនសញ្ញា ។ ព្រោះហេតុនោះ បើសេចក្ដីក្រវល់ក្រវាយណាមិនមាន ត្រង់កន្លែងនោះ ភិក្ខុពិចារណាឃើញ នូវសេចក្ដីក្រវល់ក្រវាយនោះ ត្រង់កន្លែងនោះ ថាជារបស់សូន្យ បើសេចក្ដីក្រវល់ក្រវាយណាសេសសល់នៅ ត្រង់កន្លែងនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្ដីក្រវល់ក្រវាយ ដែលនៅមាននោះថា សេចក្ដីក្រវល់ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្ដីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្លះ ។

(៦) បុន ចបរំ អានន្ទ ភិក្ខុ អមនសិការិត្វា អាកាសានញ្ចាយតនសញ្ញំ អមនសិការិត្វា វិញ្ញាណញ្ចាយតនសញ្ញំ អាកិញ្ចញ្ញាយតនសញ្ញំ បដិច្ច មនសិករោតិ ឯកត្តំ ។ តស្ស អាកិញ្ចញ្ញាយតនសញ្ញាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ ។ សោ ឯវំ បជានាតិ យេ អស្សុ ទរថា អាកាសានញ្ចាយតនសញ្ញំ បដិច្ច តេធ ន សន្តិ យេ អស្សុ ទរថា វិញ្ញាណញ្ចាយតនសញ្ញំ បដិច្ច តេធ ន សន្តិ អត្ថិ ចេវាយំ ទរថមត្តា យទិទំ អាកិញ្ចញ្ញាយតនសញ្ញំ បដិច្ច ឯកត្តន្តិ ។ សោ សុញ្ញមិទំ សញ្ញាគតំ អាកាសានញ្ចាយតនសញ្ញាយាតិ បជានាតិ សុញ្ញមិទំ សញ្ញាគតំ វិញ្ញាណញ្ចាយតនសញ្ញាយាតិ បជានាតិ ។ អត្ថិ ចេវិទំ អសុញ្ញតំ យទិទំ អាកិញ្ចញ្ញាយតនសញ្ញំ បដិច្ច ឯកត្តន្តិ ។



(៦) ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវអាកាសានញ្ចាយតនសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវវិញ្ញាណញ្ចាយតនសញ្ញាទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនសញ្ញា ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងអាកិញ្ចញ្ញាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យអាកាសានញ្ចាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្តីក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសំគាល់ថាសូន្យ ចាកអាកាសានញ្ចាយតនសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសំគាល់ថាសូន្យ ចាកវិញ្ញាណញ្ចាយតនសញ្ញា ។ តែទីនេះ មិនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនសញ្ញា ។

នត្ថិ យំ ហិ ខោ តត្ថ ន ហោតិ តេន តំ សុញ្ញំ សមនុបស្សតិ យំ បន តត្ថ អវសិដ្ឋំ ហោតិ តំ សន្តំ ឥទមត្ថីតិ បជានាតិ ។ ឯវម្បិស្ស ឯសា អានន្ទ យថាភុច្ចា អវិបល្លត្ថា បរិសុទ្ធា សុញ្ញតាវក្កន្តិ ភវតិ ។

(៧) បុន ចបរំ អានន្ទ ភិក្ខុ អមនសិការិត្វា វិញ្ញាណញ្ចាយតនសញ្ញំ អមនសិការិត្វា អាកិញ្ចញ្ញាយតនសញ្ញំ នេវសញ្ញានាសញ្ញាយតនសញ្ញំ បដិច្ច មនសិការោតិ ឯកត្តំ ។ តស្ស នេវសញ្ញានាសញ្ញាយតនសញ្ញាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ ។ សោ ឯវំ បជានាតិ យេ អស្សុ ទរថា វិញ្ញាណញ្ចាយតនសញ្ញំ បដិច្ច តេធ ន សន្តិ



ព្រោះហេតុនោះ បើសេចក្តីក្រវល់ក្រវាយណា មិនមានក្នុងទីនោះ ភិក្ខុពិចារណាឃើញនូវសេចក្តីក្រវល់ក្រវាយនោះ ត្រង់កន្លែងនោះ ថាជារបស់សូន្យ បើសេចក្តីក្រវល់ក្រវាយណា សេសសល់នៅក្នុងទីនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្តីក្រវល់ក្រវាយ ដែលមាននោះថា សេចក្តីក្រវល់ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្តីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធ ស្អាតយ៉ាងនេះឯង ។

(៧) ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវវិញ្ញាណញ្ចាយតនសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនសញ្ញាទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនសញ្ញា ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងនេវសញ្ញានាសញ្ញាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ

យេ អស្សុ ទរថា អាកិញ្ចញ្ញាយតនសញ្ញំ បដិច្ច តេបិធ ន សន្តិ អត្ថិ ចេវាយំ ទរថមត្តា យទិទំ នេវសញ្ញានាសញ្ញាយតនសញ្ញំ បដិច្ច ឯកត្តន្តិ ។ សោ សុញ្ញមិទំ សញ្ញាគតំ វិញ្ញាណញ្ចាយតនសញ្ញាយាតិ បជានាតិ សុញ្ញមិទំ សញ្ញាគតំ អាកិញ្ចញ្ញាយតនសញ្ញាយាតិ បជានាតិ ។ អត្ថិ ចេវិទំ អសុញ្ញតំ យទិទំ នេវសញ្ញានាសញ្ញាយតនសញ្ញំ បដិច្ច ឯកត្តន្តិ ។ ឥតិ យំ ហិ ខោ ន ហោតិ តេន តំ សុញ្ញំ សមនុបស្សតិ យំ បន តត្ថ អវសិដ្ឋំ ហោតិ តំ សន្តំ ឥទមត្ថីតិ បជានាតិ ។ ឯវម្បិស្ស ឯសា អានន្ទ យថាភុច្ចា អវិបល្លត្ថា បរិសុទ្ធា សុញ្ញតាវក្កន្តិ ភវតិ ។



សេចក្ដីក្រវល់ក្រវាយទាំងឡាយណានៅមាន ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនសញ្ញា សេចក្ដីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្ដីក្រវល់ក្រវាយនេះ បែបជានៅមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសំគាល់ថាសូន្យ ចាកវិញ្ញាណញ្ចាយតនសញ្ញា ដឹងច្បាស់ថា ទីនេះដល់នូវសេចក្ដីសំគាល់ថាសូន្យ ចាកអាកិញ្ចញ្ញាយតនសញ្ញា ។ តែទីនេះ មិនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនសញ្ញា ។ ព្រោះហេតុនោះ បើសេចក្ដីក្រវល់ក្រវាយណា មិនមានក្នុងទីនោះ ភិក្ខុពិចារណាឃើញនូវសេចក្ដីក្រវល់ក្រវាយនោះ ត្រង់ទីនោះ ថាជារបស់សូន្យ បើសេចក្ដីក្រវល់ក្រវាយណានៅមានសល់ត្រង់ទីនោះ ភិក្ខុក៏ដឹងច្បាស់ថា សេចក្ដីក្រវល់ក្រវាយដែលនៅមាននោះថា សេចក្ដីក្រវល់ក្រវាយនេះនៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្ដីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្លះ ។

(៨) បុន ចបរំ អានន្ទ ភិក្ខុ អមនសិការិត្វា អាកិញ្ចញ្ញាយតនសញ្ញំ អមនសិការិត្វា នេវសញ្ញានាសញ្ញាយតនសញ្ញំ អនិមិត្តំ ចេតោសមាធិំ បដិច្ច មនសិករោតិ ឯកត្តំ ។ តស្ស អនិមិត្តេ ចេតោសមាធិម្ហិ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ ។ សោ ឯវំ បជានាតិ យេ អស្សុ ទរថា អាកិញ្ចញ្ញាយតនសញ្ញំ បដិច្ច តេធ ន សន្តិ យេ អស្សុ ទរថា នេវសញ្ញានាសញ្ញាយតនសញ្ញំ បដិច្ច តេធ ន សន្តិ អត្ថិ ចេវាយំ ទរថមត្តា យទិទំ ឥមមេវ កាយំ បដិច្ច សឡាយតនិកំ ជីវិតប្បច្ចយាតិ ។ សោ សុញ្ញមិទំ សញ្ញាគតំ អាកិញ្ចញ្ញាយតនសញ្ញាយាតិ បជានាតិ សុញ្ញមិទំ សញ្ញាគតំ នេវសញ្ញានាសញ្ញាយតនសញ្ញាយាតិ បជានាតិ ។ អត្ថិ ចេវិទំ អសុញ្ញតំ



(៨) ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនេវសញ្ញានាសញ្ញាយតនសញ្ញា តែធ្វើទុកក្នុងចិត្តនូវជាសភាវៈមួយ ព្រោះអាស្រ័យអនិមិត្តចេតោសមាធិ[១] ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ចុះស៊ប់ ក្នុងអនិមិត្តចេតោសមាធិ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណានៅមាន ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្តីក្រវល់ក្រវាយនេះ ដែលនៅមាន គឺមាន ព្រោះអាស្រ័យនូវកាយដែលប្រកបដោយសឡាយតនៈនេះ ដោយមានជីវិតជាបច្ច័យ ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះដល់នូវសេចក្តីសំគាល់ថាសូន្យ ចាកអាកិញ្ចញ្ញាយតនសញ្ញា ដឹងច្បាស់ថា ទីនេះដល់នូវសេចក្តីសំគាល់ថាសូន្យ ចាកនេវសញ្ញានាសញ្ញាយតនសញ្ញា ។ តែទីនេះ មិនឈ្មោះថាសូន្យទេ

---

១ អនិមិត្តចេតោសមាធិនោះ បានដល់សមាធិចិត្តដែលប្រកបដោយវិបស្សនា ។ ព្រោះសមាធិនោះ ប្រាសចាកនិមិត្ត មានសេចក្តីមិនទៀងជាដើម បានជាលោកហៅថាអនិមិត្ត ។

យទិទំ ឥមមេវ កាយំ បដិច្ច សឡាយតនិកំ ជីវិតបច្ចយាតិ ។ ឥតិ យំ ហិ ខោ តត្ថ ន ហោតិ តេន តំ សុញ្ញំ សមនុបស្សតិ យំ បន តត្ថ អវសិដ្ឋំ ហោតិ តំ សន្តំ ឥទមត្ថីតិ បជានាតិ ។ ឯវម្បិស្ស ឯសា អានន្ទ យថាភុច្ចា អវិបល្លត្ថា បរិសុទ្ធា សុញ្ញតាវក្កន្តិ ភវតិ ។

(៨) បុន ចបរំ អានន្ទ ភិក្ខុ អមនសិការិត្វា អាកិញ្ចញ្ញាយតនសញ្ញំ អមនសិការិត្វា នេវសញ្ញានាសញ្ញាយតនសញ្ញំ អនិមិត្តំ ចេតោសមាធឹ បដិច្ច មនសិ ករោតិ ឯកត្តំ ។ តស្ស អនិមិត្តេ ចេតោសមាធិម្ហិ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ អធិមុច្ចតិ ។ សោ ឯវំ បជានាតិ អយំ ហិ ខោ[១] អនិមិត្តោ ចេតោសមាធិ អភិសង្ខតោ អភិសញ្ចេតយិតោ ។ យំ ខោ បន កិញ្ចិ អភិសង្ខតំ អភិសញ្ចេតយិតំ តទនិច្ចំ និរោធធម្មន្តិ បជានាតិ ។

១ ម. អយម្បិ ខោតិ ទិស្សតិ ។



គឺនៅមាន ព្រោះអាស្រ័យកាយ ដែលប្រកប ដោយសឡាយតនៈនេះ ដោយមានជីវិតជាបច្ច័យ ។ ព្រោះហេតុនោះ បើសេចក្តីក្រវល់ក្រវាយណា មិនមានក្នុងទីនោះ ភិក្ខុក៏ពិចារណាឃើញសេចក្តីក្រវល់ក្រវាយនោះ ក្នុងទីនោះ ថាជារបស់សូន្យ បើសេចក្តីក្រវល់ក្រវាយណា សល់នៅក្នុងទីនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្តីក្រវល់ក្រវាយ ដែលមាននោះថា សេចក្តីក្រវល់ក្រវាយនេះនៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្តីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្លះ ។

(៨) ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវនេវសញ្ញានាសញ្ញាយតនសញ្ញា តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យអនិមិត្តចេតោសមាធិ ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ក្នុងអនិមិត្តចេតោសមាធិ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា អនិមិត្តចេតោសមាធិនេះ អាត្មាអញបានតាក់តែងហើយ បាននឹកគិតសន្សំហើយ ។ ភិក្ខុនោះដឹងទៀតថា បើធម្មជាតណាមួយ ដែលអាត្មាអញតាក់តែងហើយ នឹកគិតសន្សំហើយ ធម្មជាតនោះ មិនទៀង មានការរលត់ជាធម្មតា ។

តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ សោ ឯវំ បជានាតិ យេ អស្សុ ទរថា កាមាសវំ បដិច្ច តេធ ន សន្តិ យេ អស្សុ ទរថា ភវាសវំ បដិច្ច តេធ ន សន្តិ យេ អស្សុ ទរថា អវិជ្ជាសវំ តេធ ន សន្តិ អត្ថិ ចេវាយំ ទរថមត្តា យទិទំ ឥមមេវ កាយំ បដិច្ច សឡាយតនិកំ



កាលបើភិក្ខុដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តក៏រួចចាកកាមាសវៈផង ចិត្តក៏រួចចាកភវាសវៈផង ចិត្តក៏រួចចាកអវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះហើយ ញាណក៏កើតឡើងថា អាត្មាអញ មានចិត្តរួចស្រឡះហើយ ភិក្ខុនោះដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចារ្យ អាត្មាអញបានប្រព្រឹត្តស្រេចហើយ កិច្ចដែលអញត្រូវធ្វើ ក៏ធ្វើស្រេចហើយ មិនមានកិច្ចដទៃក្រៅពីនេះទៀតទេ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណានៅមាន ព្រោះអាស្រ័យកាមាសវៈ សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណានៅមាន ព្រោះអាស្រ័យភវាសវៈ សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណានៅមាន ព្រោះអាស្រ័យអវិជ្ជាសវៈ សេចក្តីក្រវល់ក្រវាយ ទាំងនោះ មិនមានក្នុងទីនេះ តែសេចក្តីក្រវល់ក្រវាយនេះ ដែលនៅមាន គឺនៅមាន ព្រោះអាស្រ័យកាយ ដែលប្រកបដោយសឡាយតនៈនេះឯង

ជីវិតប្បច្ចយាតិ ។ សោ សុញ្ញមិទំ សញ្ញាគតំ កាមាសវេនាតិ បជានាតិ សុញ្ញមិទំ សញ្ញាគតំ ភវាសវេនាតិ បជានាតិ សុញ្ញមិទំ សញ្ញាគតំ អវិជ្ជាសវេនាតិ បជានាតិ ។ អត្ថិ ចេវិទំ អសុញ្ញតំ យទិទំ ឥមមេវ កាយំ បដិច្ច សឡាយតនិកំ ជីវិតប្បច្ចយាតិ ។ ឥតិ យំ ហិ ខោ តត្ថ ន ហោតិ តេន តំ សុញ្ញំ សមនុបស្សតិ យំ បន តត្ថ អវសិដ្ឋំ ហោតិ តំ សន្តំ ឥទមត្ថីតិ បជានាតិ ។ ឯវម្បិស្ស ឯសា អានន្ទ យថាភុច្ចា អវិបល្លត្ថា បរិសុទ្ធា បរមានុត្តរា សុញ្ញតាវក្កន្តិ ភវតិ ។

(១០) យេបិ ហិ(១) កេចិ អានន្ទ អតីតមទ្ធានំ ស-មណា វា ព្រាហ្មណា វា បរិសុទ្ធំ បរមានុត្តរំ សុញ្ញតំ ឧបសម្បជ្ជ វិហរិំសុ សព្វេ តេ ឥមំយេវ បរិសុទ្ធំ ប-រមានុត្តរំ សុញ្ញតំ ឧបសម្បជ្ជ វិហរិំសុ ។ យេបិ ហិ(២) កេចិ អានន្ទ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា បរិសុទ្ធំ បរមានុត្តរំ សុញ្ញតំ ឧបសម្បជ្ជ វិហរិស្សន្តិ

១-២ ម. យេហិកេចិ ទិស្សតិ ។ ម. ម. វិហរន្តិ ។



ព្រោះមានជីវិតជាបច្ច័យ ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះដល់នូវសេចក្តីសំគាល់ថាសូន្យ ចាកកាមាសវៈ ដឹងច្បាស់ថា ទីនេះដល់នូវសេចក្តីសំគាល់ថាសូន្យ ចាកភវាសវៈ ដឹងច្បាស់ថា ទីនេះដល់នូវសេចក្តីសំគាល់ថាសូន្យ ចាកអវិជ្ជាសវៈ ។ តែទីនេះ មិនឈ្មោះថាសូន្យទេ គឺនៅមាន ព្រោះអាស្រ័យកាយ ដែលប្រកបដោយសឡាយតនៈនេះឯង ព្រោះមានជីវិតជាបច្ច័យ ។ សេចក្តីក្រវល់ក្រវាយណា មិនមានក្នុងទីនោះ ភិក្ខុពិចារណាឃើញ នូវសេចក្តីក្រវល់ក្រវាយនោះ ត្រង់ទីនេះ ថាជារបស់សូន្យ ពុំនោះ បើសេចក្តីក្រវល់ក្រវាយណា សល់នៅក្នុងទីនោះ ភិក្ខុក៏ដឹងច្បាស់ នូវសេចក្តីក្រវល់ក្រវាយដែលមាននោះថា សេចក្តីក្រវល់ក្រវាយនេះនៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្តីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធ ប្រសើរក្រៃលែង យ៉ាងនេះឯង ។

(១០) ម្នាលអានន្ទ សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងអតីតកាល បានចូលកាន់សុញ្ញតៈ ដ៏បរិសុទ្ធ ប្រសើរ ក្រៃលែង ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ តែងចូលកាន់សុញ្ញតៈ ដ៏បរិសុទ្ធ ប្រសើរ ក្រៃលែង នេះឯង ។ ម្នាលអានន្ទ បើពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងអនាគតកាល នឹងចូលកាន់សុញ្ញតៈដ៏បរិសុទ្ធ ប្រសើរក្រៃលែង

សព្វេ តេ ឯតំយេវ បរិសុទ្ធំ បរមានុត្តរំ សុញ្ញតំ ឧបសម្បជ្ជ វិហរិស្សន្តិ ។ យេបិ ហិ កេចិ អានន្ទ ឯតរហិ សមណា វា ព្រាហ្មណា វា បរិសុទ្ធំ បរមានុត្តរំ សុញ្ញតំ ឧបសម្បជ្ជ វិហរន្តិ សព្វេ តេ ឯតំយេវ បរិសុទ្ធំ បរមានុត្តរំ សុញ្ញតំ ឧបសម្បជ្ជ វិហរន្តិ[១] ។ តស្មាតិហ អានន្ទ បរិសុទ្ធំ បរមានុត្តរំ សុញ្ញតំ ឧបសម្បជ្ជ វិហរិស្សាមាតិ[២] ឯវញ្ហិ វោ អានន្ទ សិក្ខិតព្វន្តិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ចូឡសុញ្ញតសុត្តំ បឋមំ និដ្ឋិតំ ។

---



ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ នឹងចូលកាន់សុញ្ញតៈ ដ៏បរិសុទ្ធ ប្រសើរក្រៃលែង នេះឯង ។ ម្នាលអានន្ទ បើពួកសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងបច្ចុប្បន្នកាល ចូលកាន់សុញ្ញតៈ ដ៏បរិសុទ្ធ ប្រសើរក្រៃលែង ពួកសមណៈឬព្រាហ្មណ៍ទាំងអស់នោះ តែងចូលកាន់សុញ្ញតៈ ដ៏បរិសុទ្ធ ប្រសើរក្រៃលែង នេះឯង ។ ម្នាលអានន្ទ ហេតុនោះ ក្នុងសាសនានេះ ភិក្ខុត្រូវតែគិតថា យើងរាល់គ្នា នឹងចូលកាន់សុញ្ញតៈ ដ៏បរិសុទ្ធ ប្រសើរក្រៃលែង ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សា យ៉ាងនេះឯង ។ លុះព្រះមានព្រះភាគ ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។

ចប់ ចូឡសុញ្ញតសូត្រ ទី ១ ។

# ទុតិយំ មហាសុញ្ញតសុត្តំ

(១១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្ត-ចីវរមាទាយ កបិលវត្ថុំ បិណ្ឌាយ បាវិសិ ។ កបិ-លវត្ថុស្មឹ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្ប-ដិក្កន្តោ យេន កាឡខេមកស្ស[១] សក្កស្ស វិហារោ តេនុបសង្កមិ ទិវាវិហារាយ ។ តេន ខោ បន សម-យេន កាឡខេមកស្ស សក្កស្ស វិហារេ សម្ពហុ-លានិ សេនាសនានិ បញ្ញត្តានិ ហោន្តិ ។ អទ្ទសា ខោ ភគវា កាឡខេមកស្ស សក្កស្ស វិហារេ សម្ពហុលានិ សេនាសនានិ បញ្ញត្តានិ ។ ទិស្វាន ភគវតោ ឯតទហោសិ សម្ពហុលានិ ខោ កាឡ-ខេមកស្ស សក្កស្ស វិហារេ សេនាសនានិ បញ្ញត្តា-និ សម្ពហុលា នុ ខោ ឥធ ភិក្ខូ វិហរន្តីតិ ។

១ កាឡក្ខេមកស្សាតិបិ សំយោគោ ។

# មហាសុញ្ញតសូត្រ ទី ២

(១១) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ នាដែនរបស់ពួកសក្កៈ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ ប្រដាប់បាត្រ ចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅបិណ្ឌបាត ក្នុងក្រុងកបិលពស្តុ ។ លុះព្រះអង្គចូលទៅបិណ្ឌបាត ក្នុងក្រុងកបិលពស្តុហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅកាន់វិហាររបស់សក្កៈឈ្មោះកាឡខេមកៈ ដើម្បីសម្រាកព្រះអង្គក្នុងវេលាថ្ងៃ ។ សម័យនោះឯង ក្នុងវិហាររបស់កាឡខេមកសក្កៈ មានគេក្រាលសេនាសនៈ ទុកច្រើន ។ លំដាប់នោះ ព្រះមានបុណ្យ ទ្រង់ទតឃើញសេនាសនៈច្រើន គេរៀបចំទុកក្នុងវិហារ របស់កាឡខេមកសក្កៈ ។ លុះព្រះអង្គទតឃើញហើយ ក៏មានព្រះហឫទ័យត្រិះរិះដូច្នេះថា សេនាសនៈច្រើន គេរៀបចំទុក ក្នុងវិហារ របស់កាឡខេមកសក្កៈ ចំនួនជាមានពួកភិក្ខុច្រើន នៅក្នុងទីនេះទេដឹង ។

(១៦) តេន ខោ បន សមយេន អាយស្មា អានន្ទោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ឃដាយសក្កស្ស វិហារេ ចីវរកម្មំ ករោតិ ។ អថ ខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ឃដាយសក្កស្ស វិហារោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ សម្ពហុលានិ ខោ អានន្ទ កាឡខេមកស្ស សក្កស្ស វិហារេ សេនាសនានិ បញ្ញត្តានិ សម្ពហុលា[១] ឯត្ថ ភិក្ខូ វិហរន្តីតិ ។ សម្ពហុលានិ ភន្តេ កាឡខេមកស្ស សក្កស្ស វិហារេ សេនាសនានិ បញ្ញត្តានិ សម្ពហុលា ភិក្ខូ ឯត្ថ វិហរន្តិ ចីវរការសមយោ នោ ភន្តេ វត្តតីតិ ។

១ ម. ឯត្ថ នុ ខោតិ ទិស្សតិ ។



(១៦) សម័យនោះឯង ព្រះអានន្ទមានអាយុ កំពុងចាត់ចែងដេរចីវរ ក្នុងវិហាររបស់ឃដាយសក្កៈ ជាមួយនឹងពួកភិក្ខុច្រើនរូប ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីផលសមាបត្តិ ក្នុងសាយណ្ហសម័យ ហើយស្ដេចចូលទៅកាន់វិហាររបស់ឃដាយសក្កៈ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេរៀបចំទុក ។ លុះព្រះអង្គគង់ស៊ប់ហើយ ក៏ត្រាស់សួរព្រះអានន្ទមានអាយុថា ម្នាលអានន្ទ សេនាសនៈច្រើនដែលគេបានរៀបចំទុក ក្នុងវិហាររបស់កាឡខេមកសក្កៈ ហើយមានតាំងពួកភិក្ខុនៅក្នុងទីនុ៎ះ ឬច្រើនម្ល៉េះ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន សេនាសនៈច្រើន ដែលគេរៀបចំទុកក្នុងវិហារ របស់កាឡខេមកសក្កៈ ហើយមានពួកភិក្ខុច្រើននៅក្នុងទីនុ៎ះ បពិត្រព្រះអង្គដ៏ចំរើន (ព្រោះ) ពេលនេះ ជាពេលធ្វើចីវរ ប្រព្រឹត្តមកដល់យើងខ្ញុំទាំងឡាយ ។

(១៣) ន ខោ អានន្ទ ភិក្ខុ សោភតិ សង្គណិការាមោ សង្គណិការតោ សង្គណិការាមតំ អនុយុត្តោ គណារាមោ គណរតោ គណសម្មុទិតោ(១) សោ វតានន្ទ ភិក្ខុ សង្គណិការាមោ សង្គណិការតោ សង្គណិការាមតំ អនុយុត្តោ គណារាមោ គណរតោ គណសម្មុទិតោ យន្តំ នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ សម្ពោធិសុខំ តស្ស សុខស្ស និកាមលាភី ភវិស្សតិ អកិច្ឆលាភី អកសិរលាភីតិ នេតំ ឋានំ វិជ្ជតិ ។ យោ ច ខោ សោ អានន្ទ ភិក្ខុ ឯកោ គណស្មា វូបកដ្ឋោ វិហរតិ តស្សេតំ ភិក្ខុនោ បាដិកង្ខំ យន្តំ នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ សម្ពោធិសុខំ តស្ស សុខស្ស និកាមលាភី ភវិស្សតិ អកិច្ឆលាភី អកសិរលាភីតិ ឋានមេតំ វិជ្ជតិ ។ សោ វតានន្ទ ភិក្ខុ សង្គណិការាមោ សង្គណិការតោ សង្គណិការាមតំ អនុយុត្តោ

១ ម. គណសម្បមុទិតោ ។



(១៣) ម្នាលអានន្ទ ភិក្ខុដែលត្រេកអរនឹងពួក ចូលចិត្តនឹងពួក ប្រកបរឿយ ៗ នូវសេចក្ដីត្រេកអរនឹងពួក ត្រេកអរនឹងគ្នា ចូលចិត្តនឹងមានគ្នា រីករាយនឹងគ្នា មិនល្អទេ ម្នាលអានន្ទ ភិក្ខុដែលត្រេកអរនឹងពួក ចូលចិត្តនឹងពួក ប្រកបរឿយ ៗ នូវសេចក្ដីត្រេកអរនឹងពួក ត្រេកអរនឹងគ្នា ចូលចិត្តនឹងមានគ្នា រីករាយនឹងគ្នានោះ ហើយបានមិនបាច់ព្រួញ បានមិនលំបាក បានដោយស្រួល នូវនេក្ខម្មសុខ វិវេកសុខ ឧបសមសុខ សម្ពោធិសុខ ពាក្យដូច្នេះ មិនសមហេតុឡើយ ។ ម្នាលអានន្ទ បើភិក្ខុណាចេញចាកពួក ហើយនៅតែម្នាក់ឯង ភិក្ខុនោះ នឹងបានមិនបាច់ព្រួញ បានមិនលំបាក បានដោយស្រួលនូវនេក្ខម្មសុខ វិវេកសុខ ឧបសមសុខ សម្ពោធិសុខ ជាប្រាកដ ពាក្យដូច្នេះ ទើបសមហេតុ ។ ម្នាលអានន្ទ ភិក្ខុនោះ ត្រេកអរនឹងពួក ចូលចិត្តនឹងពួក ប្រកបរឿយ ៗ នូវសេចក្ដីត្រេកអរនឹងពួក

គណារាមោ គណរតោ គណសម្មុទិតោ សាមា-
យិកំ វា កន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ វិហរិស្សតិ
អសាមាយិកំ វា អកុប្បន្តិ នេតំ ឋានំ វិជ្ជតិ ។
យោ ច ខោ សោ អានន្ទ ភិក្ខុ ឯកោ គណស្មា
វូបកដ្ឋោ វិហរតិ តស្សេតំ ភិក្ខុនោ បាដិកង្ខំ
សាមាយិកំ វា កន្តំ ចេតោវិមុត្តឹ ឧបសម្បជ្ជ
វិហរិស្សតិ អសាមាយិកំ វា អកុប្បន្តិ ឋានមេតំ
វិជ្ជតិ ។ នាហំ អានន្ទ ឯកំ រូបម្បិ សមនុបស្សាមិ
យត្ថ រត្តស្ស យថាភិរតស្ស រូបស្ស វិបរិណាមញ្ញ-
ថាភាវា ន ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោម-
នស្សុបាយាសា ។



ត្រេកអរនឹងពួក ចូលចិត្តនឹងពួក រីករាយនឹងពួក ពេចនឹងចូលកាន់
ចេតោវិមុត្តិ ដែលផុតស្រឡះចាកកិលេស ជាទីរីករាយ ឬនឹងចូលកាន់
ចេតោវិមុត្តិ ដែលមិនទាន់ផុតស្រឡះចាកពួកកិលេស ជាវិមុត្តិមិនកើត
ដោយកិលេសបាន ពាក្យដូច្នេះ មិនសមហេតុឡើយ ។ ម្នាលអានន្ទ
លុះតែភិក្ខុណាចេញចាកពួក ហើយទៅសម្ងំនៅតែម្នាក់ឯង ភិក្ខុនោះ
នឹងចូលកាន់ចេតោវិមុត្តិ ដែលផុតចាកពួកកិលេស ជាទីរីករាយ ឬនឹង
ចូលកាន់ចេតោវិមុត្តិ ដែលមិនទាន់ផុតចាកពួកកិលេស ជាវិមុត្តិមិន
កំរើកដោយកិលេស ជាប្រាកដ ពាក្យដូច្នេះ ទើបសមហេតុ ។
ម្នាលអានន្ទ តថាគតពិចារណាគេមើលមិនឃើញនូវរូប សូម្បីតែមួយ
ដែលបុគ្គលត្រេកអរ ត្រេកត្រអាលយ៉ាងខ្លាំង ហើយមិនកើតសេចក្តីសោក
ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្តនិងសេចក្តីតានតឹង ព្រោះមិនមាន
ការប្រែប្រួលទៅជាប្រការដទៃ នោះសោះឡើយ ។

(១៤) អយំ ខោ បនានន្ទ វិហារោ តត្ថ[១] តថាគតេន អភិសម្ពុទ្ធោ យទិទំ សព្ពនិមិត្តានំ អមនសិការា អជ្ឈត្តំ សុញ្ញតំ ឧបសម្បជ្ជ វិហរិតុំ ។ តត្រ ចេ អានន្ទ តថាគតំ ឥមិនា វិហារេន វិហរន្តំ ភវន្តិ ឧបសង្កមិតារោ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ រាជានោ រាជមហាមត្តា តិត្ថិយា តិត្ថិយសាវកា តត្រានន្ទ តថាគតោ វិវេកនិន្នេនេវ ចិត្តេន វិវេកបោណេន វិវេកបព្ភារេន វូបកដ្ឋេន នេក្ខម្មាភិរតេន ព្យន្តីភូតេន សព្ពសោ អាសវដ្ឋានីយេហិ ធម្មេហិ អញ្ញទត្ថុ ឧយ្យោជនិកប្បដិសំយុត្តំយេវ កថំ កត្តា ហោតិ ។ តស្មាតិហានន្ទ ភិក្ខុ ចេបិ អាកង្ខេយ្យ អជ្ឈត្តំ សុញ្ញតំ ឧបសម្បជ្ជ វិហរេយ្យន្តិ តេនានន្ទ ភិក្ខុនា អជ្ឈត្តមេវ ចិត្តំ សណ្ឋបេតព្វំ សន្និសាទេតព្វំ[២] ឯកោទិកាតព្វំ សមាទហាតព្វំ ។

---
១ ម. តត្ថាតិ ន ទិស្សតិ ។ ២ ម. សន្និសាទេតព្ពំ ។



(១៤) ម្នាលអានន្ទ វិហារធម៌ (ការនៅ) គឺចូលស្ងាត់ តថាគតបាន ត្រាស់ដឹងហើយ គឺបានសម្រេចនូវសុញ្ញតផលសមាបត្តិក្នុងសន្តាន ព្រោះ មិនធ្វើទុកក្នុងចិត្តនូវសង្ខារនិមិត្តទាំងអស់ (មានរូបជាដើម) ។ ម្នាលអានន្ទ បើពួកភិក្ខុ ពួកភិក្ខុនី ពួកឧបាសក ពួកឧបាសិកា ពួកព្រះរាជា ពួករាជមហាមាត្យ ពួកតិរ្ថិយ ពួកសាវ័កនៃតិរ្ថិយ ជាអ្នកចូលមករក តថាគត ជាភគវន្ត ដែលកំពុងនៅ ដោយវិហារធម៌នេះ ម្នាលអានន្ទ តថាគតក៏បែរទៅ ក្នុងកណ្ដាលបរិស័ទនោះ ក៏មានចិត្តឈមទៅរកវិវេក បែរទៅរកវិវេក ទោរទន់ទៅរកវិវេក ស្ងាត់ចាកពួកគណៈ ត្រេកអរនឹង នេក្ខម្មៈ ប្រាសចាកធម៌ដែលជាទីតាំងនៃអាសវៈ ជាអ្នកធ្វើនូវពាក្យដែល ប្រកបដោយការដាស់តឿន ឲ្យវៀរចាកធម៌ជាទីតាំងនៃអាសវៈ សព្វគ្រប់ ដោយពិត ។ ម្នាលអានន្ទ ហេតុនោះ ភិក្ខុក្នុងសាសនានេះ បើមាន សេចក្ដីប្រាថ្នាថា អាត្មាអញ គប្បីសម្រេចនូវសុញ្ញតផលសមាបត្តិ ខាង ក្នុង គឺបញ្ចក្ខន្ធរបស់ខ្លួន ម្នាលអានន្ទ ភិក្ខុនោះ ត្រូវតាំងចិត្ត ត្រូវ ញ៉ាំងចិត្តឲ្យតែកយ ត្រូវធ្វើចិត្តឲ្យស្ងប់ស្ងាត់ ត្រូវធ្វើចិត្តឲ្យប្រជុំ ខាង ក្នុង តែមួយយ៉ាង ។

(១៨) កថញ្ចានន្ទ ភិក្ខុ អជ្ឈត្តមេវ ចិត្តំ សណ្ឋាបេតិ សន្និសាទេតិ ឯកោទិករោតិ សមាទហតិ ។ ឥធានន្ទ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ... ទុតិយំ ឈានំ ... តតិយំ ឈានំ ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯវំ ខោ អានន្ទ ភិក្ខុ អជ្ឈត្តមេវ ចិត្តំ សណ្ឋបេតិ សន្និសាទេតិ ឯកោទិករោតិ សមាទហតិ ។ សោ អជ្ឈត្តំ សុញ្ញតំ មនសិករោតិ ។ តស្ស អជ្ឈត្តំ សុញ្ញតំ មនសិករោតោ អជ្ឈត្តំ សុញ្ញតាយ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតិ ។ ឯវំ សន្តមេតំ អានន្ទ ភិក្ខុ ឯវំ បជានាតិ អជ្ឈត្តំ សុញ្ញតំ ខោ មេ មនសិករោតោ អជ្ឈត្តំ សុញ្ញតាយ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ ន វិមុច្ចតីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ សោ



(១៨) ម្នាលអានន្ទ ចុះភិក្ខុតាំងចិត្ត ធ្វើចិត្តឲ្យរីករាយ ធ្វើចិត្តឲ្យស្ងប់ស្ងាត់ ធ្វើចិត្តឲ្យជ្រះថ្លា ខាងក្នុង គឺបញ្ចក្ខន្ធរបស់ខ្លួន តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុ ក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក ... ចូលកាន់ទុតិយជ្ឈាន... ចូលកាន់តតិយជ្ឈាន ... ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលអានន្ទ ភិក្ខុតាំងចិត្ត ធ្វើចិត្តឲ្យជ្រះថ្លា ធ្វើចិត្តឲ្យស្ងប់ស្ងាត់ ធ្វើចិត្តឲ្យរីករាយ ខាងក្នុង យ៉ាងនេះឯង ។ ភិក្ខុនោះ ឈ្មោះថាធ្វើទុកក្នុងចិត្ត នូវសុញ្ញតផលសមាបត្តិ ខាងក្នុង ។ តែកាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិ ខាងក្នុងហើយ ចិត្តមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនចុះចិត្តស៊ប់ ក្នុងសុញ្ញតផលសមាបត្តិ ខាងក្នុងទេ ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុគប្បីដឹងច្បាស់យ៉ាងនេះថា កាលអាត្មាអញធ្វើទុកក្នុងចិត្ត នូវសុញ្ញតផលសមាបត្តិ ខាងក្នុង ចិត្តមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនចុះចិត្តស៊ប់ ក្នុងសុញ្ញតផលសមាបត្តិ ខាងក្នុងទេ ។ ភិក្ខុនោះជាអ្នកដឹងច្បាស់ ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ បើភិក្ខុនោះ

ពហិទ្ធា សុញ្ញតំ មនសិករោតិ ។ សោ អជ្ឈត្តពហិទ្ធា សុញ្ញតំ មនសិករោតិ ។ សោ អានេញ្ជំ មនសិករោតិ ។ តស្ស អានេញ្ជំ មនសិករោតោ អានេញ្ជាយ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ នាធិមុច្ចតិ ។ ឯវំ សន្តមេតំ អានន្ទ ភិក្ខុ ឯវំ បជានាតិ អានេញ្ជំ ខោ មេ មនសិករោតោ អានេញ្ជាយ ចិត្តំ ន បក្ខន្ទតិ ន បសីទតិ ន សន្តិដ្ឋតិ នាធិមុច្ចតីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ តេនានន្ទ ភិក្ខុនា តស្មិំយេវ បុរិមស្មឹ សមាធិនិមិត្តេ អជ្ឈត្តមេវ ចិត្តំ សណ្ឋបេតព្វំ សន្និសាទេតព្វំ ឯកោទិកាតព្វំ សមាទហាតព្វំ ។ សោ អជ្ឈត្តំ សុញ្ញតំ មនសិករោតិ ។ តស្ស អជ្ឈត្តំ សុញ្ញតំ មនសិករោតោ អជ្ឈត្តំ សុញ្ញតាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ។ ឯវំ សន្តមេតំ អានន្ទ ភិក្ខុ



ធ្វើទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិ ខាងក្រៅ និងខាងក្នុងផង ។ បើភិក្ខុនោះ ធ្វើទុកក្នុងចិត្ត នូវសុញ្ញតផលសមាបត្តិ ខាងក្នុងនិងខាងក្រៅ ។ បើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រ គឺអរូបសមាបត្តិ ។ កាលភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រ ចិត្តមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនចុះចិត្តស៊ប់ ក្នុងសេចក្តីមិនញាប់ញ័រ ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុគប្បីដឹងច្បាស់យ៉ាងនេះថា កាលអាត្មាអញធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនចុះចិត្តស៊ប់ ក្នុងសេចក្តីមិនញាប់ញ័រ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ភិក្ខុនោះ ត្រូវតាំងចិត្ត ធ្វើចិត្តឲ្យជ្រះថ្លា ធ្វើចិត្តឲ្យស្ងប់ស្ងាត់ ធ្វើចិត្តឲ្យកើតឯកោ ខាងក្នុង ក្នុងសមាធិនិមិត្ត ពីមុននោះវិញ ។ ភិក្ខុនោះ ធ្វើទុកក្នុងចិត្ត នូវសុញ្ញតផលសមាបត្តិខាងក្នុង ។ កាលភិក្ខុនោះ ធ្វើទុកក្នុងចិត្ត នូវសុញ្ញតផលសមាបត្តិ ខាងក្នុងហើយ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ចុះចិត្តស៊ប់ ក្នុងសុញ្ញតផលសមាបត្តិខាងក្នុង ។ ម្នាលអានន្ទ កាលបើចិត្តនុះស្ងប់ស្ងាត់យ៉ាងនេះ ភិក្ខុ

ឯវំ បជានាតិ អជ្ឈត្តំ សុញ្ញតំ ខោ មេ មនសិករោតោ អជ្ឈត្តំ សុញ្ញតាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ សោ ពហិទ្ធា សុញ្ញតំ មនសិករោតិ ។ សោ អជ្ឈត្តពហិទ្ធា សុញ្ញតំ មនសិករោតិ ។ សោ អានេញ្ជំ មនសិករោតិ ។ តស្ស អានេញ្ជំ មនសិករោតោ អានេញ្ជាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ ។ ឯវំ សន្តមេតំ អានន្ទ ភិក្ខុ ឯវំ បជានាតិ អានេញ្ជំ ខោ មេ មនសិករោតោ អានេញ្ជាយ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។

(១៦) តស្ស ចេ អានន្ទ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ ចង្កមាយ ចិត្តំ នមតិ ។ សោ ចង្កមតិ ឯវំ មំ ចង្កមន្តំ នាភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវិស្សន្តីតិ ។



ក៏ដឹងច្បាស់យ៉ាងនេះថា កាលអាត្មាអញ ធ្វើទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិខាងក្នុងហើយ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ចុះចិត្តស៊ប់ក្នុងសុញ្ញតផលសមាបត្តិខាងក្នុង ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ បើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវផលសមាបត្តិខាងក្រៅ ។ បើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិ ខាងក្នុងនិងខាងក្រៅ ។ បើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រ ។ កាលភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រហើយ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ចុះចិត្តស៊ប់ ក្នុងសេចក្តីមិនញាប់ញ័រ ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុគប្បីដឹងច្បាស់យ៉ាងនេះថា កាលអាត្មាអញ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រហើយ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ចុះចិត្តស៊ប់ ក្នុងសេចក្តីមិនញាប់ញ័រ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។

(១៦) ម្នាលអានន្ទ កាលបើភិក្ខុនោះ នៅដោយវិហារធម៌ គឺសមាបត្តិនេះ ចិត្តក៏បង្អោនទៅដើម្បីចង្រ្កម ។ ភិក្ខុនោះចង្រ្កម ដោយគិតដូច្នេះថា អកុសលធម៌ទាំងឡាយ ដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនជាប់តាមអាត្មាអញដែលកំពុងចង្រ្កម យ៉ាងនេះ ។

ឥតិហ តត្ថ សម្បជានោ ហោតិ ។ តស្ស ចេ អានន្ទ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ ឋានាយ ចិត្តំ នមតិ ។ សោ តិដ្ឋតិ ឯវំ មំ ឋិតំ នាភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវិស្សន្តីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ តស្ស ចេ អានន្ទ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ និសជ្ជាយ ចិត្តំ នមតិ ។ សោ និសីទតិ ឯវំ មំ និសិន្នំ នាភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវិស្សន្តីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ តស្ស ចេ អានន្ទ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ សយនាយ ចិត្តំ នមតិ ។ សោ សយតិ ឯវំ មំ សយន្តំ នាភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវិស្សន្តីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ តស្ស ចេ អានន្ទ ភិក្ខុនោ ឥមិនា វិហារេន វិហរតោ កាថាយ ចិត្តំ នមតិ ។ សោ យាយំ កថា ហីនា



ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌គឺសមថវិបស្សនានេះ ចិត្តក៏បង្អោនទៅ ដើម្បីកិរិយាឈរ ។ ភិក្ខុនោះ ឈរដោយគិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងឈរ យ៉ាងនេះ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌ គឺសមថវិបស្សនានេះ ចិត្តក៏បង្អោនទៅដើម្បីអង្គុយ ។ ភិក្ខុនោះ ក៏អង្គុយដោយគិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងអង្គុយនៅ យ៉ាងនេះ ។ ភិក្ខុនោះ ជាអ្នកដឹង ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះនៅដោយវិហារធម៌ គឺសមថវិបស្សនានេះ ចិត្តក៏បង្អោនទៅដើម្បីដេក ។ ភិក្ខុនោះក៏ដេក ដោយគិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងដេក យ៉ាងនេះ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់នូវហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌ គឺសមថវិបស្សនានេះ ចិត្តក៏បង្អោនទៅដើម្បីនិយាយ ។ ភិក្ខុនោះគិតថា កថាណា ថោកទាប

គម្មា បោថុជ្ជនិកា អនរិយា អនត្ថសំហិតា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ សេយ្យថីទំ រាជកថា ចោរកថា មហាមត្តកថា សេនាកថា ភយកថា យុទ្ធកថា អន្នកថា បានកថា វត្ថកថា សយនកថា មាលាកថា គន្ធកថា ញាតិកថា យានកថា គាមកថា និគមកថា នគរកថា ជនបទកថា ឥត្ថីកថា សូរកថា វិសិខាកថា កុម្ភដ្ឋានកថា បុព្វបេតកថា នានត្ត-



ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ មិនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីរលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន គឺរាជកថា (និយាយពីព្រះរាជា) ចោរកថា (និយាយពីចោរ) មហាមត្តកថា (និយាយពីអាមាត្យធំ) សេនាកថា (និយាយពីសេនា) ភយកថា (និយាយពីភ័យ) យុទ្ធកថា (និយាយពីចម្បាំង) អន្នកថា (និយាយពីបាយ) បានកថា (និយាយពីទឹក) វត្ថកថា (និយាយពីសំពត់) សយនកថា (និយាយពីដំណេក) មាលាកថា (និយាយពីកម្រងផ្កា) គន្ធកថា (និយាយពីគ្រឿងក្រអូប) ញាតិកថា (និយាយពីញាតិ) យានកថា (និយាយពីយានជំនិះ) គាមកថា (និយាយពីស្រុក) និគមកថា (និយាយពីនិគម) នគរកថា (និយាយពីក្រុង) ជនបទកថា (និយាយពីជនបទ) ឥត្ថីកថា (និយាយពីស្ត្រី) សូរកថា (និយាយពីមនុស្សក្លៀវក្លា) វិសិខាកថា (និយាយពីកំប៉ោយ) កុម្ភដ្ឋានកថា (និយាយពីកន្លែងដាក់ក្អមទឹក ឬកន្លែងកំណាប់) បុព្វបេតកថា (និយាយពីមនុស្សដែលស្លាប់ហើយ) នានត្ត-

កថា លោកក្ខាយិកា សមុទ្ទក្ខាយិកា ឥតិភវាភវកថា ឥតិ វា ឯវរូបំ កថំ ន កថេស្សាមីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ យា ច[1] ខោ អយំ អានន្ទ កថា អភិសល្លេខិកា ចេតោវិវរណសប្បាយា[2] ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញាណទស្សនកថា ឥតិ ឯវរូបំ កថំ កថេស្សាមីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ តស្ស ចេ អានន្ទ ភិក្ខុនោ

១. ចក ។ ២. ចេតោវិវរណសប្បាយា ។ ម. ចេតោវិនីវរណសប្បាយា ។



កថា (និយាយពីមនុស្សផ្សេងៗគ្នា) លោកក្ខាយិកា (និយាយពីព្រេងកសាងលោក) សមុទ្ទក្ខាយិកា (និយាយពីព្រេងកសាងសមុទ្រ) និយាយអំពីភពតូចនិងភពធំ ជាដូច្នោះៗដូច្នេះៗ ភាពអញមិននិយាយនូវកថាមានសភាពយ៉ាងនោះឡើយ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កថាណាដូចជា ជាទីសប្បាយដល់ការពិចារណា តាមដំណើរចិត្ត ប្រព្រឹត្តទៅ ដើម្បីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន គឺអប្បិច្ឆកថា (និយាយពីសេចក្ដីប្រាថ្នាតិច) សន្តុដ្ឋិកថា (និយាយពីសេចក្ដីសន្តោស) បវិវេកកថា (និយាយពីសេចក្ដីស្ងប់ស្ងាត់) អសំសគ្គកថា (និយាយពីការមិនជាប់ជំពាក់) វីរិយារម្ភកថា (និយាយពីការប្រារព្ធព្យាយាម) សីលកថា (និយាយពីសីល) សមាធិកថា (និយាយពីសមាធិ) បញ្ញាកថា (និយាយពីប្រាជ្ញា) វិមុត្តិកថា (និយាយពីការរួចចាកកិលេស) វិមុត្តិញាណទស្សនកថា (និយាយពីការឃើញដោយបញ្ញា ចំពោះកិរិយារួចចាកកិលេស) ភាពអញនឹងនិយាយនូវកថាមានសភាពយ៉ាងនេះឯង ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះ

ឥមិនា វិហារេន វិហរតោ វិតក្កាយ ចិត្តំ នមតិ ។ សោ យេ មេ វិតក្កា ហីនា គម្មា បោថុជ្ជនិកា អនរិយា អនត្ថសំហិតា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តន្តិ សេយ្យថីទំ កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ឥតិ ឯវរូបេ វិតក្កេ ន វិតក្កេស្សាមីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ យេ ច ខោ ឥមេ វិតក្កា អរិយា និយ្យានិកា និយ្យន្តិ តក្ករស្ស សម្មា ទុក្ខក្ខយាយ សេយ្យថីទំ នេក្ខម្មវិតក្កោ អព្យាបាទវិតក្កោ អវិហឹសាវិតក្កោ ឥតិ ឯវរូបេ វិតក្កេ វិតក្កេស្សាមីតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។



កំពុងនៅ ដោយវិហារធម៌ គឺសមាធិរបស់ខ្លួននោះ ចិត្តក៏បង្អោនទៅ ដើម្បីវិតក្កៈ (សេចក្តីត្រិះរិះ) ។ ភិក្ខុនោះគិតថា វិតក្កៈទាំងឡាយណា ដែលថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ មិនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីរលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹង មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន គឺកាមវិតក្កៈ ព្យាបាទវិតក្កៈ វិហឹសាវិតក្កៈ អាត្មាអញនឹងមិនត្រិះរិះ ដោយវិតក្កៈ មានសភាពយ៉ាងនោះឡើយ ។ ភិក្ខុនោះ ជាអ្នកដឹងខ្លួនក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត វិតក្កៈទាំងឡាយណា ដ៏ប្រសើរ ជានិយ្យានិកៈ ដឹកនាំសត្វ តែងដឹកនាំបុគ្គលជាអ្នកធ្វើតាមពាក្យនៃវិតក្កៈនោះ ឲ្យអស់ទៅនៃទុក្ខដោយប្រពៃ គឺនេក្ខម្មវិតក្កៈ អព្យាបាទវិតក្កៈ អវិហឹសាវិតក្កៈ ភិក្ខុគិតថា អាត្មាអញនឹងត្រិះរិះនូវវិតក្កៈទាំងឡាយ មានសភាពយ៉ាងនោះ ៦៨ ។ ភិក្ខុនោះ ជាអ្នកដឹងខ្លួនក្នុងហេតុនោះ ដោយប្រការដូច្នេះ ។

(១៧) បញ្ច ខោ ឥមេ អានន្ទ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសំហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសំហិតា រជនីយា ឥមេ ខោ អានន្ទ បញ្ច កាមគុណា ។ យត្ថ ភិក្ខុនា អភិក្ខណំ សកំ ចិត្តំ បច្ចវេក្ខិតព្វំ អត្ថិ នុ ខោ មេ ឥមេសុ បញ្ចសុ កាមគុណេសុ អញ្ញតរស្មិំ វា អញ្ញតរស្មិំ វា អាយតនេ ឧប្បជ្ជតិ ចេតសោ សមុទាចារោតិ ។ សចេ អានន្ទ ភិក្ខុ បច្ចវេក្ខមានោ ឯវំ បជានាតិ អត្ថិ នុ ខោ មេ ឥមេសុ បញ្ចសុ កាមគុណេសុ អញ្ញតរស្មិំ វា អញ្ញតរស្មិំ វា អាយតនេ ឧប្បជ្ជតិ ចេតសោ សមុទាចារោតិ ។ ឯវំ សន្តមេតំ អានន្ទ ភិក្ខុ ឯវំ បជានាតិ យោ ខោ ឥមេសុ[1] បញ្ចសុ កាមគុណេសុ ឆន្ទរាគោ សោ មេ អប្បហីនោតិ[2] ។

---
១ ម. ខោមេ ។ ២ ម. ឧប្បហីនោតិ ។



(១៧) ម្នាលអានន្ទ កាមគុណនេះ មាន៥ប្រការ កាមគុណ ៥ ប្រការ គឺអ្វីខ្លះ រូបទាំងឡាយ ដែលបុគ្គលដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេក ១ សំឡេងទាំងឡាយ ដែលបុគ្គលដឹងដោយត្រចៀក ...១ ក្លិនទាំងឡាយ ដែលបុគ្គលដឹងដោយច្រមុះ ..១ រសទាំងឡាយ ដែលបុគ្គលដឹងដោយអណ្តាត...១ ផោដ្ឋព្វៈទាំងឡាយ ដែលបុគ្គលដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេក ១ ម្នាលអានន្ទ កាមគុណ ៥ ប្រការ នេះឯង ។ ភិក្ខុត្រូវពិចារណាចិត្តរបស់ខ្លួនឲ្យរឿយៗថា បណ្តាកាមគុណទាំង ៥ នេះ សេចក្តីផ្សុលព្រាលចិត្ត នៃអាត្មាអញ កើតឡើង ក្នុងហេតុជាទីកើតនៃកិលេស ចំពោះកាមគុណណាមួយ មានដែរឬទេ ។ ម្នាលអានន្ទ បើភិក្ខុពិចារណាទៅ ដឹងយ៉ាងនេះថា បណ្តាកាមគុណទាំង ៥ នេះ សេចក្តីផ្សុលព្រាលនៃចិត្តរបស់អាត្មាអញ កើតឡើងក្នុងហេតុ ជាទីកើតនៃកិលេស ចំពោះកាមគុណណាមួយ ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុនោះដឹងយ៉ាងនេះថា តម្រេកណា ដែលកើតក្នុងកាមគុណទាំង ៥ នេះ តម្រេកនោះ អាត្មាអញ មិនទាន់លះបង់បានទេ ។

សចេ បនានន្ទ ភិក្ខុ បច្ចវេក្ខមានោ ឯវំ បជានាតិ នត្ថិ ខោ មេ ឥមេសុ បញ្ចសុ កាមគុណេសុ អញ្ញតរស្មឹ វា អញ្ញតរស្មឹ វា អាយតនេ ឧប្បជ្ជតិ ចេតសោ សមុទាចារោតិ ។ ឯវំ សន្តមេតំ អានន្ទ ភិក្ខុ ឯវំ បជានាតិ យោ ខោ ឥមេសុ បញ្ចសុ កាមគុណេសុ ឆន្ទរាគោ សោ មេ បហីនោតិ ។ ឥតិហ តត្ថ[1] សម្បជានោ ហោតិ ។

(១៨) បញ្ច ខោ ឥមេ[2] អានន្ទ ឧបាទានក្ខន្ធា ។ យត្ថ ភិក្ខុនា ឧទយព្វយានុបស្សិនា[3] វិហាតព្វំ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា... ឥតិ សញ្ញា... ឥតិ សង្ខារា... ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ តស្ស ឥមេសុ បញ្ចសុបាទានក្ខន្ធេសុ ឧទយព្វយានុបស្សិនោ វិហរតោ យោ បញ្ចសុបាទានក្ខន្ធេសុ អស្មិមានោ សោ បហីយតិ ។

១ ឱ. តត្ថាតិ ន ទិស្សតិ ។ ២ ឱ. មេ ។ ៣ ឱ. ឧទយព្វយានុបស្សិនា ។



ម្នាលអានន្ទ មួយទៀត បើភិក្ខុពិចារណាទៅ ដឹងយ៉ាងនេះថា បណ្តាកាមគុណទាំង ៥ នេះ សេចក្តីត្រួលត្រាល់នៃចិត្តរបស់អាត្មាអញ មិនកើតឡើង ក្នុងហេតុជាទីកើតនៃកិលេស ចំពោះកាមគុណណាមួយទេ ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុក៏ដឹងយ៉ាងនេះថា សេចក្តីប្រាថ្នាណា ក្នុងកាមគុណទាំង ៥ នេះ សេចក្តីប្រាថ្នានោះ អាត្មាអញលះបង់ហើយ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។

( ១៨ ) ម្នាលអានន្ទ ឧបាទានក្ខន្ធនេះ មាន ៥ យ៉ាង ។ ភិក្ខុត្រូវប្រព្រឹត្ត ដោយពិចារណាឃើញ នូវសេចក្តីកើតនឹងសេចក្តីរលត់ ដូច្នេះថា រូបដូច្នេះ ការកើតឡើងនៃរូប ដូច្នេះ ការវិនាសទៅនៃរូប ដូច្នេះ វេទនាដូច្នេះ... សញ្ញាដូច្នេះ... សង្ខារទាំងឡាយដូច្នេះ... វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ ការវិនាសទៅនៃវិញ្ញាណដូច្នេះ ។ កាលបើភិក្ខុនោះ ពិចារណាឃើញនូវសេចក្តីកើតនឹងការរលត់ ក្នុងឧបាទានក្ខន្ធទាំង ៥ នេះ ភិក្ខុនោះ រមែងលះបង់អស្មិមានះ ក្នុងឧបាទានក្ខន្ធទាំង ៥ ចេញបាន ។

ឯវំ សន្តមេតំ អានន្ទ ភិក្ខុ ឯវំ បជានាតិ យោ ខោ មេ បញ្ចសុ ឧបាទានក្ខន្ធេសុ អស្មិមានោ សោ មេ បហីនោតិ ។ ឥតិហ តត្ថ សម្បជានោ ហោតិ ។ ឥមេ ខោ តេ អានន្ទ ធម្មា ឯកន្តកុសលាយតិកា អរិយា លោកុត្តរា អនវក្កន្តា បាបិមតា ។ តំ កឹ មញ្ញសិ អានន្ទ កំ អត្ថវសំ សម្បស្សមានោ អរហតិ សាវកោ សត្ថារំ អនុពន្ធិតុំ អបិ បនុជ្ជមានោតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។

(១៤) ន ខោ អានន្ទ អរហតិ សាវកោ សត្ថារំ អនុពន្ធិតុំ យទិទំ សុត្តគេយ្យវេយ្យាករណស្ស សោតុំ តំ កិស្ស ហេតុ ទីឃរត្តស្ស ហិ តេ អានន្ទ ធម្មា សុតា ធាតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។ យា ច ខោ អយំ អានន្ទ កថា អភិសល្លេខិតា



ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុដឹងយ៉ាងនេះថា អាត្មាអញ ប្រកាន់ថាអស្មិមានះ ក្នុងឧបាទានក្ខន្ធទាំង ៥ បានហើយ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ធម៌ទាំងឡាយនេះឯង ជាប់មកតាមកុសលដោយចំណែកមួយ ដ៏បរិសុទ្ធ ប្រសើរក្រៃលែងលោក ដែលមារមានចិត្តបាប មិនអាចគ្របសង្កត់បាន ។ ម្នាលអានន្ទ អ្នកសំគាល់នូវហេតុនោះ ដូចម្តេច សាវ័កពិចារណា ឃើញនូវអំណាចនៃប្រយោជន៍ដូចម្តេច បានជាមិនទៅរក តែគួរដើរតាមសាស្តា ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ សំដែងសេចក្តីនៃភាសិតនុ៎ះដោយប្រពៃ ដល់យើងខ្ញុំ ពួកភិក្ខុស្តាប់ភាសិត របស់ព្រះអង្គហើយ នឹងចងចាំទុក ។

(១៤) ម្នាលអានន្ទ សាវ័កមិនគួរដើរតាមតែព្រះសាស្តាទេ គឺថា គួរតែស្តាប់នូវសុត្តៈ គេយ្យៈ វេយ្យាករណៈ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះថាធម៌ទាំងឡាយ អ្នកទាំងឡាយ ក៏បានស្តាប់ បានទ្រទ្រង់ ចាំរកមាត់ ស្ទាត់ក្នុងចិត្ត ចាក់ធ្លុះដោយទិដ្ឋិជាយូរយារហើយ ។ ម្នាលអានន្ទ មួយទៀត កថាណា ដូចផង់ក្រៃលែង

ចេតោវិវរណសប្បាយា ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ សេយ្យថីទំ អប្បិច្ឆកថា សន្តុដ្ឋិ-កថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញាណទស្សនកថា ឯវរូបិយា ខោ អានន្ទ កថាយ ហេតុំ[១] អរហតិ សាវកោ សត្ថារំ អនុពន្ធិតុំ អបិ បណុជ្ជមានោតិ[២] ។ ឯវំ សន្តេ[៣] អានន្ទ អាចរិយូបទ្ទវោ ហោតិ ឯវំ សន្តេ អន្តេវាសូ-បទ្ទវោ ហោតិ ឯវំ សន្តេ ព្រហ្មចារូបទ្ទវោ ហោតិ ។

(២០) កថញ្ចានន្ទ អាចរិយូបទ្ទវោ ហោតិ ។ ឥធា-នន្ទ ឯកច្ចោ សត្ថា វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ តស្ស តថាវូបកដ្ឋស្ស វិហរតោ អន្វាវត្តន្តិ ព្រាហ្មណគហបតិកា នេគមា ចេវ

---

១ ម. ហេតុ ។ ២ ម. ឥតិសទ្ទោ នត្ថិ ។ ៣ ម. សន្តេ ខោ ។



ជាទីសប្បាយដល់កិរិយាពិចារណាដោយចិត្ត ប្រព្រឹត្តទៅ ដើម្បីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីរលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន កថា-នោះ គឺ អប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភក-ថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញាណ-ទស្សនកថា ម្នាលអានន្ទ សាវកគួរតែស្តាប់ ទុកជា មានសាស្តា យ៉ាងនោះ ទើបឈ្មោះថាមិនហៅគេ តែគួរដើរតាមសាស្តា ។ ម្នាល អានន្ទ កាលបើមានហេតុយ៉ាងនេះ ឧបទ្រពអាចារ្យ ក៏មាន កាល បើមានហេតុយ៉ាងនេះ ឧបទ្រពកូនសិស្ស ក៏មាន កាលបើមានហេតុ យ៉ាងនេះ ឧបទ្រពព្រហ្មចារ្យ ក៏មាន ។

(២០) ម្នាលអានន្ទ ឧបទ្រពអាចារ្យ តើដូចម្តេច ។ ម្នាល អានន្ទ សាស្តាខ្លះ ក្នុងលោកនេះ នៅអាស្រ័យ នូវសេនាសនៈ ដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោកភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ដងព្រៃ ទីវាល គំនរចំបើង ។ កាលដែលសាស្តានោះ ចៀស ចេញចាកពួកគណៈដូច្នោះ ពួកព្រាហ្មណ៍នឹងគហបតី អ្នកនិគមក្តី

ជានបទា ច ។ សោ អន្វាវត្តេសុ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច មុច្ឆំ និកាមយតិ(១) គេធំ អាបជ្ជតិ អាវត្តតិ ពាហុល្លាយ ។ អយំ វុច្ចតានន្ទ ឧបទ្ទវោ អាចរិយោ អាចរិយូបទ្ទវេន ។ អវធឹសុ នំ បាបកា អកុសលា ធម្មា សង្កិលេសិកា ពោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា ។ ឯវំ ខោ អានន្ទ អាចរិយូបទ្ទវោ ហោតិ ។

(២១) កថញ្ចានន្ទ អន្តេវាសិកូបទ្ទវោ ហោតិ ។ តស្សេវ ខោ បនានន្ទ សត្ថុ សាវកោ តស្ស សត្ថុ វិវេកមនុព្រូហយមានោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ តស្ស តថាវូបកដ្ឋស្ស វិហរតោ អន្វាវត្តន្តិ ព្រាហ្មណគហបតិកា នេគមា ចេវ ជានបទា ច ។ សោ

១ ឱ. មុច្ឆតិ កាមយតិ ។ ម. មុច្ឆំ កាមយតិ ។



អ្នកជនបទក្តី គឺប្រព្រឹត្តតាម (បែបផែននោះ) ។ កាលបើព្រាហ្មណ៍និងគហបតីក្តី អ្នកនិគមក្តី អ្នកជនបទក្តី ប្រព្រឹត្តតាមដូច្នោះហើយ សាស្តានោះ ប្រាថ្នានូវតណ្ហា ជាធម្មជាតិជ្រួលជ្រប់ ដល់នូវសេចក្តីត្រេកអរ គឺត្រឡប់មកកាន់សេចក្តីល្មោភវិញ ។ ម្នាលអានន្ទ នេះ គប្បីហៅថា ឧបទ្រពអាចារ្យ ព្រោះឧបទ្រពគឺកិលេស កើតក្នុងអាចារ្យ ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ជាគ្រឿងសៅហ្មង ជាធម៌នាំឲ្យកើតក្នុងភពថ្មីទៀត ប្រព្រឹត្តទៅដោយសេចក្តីក្រវល់ក្រវាយ ឲ្យផលជាទុក្ខ ប្រកបដោយជាតិ ជរានិងមរណៈ តទៅមុខ ក៏សម្លាប់នូវសាស្តានោះ ។ ម្នាលអានន្ទ យ៉ាងនេះឯង ជាឧបទ្រពអាចារ្យ ។

(២១) ម្នាលអានន្ទ ចុះឧបទ្រពសិស្ស តើដូចម្តេច ។ ម្នាលអានន្ទ សាវ័ករបស់សាស្តានោះឯង កាលចំរើនវិវេក យកតម្រាប់សាស្តានោះ ក៏អាស្រ័យនៅនូវសេនាសនៈដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោកភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ជនំព្រៃ ទីវាល គំនរចំបើង ។ ពួកព្រាហ្មណ៍និងគហបតីក្តី អ្នកនិគមក្តី អ្នកជនបទក្តី ក៏ប្រព្រឹត្តតាមសាវ័ក ដែលចេញចាកពួកដូច្នោះ ។ សាវ័កនោះប្រាថ្នា

អន្វាវត្តេសុ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច មុច្ឆំ និកាមយតិ គេធំ អាបជ្ជតិ អាវត្តតិ ពាហុល្លាយ ។ អយំ វុច្ចតានន្ទ ឧបទ្ទុតោ អន្តេវាសី អន្តេវាសូបទ្ទវេន ។ អវធិំសុ នំ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា ។ ឯវំ ខោ អានន្ទ អន្តេវាសូបទ្ទវោ ហោតិ ។

(២២) កថញ្ចានន្ទ ព្រហ្មចារូបទ្ទវោ ហោតិ ។ ឥធានន្ទ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ។ សោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ



នូវតណ្ហា ជាធម្មជាតិជ្រុលជ្រប់ ដល់នូវសេចក្តីត្រេកអរ ក៏ត្រឡប់មកកាន់សេចក្តីល្មោភ ក្នុងពួកព្រាហ្មណ៍និងគហបតី អ្នកនិគម អ្នកជនបទ ដែលប្រព្រឹត្តតាម (តាំងអម្បាលនោះ)វិញ ។ ម្នាលអានន្ទ នេះ តថាគតហៅថា ឧបទ្រពសិស្ស ព្រោះឧបទ្រពគឺកិលេស កើតក្នុងសិស្ស ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ជាគ្រឿងសៅហ្មង ជាធម៌នាំឲ្យកើត ក្នុងភពថ្មីទៀត ប្រព្រឹត្តទៅដោយសេចក្តីក្រវល់ក្រវាយ ឲ្យផលជាទុក្ខ ប្រកបដោយជាតិ ជរា និងមរណៈតទៅ ក៏សម្លាប់នូវសាវ័កនោះ ។ ម្នាលអានន្ទ យ៉ាងនេះឯង ជាឧបទ្រពសិស្ស ។

(៦៦) ម្នាលអានន្ទ ចុះឧបទ្រពព្រហ្មចារ្យ កើតមានដូចម្តេច ។ ម្នាលអានន្ទ ព្រះតថាគតឆ្ងាយចាកសឹកសត្រូវគឺកិលេស ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អទៅកាន់ព្រះនិព្វាន ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវចតុរារិយសច្ច មិនត្រឡប់មកកាន់ត្រៃភព ព្រះអង្គកើតឡើងក្នុងលោកនេះ ។ ព្រះតថាគតនោះ អាស្រ័យនៅទីសេនាសនៈដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោកភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ដងព្រៃ

អព្ភោកាសំ បលាលបុញ្ជំ ។ តស្ស តថាវូបកដ្ឋស្ស វិហរតោ អន្វាវត្តន្តិ ព្រាហ្មណគហបតិកា នេគមា ចេវ ជានបទា ច ។ សោ អន្វាវត្តន្តេសុ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច មុច្ឆំ និកាមយតិ គេធំ អាបជ្ជតិ អាវត្តតិ ពាហុល្លាយ ។ តស្សេវ ខោ បនានន្ទ សត្ថុ សាវកោ តស្ស សត្ថុ វិវេកមនុព្រូហយមានោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ តស្ស តថាវូបកដ្ឋស្ស វិហរតោ អន្វាវត្តន្តិ ព្រាហ្មណគហបតិកា នេគមា ចេវ ជានបទា ច ។ សោ អន្វាវត្តន្តេសុ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច មុច្ឆំ និកាមយតិ គេធំ អាបជ្ជតិ អាវត្តតិ ពាហុល្លាយ ។ អយំ វុច្ចតិ អានន្ទ ឧបទ្ទវោ ព្រហ្មចារី ព្រហ្មចារូបទ្ទវេន ។ អវធិំសុ នំ បាបកា អកុសលា ធម្មា សង្កិលេសិកា បោនោព្ភវិកា សទរា ទុក្ខវិបាកា អាយតិំ ជាតិជរាមរណិយា ។



វាលស្រឡះ គំនរចំបើង ។ ពួកព្រាហ្មណ៍និងគហបតី អ្នកនិគម អ្នកជនបទ ក៏ប្រព្រឹត្តតាមព្រះតថាគត ដែលចេញចាកពួកដូច្នោះ ។ ព្រះតថាគតនោះ មិនប្រាថ្នានូវតណ្ហាជាធម្មជាតិជ្រុលជ្រប់ មិនដល់នូវសេចក្ដីត្រេកអរ មិនត្រឡប់មកកាន់សេចក្ដីល្មោភ ក្នុងពួកព្រាហ្មណ៍និងគហបតី អ្នកនិគម អ្នកជនបទ ដែលប្រព្រឹត្តតាម (នោះ) ទេ ។ ម្នាលអានន្ទ តែថាសាវ័ករបស់សាស្ដានោះឯង ចំរើនវិវេក យកតម្រាប់សាស្ដានោះ គប់រកទីសេនាសនៈដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ដងព្រៃ វាលស្រឡះ គំនរចំបើង ។ ពួកព្រាហ្មណ៍និងគហបតី អ្នកនិគម អ្នកជនបទ ក៏ប្រព្រឹត្តតាមសាវ័កដែលចេញចាកពួកដូច្នោះ ។ សាវ័កនោះ បែរជាប្រាថ្នានូវតណ្ហាជាធម្មជាតិជ្រុលជ្រប់ ដល់នូវសេចក្ដីត្រេកអរ ក៏ត្រឡប់មកកាន់សេចក្ដីល្មោភ ក្នុងពួកព្រាហ្មណ៍និងគហបតី អ្នកនិគម អ្នកជនបទ ដែលប្រព្រឹត្តតាមនោះវិញ ។ ម្នាលអានន្ទ នេះឯង តថាគតហៅថា ឧបទ្រពព្រហ្មចារី ព្រោះឧបទ្រពគឺកិលេស ក្នុងព្រហ្មចារី ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ជាគ្រឿងសៅហ្មង ជាធម៌នាំឲ្យកើតក្នុងភពថ្មីទៀត ប្រព្រឹត្តទៅដោយសេចក្ដីក្រវល់ក្រវាយ ឲ្យផលជាទុក្ខ ប្រកបដោយជាតិ ជរា និងមរណៈតទៅ ក៏សម្លាប់នូវសាវ័កនោះ ។

ឯវំ ខោ អានន្ទ ព្រហ្មចារូបទ្ទវោ ហោតិ ។ តត្រានន្ទ យោ ចេវ[1] អាចរិយូបទ្ទវោ យោ ច អន្តេវាសូបទ្ទវោ អយំ តេហិ ព្រហ្មចារូបទ្ទវោ ទុក្ខវិបាកតរោ ចេវ កដុកវិបាកតរោ ច អបិ ច វិនិបាតាយ សំវត្តតិ ។ តស្មាតិហ មំ អានន្ទ មិត្តវតាយ សមុទាចរថ មា សបត្តវតាយ តំ វោ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយ ។

(២៣) កថញ្ចានន្ទ សត្ថារំ សាវកា សបត្តវតាយ សមុទាចរន្តិ នោ មិត្តវតាយ ។ ឥធានន្ទ សត្ថា

---
១ ម. ចេវាយំ ។



ម្នាលអានន្ទ យ៉ាងនេះឯង ជាឧបទ្រពព្រហ្មចារី ។ ម្នាលអានន្ទ បណ្តាឧបទ្រពទាំងនោះ ឧបទ្រពអាចារ្យក្តី ឧបទ្រពសិស្សក្តី ឲ្យផលជាទុក្ខល្មមទេ ចំណែកឧបទ្រពព្រហ្មចារីនេះ ទើបឲ្យផលជាទុក្ខយ៉ាងក្រៃលែង ឲ្យផលផ្សាក្តៅយ៉ាងក្រៃលែង ជាងឧបទ្រពអាចារ្យ នឹងឧបទ្រពសិស្សទាំងនោះទៅទៀត មិនតែប៉ុណ្ណោះ ប្រព្រឹត្តទៅ ដើម្បីធ្លាក់ចុះទៅកាន់អបាយ ។ ម្នាលអានន្ទ ហេតុនោះ អ្នកទាំងឡាយចូររាប់អានតថាគតដោយសេចក្តីប្រតិបត្តិជាមិត្ត កុំរាប់អានតថាគត ដោយសេចក្តីប្រតិបត្តិជា ជាអ្នកមានពៀរឡើយ សេចក្តីប្រតិបត្តិជាមិត្តនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយអស់កាលជាអង្វែងទៅ ។

(២៣) ម្នាលអានន្ទ ចុះពួកសាវ័ក រាប់អានសាស្តា ដោយសេចក្តីប្រតិបត្តិ ជាអ្នកមានពៀរ មិនរាប់អានសាស្តា ដោយសេចក្តីប្រតិបត្តិជាមិត្ត តើដូចម្តេច ។ ម្នាលអានន្ទ សាស្តាក្នុងលោកនេះ

សាវកានំ ធម្មំ ទេសេតិ អនុកម្បកោ ហិតេសី អនុកម្បំ ឧបាទាយ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស សាវកា ន សុស្សូសន្តិ ន សោតំ ឱទហន្តិ ន អញ្ញា ចិត្តំ(១) ឧបដ្ឋបេន្តិ វោក្កម្ម ច សត្ថុ សាសនំ(២) វត្តន្តិ ។ ឯវំ ខោ អានន្ទ សត្ថារំ សាវកា សបត្តវតាយ សមុទាចរន្តិ នោ មិត្តវតាយ ។

(២៤) កថញ្ចានន្ទ សត្ថារំ សាវកា មិត្តវតាយ សមុទាចរន្តិ នោ សបត្តវតាយ ។ ឥធានន្ទ សត្ថា សាវកានំ ធម្មំ ទេសេតិ អនុកម្បកោ ហិតេសី អនុកម្បំ ឧបាទាយ ឥទំ វោ ហិតាយ

---

១ ម. ឥ អញ្ញំ ចិត្តំ ។ ២ ម. យ. សាសនា ។



ជាអ្នកអនុគ្រោះ ស្វែងរកប្រយោជន៍ ប្រកបដោយសេចក្តីអនុគ្រោះ ទើបសំដែងធម៌ ដល់ពួកសាវកថា ធម្មជាតនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់អ្នកទាំងឡាយ ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ ឯពួកសាវករបស់សាស្តានោះ មិនស្តាប់ដោយគោរព មិនផ្ទៀងត្រចៀកស្តាប់ មិនតាំងចិត្តដែលត្រាច់ទៅក្នុងទីដទៃឲ្យតាំងនៅនឹង លះបង់លែងប្រព្រឹត្តតាមសាសនារបស់សាស្តា ។ ម្នាលអានន្ទ ពួកសាវកគប់កាន់សាស្តា ដោយប្រតិបត្តិជាអ្នកមានពៀរ មិនគប់កាន់ដោយសេចក្តីប្រតិបត្តិ ដើម្បីជាមិត្ត យ៉ាងនេះឯង ។

(២៤) ម្នាលអានន្ទ ចុះពួកសាវកគប់កាន់សាស្តា ដោយសេចក្តីប្រតិបត្តិជាមិត្ត មិនគប់កាន់ដោយសេចក្តីប្រតិបត្តិជាអ្នកមានពៀរ តើដូចម្តេច ។ ម្នាលអានន្ទ សាស្តាក្នុងលោកនេះ ជាអ្នកអនុគ្រោះ ស្វែងរកប្រយោជន៍ ប្រកបដោយសេចក្តីអនុគ្រោះ ទើបសំដែងធម៌ ដល់ពួកសាវកថា ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់អ្នកទាំងឡាយ

ទំ វោ សុខាយាតិ ។ តស្ស សាវកា សុស្សូសន្តិ សោតំ ឱទហន្តិ អញ្ញា ចិត្តំ ឧបដ្ឋបេន្តិ ន ច វោក្កម្ម សត្ថុ សាសនា វត្តន្តិ ។ ឯវំ ខោ អានន្ទ សត្ថារំ សាវកា មិត្តវតាយ សមុទាចរន្តិ នោ សបត្តវតាយ ។ តស្មាតិហ មំ អានន្ទ មិត្តវតាយ សមុទាចរថ មា សបត្តវតាយ តំ វោ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយាតិ[១] ។ ន វោ អហំ អានន្ទ តថា បរក្កមិស្សាមិ យថា កុម្ភការោ អាមកេ អាមកមត្តេ ។

១ ម. ហិតសុខាយាតិ ។



ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយ ។ ពួកសាវ័ក របស់សាស្តានោះ ខំប្រឹងស្តាប់ ផ្ទៀងត្រចៀកស្តាប់ តាំងចិត្តដែលត្រូវទៅ ក្នុងទីជាទីឲ្យត្រាស់ដឹង ទាំងមិនលះបង់ វែងប្រព្រឹត្តតាមសាសនា របស់សាស្តាឡើយ ។ ម្នាលអានន្ទ ពួកសាវ័ករាប់អានសាស្តា ដោយសេចក្តីប្រតិបត្តិជាមិត្ត មិនរាប់អានដោយសេចក្តីប្រតិបត្តិជាអ្នកមានពៀរ យ៉ាងនេះឯង ។ ម្នាលអានន្ទ ព្រោះហេតុនោះ អ្នកទាំងឡាយ គួររាប់អានតថាគត ដោយសេចក្តីប្រតិបត្តិជាមិត្តចុះ កុំរាប់អានតថាគត ដោយសេចក្តីប្រតិបត្តិជាអ្នកមានពៀរឡើយ ការប្រតិបត្តិជាមិត្តនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយ អស់កាលជាអង្វែងទៅ ។ ម្នាលអានន្ទ ស្មូនឆ្នាំង កាន់ភាជន៍ដីកមិនទាន់ស្ងួត (ថ្នមមិនឲ្យបែក) យ៉ាងណា តថាគត មិនបៀតបៀនអ្នកទាំងឡាយ យ៉ាងនោះដែរ ។

សុញ្ញតវគ្គស្ស មហាសុញ្ញតសុត្តំ មិត្តវត្តបដិបត្តិ

និគ្គយ្ហនិគ្គយ្ហាហំ អានន្ទ វក្ខាមិ បវយ្ហបវយ្ហាហំ(១) អានន្ទ វក្ខាមិ(២) យោ សារោ សោ ឋស្សតីតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

មហាសុញ្ញតសុត្តំ ទុតិយំ និដ្ឋិតំ ។

---

១ ។ បវយ្ហបវយ្ហាតិ ទិស្សតិ ។ ម. បគ្គយ្ហបគ្គយ្ហាតិ ទិស្សតិ ។ ២ ។. អានន្ទ វក្ខាមីតិ ន ទិស្សតិ ។



សុញ្ញតវគ្គ មហាសុញ្ញតសូត្រ សេចក្ដីប្រតិបត្តិជាមិត្ត

ម្នាលអានន្ទ តថាគតសង្កត់សង្កិនហើយ ប្រៀនប្រដៅរឿយ ៗ ម្នាលអានន្ទ តថាគតបន្ធូរបន្ថយ បំផ្លាញបន្ទូរទោសចេញហើយ ប្រៀនប្រដៅថែមទៀត ដោយគិតថាខ្លឹមឲ្យអ្នកទាំងឡាយ មានសារៈគឺមគ្គផល តាំងនៅក្នុងសន្តាន ៗ លុះព្រះមានបុណ្យ បានត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានសេចក្ដីពេញចិត្ត ត្រេកអរ ចំពោះភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ៗ

ចប់ មហាសុញ្ញតសូត្រ ទី ២ ។

# តតិយំ អច្ឆរិយព្ភុតធម្មសុត្តំ

(២៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថ ខោ សម្ពហុលានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តានំ ឧបដ្ឋានសាលាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ តថាគតស្ស មហិទ្ធិកតា មហានុភាវតា យត្រ ហិ នាម តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នបបញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ ជានិស្សតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំនាមា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំគោត្តា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំសីលា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំធម្មា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំបញ្ញា តេ ភគវន្តោ អហេសុំ ឥតិបិ

# អច្ឆរិយព្ភុតធម្មសូត្រ

(២៨) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាលពួកភិក្ខុមានចំនួនច្រើន ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត អង្គុយប្រជុំគ្នាក្នុងឧបដ្ឋានសាលា ក្នុងកាលនោះឯង អន្តរាកថានេះ កើតឡើងថា អស្ចារ្យណាស់ អាវុសោ ចំឡែកណាស់ អាវុសោ ត្រង់ដែលព្រះតថាគត ព្រះអង្គមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថា ព្រះតថាគត ទ្រង់ជ្រាប នូវព្រះអតីតពុទ្ធទាំងឡាយ ដែលបរិនិព្វានហើយ ទ្រង់ផ្តាច់ផ្តិលនូវកិលេស ជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្លងផុតនូវទុក្ខទាំងពួងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ ព្រះមានព្រះភាគ ទាំងនោះ មានព្រះនាមយ៉ាងនេះខ្លះ ព្រះមានព្រះភាគ ទាំងនោះ មានព្រះគោត្រយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានសីលយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានធម៌យ៉ាងនេះខ្លះ ព្រះមានព្រះភាគ ទាំងនោះ មានបញ្ញាយ៉ាងនេះខ្លះ

ឯវំវិហារី តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ តេ ភិក្ខូ ឯតទវោច អច្ឆរិយា ចេវ អាវុសោ តថាគតា អច្ឆរិយធម្មសមន្នាគតា ច អព្ភុតា ចេវ អាវុសោ តថាគតា អព្ភុតធម្មសមន្នាគតាតិ ។ អយញ្ច ហិទំ តេសំ ភិក្ខូនំ អយំ(១) អន្តរាកថា វិប្បកតា ហោតិ ។

(៤៦) អថ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនុបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឥធ ភន្តេ អម្ហាកំ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តានំ

១ ឱ. អយន្តុ ខ វិប្បតិ ។



ព្រះមានព្រះភាគទាំងនោះ មានវិហារធម៌យ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ។ លុះភិក្ខុទាំងឡាយ និយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ បានពោលនឹងភិក្ខុទាំងនោះដូច្នេះថា ម្នាលអាវុសោ ព្រះតថាគតទាំងឡាយ ជាបុគ្គលអស្ចារ្យ ទាំងប្រកបដោយធម៌អស្ចារ្យមែន ម្នាលអាវុសោ ព្រះតថាគតទាំងឡាយ ជាបុគ្គលចំឡែក ទាំងប្រកបដោយធម៌ដ៏ចំឡែកមែន ។ នេះជាអន្តរាកថា របស់ភិក្ខុទាំងនោះ អន្តរាកថានេះ គឺដាច់ពាក់កណ្ដាលទៅ ។

(៤៦) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីការសម្ងំក្នុងសាយណ្ហសម័យ ហើយចូលសំដៅទៅឧបដ្ឋានសាលា លុះទ្រង់ចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ហើយ ក៏មានព្រះបន្ទូលនឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ អង្គុយប្រជុំគ្នានិយាយដូចម្ដេច ចុះពាក្យដូចម្ដេច ដែលអ្នកទាំងឡាយបញ្ឈប់ទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន អម្បាញ់មិញនេះ ខ្ញុំព្រះអង្គទាំងឡាយ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត

ឧបដ្ឋានសាលាយំ សន្និសិន្នានំ សន្និបតិតានំ អយម-
ន្តរាកថា ឧទបាទិ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ
តថាគតស្ស មហិទ្ធិកតា មហានុភាវតា យត្រ ហិ
នាម តថាគតោ អតីតេ ពុទ្ធេ បរិនិព្វុតេ ឆិន្នប-
បញ្ចេ ឆិន្នវដុមេ បរិយាទិន្នវដ្ដេ សព្វទុក្ខវីតិវត្តេ ជា-
និស្សតិ ឯវំជច្ចា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំ-
នាមា... ឯវំគោត្តា... ឯវំសីលា... ឯវំធម្មា... ឯវំបញ្ញា...
ឯវំវិហារី... ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ
ឯវំ វុត្តេ ភន្តេ អាយស្មា អានន្ទោ អម្ហេ ឯតទវោច
អច្ឆរិយា ចេវ អាវុសោ តថាគតា អច្ឆរិយធម្មស-
មន្នាគតា ច អព្ភុតា ចេវ អាវុសោ តថាគតា



ក៏អង្គុយប្រជុំគ្នាក្នុងឧបដ្ឋានសាលា អន្តរកថានេះ កើតឡើងដូច្នេះថា
អស្ចារ្យណាស់ អាវុសោ ចំឡែកណាស់ អាវុសោ ត្រង់ដែលព្រះតថា-
គត ព្រះអង្គមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថា ព្រះតថាគត
ទ្រង់ជ្រាប នូវព្រះអតីតពុទ្ធទាំងឡាយ ដែលបរិនិព្វានហើយ ទ្រង់ផ្ដាច់
ផ្ដិលនូវកិលេស ជាគ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្ដាច់
ផ្ដិលនូវកម្ម ជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់ នូវកម្ម
ជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់កន្លងផុត នូវទុក្ខទាំងពួង ថា
ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ... មានព្រះនាម
យ៉ាងនេះខ្លះ .. មានព្រះគោត្រយ៉ាងនេះខ្លះ... មានសីលយ៉ាងនេះខ្លះ...
មានធម៌យ៉ាងនេះខ្លះ... មានប្រាជ្ញាយ៉ាងនេះខ្លះ... មានវិហារធម៌យ៉ាង
នេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ បពិត្រ
ព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គទាំងឡាយ និយាយយ៉ាងនេះហើយ ព្រះ
អានន្ទមានអាយុ ក៏និយាយនឹងខ្ញុំព្រះអង្គទាំងឡាយដូច្នេះថា ម្នាល
អាវុសោ ព្រះតថាគតទាំងឡាយ មានសេចក្ដីអស្ចារ្យ ទាំងប្រកបដោយ
ធម៌ដ៏អស្ចារ្យមែន ម្នាលអាវុសោ ព្រះតថាគតទាំងឡាយ ជាបុគ្គលចំឡែក

អព្ភុតធម្មសមន្នាគតា ជាតិ អយំ ខោ នោ ភន្តេ អន្តរាកថា វិប្បកតា អថ ភគវា អនុប្បត្តោតិ ។

(២៧) អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ តស្មាតិហ តំ អានន្ទ ភិយ្យោសោ មត្តាយ បដិភន្តុ តថាគតស្ស អច្ឆរិយា អព្ភុតធម្មាតិ ។

(២៨) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ សតោ សម្បជានោ អានន្ទ ពោធិសត្តោ តុសិតំ កាយំ ឧបបជ្ជីតិ[១] ។ យម្បិ ភន្តេ សតោ សម្បជានោ ពោធិសត្តោ តុសិតំ កាយំ ឧបបជ្ជិ ឥទម្បាហំ[២] ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

---

១ ម. ឧបបជ្ជតីតិ ។ ឱ. ឧបបជ្ជីតិ ។ ២ ម. ឥទម្បហំ ។ ម. ឥទំបាហំ ។



ជាបុគ្គលប្រកបដោយធម៌ដ៏អស្ចារ្យចំឡែក បពិត្រព្រះអង្គដ៏ចំរើន នេះជាអន្តរកថា ដែលខ្ញុំព្រះអង្គទាំងឡាយ បញ្ឈប់ក្នុងវេលា ដែលព្រះមានព្រះភាគ ទ្រង់ស្តេចមកដល់ ។

(២៧) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះអានន្ទថា ម្នាលអានន្ទ បើដូច្នោះ ធម៌ណា ដែលអស្ចារ្យ ដែលចំឡែក អ្នកចូរបំភ្លឺនូវធម៌នោះ ចំពោះតថាគត ឲ្យលើសលន់ពន់ប្រមាណ ក្នុងទីនេះចុះ ។

(២៨) ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យនុ៎ះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្រ្ត ពាក្យនេះ ខ្ញុំព្រះអង្គបានទទួលក្នុងទីចំពោះព្រះភក្រ្ត របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វកើតក្នុងពួកទេវតាជាន់តុសិត តែងមានសតិសម្បជញ្ញៈ ។ បពិត្រព្រះអង្គដ៏ចំរើន ពោធិសត្វកើតក្នុងពួកទេវតាជាន់តុសិត តែងមានសតិសម្បជញ្ញៈ ដោយហេតុណា បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភុតធម៌ (ធម៌អស្ចារ្យចំឡែក) របស់ព្រះមានព្រះភាគ ។

(២៩) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ សតោ សម្បជានោ អានន្ទ ពោធិសត្តោ តុសិតេ កាយេ អដ្ឋាសីតិ ។ យម្បិ ភន្តេ សតោ សម្បជានោ ពោធិសត្តោ តុសិតេ កាយេ អដ្ឋាសិ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

(៣០) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យាវតាយុកំ អានន្ទ ពោធិសត្តោ តុសិតេ កាយេ អដ្ឋាសីតិ ។ យម្បិ ភន្តេ យាវតាយុកំ ពោធិសត្តោ តុសិតេ កាយេ អដ្ឋាសិ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។



(២៩) បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វ ឋិតនៅក្នុងពួកទេវតាជាន់តុសិត តែងមានសតិសម្បជញ្ញៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ពោធិសត្វឋិតនៅក្នុងពួកទេវតាជាន់តុសិត តែងមានសតិសម្បជញ្ញៈ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះមានព្រះភាគ ។

(៣០) បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វ ឋិតនៅក្នុងពួកទេវតាជាន់តុសិត ដរាបដល់អស់អាយុ ។ បពិត្រព្រះអង្គដ៏ចម្រើន ពោធិសត្វ ឋិតនៅក្នុងពួកទេវតាជាន់តុសិត ដរាបដល់អស់ព្រះជន្មាយុ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះមានព្រះភាគ ។

(៣១) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ សតោ សម្បជានោ អានន្ទ ពោធិសត្តោ តុសិតា កាយា ចវិត្វា មាតុ កុច្ឆឹ ឱក្កមីតិ ។ យម្បិ ភន្តេ សតោ សម្បជានោ ពោធិសត្តោ តុសិតា កាយា ចវិត្វា មាតុ កុច្ឆឹ ឱក្កមិ ឥទម្បហំ ភន្តេ ។ បេ ។ ធារេមិ ។

(៣២) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ ពោធិសត្តោ តុសិតា កាយា ចវិត្វា មាតុ កុច្ឆឹ ឱក្កមតិ[១] អថ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អប្បមាណោ ឧឡារោ[២] ឱភាសោ បាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ យាបិ តា លោកន្តរិកា[៣] អឃា អសំវុតា អន្ធការា អន្ធការតិមិសា យត្ថបិមេ ចន្ទិមសុរិយា ឯវំមហិទ្ធិកា

១ ឱ ឱក្កមតិ ទិស្សតិ។ ២ ឱ.ម. ឧឡារោ។ ៣ លោកន្តរិកាតិបាឋោ ទិស្សតិ អដ្ឋកថាយំ ។



(៣១) បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ ក្នុងទីចំពោះព្រះភ័ក្ត្រ បានទទួលក្នុងទីចំពោះព្រះភ័ក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វ ច្យុតចាកពួកទេវតាជាន់តុសិត ចុះមកកាន់ផ្ទៃនៃមាតា តែងមានសតិសម្បជញ្ញៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ពោធិសត្វ ច្យុតចាកពួកទេវតាជាន់តុសិត ទ្រង់ចុះមកកាន់ផ្ទៃព្រះមាតា តែងមានសតិសម្បជញ្ញៈ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ។ បេ ។

(៣២) បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ ក្នុងទីចំពោះព្រះភ័ក្ត្រ បានទទួលក្នុងទីចំពោះព្រះភ័ក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលណាពោធិសត្វ ច្យុតចាកពួកទេវតាជាន់តុសិត ចុះមកកាន់ផ្ទៃនៃមាតា កាលនោះពន្លឺដ៏លើសលុបហួសប្រមាណ កើតប្រាកដក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ទាំងសមណព្រាហ្មណ៍ និងពួកសត្វ គឺទេវតានិងមនុស្សដ៏សេស ជាគន្លងនូវទេវានុភាព របស់ទេវតាទាំងឡាយ ទាំងចន្លោះនៃលោកណា ដែលបើកចំហ មិនមានទីតម្កល់នៅខាងក្រោម មានតែងងឹត ប្រកបដោយងងឹតងងឹតអន្ធ ព្រះចន្ទ្រនិងព្រះអាទិត្យនេះ មានឫទ្ធិច្រើនយ៉ាងនេះ

វំមហានុភាវា អាភាយ នានុភោន្តិ តត្ថបិ អប្បមា-
ណោ ឧឡារោ ឱភាសោ បាតុភវតិ អតិក្កមេវ ទេវានំ
ទេវានុភាវំ ។ យេបិ តត្ថ សត្តា ឧបបន្នា តេបិ តេនោភា-
សេន អញ្ញមញ្ញស្ស ជានន្តិ[១] អញ្ញេបិ កិរ ភោ សន្តិ
សត្តា ឥធូបបន្នាតិ អយញ្ច ទសសហស្សី លោក-
ធាតុ សង្កម្បតិ សម្បកម្បតិ សម្បវេធតិ អប្ប-
មាណោ ច ឧឡារោ ឱភាសោ លោកេ បាតុភវតិ
អតិក្កមេវ ទេវានំ ទេវានុភាវន្តិ ។ យម្បិ ភន្តេ
។ បេ ។ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ
អព្ភុតធម្មំ ធារេមិ ។

(៣៣) សម្មុខា មេតំ ភន្តេ ភគវតោ
សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ
ពោធិសត្តោ មាតុ កុច្ឆិំ ឱក្កន្តោ ហោតិ ចត្តា-
រោ នំ ទេវបុត្តា ចតុទ្ទិសារក្ខាយ ឧបគច្ឆន្តិ

១ ឱ. ម. អញ្ញមញ្ញំ សញ្ជានន្តិ ទិស្សតិ ។ ២ ម. សំកម្បិ សំបកម្បិ សំបវេធិ ទិស្សតិ ។



មានអានុភាពច្រើនយ៉ាងនេះ មិនបានចាំងទៅក្នុងទីណា ពន្លឺដ៏លើស
លុបហួសប្រមាណ កន្លងបង់នូវទេវានុភាព របស់ទេវតាទាំងឡាយ ក៏
កើតប្រាកដក្នុងទីនោះ មួយទៀត ពួកសត្វណា ដែលកើតក្នុងទីនោះ
ពួកសត្វនោះ ក៏ស្គាល់គ្នាស្រស់ទៅវិញទៅមក ដោយពន្លឺនោះថា យីអើ
ពួកសត្វដទៃមានមកកើត ក្នុងទីនេះដែរតើ មួយទៀត លោកធាតុទាំង
មួយម៉ឺននេះ ក៏រំភើប ញាប់ញ័រ រន្ធត់ ឯពន្លឺដ៏លើសលុបហួសប្រមាណ
កន្លងបង់នូវទេវានុភាព របស់ទេវតា ក៏កើតប្រាកដក្នុងលោក បពិត្រ
ព្រះអង្គដ៏ចំរើន ដោយហេតុណា ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន
ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ជាអច្ឆរិយព្ភុតធម៌ របស់
ព្រះមានព្រះភាគ ។

(៣៣) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់
ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមាន
ព្រះភាគថា ម្នាលអានន្ទ កាលណាពោធិសត្វ ចុះកាន់ផ្ទៃព្រះមាតា
មានទេវបុត្រ ៤ អង្គ ចូលមកការពារពោធិសត្វនោះ ក្នុងទិសទាំង ៤

មា នំ(១) ពោធិសត្តំ វា ពោធិសត្តមាតរំ វា មនុស្សោ វា អមនុស្សោ វា កោចិ វា វិហេសេសីតិ(២) ។ យម្បិ ភន្តេ ។បេ។ ឥទម្បហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

(៣៤) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ ពោធិសត្តោ មាតុកុច្ឆិំ ឱក្កន្តោ ហោតិ បកតិយា សីលវតី ពោធិសត្តមាតា ហោតិ វិរតា បាណាតិបាតា វិរតា អទិន្នាទានា វិរតា កាមេសុ មិច្ឆាចារា វិរតា មុសាវាទា វិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា ។ យម្បិ ភន្តេ ។បេ។ ឥទម្បហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

១ ឱ. នំ គោតិ ទិស្សតិ ។ ២ ឱ. ម. វិហេឋេសីតិ ។



ដោយគិតថា កុំឲ្យមនុស្សឬអមនុស្ស ឬអ្នកណាមួយ បៀតបៀនពោធិសត្វនឹងមាតាពោធិសត្វបានឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះមានព្រះភាគ ។

(៣៤) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលណាពោធិសត្វ ចុះកាន់ផ្ទៃមាតា មាតានៃពោធិសត្វ ជាអ្នកមានសីលដោយប្រក្រតី គឺជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ។ បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះមានព្រះភាគ ។

(៣៥) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ ពោធិសត្តោ មាតុ កុច្ឆឹ ឱក្កន្តោ ហោតិ ន ពោធិសត្តមាតុ បុរិសេសុ មានសំ ឧប្បជ្ជតិ កាមគុណោបសញ្ហិតំ អនតិក្កមនីយា ច ពោធិសត្តមាតា ហោតិ កេនចិ បុរិសេន រត្តចិត្តេនាតិ ។ យម្បិ ភន្តេ ។ បេ ។ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

(៣៦) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ ពោធិសត្តោ មាតុ កុច្ឆឹ ឱក្កន្តោ ហោតិ លាភិនី ពោធិសត្តមាតា ហោតិ បញ្ចន្នំ កាមគុណានំ សា បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិចារេតីតិ[1] យម្បិ ភន្តេ ។ បេ ។ ឥទម្បហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

[1] ម. បរិចារេតិ ។



(៣៥) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចុះកាន់ផ្ទៃមាតា មាតានៃពោធិសត្វ មិនកើតចំណង់ដែលប្រកបដោយកាមគុណ ក្នុងបុរសទាំងឡាយឡើយ ទាំងបុរសណាមួយ ដែលមានចិត្តត្រេក ក៏មិនអាចប្រព្រឹត្តកន្លងមាតាពោធិសត្វបានទេ ។ បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៣៦) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចុះកាន់ផ្ទៃមាតា មាតានៃពោធិសត្វ ជាស្ត្រីបាននូវកាមគុណទាំង៥ប្រការ ឆ្អែតស្កប់ស្កល់ មូលមិត្ត ដោយកាមគុណទាំង៥ប្រការ ។ បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៣៧) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ ពោធិសត្តោ មាតុកុច្ឆឹ ឱក្កន្តោ ហោតិ ន ពោធិសត្តមាតុ កោចិទេវ អាពាធោ ឧប្បជ្ជតិ សុខិនី ពោធិសត្ត-មាតា ហោតិ អកិលន្តកាយា ពោធិសត្តញ្ច ពោធិ-សត្តមាតា តិរោកុច្ឆិគតំ បស្សតិ សព្វង្គបច្ចង្គឹ អ-ហីនិន្ទ្រិយំ ។ សេយ្យថាបិ អានន្ទ មណិ វេឡុ-រិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ ។ តត្រស្ស សុត្តំ អាវុតំ នីលំ វា បីតំ វា លោហិតកំ[១] វា ឱទាតំ វា បណ្ឌុសុត្តំ វា ។ តមេនំ ចក្ខុមា បុរិសោ ហត្ថេ ករិត្វា បច្ចវេក្ខេយ្យ អយំ ខោ មណិ វេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ ។

១ ម. ម. លោហិតំ ។



(៣៧) បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្ដាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលណាពោធិសត្វ ចុះកាន់ផ្ទៃមាតា មាតាពោធិសត្វ ឥតមានអាពាធណាមួយកើតឡើងទេ មាតាពោធិសត្វជាស្ត្រីមានសេចក្ដីសុខ ឥតមានលំបាកកាយ មាតាពោធិសត្វ តែងឃើញពោធិសត្វសព្វអវយវៈតូចធំ មានឥន្ទ្រិយមិនសៅហ្មង ហាក់ដូចជាបិតនៅខាងក្រៅផ្ទៃ ។ ម្នាលអានន្ទ ដូចកែវមណីដ៏កែវពិទូរ្យដ៏ល្អ មានពន្លឺ មានជ្រុង ៨ ដែលគេធ្វើហើយជាយល្អ ។ បុគ្គលយកសូត្រដែលមានពណ៌ខៀវក្ដី លឿងក្ដី ក្រហមក្ដី សក្ដី សូត្រដែលមានពណ៌លឿងទុំក្ដី ទៅដោតក្នុងកែវនោះ ។ បុរសដែលមានចក្ខុ យកមកដាក់ក្នុងដៃហើយ ពិចារណាស្គាល់ច្បាស់នូវកែវនោះថា នេះជាកែវមណី ជាកែវពិទូរ្យ ដ៏ល្អ មានពន្លឺ មានជ្រុង ៨ ដែលគេធ្វើជាយប្រពៃ ។

តត្រាស្ស សុត្តំ អាវុតំ នីលំ វា បីតំ វា លោហិតកំ វា ឱទាតំ វា បណ្ឌុសុត្តំ វាតិ ឯវមេវ ខោ អានន្ទ យទា បោធិសត្តោ មាតុ កុច្ឆិំ ឱក្កន្តោ ហោតិ ន បោធិសត្តមាតុ កោចិទេវ អាពាធោ ឧប្បជ្ជតិ សុខិនី បោធិសត្តមាតា ហោតិ អកិលន្តកាយា បោធិសត្តញ្ច បោធិសត្តមាតា តិរោកុច្ឆិគតំ បស្សតិ សព្វង្គប្បច្ចង្គិំ អហីនិន្ទ្រិយន្តិ ។ យម្បិ ភន្តេ ។ បេ ។ ឥទម្បហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

(៣៨) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ សត្តាហំ ជាតេ អានន្ទ បោធិសត្តេ បោធិសត្តមាតា កាលំ ករោតិ តុសិតកាយំ ឧបបជ្ជតីតិ ។ យម្បិ ភន្តេ ។ បេ ។ ឥទម្បហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។



បុគ្គលយកសូត្រ ដែលមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី សក្តី សូត្រដែលមានពណ៌លឿងទុំក្តី ទៅដោតក្នុងកែវនោះ យ៉ាងណា ម្នាលអានន្ទ កាលណាពោធិសត្វ ចុះកាន់ផ្ទៃមាតា មាតាពោធិសត្វ មិនដែលមានអាពាធណាមួយកើតឡើងទេ មាតាពោធិសត្វ ជាស្ត្រីមានសេចក្តីសុខ ឥតមានលំបាកកាយ មាតាពោធិសត្វ រមែងឃើញពោធិសត្វសព្វអវយវៈតូចធំ មានឥន្ទ្រិយមិនថោកថយ ហាក់ដូចជាឋិតនៅខាងក្រៅផ្ទៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៣៨) បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលពោធិសត្វប្រសូតហើយ បាន ៧ ថ្ងៃ មាតាពោធិសត្វរមែងធ្វើមរណកាល ទៅកើតក្នុងពួកទេវតាជាន់តុសិត ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៣៩) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យថា ខោ បនានន្ទ អញ្ញា ឥត្ថិកា នវ វា ទស វា មាសេ គព្ភំ កុច្ឆិនា បរិហរិត្វា វិជាយន្តិ ន ហេវំ ពោធិសត្តំ ពោធិសត្តមាតា វិជាយតិ ទសេវ មាសានិ ពោធិសត្តំ ពោធិសត្តមាតា កុច្ឆិនា បរិហរិត្វា វិជាយតីតិ ។ យម្បិ ភន្តេ ។បេ។ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

(៤០) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យថា ខោ បនានន្ទ អញ្ញា ឥត្ថិកា និសិន្នា វា និបន្នា វា វិជាយន្តិ ន ហេវំ ពោធិសត្តំ ពោធិសត្តមាតា វិជាយតិ ឋិតាវ ពោធិសត្តំ ពោធិសត្តមាតា វិជាយតីតិ ។ យម្បិ ភន្តេ ។បេ។ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។



(៣៩) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពួកស្ត្រីដទៃទៀត ពរគភ៌ដោយផ្ទៃអស់ ៩ ខែខ្លះ ១០ ខែខ្លះ ទើបប្រសូតកូនដូចម្តេចមិញ ឯមាតាពោធិសត្វមិនប្រសូតពោធិសត្វដូច្នោះទេ មាតាពោធិសត្វ លុះរក្សាពោធិសត្វដោយផ្ទៃអស់ ១០ ខែគត់ ទើបប្រសូត ។ បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៤០) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួល ក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពួកស្ត្រីដទៃទៀត អង្គុយប្រសូតក៏មាន ដេកប្រសូតក៏មាន ឯមាតាពោធិសត្វ មិនប្រសូតពោធិសត្វបែបនេះទេ មាតាពោធិសត្វ តែងឈរប្រសូតពោធិសត្វតែមួយយ៉ាង បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៤៥) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ ពោធិសត្តោ មាតុកុច្ឆិម្ហា[១] និក្ខមតិ ទេវា បឋមំ បដិគ្គណ្ហន្តិ[២] បច្ឆា មនុស្សាតិ ។ យម្បិ ភន្តេ ។ បេ ។ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

(៤៦) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ ពោធិសត្តោ មាតុកុច្ឆិម្ហា និក្ខមតិ អប្បត្តោវ ពោធិសត្តោ បឋវឹ ហោតិ ចត្តារោ នំ ទេវបុត្តា បដិគ្គហេត្វា មាតុ បុរតោ ឋ[៣]បេន្តិ អត្តមនា ទេវី ហោហិ[៤] មហេសក្ខោ តេ បុត្តោ ឧប្បន្នោតិ ។ យម្បិ ភន្តេ ។ បេ ។ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

---

១ ឱ. កុច្ឆិស្មា ។ ២ ម. បដិគ្គណ្ហន្តិ ទិស្សតិ ។ ៣ ឱ. វេសេក្កោ ឋន្តិ ។ ៤ ឱ.ម. ហោតិ ។



(៤៥) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃមាតា ពួកទេវតាទទួលមុន ទើបពួកមនុស្សទទួលក្រោយ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៤៦) បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃមាតា ពោធិសត្វមិនទាន់ដល់ផែនដីនៅឡើយ ទេវបុត្រ ៤ អង្គទទួលពោធិសត្វនោះ មកតម្កល់ទុកនៅទីចំពោះព្រះភក្ត្រមាតា ហើយពោលថា សូមព្រះនាងទេវីមានព្រះទ័យត្រេកអរចុះ ព្រះរាជបុត្រមានស័ក្តិធំរបស់ព្រះនាងកើតហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៤៣) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ សោ[១] ពោធិសត្តោ មាតុ កុច្ឆិម្ហា និក្ខមតិ អថ វិសុទ្ធោវ និក្ខមតិ អមក្ខិតោ ឧទ្ទេន អមក្ខិតោ សេម្ហេន អមក្ខិតោ រុហិរេន អមក្ខិតោ កេនចិ អសុចិនា សុទ្ធោ វិសុទ្ធោ ។ សេយ្យថាបិ អានន្ទ មណិរតនំ កាសិកេ វត្ថេ និក្ខិត្តំ នេវ មណិរតនំ កាសិកំ វត្ថំ មក្ខេតិ នាបិ កាសិកំ វត្ថំ មណិរតនំ មក្ខេតិ តំ កិស្ស ហេតុ ឧភិន្នំ សុទ្ធត្តា ឯវមេវ ខោ អានន្ទ យទា ពោធិសត្តោ មាតុ កុច្ឆិម្ហា និក្ខមតិ វិសុទ្ធោ និក្ខមតិ អមក្ខិតោ ឧទ្ទេន អមក្ខិតោ សេម្ហេន ។បេ។ អមក្ខិតោ កេនចិ អសុចិនា សុទ្ធោ វិសុទ្ធោតិ ។ យម្បិ ភន្តេ ។បេ។ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

១ ម. សោតិ ន ទិស្សតិ ។



(៤៣) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្ដាប់ ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃព្រះមាតា ក៏ចេញមកស្អាតបាត មិនប្រឡាក់ដោយទឹករំអិល មិនប្រឡាក់ដោយស្លេស្ម មិនប្រឡាក់ដោយឈាម មិនប្រឡាក់ដោយខ្ទុះ មិនប្រឡាក់ដោយវត្ថុមិនស្អាត ណាមួយឡើយ ជាទ្រង់បរិសុទ្ធស្អាតវិសេស ។ ម្នាលអានន្ទ ដូចកែវមណី ដែលគេដាក់លើកាសិកពស្ត្រ កែវមណីមិនបានប្រឡាក់កាសិកពស្ត្រ ចំណែកកាសិកពស្ត្រក៏មិនប្រឡាក់កែវមណីឡើយ ដំណើរនោះព្រោះហេតុអ្វី ព្រោះហេតុវត្ថុទាំងពីរនោះ ជារបស់ស្អាតដូចគ្នា សេចក្ដីនេះយ៉ាងណា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃមាតា ក៏ចេញមក ស្អាតវិសេស មិនប្រឡាក់ដោយទឹករំអិលមិនប្រឡាក់ដោយស្លេស្ម ។បេ។ មិនប្រឡាក់ដោយវត្ថុមិនស្អាតណាមួយឡើយ ជាទ្រង់បរិសុទ្ធស្អាតវិសេស ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៦៦) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ ពោធិសត្តោ មាតុ កុច្ឆិម្ហា និក្ខមតិ ទ្វេ ឧទកស្ស ធារា អន្តលិក្ខា បាតុភវន្តិ ឯកា សីតស្ស ឯកា ឧណ្ហស្ស យេន ពោធិសត្តស្ស ឧទកកិច្ចំ ករោតិ[១] មាតុ ចាតិ ។ យម្បិ ភន្តេ ។ បេ ។ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

(៦៧) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ សម្បតិជាតោ អានន្ទ ពោធិសត្តោ សមេហិ បាទេហិ បឋវិយំ[២] បតិដ្ឋហិត្វា ឧត្តរាភិមុខោ សត្តបទវីតិហារេន គច្ឆតិ សេតម្ហិ ឆត្តេ អនុហីរមានេ[៣] សព្វា ច ទិសា វិលោកេតិ អាសភិញ្ច វាចំ ភាសតិ អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស

១. ឱ. ករោន្តិ ។ ២. ឱ. បឋវិយន្តិ ន ទិស្សតិ ។ ៣. ឱ. អនុហីរមានេ ។ ម. អនុធារិយមានេ ។



(៦៦) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃមាតា មានធារទឹក ២ ហូរមកអំពីអាកាស គឺធារទឹកត្រជាក់ ១ ធារទឹកក្តៅ ១ អ្នកផងក៏ធ្វើទឹកកិច្ច ដល់ពោធិសត្វនឹងព្រះមាតា ដោយធារដែលហូរមកនោះ ។ បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(៦៧) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ឋានលើផែនដី ដោយព្រះបាទដ៏ស្មើ បែរព្រះភក្ត្រទៅទិសខាងជើង ទ្រង់ស្តេចដោយព្រះបាទបាន ៧ ជំហាន កាលគេកំពុងបាំងស្វេតច្ឆត្រថ្វាយ ទ្រង់ក្រឡេកមើលគ្រប់ទិសទាំងអស់ ទើបបញ្ចេញអាសភិវាចាថា អាត្មាអញ ជាកំពូលរបស់លោក អាត្មាអញ ជាបុគ្គលច្បងជាងលោក

សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ យម្បិ ភន្តេ ។ បេ ។ ឥទម្បហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមិ ។

(៤៦) សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យទា អានន្ទ ពោធិសត្តោ មាតុ កុច្ឆិម្ហា និក្ខមតិ អថ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវ-មនុស្សាយ អប្បមាណោ ឧឡារោ ឱភាសោ បាតុភវតិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ យាបិ តា លោ-កន្តរិកា អឃា អសំវុតា អន្ធការា អន្ធការ-តិមិសា យត្ថបិមេ ចន្ទិមសុរិយា ឯវំមហិទ្ធិកា



អាត្មាអញ ជាបុគ្គលប្រសើរជាងសត្វលោក ជាតិនេះជាជាតិទីបំផុត ឥឡូវនេះ មិនមានភពថ្មីទៀតឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។ បេ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះមានព្រះភាគ ។

(៤៦) បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃមាតា មានពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន កើតប្រាកដ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ គឺនឹងមនុស្សជាសម្មតិទេព ព្រមទាំងមនុស្សដ៏សេស ជាពន្លឺកន្លងបង់នូវទេវានុភាព របស់ទេវតាទាំងឡាយ ទាសណាដែលចំហទទេ មានក្នុងចន្លោះលោក ឥតមានអ្វីបាំងកំបាំង មានតែអន្ធងងឹតមួយទៀត ព្រះច័ន្ទព្រះអាទិត្យទាំងនេះ សឹងមានឫទ្ធិច្រើនយ៉ាងនេះ

ឯវំមហានុភាវា អាភាយ នានុភោន្តិ តត្ថបិ អប្បមា-
ណោ ឧឡារោ ឱភាសោ បាតុភវតិ អតិក្កមេ្មវ
ទេវានំ ទេវានុភាវំ ។ យេបិ តត្ថ សត្តា ឧបបន្នា តេបិ
តេនោភាសេន អញ្ញមញ្ញំ សញ្ជានន្តិ អញ្ញេបិ កិរ ភោ
សន្តិ សត្តា ឥធូបបន្នាតិ អយំ ច(១) ទសសហស្សី
លោកធាតុ សង្កម្បតិ សម្បកម្បតិ សម្បវេធតិ
អប្បមាណោ ច ឧឡារោ ឱភាសោ លោកេ បាតុភវតិ
អតិក្កមេ្មវ ទេវានំ ទេវានុភាវន្តិ ។ យម្បិ ភន្តេ ។បេ។
ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមីតិ ។

(២៧) តស្មាតិហ ត្វំ អានន្ទ ឥទម្បិ តថាគតស្ស
អច្ឆរិយំ អព្ភុតធម្មំ ធារេហិ ។ ឥធានន្ទ តថាគតស្ស
វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា
អព្ភត្ថំ គច្ឆន្តិ វិទិតា សញ្ញា... វិទិតា វិតក្កា ឧប្ប-
ជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។

១ ម. អយម្បិ ។



មានអានុភាពច្រើនយ៉ាងនេះ ផ្សាយពន្លឺទៅមិនដល់ ក្នុងទីឱកាសណា
ពន្លឺភ្លឺស្វាងឧឡារ ក៏ប្រមាណមិនបាន កន្លងបង់នូវទេវានុភាពរបស់
ទេវតាទាំងឡាយ ក៏កើតប្រាកដឡើងក្នុងទីឱកាសទាំងនោះ ពួកសត្វ
ដែលកើតក្នុងទីនោះ ក៏ស្គាល់គ្នាទៅវិញទៅមក ដោយសារពន្លឺនោះថា
អើហ្ន៎ មានពួកសត្វដទៃមកកើត ក្នុងទីនេះដែរតើ ។ លោកធាតុទាំង
១ ម៉ឺននេះ ក៏កក្រើករំពើកញាប់ញ័រ ឯពន្លឺភ្លឺស្វាងឧឡារក៏ប្រមាណមិន
បាន ក៏កើតប្រាកដឡើងក្នុងលោក ជាពន្លឺកន្លងបង់នូវទេវានុភាពរបស់
ទេវតាទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចំរើន ដោយហេតុណា ។បេ។
បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជា
អច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

(២៧) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ ព្រោះហេតុ
នោះ អ្នកចូរចាំទុក នូវហេតុនេះថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះតថា-
គត ក្នុងសាសនានេះចុះ ។ ម្នាលអានន្ទ តថាគត មានវេទនាកើតប្រាកដ
តាំងនៅប្រាកដ ដល់នូវកិរិយាអស់ទៅប្រាកដ សញ្ញា... វិតក្កៈ កើត
ប្រាកដ តាំងនៅប្រាកដ ដល់នូវកិរិយាអស់ទៅប្រាកដ ក្នុងលោកនេះ ។

ឥទម្បិ ខោ ត្វំ អានន្ទ តថាគតស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេហីតិ ។ យម្បិ ភន្តេ ភគវតោ វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ វិទិតា សញ្ញា... វិទិតា វិតក្កា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ ឥទម្បាហំ ភន្តេ ភគវតោ អច្ឆរិយំ អព្ភុតធម្មំ ធារេមីតិ ។ ឥទមវោច អាយស្មា អានន្ទោ ។ សមនុញ្ញោ សត្ថា អហោសិ ។ អត្តមនា(១) តេ ភិក្ខូ អាយស្មតោ អានន្ទស្ស ភាសិតំ អភិនន្ទុន្តិ ។

អច្ឆរិយព្ភុតធម្មសុត្តំ និដ្ឋិតំ ។

១ ម. អត្តមនា ប ។



ម្នាលអានន្ទ ចូរអ្នកចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះតថាគតចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មានវេទនាកើតប្រាកដ តាំងនៅប្រាកដ ដល់នូវកិរិយាអស់ទៅប្រាកដ ដោយហេតុណា ។ សញ្ញា... វិតក្កៈ កើតប្រាកដ តាំងនៅប្រាកដ ដល់នូវកិរិយាអស់ទៅប្រាកដ ដោយហេតុណា ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចាំទុក ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះមានព្រះភាគ ។ ព្រះអានន្ទមានអាយុ បានពោលពាក្យនេះ ។ ព្រះសាស្តាទ្រង់ពេញព្រះហឫទ័យ ។ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិតរបស់ព្រះអានន្ទមានអាយុ ។

ចប់ អច្ឆរិយព្ភុតធម្មសូត្រ ទី ៣ ។

## ចតុត្ថំ ពក្កុលត្ថេរប្បវត្តិសុត្តំ(*)

(៤៨) ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា ពក្កុលោ រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ អចេលោ កស្សបោ(២) អាយស្មតោ ពក្កុលស្ស បុរាណគិហិសហាយោ យេនាយស្មា ពក្កុលោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា ពក្កុលេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អចេលោ កស្សបោ អាយស្មន្តំ ពក្កុលំ ឯតទវោច កីវចិរំ បព្វជិតោសិ អាវុសោ ពក្កុលាតិ ។ អសីតិ មេ អាវុសោ វស្សានិ បព្វជិតស្សាតិ ។ ឥមេហិ បន តេ អាវុសោ ពក្កុល អសីតិយា វស្សេហិ កតិក្ខត្តុំ មេថុនោ ធម្មោ បដិសេវិតោតិ ។

* ១. ពក្កុលសុត្តន្តិ ទិស្សតិ ។ ម. ពាកុលត្ថេរស្ស អច្ឆរិយសុត្តំ ។ ២ ឱ. ម. អចេលកស្សបោ ។

## ពក្កុលត្ថេរប្បវត្តិសូត្រ ទី ៤

(៤៨) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះពក្កុលៈ មានអាយុ នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង អចេល ឈ្មោះកស្សប ជាសំឡាញ់របស់ព្រះពក្កុលៈមានអាយុ ក្នុងកាលនៅជាគ្រហស្ថពីដើម ចូលទៅរកព្រះពក្កុលៈមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យរាក់ទាក់សំណេះសំណាល ទៅរកព្រះពក្កុលៈមានអាយុ លុះបញ្ចប់ពាក្យសំណេះសំណាល ដ៏នីពាក្យដែលគួររលឹកហើយ ទើបអង្គុយក្នុងទីសមគួរ ។ លុះអចេលកស្សបអង្គុយ ក្នុងទីសមគួរហើយ ក៏សួរព្រះពក្កុលៈមានអាយុដូច្នេះថា បពិត្រព្រះពក្កុលៈមានអាយុ លោកម្ចាស់បួសយូរប៉ុន្មានឆ្នាំហើយ ។ ព្រះពក្កុលៈឆ្លើយថា អាត្មាបួស ៨០ វស្សាហើយ ។ អចេលកស្សបសួរទៀតថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនប៉ុន្មានដង ។

(៦៩) ន ខោ មំ អាវុសោ កស្សប ឯវំ បុច្ឆិតព្វំ កិត្តកំ បន តេ អាវុសោ ពក្កុល មេថុនោ ធម្មោ បដិសេវិតោតិ ឯវញ្ច ខោ មំ អាវុសោ កស្សប បុច្ឆិតព្វំ កិត្តកំ បន តេ អាវុសោ ពក្កុល អសីតិយា វស្សេហិ កាមសញ្ញា ឧប្បន្នបុព្វាតិ ។ អសីតិ មេ អាវុសោ វស្សានិ បព្វជិតស្ស នាភិជានាមិ កាមសញ្ញំ ឧប្បន្នបុព្វន្តិ(១) ។ យម្បាយស្មា ពក្កុលោ អសីតិយា វស្សេហិ នាភិជានាតិ កាមសញ្ញំ ឧប្បន្នបុព្វំ ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេម ។ អសីតិ មេ អាវុសោ វស្សានិ បព្វជិតស្ស នាភិជានាមិ ព្យាបាទសញ្ញំ... វិហឹសាសញ្ញំ ឧប្បន្នបុព្វំ ។ យម្បាយស្មា ពក្កុលោ អសីតិយា វស្សេហិ នាភិជានាតិ វិហឹសាសញ្ញំ ឧប្បន្នបុព្វំ ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេម ។

១ ម. ឧ. ឥតិសទ្ទោ នត្ថិ ។



(៦៩) ម្នាលអាវុសោកស្សប អ្នកកុំសួរអាត្មាថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនប៉ុន្មានដង យ៉ាងនេះឡើយ ម្នាលអាវុសោកស្សប អ្នកត្រូវសួរអាត្មាថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ កាមសញ្ញារបស់លោកធ្លាប់កើតប៉ុន្មានដង យ៉ាងនេះវិញ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានកាមសញ្ញាកើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានកាមសញ្ញាកើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងទាំងឡាយចាំទុក នូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានព្យាបាទសញ្ញា... មិនដែលមានវិហឹសាសញ្ញា កើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានវិហឹសាសញ្ញា កើតឡើង អស់ ៨០ វស្សាហើយ ដោយហេតុណា យើងទាំងឡាយចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

(៨០) អសីតិ មេ អាវុសោ វស្សានិ បព្វជិតស្ស នាភិជានាមិ កាមវិតក្កំ ឧប្បន្នបុព្វំ ។ យម្បាយស្មា ពក្កុលោ អសីតិយា វស្សេហិ នាភិជានាតិ កាមវិតក្កំ ឧប្បន្នបុព្វំ ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេម ។ អសីតិ មេ អាវុសោ វស្សានិ បព្វជិតស្ស នាភិជានាមិ ព្យាបាទវិតក្កំ... វិហឹសាវិតក្កំ ឧប្បន្នបុព្វំ ។ យម្បាយស្មា ពក្កុលោ អសីតិយា វស្សេហិ នាភិជានាតិ វិហឹសាវិតក្កំ ឧប្បន្នបុព្វំ ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេម ។

(៨១) អសីតិ មេ អាវុសោ វស្សានិ បព្វជិតស្ស នាភិជានាមិ គហបតិចីវរំ សាទិតា ។ យម្បាយស្មា ពក្កុលោ អសីតិយា វស្សេហិ នាភិជានាតិ គហបតិចីវរំ សាទិតា ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេម ។ អសីតិ មេ អាវុសោ វស្សានិ បព្វជិតស្ស



(៨០) ម្នាលអាវុសោ កាលខ្ញុំបួស ៨០ វស្សាហើយ ខ្ញុំមិនដែលមានកាមវិតក្កៈ កើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានកាមវិតក្កៈកើតឡើង អស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ កាលខ្ញុំបួស ៨០ វស្សាហើយ ខ្ញុំមិនដែលមានព្យាបាទវិតក្កៈ... មិនដែលមានវិហឹសាវិតក្កៈ កើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានវិហឹសាវិតក្កៈ កើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភុតធម៌របស់ព្រះពក្កុលៈមានអាយុ ។

(៨១) ម្នាលអាវុសោ កាលខ្ញុំបួស ៨០ វស្សាហើយ ខ្ញុំមិនធ្លាប់ត្រេកអរ នឹងគហបតិចីវរទេ ។ ព្រះពក្កុលៈមានអាយុ មិនធ្លាប់ត្រេកអរនឹងគហបតិចីវរ អស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំ ចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ កាលខ្ញុំបួស ៨០ វស្សាហើយ

នាភិជានាមិ សត្ថេន ចីវរំ ឆិន្ទិតា... នាភិជានាមិ សូចិយា ចីវរំ សិព្វិតា... នាភិជានាមិ រជនេន ចីវរំ រជិតា... នាភិជានាមិ កឋិនេ ចីវរំ សិព្វិតា... នាភិជានាមិ សព្រហ្មចារីនំ ចីវរកម្មេ វិចារិតា... នាភិជានាមិ និមន្តនំ សាទិតា... នាភិជានាមិ ឯវរូបំ ចិត្តំ ឧប្បន្នបុព្វំ អហោ វត មំ កោចិ និមន្តេយ្យាតិ ។ បេ ។ នាភិជានាមិ អន្តរឃរេ និសីទិតា... នាភិជានាមិ អន្តរឃរេ ភុញ្ជិតា... នាភិជានាមិ មាតុគ្គាមស្ស អនុព្យញ្ជនសោ និមិត្តំ គហេតា... នាភិជានាមិ មាតុគ្គាមស្ស ធម្មំ ទេសិតា អន្តមសោ ចតុប្បទម្បិ គាថំ... នាភិជានាមិ ភិក្ខុនុបស្សយំ ឧបសង្កមិតា... នាភិជានាមិ ភិក្ខុនិយា ធម្មំ ទេសិតា... នាភិជានាមិ សិក្ខមានាយ ធម្មំ ទេសិតា... នាភិជានាមិ សាមណេរិយា ធម្មំ ទេសិតា... នាភិជានាមិ បព្វាជេតា... នាភិជានាមិ ឧបសម្បាទេតា... នាភិជានាមិ និស្សយំ ទេតា... នាភិជានាមិ



អាត្មាមិនធ្លាប់កាត់ចីវរ ដោយកាំបិតទេ... អាត្មាមិនធ្លាប់ដេរចីវរដោយម្ជុលទេ... មិនធ្លាប់ជ្រលក់ចីវរ ដោយគ្រឿងជ្រលក់ទេ... មិនធ្លាប់ដេរចីវរលើឈើស៊ុំទេ... មិនធ្លាប់ចាត់ចែងចីវរកម្ម របស់សព្រហ្មចារីបុគ្គលទាំងឡាយទេ... មិនធ្លាប់ត្រេកអរនឹងការនិមន្តទេ... មិនធ្លាប់មានគំនិតកើតឡើងថា ធ្វើម្ដេចហ្ន៎ បុគ្គលណាមួយ គប្បីមកនិមន្តអាត្មាទេ ។ បេ ។ អាត្មាមិនដែលអង្គុយក្នុងចន្លោះផ្ទះទេ... មិនដែលឆាន់ក្នុងចន្លោះផ្ទះទេ... មិនដែលកាន់យកនិមិត្ត របស់មាតុគ្រាមដោយអនុព្យញ្ជនៈទេ... មិនដែលសំដែងធម៌ដល់មាតុគ្រាម ដោយហោចទៅសូម្បីត្រឹមតែគាថា ៤ បទទេ... មិនដែលចូលទៅកាន់សំណាក់ភិក្ខុនីទេ... មិនដែលសំដែងធម៌ដល់ភិក្ខុនីទេ... មិនដែលសំដែងធម៌ ដល់សិក្ខមានាទេ... មិនដែលសំដែងធម៌ ដល់សាមណេរីទេ... មិនដែលបំបួសទេ... មិនដែលឲ្យឧបសម្បទាទេ... មិនដែលឲ្យនិស្ស័យទេ...

សាមណេរំ ឧបដ្ឋាបេតា... នាភិជានាមិ នហានឃរេ នហាយិតា... នាភិជានាមិ ចុណ្ណេន នហាយិតា... នាភិជានាមិ សព្រហ្មចារិគត្តបរិកម្មំ សាទិតា... នាភិជានាមិ អាពាធំ ឧប្បន្នបុព្វំ អន្តមសោ គទ្ទុហនមត្តម្បិ... នាភិជានាមិ ភេសជ្ជំ ឧបហរិតា អន្តមសោ ហរីតកីខណ្ឌម្បិ... នាភិជានាមិ អបស្សេនកំ អបស្សយិតា... នាភិជានាមិ សេយ្យំ កប្បេតា ។ យម្បាយស្មា ពក្កុលោ អសីតិយា វស្សេហិ នាភិជានាមិ សេយ្យំ កប្បេតា ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេម ។

(៨៦) អសីតិ មេ អាវុសោ វស្សានិ បព្វជិតស្ស នាភិជាមិ គាមន្តសេនាសនេ វស្សំ ឧបគន្តា ។ យម្បាយស្មា ពក្កុលោ អសីតិយា វស្សេហិ នាភិជានាមិ គាមន្តសេនាសនេ វស្សំ ឧបគន្តា ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេម ។ សត្តាហមេវ ខោ អហំ អាវុសោ សារណោ[1] រដ្ឋបិណ្ឌំ ភុញ្ជិំ អថ អដ្ឋមិយំ

១ ម. សាណោ ។ អដ្ឋកថាយំ សរណោតិ ឆាតោ ទិស្សតិ ។



មិនដែលឲ្យសាមណេរបម្រើទេ... មិនដែលស្រប់កាយ ក្នុងផ្ទះសម្រាប់កម្តៅកាយទេ... មិនដែលស្រប់កាយ ដោយគ្រឿងលំអិតទេ... មិនដែលត្រេកអរនឹងការគក់ច្របាច់ខ្លួន របស់សព្រហ្មចារីបុគ្គលទេ.. មិនដែលមានអាពាធកើតឡើង ដោយហោចទៅ សូម្បីតែដំណួចតិសទេ... មិនដែលថែរក្សាថ្នាំទុក ដោយហោចទៅ សូម្បីតែចំណិតផ្លែស្រម៉ទេ... មិនដែលផ្អែកបង្អែកទេ... មិនដែលដេកទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលដេក អស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

(៨៦) ម្នាលអាវុសោ ខ្ញុំបួស ៨០ វស្សាហើយ ខ្ញុំមិនដែលចូលវស្សា ក្នុងទីសេនាសនៈ ក្នុងស្រុកទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលចូលវស្សា ក្នុងទីសេនាសនៈ ក្នុងស្រុក អស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ ខ្ញុំប្រកបដោយកិលេស នាំបិណ្ឌបាតរបស់អ្នកដែនតែ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨

អញ្ញា ឧទបាទិ ។ យម្បាវុសោ ពក្កុលោ សត្តាហមេវ សរណោ រដ្ឋបិណ្ឌំ ភុញ្ជិ អថ អដ្ឋមិយំ អញ្ញា ឧទបាទិ ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេម ។

(៩៣) លភេយ្យាហំ អាវុសោ ពក្កុល ឥមស្មឹ ធម្មវិនយេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អលត្ថ ខោ អចេលោ កស្សបោ ឥមស្មឹ ធម្មវិនយេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ បនាយស្មា កស្សបោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ខោ បនាយស្មា កស្សបោ អរហតំ អហោសិ ។



អរហត្តផលក៏កើតឡើង ។ ព្រះពក្កុលៈមានអាយុ ប្រកបដោយកិលេស ឆាន់បិណ្ឌបាតរបស់អ្នកដែនតែ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ អរហត្តផលក៏កើតឡើង ដោយហេតុណា យើងខ្ញុំទាំងឡាយទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភុតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

(៩៣) បពិត្រព្រះពក្កុលៈមានអាយុ ខ្ញុំគប្បីបាននូវបព្វជ្ជា គប្បីបាននូវឧបសម្បទា ក្នុងធម្មវិន័យនេះ ។ អចេលកស្សប ក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងធម្មវិន័យនេះ ។ លុះព្រះកស្សបមានអាយុ បានឧបសម្បទា មិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្រទាំងឡាយចេញចាកផ្ទះ ទៅបួសក្នុងផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តម ចំពោះខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចនូវនៅដោយឥរិយាបថទាំង ៤ រមែងដឹងថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញ បានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះកស្សបមានអាយុ ក៏ជាព្រះអរហន្តមួយរូបដែរ ។

(៧៦) អថខោ អាយស្មា ពក្កុលោ អបរេន សមយេន អបាបុរណំ អាទាយ វិហារេន វិហារំ ឧបសង្កមិត្វា ឯវមាហ អភិក្កមថាយស្មន្តោ អភិក្កមថាយស្មន្តោ អជ្ជ មេ បរិនិព្វានំ ភវិស្សតីតិ ។ យម្បាយស្មា ពក្កុលោ អបាបុរណំ អាទាយ វិហារេន វិហារំ ឧបសង្កមិត្វា ឯវមាហ អភិក្កមថាយស្មន្តោ អភិក្កមថាយស្មន្តោ អជ្ជ មេ បរិនិព្វានំ ភវិស្សតីតិ ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេម ។

(៧៧) អថខោ អាយស្មា ពក្កុលោ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នកោវ បរិនិព្វាយិ ។ យម្បាយស្មា ពក្កុលោ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នកោវ បរិនិព្វាយិ ឥទម្បិ មយំ អាយស្មតោ ពក្កុលស្ស អច្ឆរិយំ អព្ភុតធម្មំ ធារេមាតិ ។

ពក្កុលត្ថេរច្ឆរិយព្ភុតសុត្តំ ចតុត្ថំ និដ្ឋិតំ ។



(៧៦) លុះសម័យជាខាងក្រោយមក ព្រះពក្កុលៈ មានអាយុ កាន់យកកូនសោ ចេញអំពីវិហារ ចូលទៅកាន់វិហារ ហើយពោលពាក្យយ៉ាងនេះថា សូមលោកមានអាយុទាំងឡាយ ដើរចេញទៅសិន សូមលោកមានអាយុទាំងឡាយ ដើរចេញទៅសិន ខ្ញុំនឹងបរិនិព្វាន ក្នុងថ្ងៃនេះ ។ ព្រះតេស្សរបរិពាលថា ព្រះពក្កុលៈមានអាយុ បានកាន់យកកូនសោ ចេញអំពីវិហារ ចូលទៅកាន់វិហារ ហើយពោលយ៉ាងនេះថា សូមលោកមានអាយុទាំងឡាយ ដើរចេញទៅសិន សូមលោកមានអាយុទាំងឡាយ ដើរចេញទៅសិន ខ្ញុំនឹងបរិនិព្វាន ក្នុងថ្ងៃនេះ ដោយហេតុណា ខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

(៧៧) ឯព្រះពក្កុលៈមានអាយុ អង្គុយបរិនិព្វាន ក្នុងទីកណ្ដាលភិក្ខុសង្ឃ ។ ព្រះពក្កុលៈមានអាយុ អង្គុយបរិនិព្វាន ក្នុងទីកណ្ដាលភិក្ខុសង្ឃ ដោយហេតុណា ខ្ញុំក៏ចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

ចប់ ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ ទី ៤ ។

# បញ្ចមំ ទន្តភូមិសុត្តំ

(៤៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អចិរវតោ សមណុទ្ទេសោ អរញ្ញកុដិកាយំ វិហរតិ ។ អថខោ ជយសេនោ រាជកុមារោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេន អចិរវតោ សមណុទ្ទេសោ តេនុបសង្កមិ ឧបសង្កមិត្វា អចិរវតេន សមណុទ្ទេសេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

(៤៧) ឯកមន្តំ និសិន្នោ ខោ ជយសេនោ រាជកុមារោ អចិរវតំ សមណុទ្ទេសំ ឯតទវោច សុតំ មេតំ ភោ អគ្គិវេស្សន ឥធ ភិក្ខុ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ផុសេយ្យ ចិត្តស្ស ឯកគ្គតន្តិ ។

# ទន្តភូមិសូត្រ ទី ៥

(៤៦) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះ សមណុទ្ទេស ឈ្មោះអចិរវតៈ នៅក្នុងកុដិជាវព្រៃ ។ គ្រានោះឯង ជ័យសេនរាជកុមារ[១] ស្តេចយាងដើរត្រាច់ៗ ដើម្បីសម្រួលព្រះជង្ឃា បានចូលទៅរកអចិរវតសមណុទ្ទេស លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលទៅនឹងអចិរវតសមណុទ្ទេស លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏គង់ក្នុងទីសមគួរ ។

(៤៧) លុះជ័យសេនរាជកុមារ គង់ក្នុងទីសមគួរហើយ បានពោលនឹងអចិរវតសមណុទ្ទេស ដូច្នេះថា បពិត្រអគ្គិវេស្សនៈដ៏ចម្រើន ខ្ញុំបានឮមកថា ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន គប្បីបាននូវចិត្តជាឯកគ្គតា (ចិត្តដែលមានអារម្មណ៍តែមួយ) មែនឬ ។

១ ជាព្រះរាជបុត្ររបស់ព្រះបាទពិម្ពិសារ ។ អដ្ឋកថា ។

ឯវមេតំ រាជកុមារ ឯវមេតំ រាជកុមារ ឥធ ភិក្ខុ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ផុសេយ្យ ចិត្តស្ស ឯកគ្គតន្តិ ។ ភាសតុ មេ ភវំ អគ្គិវេស្សនោ យថាសុតំ យថាបរិយត្តំ ធម្មំ ទេសេតូតិ ។

(៤៨) ន ខោ ត្យាហំ រាជកុមារ សក្កោមិ យថាសុតំ យថាបរិយត្តំ ធម្មំ ទេសេតុំ អហញ្ចហិ តេ រាជកុមារ យថាសុតំ យថាបរិយត្តំ ធម្មំ ទេសេយ្យំ តុញ្ច មេ ភាសិតស្ស អត្ថំ ន អាជានេយ្យាសិ សោ មមស្ស កិលមថោ សា មមស្ស វិហេសាតិ ។ ទេសេតុ មេ ភវំ អគ្គិវេស្សនោ យថាសុតំ យថាបរិយត្តំ ធម្មំ អប្បេវនាមហំ ភោតោ អគ្គិវេស្សនស្ស ភាសិតស្ស អត្ថំ អាជានេយ្យន្តិ ។



អចិរវតសមណុទ្ទេសតបថា ថ្វាយព្រះពរព្រះរាជកុមារ ការណ៍នុ៎ះយ៉ាងហ្នឹងហើយ ថ្វាយព្រះពរព្រះរាជកុមារ ការណ៍នុ៎ះ យ៉ាងហ្នឹងហើយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រហែសធ្វេស មានព្យាយាមដុតកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន គប្បីបាននូវចិត្តជាឯកគ្គតាផង ។ ជយសេនរាជកុមារតបថា ខ្ញុំសូមអង្វរ សូមអគ្គិវេស្សនៈដ៏ចម្រើន សំដែងធម៌តាមទំនងដែលលោកបានស្ដាប់ បានរៀនមក ប្រាប់ខ្ញុំផង ។

(៤៨) អចិរវតសមណុទ្ទេសពោលថា ថ្វាយព្រះពរព្រះរាជកុមារ អាត្មាភាព មិនអាចនឹងសំដែងធម៌ តាមទំនង ដែលបានស្ដាប់ បានរៀនមក ថ្វាយទ្រង់បានទេ ពោះបើអាត្មាភាព សំដែងធម៌ តាមទំនង ដែលបានស្ដាប់ បានរៀនមកថ្វាយទ្រង់ ក៏ទ្រង់យល់នូវសេចក្ដីនៃភាសិត របស់អាត្មាភាពពុំបាន អាត្មាភាព មុខជានឹងមានសេចក្ដីលំបាកនោះ អាត្មាភាព មុខជានឹងមានសេចក្ដីទៀយហត់នោះ (ឥតអំពើ) ។ សូមអគ្គិវេស្សនៈដ៏ចម្រើន សំដែងធម៌ តាមទំនង ដែលបានស្ដាប់ បានរៀនមក ប្រាប់ខ្ញុំ ហើយធ្វើដូចម្ដេច ឲ្យខាងខ្ញុំបានយល់សេចក្ដីនៃភាសិត របស់អគ្គិវេស្សនៈដ៏ចម្រើនផង ។

ទេសេយ្យំ ខោ តេ អហំ រាជកុមារ យថាសុតំ យថាបរិយត្តំ ធម្មំ សចេ មេ ត្វំ ភាសិតស្ស អត្ថំ អាជានេយ្យាសិ ឥច្ចេតំ កុសលំ នោ ចេ មេ ត្វំ ភាសិតស្ស អត្ថំ អាជានេយ្យាសិ យថាសកេ តិដ្ឋេយ្យាសិ ន មំ តត្ថ ឧត្តរឹ បដិបុច្ឆេយ្យាសីតិ ។ ទេសេតុ មេ ភវំ អគ្គិវេស្សនោ យថាសុតំ យថា-បរិយត្តំ ធម្មំ សចេ អហំ ភោតោ អគ្គិវេស្សនស្ស ភាសិតស្ស អត្ថំ អាជានេយ្យាមិ[១] ឥច្ចេតំ កុសលំ នោ ចេ អហំ ភោតោ អគ្គិវេស្សនស្ស ភាសិតស្ស អត្ថំ អាជានិស្សាមិ យថាសកេ តិដ្ឋិស្សាមិ នាហំ តត្ថ ភវន្តំ អគ្គិវេស្សនំ ឧត្តរឹ បដិបុច្ឆិស្សាមីតិ ។

(៨៤) អថខោ អចិរវតោ សមណុទ្ទេសោ ជយ-សេនស្ស រាជកុមារស្ស យថាសុតំ យថាបរិយត្តំ ធម្មំ ទេសេសិ ។ ឯវំ វុត្តេ ជយសេនោ រាជកុមារោ

១. ម. អាជានិស្សាមិ ។



បពិត្រព្រះរាជកុមារ អាត្មាភាព សូមសំដែងធម៌តាមចំណេះ ដែលបានស្តាប់ បានរៀនមក ថ្វាយទ្រង់ ប្រសិនបើទ្រង់យល់សេចក្តីនៃភាសិតរបស់អាត្មាភាព ការយល់នុ៎ះ ជាការប្រពៃ តែបើទ្រង់មិនយល់សេចក្តីនៃភាសិតរបស់អាត្មាភាពទេ សូមទ្រង់ឋិតនៅ ក្នុងការមិនយល់របស់ទ្រង់ដដែលចុះ ទ្រង់មិនគប្បីត្រឡប់សួរអាត្មាភាព ក្នុងសេចក្តីនោះតទៅទៀតឡើយ ។ សូមអគ្គិវេស្សនៈដ៏ចំរើន សំដែងធម៌តាមចំណេះ ដែលលោកបានស្តាប់ បានរៀនមក ប្រាប់ខ្ញុំចុះ បើខ្ញុំយល់សេចក្តីនៃភាសិតរបស់អគ្គិវេស្សនៈដ៏ចំរើន ការដែលយល់នុ៎ះ ជាការប្រពៃ តែបើខ្ញុំមិនយល់សេចក្តីនៃភាសិត របស់អគ្គិវេស្សនៈដ៏ចំរើនទេ ខ្ញុំនឹងឋិតនៅក្នុងការមិនយល់របស់ខ្លួនដដែល ខ្ញុំមិនត្រឡប់សួរអគ្គិវេស្សនៈដ៏ចំរើន ក្នុងសេចក្តីនោះ តទៅទៀតទេ ។

(៨៤) លំដាប់នោះ អចិរវតសមណុទ្ទេស ក៏សំដែងធម៌តាមចំណេះដែលបានស្តាប់ បានរៀនមក ថ្វាយជយសេនរាជកុមារ ។ កាលបើអចិរវតសមណុទ្ទេស សំដែងដូច្នោះហើយ ជយសេនរាជកុមារ

អចិរវតំ សមណុទ្ទេសំ ឯតទវោច អដ្ឋានមេតំ ភោ អគ្គិវេស្សន អនវកាសោ យំ ភិក្ខុ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ផុសេយ្យ ចិត្តស្ស ឯកគ្គតន្តិ ។ អថ ខោ ជយសេនោ រាជកុមារោ អចិរវតស្ស សមណុទ្ទេសស្ស អដ្ឋានញ្ច[១] បវេទេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថ ខោ អចិរវតោ សមណុទ្ទេសោ អចិរបក្កន្តេ ជយសេនេ រាជកុមារេ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អចិរវតោ[២] សមណុទ្ទេសោ យាវតកោ អហោសិ ជយសេនេន រាជកុមារេន សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។

(៦០) ឯវំ វុត្តេ ភគវា អចិរវតំ សមណុទ្ទេសំ ឯតទវោច តំ កុតេត្ថ អគ្គិវេស្សន លព្ភា យំ តំ នេក្ខម្មេន ញាតព្វំ នេក្ខម្មេន ទដ្ឋព្វំ នេក្ខម្មេន បត្តព្វំ នេក្ខម្មេន សច្ឆិកាតព្វំ

១ ឱ. អដ្ឋានញ្ច ។ ២ កត្ថចិ អម្ពកំ ពោត្ថកេ អគ្គិវេស្សនោតិ ទិស្សតិ ។



ក៏ពោលនឹងអចិរវតសមណុទ្ទេស ដូច្នេះថា បពិត្រអគ្គិវេស្សនៈដ៏ចំរើន ត្រង់ដែលថា ភិក្ខុជាអ្នកមិនប្រហែសធ្វេស មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកេព្រះនិព្វាន គប្បីប៉ះពាល់ចិត្ត ជាឯកគ្គតា ត្រង់នុះមិនទំនង មិនមែនជាឱកាសទេ ។ លុះជយសេនរាជកុមារ ប្រកាសនូវហេតុ ដែលមិនមែនជាទំនង មិនមែនជាឱកាស របស់អចិរវតសមណុទ្ទេស ហើយ ក៏ក្រោកអំពីអាសនៈស្តេចចេញទៅ ។ កាលដែលជយសេនរាជកុមារ ស្តេចចេញទៅមិនយូរប៉ុន្មាន អចិរវតសមណុទ្ទេស ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរ ។ លុះអចិរវតសមណុទ្ទេសអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលពាក្យចរចា ដែលខ្លួននិយាយនឹងជយសេនរាជកុមារនោះ ចំពោះព្រះមានព្រះភាគ ដោយសព្វគ្រប់ ។

(៦០) កាលអចិរវតសមណុទ្ទេស ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងអចិរវតសមណុទ្ទេសដូច្នេះថា ម្នាលអគ្គិវេស្សនៈ គុណជាតណាដែលបុគ្គលគប្បីដឹងដោយនេក្ខម្មៈ គប្បីឃើញដោយនេក្ខម្មៈ គប្បីដល់ដោយនេក្ខម្មៈ គប្បីធ្វើឲ្យជាក់ច្បាស់ដោយនេក្ខម្មៈ តើជយសេនរាជកុមារ នឹងបាននូវគុណជាតនោះអំពីទីណា ក្នុងអត្តភាពនេះ

តំ វត ជយសេនោ រាជកុមារោ កាមមជ្ឈេ វសន្តោ កាមេ បរិភុញ្ជន្តោ កាមវិតក្កេហិ ខជ្ជមានោ កាមបរិឡាហេន បរិឌយ្ហមានោ កាមបរិយេសនាយ ឧស្សុក្កោ ញស្សតិ វា ទក្ខតិ វា សច្ឆិ វា ករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

(៦១) សេយ្យថាបិស្សុ អគ្គិវេស្សន ទ្វេ ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា សុទន្តា សុវិនីតា ។ ទ្វេ ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា អទន្តា[១] អវិនីតា ។ តំ កឹ មញ្ញសិ អគ្គិវេស្សន យេ តេ ទ្វេ ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា សុទន្តា សុវិនីតា អបិ នុ តេ ទន្តា ទន្តការណំ គច្ឆេយ្យុំ ទន្តា វា ទន្តភូមឹ សម្បាបុណេយ្យុន្តិ ។

១ ម. សៅត្តនត្ថិ ។



ព្រោះជ័យសេនរាជកុមារ កំពុងនៅក្នុងកណ្តាលកាម កំពុងបរិភោគកាម កំពុងទំពាស៊ីកាមវិតក្កៈ កំពុងក្តៅក្រហាយដោយសេចក្តីក្រហល់ក្រហាយព្រោះកាម ជាអ្នកខ្វល់ខ្វាយដើម្បីស្វែងរកកាម នឹងដឹង នឹងឃើញ នឹងធ្វើឲ្យជាក់ច្បាស់នូវគុណជាតនោះ ដូចម្តេចកើត ពាក្យដូច្នេះ មិនសមហេតុទេ ។

(៦១) ម្នាលអគ្គិវេស្សនៈ ដូចសត្វពាហនៈ ២ ពួក គឺដំរីគួរទូន្មាន សេះគួរទូន្មាន ឬគោគួរទូន្មាន ដែលគេកំពុងទូន្មានជាការល្អ ១ ដែលគេទូន្មានបានល្អហើយ ១ ។ សត្វពាហនៈ ២ ពួក គឺដំរីគួរទូន្មាន សេះគួរទូន្មាន ឬគោគួរទូន្មាន ដែលគេមិនទាន់ទូន្មាននៅឡើយ ១ ដែលគេទូន្មានមិនទាន់បាន ១ ។ ម្នាលអគ្គិវេស្សនៈ អ្នកយល់សេចក្តីនោះដូចម្តេច សត្វពាហនៈ ២ ពួកណា គឺដំរីគួរទូន្មាន សេះគួរទូន្មាន ឬគោគួរទូន្មាន ដែលគេកំពុងទូន្មានជាការល្អ ១ ទូន្មានបានល្អហើយ ១ ពួកសត្វដែលគេកំពុងទូន្មាននោះ គង់នឹងដល់នូវការទូន្មានដែរឬ កាលបើទូន្មានហើយ គង់នឹងដល់ថ្នាក់ ដែលគេគួរទូន្មានដែរឬទេ ។

វំ ភន្តេ ។ យេ បនេតេ ទ្វេ ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា អទន្តា អវិនីតា អបិ នុ តេ អទន្តា វ ទន្តការណំ គច្ឆេយ្យុំ អទន្តា វ ទន្តភូមឹ សម្បាបុណេយ្យុំ សេយ្យថាបិ តេ ទ្វេ ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា សុទន្តា សុវិនីតាតិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ អគ្គិវេស្សន យំ តំ នេក្ខម្មេន ញាតព្វំ នេក្ខម្មេន ទដ្ឋព្វំ នេក្ខម្មេន បត្តព្វំ នេក្ខម្មេន សច្ឆិកាតព្វំ តំ វត ជយសេនោ រាជកុមារោ កាម-មជ្ឈេ វសន្តោ កាមេ បរិភុញ្ជន្តោ កាមវិតក្កេហិ ខជ្ជមានោ កាមបរិឡាហេន បរិឌយ្ហមានោ កាម-បរិយេសនាយ ឧស្សុក្កោ ញស្សតិ វា ទក្ខតិ វា សច្ឆិ វា ករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។



សូមទ្រង់ព្រះមេត្តាប្រោស យ៉ាងហ្នឹងហើយ ។ សត្វពាហនៈ ២ ពួកណា គឺដំរីសម្រាប់ទូន្មាន សេះសម្រាប់ទូន្មាន ឬគោសម្រាប់ទូន្មាន ដែលគេមិនទាន់បានទូន្មានទៅឡើយ ១ ទូន្មានមិនទាន់បាន១ ឬសត្វពាហនៈដែលគេមិនទាន់បានទូន្មានទៅឡើយនោះ តើនឹងដល់នូវការទូន្មានដែរឬ កាលបើមិនបានទូន្មានហើយ តើនឹងដល់ថ្នាក់ ដែលគេទូន្មាន ដូចសត្វពាហនៈ ២ ពួក គឺ ដំរីសម្រាប់ទូន្មាន សេះសម្រាប់ទូន្មាន ឬគោសម្រាប់ទូន្មាន ដែលគេកំពុងទូន្មានជិតបានល្អ នឹងដែលគេទូន្មានបានល្អហើយនោះ ដែរឬទេ ។ សូមទ្រង់ព្រះមេត្តាប្រោស មិនដូច្នោះទេ ។ ម្នាលអគ្គិវេស្សនៈ សេចក្តីនេះមានឧបមេយ្យដូចជា ជយសេនរាជកុមារ ដែលកំពុងនៅក្នុងកណ្តាលកាម កំពុងបរិភោគកាម កំពុងទំពាស៊ីកាមវិតក្កៈ កំពុងរោលរាលដោយសេចក្តីក្រហល់ក្រហាយព្រោះកាម ជាអ្នកខ្វល់ខ្វាយដើម្បីស្វែងរកកាម នឹងដឹងនឹងឃើញ នឹងធ្វើឲ្យជាក់ច្បាស់នូវគុណជាត ដែលបុគ្គលគប្បីដឹងដោយនេក្ខម្មៈ គប្បីឃើញដោយនេក្ខម្មៈ គប្បីដល់ដោយនេក្ខម្មៈ គប្បីធ្វើឲ្យជាក់ច្បាស់ដោយនេក្ខម្មៈ ដូច្នេះបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

(៦២) សេយ្យថាបិ អគ្គិវេស្សន គាមស្ស វា និគមស្ស វា អវិទូរេ មហាបព្ពតោ ។ តមេនំ ទ្វេ សហាយកា តម្ហា គាមា វា និគមា វា និក្ខមិត្វា ហត្ថវិលង្ឃកេន យេន សោ បព្ពតោ តេនុបសង្កមេយ្យុំ ឧបសង្កមិត្វា ឯកោ សហាយកោ ហេដ្ឋាបព្ពតបាទេ តិដ្ឋេយ្យ ឯកោ សហាយកោ ឧបរិបព្ពតំ អារោហេយ្យ ។ តមេនំ ហេដ្ឋាបព្ពតបាទេ ឋិតោ សហាយកោ ឧបរិបព្ពតេ ឋិតំ សហាយកំ ឯវំ វទេយ្យ យំ សម្ម កឹ ត្វំ បស្សសិ ឧបរិបព្ពតេ ឋិតោតិ ។ សោ ឯវំ វទេយ្យ បស្សាមិ ខោ អហំ សម្ម ឧបរិបព្ពតេ ឋិតោ អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណីរាមណេយ្យកន្តិ ។ សោ ឯវំ វទេយ្យ អដ្ឋានំ ខោ ឯតំ សម្ម អនវកាសោ យំ ត្វំ ឧបរិបព្ពតេ ឋិតោ បស្សេយ្យាសិ អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណីរាមណេយ្យកន្តិ ។ តមេនំ ឧបរិបព្ពតេ សហាយោ ឋិតោ ហេដ្ឋិមបព្ពតបាទំ[១] ឱរោហិត្វា

១ ម. ឋិតោ សហាយកោ ហេដ្ឋាបព្ពតបាទន្តិ ទិស្សតិ ។



(៦២) ម្នាលអគ្គិវេស្សនៈ ដូចភ្នំធំដែលនៅជិតស្រុកឬនិគម ។ មានបុរស ២ នាក់ ជាសំឡាញ់នឹងគ្នា ចេញអំពីស្រុកឬនិគមនោះ ដឹកដៃគ្នា ចូលទៅរកភ្នំនោះ លុះចូលទៅដល់ហើយ បុរសជាសំឡាញ់ម្នាក់ ឈរនៅទៀបជើងភ្នំខាងក្រោម បុរសជាសំឡាញ់ម្នាក់ ឡើងទៅខាងលើភ្នំ ។ បុរសជាសំឡាញ់ ដែលឈរក្បែរជើងភ្នំខាងក្រោម សួរសំឡាញ់ ដែលឈរលើភ្នំនោះ យ៉ាងនេះថា នែសំឡាញ់ ដែលសំឡាញ់ឯង ឈរលើកំពូលភ្នំ តើបានឃើញអ្វីដែរ ។ បុរសដែលឈរខាងលើភ្នំនោះ ប្រាប់យ៉ាងនេះថា ម្នាលសំឡាញ់ ដែលខ្ញុំឈរលើកំពូលភ្នំ បានឃើញសួនច្បារជាទីត្រេកអរ ព្រៃជាទីត្រេកអរ ភូមិជាទីត្រេកអរ ស្រះបោក្ខរណីជាទីត្រេកអរ ។ បុរសជាសំឡាញ់ ដែលឈរទៀបជើងភ្នំនោះ និយាយយ៉ាងនេះថា ម្នាលសំឡាញ់ ដែលសំឡាញ់ឯងឈរលើកំពូលភ្នំ ហើយឃើញសួនច្បារជាទីត្រេកអរ ព្រៃជាទីត្រេកអរ ភូមិជាទីត្រេកអរ ស្រះបោក្ខរណីជាទីត្រេកអរ នុ៎ះមិនមែនសមហេតុ មិនមែនជាឱកាសទេ ។ បុរសជាសំឡាញ់ ដែលឈរលើភ្នំ ក៏ចុះមកនាជើងភ្នំខាងក្រោមនោះហើយ

តំ សហាយកំ ពាហាយ គហេត្វា ឧបរិបព្វតំ អារោបេត្វា មុហុត្តំ អស្សាសេត្វា ឯវំ វទេយ្យ យំ សម្ម កឹ ត្វំ បស្សសិ ឧបរិបព្វតេ ឋិតោតិ ។ សោ ឯវំ វទេយ្យ បស្សាមិ ខោ អហំ សម្ម ឧបរិបព្វតេ ឋិតោ អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណីរាមណេយ្យកន្តិ ។ សោ ឯវំ វទេយ្យ ឥទានេវ ខោ តេ សម្ម ភាសិតំ មយំ ឯវំ អាជានាម អដ្ឋានំ ខោ ឯតំ សម្ម អនវកាសោ យំ ត្វំ ឧបរិបព្វតេ ឋិតោ បស្សេយ្យាសិ អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណីរាមណេយ្យកន្តិ ។ ឥទានេវ ច បន តេ ភាសិតំ មយំ ឯវំ អាជានាម បស្សាមិ ខោ អហំ សម្ម ឧបរិបព្វតេ ឋិតោ អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណីរាមណេយ្យកន្តិ ។



ក្បៀកបុរសជាសំឡាញ់នោះ ដោយដើមដៃ នាំឡើងទៅលើភ្នំ លួងលោមមួយស្របក់ ក៏សួរយ៉ាងនេះថា នែសំឡាញ់ ដែលសំឡាញ់ឯងឈរលើភ្នំ បានឃើញអ្វីដែរ ។ បុរសដែលឈរ ទៀបជើងភ្នំនោះ និយាយតប យ៉ាងនេះថា ម្នាលសំឡាញ់ ខ្ញុំឈរលើភ្នំ ឃើញសួនច្បារជាទីត្រេកអរ ព្រៃជាទីត្រេកអរ ភូមិជាទីត្រេកអរ ស្រះបោក្ខរណីជាទីត្រេកអរ ។ បុរសដែលឈរលើភ្នំនោះ ពោលយ៉ាងនេះថា ម្នាលសំឡាញ់ ឥឡូវនេះ យើងដឹងច្បាស់ នូវសំដីរបស់សំឡាញ់ឯងហើយ (ដែលពោល) យ៉ាងនេះថា ម្នាលសំឡាញ់ ដែលសំឡាញ់ឯងឈរលើភ្នំ ហើយឃើញសួនច្បារជាទីត្រេកអរ ព្រៃជាទីត្រេកអរ ភូមិជាទីត្រេកអរ ស្រះបោក្ខរណីជាទីត្រេកអរ នុ៎ះមិនមែនសមហេតុ មិនមែនជាឱកាសទេ ។ មួយទៀត ឥឡូវនេះ យើងដឹងច្បាស់នូវសំដីរបស់សំឡាញ់ឯងហើយ ( ដែលពោល ) យ៉ាងនេះថា ម្នាលសំឡាញ់ ដែលខ្ញុំឈរលើភ្នំ ឃើញសួនច្បារជាទីត្រេកអរ ព្រៃជាទីត្រេកអរ ភូមិជាទីត្រេកអរ ស្រះបោក្ខរណី ជាទីត្រេកអរ ។

សោ ឯវំ វទេយ្យ ឥធ ហិ បនាហំ សម្ម ឥមិនា មហតា បព្វតេន អាវុតោ[១] ទស្សនេយ្យំ នាទ្ទសន្តិ ។ ឯវមេវ ខោ ឥតោ មហន្តតរេន ខោ អគ្គិវេស្សន អវិជ្ជាខន្ធេន ជយសេនោ រាជកុមារោ អាវុតោ និវុតោ ឱផុដោ[២] បរិយោនទ្ធោ ។ សោ វត យន្តំ នេក្ខម្មេន ញាតព្វំ នេក្ខម្មេន ទដ្ឋព្វំ នេក្ខម្មេន បត្តព្វំ នេក្ខម្មេន សច្ឆិកាតព្វំ តំ វត ជយសេនោ រាជកុមារោ កាមមជ្ឈេ វសន្តោ កាមេ បរិភុញ្ជន្តោ កាមវិតក្កេហិ ខជ្ជមានោ កាមបរិឡាហេន បរិឌយ្ហមានោ កាមបរិយេសនាយ ឧស្សុក្កោ ញស្សតិ វា ទក្ខតិ វា សច្ឆិ វា ករិស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ សចេ ខោ តំ អគ្គិវេស្សន ជយសេនស្ស រាជកុមារស្ស ឥមា ទ្វេ ឧបមា បដិភាសេយ្យុំ អនច្ឆរិយន្តេ ជយសេនោ រាជកុមារោ

១ ឱ. អាវដោ ។ ២ ម. ឱផុដោ ។



សំឡាញ់ ដែលឈរទៀបជើងភ្នំនោះ និយាយយ៉ាងនេះថា ម្នាលសំឡាញ់ ពិតដូច្នោះមែនហើយ ខ្ញុំជាបុគ្គលត្រូវភ្នំធំនេះបិទបាំង បានជាមិនឃើញ នូវរបស់ដែលគួរឃើញ ។ ម្នាលអគ្គិវេស្សនៈ រឿងនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចជា ជយសេនរាជកុមារ ត្រូវគំនរអវិជ្ជាដ៏ធំវិសេសក្រៃលែងជាងភ្នំនោះទៅទៀត គ្របសង្កត់ ហ៊ុមក្រង ចាក់ស្រេះ រួបរឹតហើយ ។ ជយសេនរាជកុមារ ដែលកំពុងនៅក្នុងកណ្តាលកាម កំពុងបរិភោគកាម កំពុងទំពាស៊ីកាមវិតក្កៈ កំពុងក្តៅក្រហាយដោយសេចក្តីក្រហល់ក្រហាយព្រោះកាម ជាអ្នកខ្វល់ខ្វាយដើម្បីស្វែងរកកាម តើនឹងដឹង នឹងយល់ នឹងធ្វើឲ្យជាក់ច្បាស់ នូវគុណជាតដែលបុគ្គលគប្បីដឹងដោយនេក្ខម្មៈ គប្បីឃើញដោយនេក្ខម្មៈ គប្បីដល់ដោយនេក្ខម្មៈ គប្បីធ្វើឲ្យជាក់ច្បាស់ដោយនេក្ខម្មៈ ដូចម្តេចបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ម្នាលអគ្គិវេស្សនៈ ប្រសិនបើអ្នកបំភ្លឺសេចក្តីឧបមាទាំង ២ នេះ ដល់ជយសេនរាជកុមារនោះ ក៏ជាការអស្ចារ្យគ្រាន់បើរបស់អ្នកដែរ ជយសេនរាជកុមារ

បសីទេយ្យុំ បសន្នា ច តេ បសន្នាការំ ករេយ្យុន្តិ ។ កុតោ បន មំ ភន្តេ ជយសេនស្ស រាជកុមារស្ស ឥមា ទ្វេ ឧបមា បដិភាសិស្សន្តិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា សេយ្យថាបិ ភគវន្តន្តិ ។

(២៣) សេយ្យថាបិ អគ្គិវេស្សន រាជា ខត្តិយោ មុទ្ធាវសិត្តោ នាគវនិកំ អាមន្តេសិ ឯហិ[១] ត្វំ សម្ម នាគវនិក រញ្ញោ នាគំ អភិរុហិត្វា នាគវនំ បវិសិត្វា អារញ្ញនាគំ[២] អតិបស្សិត្វា រញ្ញោ នាគស្ស គីវាយំ ឧបនិពន្ធាហីតិ ។ ឯវំ ទេវាតិ ខោ អគ្គិវេស្សន នាគវនិកោ រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស បដិស្សុត្វា រញ្ញោ នាគំ អភិរុហិត្វា នាគវនំ បវិសិត្វា អារញ្ញនាគំ អតិបស្សិត្វា រញ្ញោ នាគស្ស គីវាយំ ឧបនិពន្ធតិ ។ តមេនំ រញ្ញោ នាគោ អព្ភោកាសំ នីហរតិ ។ ឯត្តាវតា ខោ[៣] អគ្គិវេស្សន

១ ឱ. ឯហិតិ ទេវស្សុតិ ។ ២ ឱ. ម. អារញ្ញកំ នាគំ ។ ៣ ឱ. ឯតា ។



មុខជាជ្រះថ្លា លុះជ្រះថ្លាហើយ មុខជាធ្វើនូវអាការនៃសេចក្តីជ្រះថ្លាចំពោះអ្នកមិនខាន ។ បពិត្រព្រះអង្គដ៏ចំរើន ឧបមាទាំងពីរជាទីអស្ចារ្យនេះ ខ្ញុំព្រះអង្គមិនធ្លាប់បានស្តាប់ពីមុនមកសោះ នឹងបំភ្លឺដល់ជយសេនរាជកុមារ ឲ្យដូចជាព្រះមានព្រះភាគ ដូចម្តេចបាន ។

(២៣) ម្នាលអគ្គិវេស្សនៈ ដូចក្សត្រិយ៍ជាព្រះរាជា បានមុទ្ធាភិសេកហើយ ត្រាស់នឹងហ្មដំរីថា ម្នាលហ្មដំរីមានចិត្តស្មោះស្ម័គ្រ ចូរអ្នកមកណេះ ចូរអ្នកឡើងជិះដំរីព្រះរាជទ្រព្យ ចូលទៅឯព្រៃដំរី លុះឃើញដំរីព្រៃឬសលាស់ហើយ ចូរចងកដំរីព្រះរាជទ្រព្យឲ្យមាំ ។ ម្នាលអគ្គិវេស្សនៈ ហ្មដំរីក៏ទទួលព្រះរាជឱង្ការនៃក្សត្រិយ៍ ជាព្រះរាជាបានមុទ្ធាភិសេកហើយថា ព្រះករុណាថ្លៃវិសេស ហើយក៏ឡើងជិះដំរីព្រះរាជទ្រព្យ ចូលទៅឯព្រៃដំរី ឃើញដំរីឬសលាស់ហើយ ក៏ចងកដំរីព្រះរាជទ្រព្យ យ៉ាងមាំ ។ ឯដំរីព្រះរាជទ្រព្យ ក៏កៀរដំរីព្រៃនោះទៅកាន់ទីវាល ។ ម្នាលអគ្គិវេស្សនៈ ដោយហេតុប៉ុណ្ណេះឯង

អារញ្ញកោ នាគោ អព្ភោកាសគតោ ហោតិ ។ ឯត្ថ គេធា ហិ អគ្គិវេស្សន អារញ្ញកា នាគា(១) យទិទំ នាគវនំ ។ តមេនំ នាគវនិកោ រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស អារោចេសិ អព្ភោកាសគតោ ខោ តេ(២) ទេវ អារញ្ញកោ នាគោតិ ។ តមេនំ រាជា ខត្តិយោ មុទ្ធាវសិត្តោ ហត្ថិទមកំ អាមន្តេសិ ឯហិ ត្វំ សម្ម ហត្ថិទមក អារញ្ញកំ នាគំ ទមយាហិ អារញ្ញកានញ្ចេវ សីលានំ អភិនិម្មទនាយ អារញ្ញកានញ្ចេវ សរសង្កប្បានំ អភិនិម្មទនាយ អារញ្ញកានញ្ចេវ ទរថកិលមថបរិឡាហានំ អភិនិម្មទនាយ គាមន្តេ អភិរមាបនាយ មនុស្សកន្តេសុ សីលេសុ សមាទបនាយាតិ ។ ឯវំ ទេវាតិ ខោ អគ្គិវេស្សន ហត្ថិទមកោ រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស បដិស្សុត្វា មហន្តំ ថម្ភំ បឋវិយំ និខណិត្វា

១ ម. អារញ្ញកោ នាគោ ។ ២ ម. តេតិ ន ទិស្សតិ ។



ដំរីព្រៃក៏ទៅនៅក្នុងទីវាល ។ ម្នាលអគ្គិវេស្សនៈ ព្រោះបើផុតពីនោះ ដំរីព្រៃគឺទៅតែមានចិត្តជាប់ជំពាក់ ក្នុងព្រៃដំរីដែល ។ ហ្មដំរីក៏ក្រាបបង្គំទូលដំណើរនោះចំពោះក្សត្រិយ៍ ជាព្រះរាជាដែលបានមុទ្ធាភិសេកហើយថា បពិត្រព្រះសម្មតិទេព ដំរីព្រៃចេញទៅនៅក្នុងទីវាលហើយ ។ ក្សត្រិយ៍ជាព្រះរាជាដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់ត្រាស់នឹងហ្មដំរីនោះថា ម្នាលហ្មដំរីមានចិត្តស្មោះស្ម័គ្រ ចូរអ្នកមកអា ។ ចូរអ្នកទូន្មានដំរីព្រៃ ចូរអ្នកទៅញាំញី នូវសណ្ដាប់ធ្នាប់ របស់ពួកដំរីព្រៃផង ញាំញីនូវតម្រិះក្នុងការស្មរទៅ របស់ពួកដំរីព្រៃផង ញាំញីនូវសេចក្ដីក្រវល់ក្រវាយ សេចក្ដីនឿយហត់ សេចក្ដីក្ដៅក្រហាយ របស់ពួកដំរីព្រៃផង ញុំាងដំរីព្រៃឲ្យត្រេកអរ ចំពោះស្រុកផង ធ្វើឲ្យកាន់យកសណ្ដាប់ធ្នាប់ ដែលជាទីត្រេកអររបស់មនុស្សផង ។ ម្នាលអគ្គិវេស្សនៈ ហ្មដំរីក៏ទទួលព្រះបន្ទូលរបស់ក្សត្រិយ៍ ជាព្រះរាជាដែលបានមុទ្ធាភិសេកហើយថា ព្រះករុណាថ្លៃវិសេស ហើយដឹកនាំសសរយ៉ាងធំក្នុងផែនដី

អារញ្ញកស្ស នាគស្ស គីវាយំ ឧបនិពន្ធតិ អារញ្ញកានញ្ចេវ សីលានំ អភិនិម្មទនាយ អារញ្ញកានញ្ចេវ សរសង្កប្បានំ អភិនិម្មទនាយ អារញ្ញកានញ្ចេវ ទរថកិលមថបរិឡាហានំ អភិនិម្មទនាយ គាមន្តេ អភិរមាបនាយ មនុស្សកន្តេសុ សីលេសុ សមាទបនាយ ។ តមេនំ ហត្ថិទមកោ យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបាហិ វាចាហិ សមុទាចរតិ ។ យតោ ខោ អគ្គិវេស្សន អារញ្ញកោ នាគោ ហត្ថិទមកស្ស យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបាហិ វាចាហិ សមុទាចរិយមានោ សុស្សូសតិ សោតំ ឱទហតិ អញ្ញា ចិត្តំ ឧបដ្ឋបេតិ ។ តមេនំ ហត្ថិទមកោ ឧត្តរឹ តិណឃាសោទកំ អនុប្បវេច្ឆតិ(១) ។ យតោ ខោ អគ្គិវេស្សន អារញ្ញកោ នាគោ ហត្ថិទមកស្ស តិណឃាសោទកំ បដិគ្គណ្ហាតិ ។

១ ម. អនុប្បវេច្ចតិ ។



ចងក្រៀកកដំរីព្រៃដើម្បីនឹងញាំញី នូវទម្លាប់របស់ពួកដំរីព្រៃផង ដើម្បីញាំញី នូវតម្រិះក្នុងការស្ទុះទៅរបស់ពួកដំរីព្រៃផង ដើម្បីញាំញីនូវសេចក្តីក្រវល់ក្រវាយ សេចក្តីនឿយហត់ សេចក្តីក្តៅក្រហាយ របស់ពួកដំរីព្រៃផង ដើម្បីញុំាងដំរីព្រៃឲ្យត្រេកអរចំពោះស្រុកផង ដើម្បីឲ្យកាន់យកសណ្តាប់ធ្នាប់ ដែលជាទីត្រេកអររបស់មនុស្សផង ។ ហ្វឹកដំរីរមែងចរចារដោយពាក្យណាដែលឥតទោស នាំឲ្យសុខដល់ត្រចៀក ជាទីស្រឡាញ់ គួរទុកក្នុងហឫទ័យ ជាពាក្យអ្នកបុរី ជាទីត្រេកអរនៃជនច្រើនគ្នា ជាទីគាប់ចិត្តនៃជនច្រើនគ្នាតែប៉ុណ្ណោះ ។ ម្នាលអគ្គិវេស្សនៈ កាលណា ហ្វឹកដំរីពោលពាក្យដែលឥតទោស នាំឲ្យសុខដល់ត្រចៀក ជាទីស្រឡាញ់ គួរទុកក្នុងហឫទ័យ ជាពាក្យអ្នកបុរី ជាទីត្រេកអរនៃជនច្រើនគ្នា ជាទីគាប់ចិត្តនៃជនច្រើនគ្នាដូច្នោះ ដំរីព្រៃក៏ស្តាប់ដោយស្រួល ផ្ទៀងត្រចៀក តាំងចិត្តទុកក្នុងអារម្មណ៍ផង ។ ហ្វឹកដំរីរមែងឲ្យស្មៅដែលដំរីគួរស៊ីបាន និងទឹកឲ្យដំរីនោះតទៅ ។ ម្នាលអគ្គិវេស្សនៈ បើដំរីព្រៃទទួលស្មៅដែលដំរីគួរស៊ីបាន និងទឹក របស់ហ្វឹកដំរីកាលណា ។

ករោ(១) ហត្ថិទមកស្ស យំ ហោតិ ជីវិតស្សតិ ហោនាតិ អារញ្ញកោ(២) នាគោតិ ។ តមេនំ ហត្ថិទមកោ ឧត្តរឹ ការណំ ការេតិ(៣) អាទិយ(៤) កោ និក្ខិប កោតិ ។ យតោ ខោ អគ្គិវេស្សន អារញ្ញ នាគោ ហត្ថិទមកស្ស អាទាននិក្ខេបេ វចនករោ ហោតិ ឱវាទបដិករោតិ(៥) ។ តមេនំ ហត្ថិទមកោ ឧត្តរឹ ការណំ ការេតិ អភិក្កម កោ បដិក្កម កោតិ ។ យតោ ខោ អគ្គិវេស្សន អារញ្ញ នាគោ ហត្ថិទមកស្ស អភិក្កមបដិក្កមេ វចនករោ ហោតិ ឱវាទបដិករោតិ ។ តមេនំ ហត្ថិទម-កោ ឧត្តរឹ ការណំ ការេតិ ឧដ្ឋហ កោ និសីទ(៦) កោតិ ។ យតោ ខោ អគ្គិវេស្សន អារញ្ញ នាគោ ហត្ថិទមកស្ស ឧដ្ឋាននិសជ្ជាយ(៧) វចនករោ ហោតិ ឱវាទបដិករោតិ ។ តមេនំ ហត្ថិទមកោ

១ ម. គត្ត ។ ២ ម. អរញ្ញ ។ ៣ ម. ករោតិ ។ ៤ ម. អាទិយ ។ ៥ ម. ឱវាទបដិករោ ។ ៦ ម. និសីទ ។ ៧ ម. ឧដ្ឋាននិសជ្ជាយ ។



កាលនោះហ្មដំរី ក៏មានសេចក្ដីត្រិះរិះថា ដំរីនេះ ដំរីព្រៃមុខជានឹងរស់នៅបាន ។ ហ្មដំរីក៏បង្ហាត់ដំរីនោះ តទៅទៀតថា នែដំរីលើកជើង ចូរឯងកាន់ នែដំរីលើកជើង ចូរឯងដាក់ ។ ម្នាលអគ្គិវេស្សនៈ បើដំរីព្រៃនោះធ្វើតាមពាក្យ ធ្វើតាមឱវាទរបស់ហ្មដំរី គឺការកាន់ យកនឹងការដាក់ហើយ ។ ហ្មដំរីក៏បង្ហាត់តទៅទៀតថា នែដំរីលើកជើង ចូរឯងឈានទៅមុខ នែដំរីលើកជើង ចូរឯងថយក្រោយ ។ ម្នាលអគ្គិ-វេស្សនៈ កាលណាបើដំរីព្រៃនោះធ្វើតាមពាក្យ ធ្វើតាមឱវាទរបស់ហ្មដំរី គឺការឈានទៅមុខ និងការថយក្រោយហើយ ។ ហ្មដំរីក៏បង្ហាត់ដំរីនោះ តទៅទៀតថា នែដំរីលើកជើង ចូរឯងក្រោកឡើង នែដំរីលើកជើង ចូរឯងក្រាបចុះ ។ ម្នាលអគ្គិវេស្សនៈ កាលណាបើដំរីព្រៃនោះ ធ្វើតាមពាក្យ ធ្វើតាមឱវាទរបស់ហ្មដំរី គឺការក្រោកឡើង និងការក្រាបចុះហើយ ។ ហ្មដំរីក៏បង្ហាត់ដំរីនោះ

ឧត្តរឹ អានេញ្ជំ នាម ការណំ ការេតិ ម-
ហន្តស្ស ផលកំ សោណ្ឌាយ ឧបនិពន្ធតិ តោមរ-
ហត្ថោ ច បុរិសោ ឧបរិគីវាយ និសិន្នោ ហោតិ
សមន្តា ច តោមរហត្ថា បុរិសា បរិវារេត្វា
ឋិតា ហោន្តិ ហត្ថិទមកោ ច ទីឃំ តោមរយដ្ឋឹ
គហេត្វា បុរតោ ឋិតោ ហោតិ ។ សោ អានេញ្ជ-
ការណំ ការិយមានោ នេវ បុរិមេ បាទេ ចោបេតិ
ន បច្ឆិមេ បាទេ ចោបេតិ ន បុរិមំ កាយំ ចោបេតិ
ន បច្ឆិមំ កាយំ ចោបេតិ ន សីសំ ចោបេតិ
ន កណ្ណេ ចោបេតិ ន ទន្តេ ចោបេតិ ន នង្គុដ្ឋំ
ចោបេតិ ន សោណ្ឌំ ចោបេតិ ។ សោ ហោតិ រញ្ញោ
នាគោ ខមោ សត្តិប្បហារានំ អសិប្បហារានំ ឧ-
សុប្បហារានំ បរសត្ថុប្បហារានំ ភេរិបណវសទ្ទនិន្នា-
ទសទ្ទានំ(១) សព្វវង្កទោសនិហតនិន្នីតកសាវោ
រាជារហោ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។

១ ម. ភេរិបណវសង្ខតិណវសទ្ទានំ ។



ឲ្យជាសត្វមិនញាប់ញ័រតទៅទៀត គឺយកក្តារយ៉ាងធំ ទៅចងក្រៀកនឹង
ប្រមោយដំរីនោះផង បុរសមានដៃកាន់លំពែងស្នែងក្របី គឺអង្គុយលើ
កដំរីនោះផង បុរសមានដៃកាន់លំពែងស្នែងក្របី នាំគ្នាឈរព័ទ្ធដំរីនោះ
ផង ហ្មដំរីកាន់ដងលំពែងស្នែងក្របីដ៏វែង ឈរចំពីខាងមុខដំរីនោះ
ផង ។ ដំរីនោះ កាលដែលហ្មក បង្ហាត់ឲ្យជាដំរីមិនញាប់ញ័រហើយ
ក៏មិនកម្រើកជើងមុខ មិនកម្រើកជើងក្រោយ មិនកម្រើកកាយខាងមុខ
មិនកម្រើកកាយខាងក្រោយ មិនកម្រើកក្បាល មិនកម្រើកត្រចៀក មិន
កម្រើកភ្លុក មិនកម្រើកកន្ទុយ មិនកម្រើកប្រមោយ ។ ដំរីព្រះរាជទ្រព្យ
នោះ ជាសត្វអត់ទ្រាំ ចំពោះការប្រហារដោយលំពែង ការប្រហារ
ដោយដាវ ការប្រហារដោយសរ និងការប្រហាររបស់សត្រូវដទៃទៀត
និងសំឡេងពិណនិងស្គរធំ ស្គរដៃ ស័ង្ខ និងស្គរទ័ព ជាសត្វកំចាត់
បង់នូវទោសវៀចគ្រប់យ៉ាង ជាសត្វអស់កក្អកកំណាចហើយ គួរដល់
ព្រះរាជា គួរជាទីប្រើប្រាស់របស់ព្រះរាជា ដល់នូវការរាប់បញ្ចូលជា
ជាអង្គរបស់ព្រះរាជាបាន សេចក្តីនេះ មានឧបមាដូចម្តេចមិញ ។

(៦៤) ឯវមេវ ខោ អគ្គិវេស្សន ឥធ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណិំ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ តំ ធម្មំ សុណាតិ គហបតិ វា គហបតិបុត្តោ វា អញ្ញតរស្មឹ វា កុលេ បច្ចាជាតោ សោ តំ ធម្មំ សុត្វា តថាគតេ សទ្ធំ បដិលភតិ ។ សោ តេន សទ្ធាបដិលាភេន សមន្នាគតោ ឥតិ បដិសញ្ចិក្ខតិ



(៦៤) ម្នាលអគ្គិវេស្សនៈ មានឧបមេយ្យដូចជា ព្រះតថាគតបានកើតឡើង ក្នុងលោកនេះ ជាព្រះអរហន្ត ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានព្រះដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ត្រាស់ដឹងនូវចតុរារិយសច្ច លែងវិលមកកាន់ភពថ្មីទៀត ព្រះតថាគតអង្គនោះទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយព្រះអង្គឯង នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ នូវមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយតាមប្រកាសបាន ព្រះអង្គសំដែងធម៌មានលំអបទដើម មានលំអបទកណ្តាល មានលំអបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ។ គហបតីឬគហបតិបុត្រ ដែលកើតជាខាងក្រោយ ក្នុងត្រកូលណាមួយ បានស្តាប់ធម៌នោះ លុះគហបតីឬគហបតិបុត្រនោះ បានស្តាប់ធម៌នោះហើយ ក៏បានចំពោះនូវសទ្ធាក្នុងព្រះតថាគត ។ កាលបើគហបតីនោះ ប្រកបដោយកិរិយាបានចំពោះនូវសទ្ធាដូច្នេះហើយ រមែងពិចារណាឃើញច្បាស់ថា

សម្ពាធោ ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ អបរេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្ដំ បហាយ មហន្តំ វា ញាតិបរិវដ្ដំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ(១) ។ ឯត្តាវតា ខោ អគ្គិវេស្សន អរិយសាវកោ អព្ភោកាសគតោ ហោតិ ។ ឯត្ថ គេធា ហិ អគ្គិវេស្សន ទេវមនុស្សា យទិទំ បញ្ចកាមគុណា ។ តមេនំ តថាគតោ ឧត្តរឹ វិនេតិ ឯហិ ត្វំ ភិក្ខុ សីលវា ហោហិ បាតិមោក្ខសំវរសំវុតោ វិហរាហិ អាចារគោចរសម្បន្នោ

១ ឱ. ម. បព្វជតិ ។



ឃរាវាសចង្អៀតពេកណាស់ ជាផ្លូវហូរមកនៃធូលីគឺកិលេស បព្វជ្ជាទើបមានវេលាទំនេរ បុគ្គលដែលនៅគ្រប់គ្រងផ្ទះ នឹងប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌តែមួយយ៉ាង ឲ្យបរិសុទ្ធតែមួយយ៉ាង ឲ្យស្អាតដូចជាស័ង្ខដែលគេខាត់ហើយមិនងាយបានទេ បើដូច្នោះ មានតែអាត្មាអញ កោរសក់និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ លុះគ្រាក្រោយមក បុគ្គលនោះ ក៏លះបង់នូវគំនរទ្រព្យតិចផង លះបង់នូវគំនរទ្រព្យច្រើនផង លះបង់នូវញាតិវង្សតិចផង លះបង់នូវញាតិវង្សច្រើនផង ហើយកោរសក់និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ ម្នាលអគ្គិវេស្សនៈ អរិយសាវ័កដែលទៅនៅក្នុងទីទំនេរបាន ក៏ដោយសារហេតុមានប្រមាណប៉ុណ្ណេះ ។ ម្នាលអគ្គិវេស្សនៈ ពួកទេវតានិងមនុស្ស ដែលនឹងមានសេចក្តីត្រេកអរក្នុងកាមគុណទាំង ៥ ប្រការនេះឯង ។ ព្រះតថាគត ទូន្មានប្រដៅបុគ្គលនោះ តទៅទៀតថា ម្នាលភិក្ខុ ចូរអ្នកមក ចូរជាអ្នកមានសីល ចូរជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ

អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខ-ស្សុ(១) សិក្ខាបទេសូតិ ។ យតោ ខោ អគ្គិវេស្សន អរិយសាវកោ សីលវា ហោតិ បាតិមោក្ខសំវរ-សំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុ-មត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ តមេនំ តថាគតោ ឧត្តរឹ វិនេតិ ឯហិ ត្វំ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោហិ ចក្ខុនា រូបំ ទិស្វា មា និមិត្តគ្គាហី ។បេ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្ពលីករណេ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ... ចិត្តេ... ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

១ ឱ. សិក្ខាហិ ។



ចូរជាអ្នកឃើញភ័យ ក្នុងទោសទាំងឡាយ សូម្បីតិចតួច ចូរសមាទាន សិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលអគ្គិវេស្សនៈ កាលបើអរិយ-សាវក ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយ អាចារៈ និងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសសូម្បីតិចតួច សមា-ទានសិក្សា ក្នុងសិក្ខាបទទាំងឡាយហើយ ។ ព្រះតថាគត ក៏ប្រដៅតទៅ ទៀតថា ម្នាលភិក្ខុ ចូរអ្នកមក ចូរជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយ ទាំងឡាយ បើឃើញរូបដោយចក្ខុ កុំមិនកាន់យកនិមិត្ត ។បេ។ ភិក្ខុនោះ លះបង់នីវរណៈទាំង ៥ ប្រការ ដែលជាគ្រឿងសៅហ្មងចិត្ត ធ្វើប្រាជ្ញាឲ្យទុព្វល ពិចារណាឃើញច្បាស់នូវកាយក្នុងកាយ ជាអ្នក ព្យាយាមដុតកំដៅកិលេស មានសតិសម្បជញ្ញៈ កំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ពិចារណាឃើញច្បាស់នូវវេទនា ក្នុង វេទនាទាំងឡាយ... ពិចារណាឃើញច្បាស់នូវចិត្ត ក្នុងចិត្ត... ពិចារណាឃើញច្បាស់ នូវធម្មារម្មណ៍ក្នុងធម្មារម្មណ៍ ព្យាយាមដុតកំដៅកិ-លេស មានសតិសម្បជញ្ញៈ កំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។

(៦៨) សេយ្យថាបិ អគ្គិវេស្សន ហត្ថិទមកោ មហន្តំ ថម្ភំ បឋវិយំ និខណិត្វា អារញ្ញកស្ស នាគស្ស គីវាយំ ឧបនិពន្ធតិ អារញ្ញកានញ្ចេវ សីលានំ អភិនិម្មទនាយ អារញ្ញកានញ្ចេវ សរសង្កប្បានំ[១] អភិនិម្មទនាយ អារញ្ញកានញ្ចេវ ទរថកិលមថបរិឡាហានំ អភិនិម្មទនាយ គាមន្តេ អភិរមាបនាយ មនុស្សកន្តេសុ សីលេសុ សមាទបនាយ ឯវមេវ ខោ អគ្គិវេស្សន អរិយសាវកស្ស ឥមេ ចត្តារោ សតិបដ្ឋានា ចេតសោ ឧបនិពន្ធា[២] ហោន្តិ គេហសិតានញ្ចេវ សីលានំ អភិនិម្មទនាយ គេហសិតានញ្ចេវ សរសង្កប្បានំ អភិនិម្មទនាយ គេហសិតានញ្ចេវ ទរថកិលមថបរិឡាហានំ អភិនិម្មទនាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ ។

---

១ ម. សង្កប្បានំ ។ ២ ម. ឧបនិពន្ធនា ។



(៦៨) ម្នាលអគ្គិវេស្សនៈ ដូចហ្មដំរី ដែលដាំសសរធំទៅក្នុងផែនដី ហើយចងក្រៀកដំរីព្រៃត្រង់ក ដើម្បីញុំាងញីនូវទម្លាប់របស់ពួកដំរីព្រៃផង ដើម្បីញុំាងញីនូវតម្រិះជាគ្រឿងស្មុះទៅ របស់ពួកដំរីព្រៃផង ញុំាងញីនូវសេចក្តីក្រវល់ក្រវាយ សេចក្តីនឿយហត់ សេចក្តីក្តៅក្រហាយ របស់ពួកដំរីព្រៃផង ដើម្បីញុំាងដំរីព្រៃឲ្យត្រេកអរ ចំពោះស្រុកផង ដើម្បីកាន់យកសណ្តាប់ធ្នាប់ ដែលជាទីស្រឡាញ់ របស់មនុស្សផង សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលអគ្គិវេស្សនៈ មានឧបមេយ្យដូចជា អរិយសាវក ដែលចងក្រៀកចិត្តភ្ជាប់នឹងសតិប្បដ្ឋានទាំង ៤ នេះ ដើម្បីញុំាងញីនូវទម្លាប់ ដែលអាស្រ័យនឹងបញ្ចកាមគុណផង ដើម្បីញុំាងញីតម្រិះជាគ្រឿងស្មុះទៅ ដែលអាស្រ័យនឹងបញ្ចកាមគុណផង ដើម្បីញុំាងញីនូវសេចក្តីក្រវល់ក្រវាយ សេចក្តីនឿយហត់ សេចក្តីក្តៅក្រហាយ ដែលអាស្រ័យនឹងបញ្ចកាមគុណផង ដើម្បីត្រាស់ដឹងនូវអដ្ឋង្គិកមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

(៦៦) តមេនំ តថាគតោ ឧត្តរឹ វិនេតិ ឯហិ ត្វំ ភិក្ខុ កាយេ កាយានុបស្សី វិហរាហិ មា ច កាយូបសញ្ហិតំ(១) វិតក្កំ វិតក្កេសិ ។ វេទនាសុ... ចិត្តេ... ធម្មេសុ ធម្មានុបស្សី វិហរាហិ មា ច ធម្មូបសញ្ហិតំ(២) វិតក្កំ វិតក្កេសិ ។ សោ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

(៦៧) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។

១ ម. កាយូបសំហិតំ ។ ២ ម. ធម្មូបសំហិតំ ។



(៦៦) ព្រះតថាគត ទ្រង់ប្រដៅភិក្ខុនោះ តទៅទៀតថា ម្នាលភិក្ខុ អ្នកចូរមក អ្នកចូរពិចារណានូវកាយក្នុងកាយ តែកុំត្រិះរិះនូវតម្រិះ ដែលប្រកបដោយកាមឡើយ ។ អ្នកចូរពិចារណានូវវេទនាក្នុងវេទនាទាំងឡាយ ... អ្នកចូរពិចារណានូវចិត្តក្នុងចិត្ត ... អ្នកចូរពិចារណានូវធម្មារម្មណ៍ក្នុងធម្មារម្មណ៍ តែកុំត្រិះរិះនូវតម្រិះ ដែលប្រកបដោយធម្មារម្មណ៍ឡើយ ។ ភិក្ខុនោះព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ហើយចូលកាន់ទុតិយជ្ឈាន ដែលមានសេចក្ដីជ្រះថ្លា ប្រព្រឹត្តទៅខាងក្នុង ជាចិត្តខ្ពស់ឯក ឥតមានវិតក្កៈ ឥតមានវិចារៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ ... ចូលកាន់តតិយជ្ឈាន... ចូលកាន់ចតុត្ថជ្ឈាន ។

(៦៧) ភិក្ខុនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការងារកម្ម ជាចិត្តនឹងនឹង ដល់នូវការមិនញាប់ញ័រ យ៉ាងនេះហើយ បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញាណ (ញាណដែលរលឹកឃើញនូវខន្ធ ដែលធ្លាប់កើតក្នុងភពមុន ៗ) ។ ភិក្ខុនោះ រមែងរលឹកឃើញនូវបុព្វេនិវាស មានច្រើនប្រការ គឺរលឹកឃើញជាតិ ១ ជាតិ ២ ។ បេ ។ រលឹកឃើញ នូវបុព្វេនិវាស មានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។

(២៨) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។

(២៩) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ



(២៨) ភិក្ខុនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការងារ ជាចិត្តនឹងនឹង ដល់នូវការមិនញាប់ញ័រ យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ (ញាណដែលឃើញនូវចុតិបដិសន្ធិ) របស់សត្វទាំងឡាយ ។ ភិក្ខុនោះ មានចក្ខុដូចជាទិព្វ គន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា រមែងឃើញពួកសត្វ ដែលកំពុងច្យុត កំពុងកើត ដ៏ថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានរូបល្អខ្លះ មានរូបអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ។ បេ ។ រមែងដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ។

(២៩) ភិក្ខុនោះ កាលបើចិត្តតាំងមាំល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារ ជាចិត្តនឹងនឹង មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ (ញាណដែលធ្វើឲ្យឃើញនូវកិរិយាក្ស័យនៃអាសវៈ) ។ ភិក្ខុនោះ រមែងដឹងច្បាស់ដោយពិតថា នេះ ជាទុក្ខ ដឹងច្បាស់ដោយពិតថា នេះ ជាតណ្ហាជាហេតុឲ្យកើតទុក្ខ

អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។



ដឹងច្បាស់ដោយពិតថា នេះ ជាព្រះនិព្វានទីរលត់ទុក្ខ ដឹងច្បាស់ដោយពិតថា នេះ ជាបដិបទា ដំណើរទៅកាន់ព្រះនិព្វានទីរលត់ទុក្ខ ។ ភិក្ខុនោះ រមែងដឹងច្បាស់ដោយពិតថា នេះជាពួកអាសវៈ ដឹងច្បាស់ដោយពិតថា នេះ ជាធម៌នាំឲ្យកើតអាសវៈ ដឹងច្បាស់ដោយពិតថា នេះ ជាព្រះនិព្វានទីរលត់អាសវៈ ដឹងច្បាស់ដោយពិតថា នេះ ជាបដិបទា ដំណើរទៅកាន់ព្រះនិព្វានទីរលត់អាសវៈ ។ កាលបើភិក្ខុនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏រួចស្រឡះចាកកាមាសវៈផង ចាកភវាសវៈផង ចាកអវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះហើយ ក៏មានសេចក្ដីដឹងថា ចិត្តរួចស្រឡះហើយដូច្នេះ ភិក្ខុនោះដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញ បានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ច នេះទៀត មិនមានឡើយ ។

(៧០) សោ(១) ភិក្ខុ ខមោ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសិរឹសប-សម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្ប-ន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិប្បានំ ក-ដុកានំ(២) អសាតានំ អមនាបានំ បាណហរានំ អ-ធិវាសកជាតិកោ ហោតិ ។ សព្វរាគទោសមោហនិ-ហតនិទ្ធន្តកសាវោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស(៣) ។

១ ម. សោ ហោតិ ។ ២ ឱ. ម. តិប្បានំ ខរានំ កដុកានំ ។ ៣ ឱ. លោកស្សាតិ ។



(៧០) ភិក្ខុនោះ ជាអ្នកអត់ទ្រាំនូវត្រជាក់ និងក្តៅ និងសេចក្តីស្រេក និងសេចក្តីឃ្លាន និងសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់ក្តួចពស់ពិសទាំងឡាយ ប្រកបដោយជាតិជាអ្នកអត់ធ្មត់ចំពោះគន្លងពាក្យ ដែលគេស្តីអាក្រក់ ដែលមានដំណើរមកអាក្រក់ និងវេទនា ដែលអាស្រ័យក្នុងសរីរៈកើតឡើងហើយ ជាទុក្ខ ដ៏ក្លា ក្តៅក្រហាយ មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត នាំបង់នូវជីវិត ។ ភិក្ខុនោះ ជាអ្នកមានទឹកចត់ គឺរាគៈ ទោសៈ មោហៈ ទាំងពួង កំចាត់បង់ហើយ ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកអំពីចម្ងាយ គួរទទួលនូវទានដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទាន របស់បុគ្គលជាអ្នកជឿកម្មផល គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

(៧១) មហល្លកោ ចេបិ អគ្គិវេស្សន រញ្ញោ នាគោ អទន្តោ អវិនីតោ កាលំ ករោតិ អទន្តមរណំ មហល្លកោ រញ្ញោ នាគោ មតោ[១] កាលង្កតោត្វេវ សង្ខំ គច្ឆតិ ។ មជ្ឈិមោ ចេបិ អគ្គិវេស្សន រញ្ញោ នាគោ... ទហរោ ចេបិ អគ្គិវេស្សន រញ្ញោ នាគោ អទន្តោ អវិនីតោ កាលំ ករោតិ អទន្តមរណំ ទហរោ រញ្ញោ នាគោ មតោ កាលង្កតោត្វេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ អគ្គិវេស្សន ថេរោ ចេបិ ភិក្ខុ អខីណាសវោ កាលំ ករោតិ អទន្តមរណំ ថេរោ ភិក្ខុ មតោ កាលង្កតោត្វេវ សង្ខំ គច្ឆតិ ។ មជ្ឈិមោ ចេបិ អគ្គិវេស្សន ភិក្ខុ... ទហរោ ចេបិ អគ្គិវេស្សន ភិក្ខុ

១ រ. ម. មតោតិ ន ទិស្សតិ ។



(៧១) ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វចាស់ គេមិនបានទូន្មាន មិនបានហ្វឹកហ្វឺន ហើយធ្វើមរណកាលទៅ ក៏ស្លាប់ទៅតាមនៃគេមិនទាន់បានទូន្មាន ដំរីព្រះរាជទ្រព្យ ជាសត្វចាស់ដែលស្លាប់ហើយនោះ ដល់នូវការរាប់ថាជាដំរីស្លាប់ហើយ ៗ ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វកណ្តាល ... ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វនៅក្មេង គេមិនទាន់ទូន្មាន មិនទាន់ហ្វឹកហ្វឺនទេ ហើយធ្វើមរណកាលទៅ ក៏ស្លាប់ទៅតាមនៃគេមិនទាន់ទូន្មាន ដំរីព្រះរាជទ្រព្យ ដែលជាសត្វនៅក្មេងស្លាប់ហើយនោះ ក៏ដល់នូវការរាប់ថា ជាដំរីស្លាប់ហើយដែរ ៗ សេចក្តីនេះ មានឧបមាដូចម្តេចមិញ ម្នាលអគ្គិវេស្សនៈ មានឧបមេយ្យដូចភិក្ខុជាថេរៈ ប្រសិនបើ មិនមែនជាព្រះខីណាស្រព ធ្វើមរណកាលទៅ ក៏ស្លាប់ទៅតាមនៃមិនទាន់បានទូន្មានខ្លួនទេ ភិក្ខុជាថេរៈ ដែលស្លាប់ហើយនោះ ដល់នូវការរាប់ថា ធ្វើមរណកាល ៗ ម្នាលអគ្គិវេស្សនៈ ប្រសិនបើភិក្ខុជាកណ្តាល ... ម្នាលអគ្គិវេស្សនៈ ប្រសិនបើភិក្ខុនៅក្មេង

អខីណាសវោ កាលំ ករោតិ អទន្តមរណំ ទហរោ
ភិក្ខុ មតោ កាលកតោត្វេវ សង្ខំ គច្ឆតិ ។

(៧៦) មហល្លកោ ចេបិ អគ្គិវេស្សន រញ្ញោ
នាគោ សុទន្តោ សុវិនីតោ កាលំ ករោតិ ទន្តម-
រណំ មហល្លកោ រញ្ញោ នាគោ មតោ កាលក-
តោត្វេវ សង្ខំ គច្ឆតិ ។ មជ្ឈិមោ ចេបិ អគ្គិវេស្សន
រញ្ញោ នាគោ… ទហរោ ចេបិ អគ្គិវេស្សន រញ្ញោ
នាគោ សុទន្តោ សុវិនីតោ កាលំ ករោតិ ទន្ត-
មរណំ ទហរោ រញ្ញោ នាគោ មតោ កាលកតោត្វេវ
សង្ខំ គច្ឆតិ ឯវមេវ ខោ អគ្គិវេស្សន ថេរោ ចេបិ
ភិក្ខុ ខីណាសវោ កាលំ ករោតិ ទន្តមរណំ
ថេរោ ភិក្ខុ មតោ កាលកតោត្វេវ សង្ខំ គច្ឆតិ ។



មិនមែនជាព្រះខីណាស្រព ធ្វើមរណកាលទៅ គឺស្លាប់ទៅទាំងមិន
ទាន់បានទូន្មានខ្លួនទេ ភិក្ខុបួសថ្មីដែលស្លាប់ហើយនោះ គឺដល់នូវកិរិយា
រាប់ថា ធ្វើមរណកាលដែរ ។

(៧៦) ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វ
ចាស់ គេបានទូន្មានប្រៀនប្រដៅ បានបែបបទហើយ ធ្វើមរណកាលទៅ
គឺស្លាប់ទៅដោយគេបានទូន្មានហើយ ដំរីព្រះរាជទ្រព្យ ជាសត្វចាស់
ដែលស្លាប់ហើយនោះ ដល់នូវកិរិយារាប់ថា ជាសត្វស្លាប់ ។ ម្នាលអគ្គិ-
វេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វនៅកណ្តាល ... ម្នាលអគ្គិ-
វេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វនៅក្មេង គេបានទូន្មាន
ប្រៀនប្រដៅ បានបែបបទហើយ ធ្វើមរណកាលទៅ គឺស្លាប់ទៅដោយ
គេបានទូន្មានហើយ ដំរីព្រះរាជទ្រព្យជាសត្វនៅក្មេង ដែលស្លាប់ហើយ
នោះ គឺដល់នូវកិរិយារាប់ថាជាសត្វស្លាប់ដែរ ។ សេចក្តីនេះមានឧបមា
ដូចម្តេចមិញ ម្នាលអគ្គិវេស្សនៈ មានឧបមេយ្យដូចភិក្ខុជាថេរៈ បើជាព្រះ
ខីណាស្រព ធ្វើមរណកាលទៅ គឺស្លាប់ទៅដោយបានទូន្មានខ្លួនហើយ
ភិក្ខុជាថេរៈដែលស្លាប់ហើយនោះ ដល់នូវកិរិយារាប់ថាធ្វើមរណកាល ។

មជ្ឈិមោ ចេបិ អគ្គិវេស្សន ភិក្ខុ ... ថេរោ ចេបិ អគ្គិវេស្សន ភិក្ខុ ខីណាសវោ កាលំ ករោតិ ទន្តមរណំ ថេរោ ភិក្ខុ មតោ កាលកតោត្វេវ សង្ខំ គច្ឆតិ ។ ឥទមវោច ភគវា អត្តមនោ អចិរវតោ សមណុទ្ទេសោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ទន្តភូមិសុត្តំ បញ្ចមំ និដ្ឋិតំ ។

---



ម្នាលអគ្គិវេស្សនៈ ប្រសិនបើភិក្ខុជាកណ្តាល ... ប្រសិនបើភិក្ខុចាស់ជាព្រះខីណាស្រព ធ្វើមរណកាល គឺស្លាប់ទៅទាំងបានទូន្មានខ្លួនហើយ ភិក្ខុចាស់ដែលធ្វើមរណកាលហើយនោះ គឺដល់នូវការរាប់ថាធ្វើមរណកាលដែរ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ អចិរវតសមណុទ្ទេស ក៏រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ទន្តភូមិសូត្រ ទី ៥ ។

## ឆដ្ឋំ ភូមិជសុត្តំ

(៧៣) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ អាយស្មា ភូមិជោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ជយសេនស្ស រាជកុមារស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ ជយសេនោ រាជកុមារោ យេនាយស្មា ភូមិជោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា ភូមិជេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

(៧៤) ឯកមន្តំ និសិន្នោ ខោ ជយសេនោ រាជកុមារោ អាយស្មន្តំ ភូមិជំ ឯតទវោច សន្តិ ភោ ភូមិជ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ

## ភូមិជសូត្រ ទី ៦

(៧៣) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះភូមិជៈមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ដំណាក់ នៃព្រះរាជកុមារព្រះនាមជយសេន លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះ ជយសេនរាជកុមារ ចូលទៅរកព្រះភូមិជៈមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះភូមិជៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏គង់ក្នុងទីសមគួរ ។

(៧៤) លុះជយសេនរាជកុមារ គង់ក្នុងទីសមគួរហើយ ក៏ពោលនឹងព្រះភូមិជៈមានអាយុ ដូច្នេះថា បពិត្រព្រះភូមិជៈដ៏ចំរើន មានសមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បើបុគ្គលធ្វើនូវបំណង (ដើម្បីត្រាស់ដឹងនូវផល) ហើយប្រព្រឹត្តព្រហ្មចរិយៈ

អភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អាសញ្ច អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ នេវាសំនានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយាតិ កិរ ភោតោ ភូមិជស្ស សត្ថា ឯវំវាទី ឯវំទិដ្ឋី ឯវមក្ខាយីតិ ។

(៧៩) ន ខោ មេតំ រាជកុមារ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ ភគវា ឯវំ ព្យាករេយ្យ អាសញ្ចេបិ ករិត្វា អយោនិសោ ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា អយោនិសោ ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ



ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលទេ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយវិញទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ ចុះគ្រូសាសនានេះ ព្រះជាគ្រូរបស់ភូមិជៈដ៏ចម្រើន តើមានវាទៈដូចម្តេច មានទិដ្ឋិដូចម្តេច ឆ្លងពោលដូចម្តេច ។

(៧៩) ថ្វាយព្រះពរព្រះរាជកុមារ ឯចំណែកខ្ញុំ អាត្មាភាពពុំដែលបានស្តាប់មក ក្នុងទីចំពោះព្រះភក្ត្រ ឬបានទទួលមក អំពីទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគទេ ប៉ុន្តែបើហេតុការណ៍នុ៎ះមាន ប្រាកដជា ព្រះមានព្រះភាគ នឹងទ្រង់ដោះស្រាយយ៉ាងនេះថា បើបុគ្គលធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ

នេវាសំនានាសញ្ចេបិ កត្វា អយោនិសោ ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អាសញ្ចេបិ កត្វា យោនិសោ ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ កត្វា យោនិសោ ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ អាសញ្ច អនាសញ្ចេបិ កត្វា យោនិសោ ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ នេវាសំនានាសញ្ចេបិ កត្វា យោនិសោ ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយាតិ ន ខោ មេតំ រាជកុមារ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ ភគវា ឯវំ ព្យាករេយ្យាតិ ។ សចេ[១] ភោតោ ភូមិជស្ស សត្ថា ឯវំវាទី ឯវមក្ខាយី អទ្ធា ភោតោ ភូមិជស្ស សត្ថា សព្វេសំយេវ បុថុសមណព្រាហ្មណានំ មុទ្ធានំ មញ្ញេ អាហច្ច តិដ្ឋតីតិ ។ អថខោ ជយសេនោ រាជកុមារោ អាយស្មន្តំ ភូមិជំ សកេនេវ ថាលិបាកេន បរិវិសិ ។

១ ម. សចេ ខោ ។



មួយទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ទើបគួរដើម្បីត្រាស់ដឹងនូវផលបាន មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ មួយវិញទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បពិត្រព្រះរាជកុមារ ឯសេចក្តីនុ៎ះ អាត្មាភាពពុំដែលបានស្តាប់មកក្នុងទីចំពោះព្រះភក្ត្រ ឬបានទទួលមក អំពីទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគទេ ប៉ុន្តែហេតុការណ៍នុ៎ះមាន ប្រាកដជា ព្រះមានព្រះភាគ នឹងទ្រង់ដោះស្រាយយ៉ាងនេះឯង ។ បើព្រះជាគ្រូរបស់ព្រះភូមិជៈដ៏ចម្រើន មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ បានពោលយ៉ាងនេះមែន ព្រះជាគ្រូរបស់ព្រះភូមិជៈដ៏ចម្រើន ហាក់ដូចជាសំពត់អំបែងក្បាល នៃពួកសមណព្រាហ្មណ៍ ជាច្រើនទាំងអស់ ដោយពិត ។ គ្រានោះ ជយសេនរាជកុមារ ក៏អង្គាសព្រះភូមិជៈមានអាយុ ដោយសម្រាប់ទឹកខ្លួន ។

(៧៦) អថខោ អាយស្មា ភូមិជោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ភូមិជោ ភគវន្តំ ឯតទវោច អហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ជយសេនស្ស រាជកុមារស្ស និវេសនំ តេនុបសង្កមឹ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទឹ។ អថខោ ភន្តេ ជយសេនោ រាជកុមារោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មយា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ភន្តេ ជយសេនោ រាជកុមារោ មំ ឯតទវោច សន្តិ ភោ ភូមិជ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ



(៧៦) លំដាប់នោះ ព្រះភូមិជៈមានអាយុ កាលត្រឡប់ពីបិណ្ឌបាតមក ក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះភូមិជៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ដំណាក់ របស់ជយសេនរាជកុមារ ក្នុងទីឯណោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ជយសេនរាជកុមារ ចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងខ្ញុំព្រះអង្គ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏គង់ក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះជយសេនរាជកុមារ គង់ក្នុងទីសមគួរហើយ ក៏សាកសួរ ចំពោះខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះភូមិជៈដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បើបុគ្គលធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ

អភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អាសញ្ច អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ នេវាសំ នានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយាតិ ឥធ ភោតោ ភូមិជស្ស សត្ថា កឹវាទី កិមក្ខាយីតិ ។ ឯវំ វុត្តេ អហំ ភន្តេ ជយសេនំ រាជកុមារំ ឯតទវោចំ ន ខោ មេតំ រាជកុមារ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ ភគវា ឯវំ ព្យាករេយ្យ អាសញ្ចេបិ ករិត្វា អយោនិសោ ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា អយោនិសោ ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អាសញ្ច អនាសញ្ចេបិ ករិត្វា



ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលទេ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ ចុះក្នុងសាសនានេះ ព្រះជាគ្រូរបស់ព្រះភូមិជៈដ៏ចម្រើន តើមានវាទៈដូចម្តេច មានទិដ្ឋិដូចម្តេច បានពោលដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើជយសេនរាជកុមារ ទូលសួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏ពោលតបទៅនឹងជយសេនរាជកុមារដូច្នេះថា ថ្វាយព្រះពរព្រះរាជកុមារ ឯដំណើរនុ៎ះ អាត្មាភាពមិនដែលបានស្តាប់ ក្នុងទីចំពោះព្រះភក្ត្រ ឬបានទទួលមក អំពីទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគទេ ប៉ុន្តែបើហេតុការណ៍នុ៎ះមាន ប្រាកដជា ព្រះមានព្រះភាគ នឹងទ្រង់ដោះស្រាយ យ៉ាងនេះថា បើបុគ្គលធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ

អយោនិសោ ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ នេវាសំ នានាសញ្ចេបិ ករិត្វា អយោនិសោ ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អាសញ្ចេបិ ករិត្វា យោនិសោ ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា ... អាសញ្ច អនាសញ្ចេបិ ករិត្វា ... នេវាសំ នានាសញ្ចេបិ ករិត្វា យោនិសោ ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយាតិ ន ខោ មេតំ រាជកុមារ ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ ឋានញ្ច ខោ ឯតំ វិជ្ជតិ យំ ភគវា ឯវំ ព្យាករេយ្យាតិ ។ សចេ ភោតោ ភូមិជស្ស សត្ថា ឯវំវាទី ឯវំទិដ្ឋី ឯវមក្ខាយី អទ្ធា ភោតោ ភូមិជស្ស សត្ថា សព្វេសំយេវ បុថុសមណព្រាហ្មណានំ មុទ្ធានំ មញ្ញេ អាហច្ច តិដ្ឋតីតិ ។ កច្ចាហំ(១) ភន្តេ ឯវំ បុដ្ឋោ ឯវំ ព្យាករមានោ វុត្តវាទី ចេវ

១ ម. កច្ចិ ។





ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ទើបគួរដើម្បីត្រាស់ដឹងនូវផលបាន បើមិនធ្វើនូវបំណង... បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ... បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បពិត្រព្រះរាជកុមារ ឯដំណើរនុ៎ះ អាត្មាភាពមិនដែលបានស្តាប់ ក្នុងទីចំពោះព្រះភក្ត្រ ឬបានទទួលមក អំពីទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគទេ ប៉ុន្តែបើហេតុការណ៍នុ៎ះមាន ព្រោះថាព្រះមានព្រះភាគ នឹងទ្រង់ដោះស្រាយយ៉ាងនេះឯង ។ ជយសេនរាជកុមារ ទ្រង់ត្រាស់ថា បើព្រះជាគ្រូរបស់ព្រះភូមិជៈដ៏ចម្រើន មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ បានពោលយ៉ាងនេះមែន ព្រះជាគ្រូរបស់ព្រះភូមិជៈដ៏ចម្រើន ហាក់ដូចជាសំពងនូវកំពែងក្បាល នៃពួកសមណព្រាហ្មណ៍ ជាច្រើនទាំងអស់ ដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើរាជកុមារ ទ្រង់សួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏បានដោះស្រាយយ៉ាងនេះ តើឈ្មោះថា ខ្ញុំព្រះអង្គពោលត្រូវតាម

ភគវតោ ហោតិ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខតិ ធម្មស្ស ចានុធម្មំ ព្យាករោតិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហដ្ឋានំ អាគច្ឆតីតិ ។

(៧៧) តគ្ឃ ត្វំ ភូមិជ ឯវំ បុដ្ឋោ ឯវំ ព្យាករមានោ វុត្តវាទី ចេវ មេ[១] ហោសិ ន ច មំ អភូតេន អព្ភាចិក្ខសិ ធម្មស្ស ចានុធម្មំ ព្យាករោសិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហដ្ឋានំ អាគច្ឆតិ ។ យេ ហិ កេចិ ភូមិជ សមណា វា ព្រាហ្មណា វា មិច្ឆាទិដ្ឋិនោ មិច្ឆាសង្កប្បា មិច្ឆាវាចា មិច្ឆាកម្មន្តា មិច្ឆាអាជីវា មិច្ឆាវាយាមា មិច្ឆាសតី មិច្ឆាសមាធិនោ តេ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អាសញ្ច អនាសញ្ចេបិ ករិត្វា

១ ម. ភគវតោ ។



ព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគនេះ ឈ្មោះថាមិនពោលបង្កាច់ព្រះមានព្រះភាគ ដោយពាក្យមិនពិតនេះ ឈ្មោះថាសំដែងនូវធម៌សមគួរដល់ធម៌នេះ ឬទេ មួយទៀត វាទានុវាទបន្តិចបន្តួច ដែលប្រកបដោយធម៌ មិនមកកាន់ទីដែលបណ្ឌិតគួរតិះដៀល ទេឬ ។

(៧៧) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អើភូមិជៈ កាលដែលព្រះរាជកុមារ ទ្រង់ចោទសួរយ៉ាងនុ៎ះ ហើយអ្នកដោះស្រាយយ៉ាងនុ៎ះ ឈ្មោះជាអ្នកពោលត្រូវតាមពាក្យរបស់តថាគតនេះ ឈ្មោះថាមិនពោលបង្កាច់តថាគតដោយពាក្យមិនពិតនេះ ឈ្មោះថាសំដែងនូវធម៌សមគួរដល់ធម៌នេះ មួយទៀត វាទានុវាទបន្តិចបន្តួច ដែលប្រកបដោយធម៌ មិនបានមកកាន់ទីដែលបណ្ឌិតគួរតិះដៀលទេ ។ ម្នាលភូមិជៈ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយដែលមានទិដ្ឋិខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានព្យាយាមខុស មានសតិខុស មានសមាធិខុស សមណព្រាហ្មណ៍ទាំងនោះ បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ

ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ នេវ-សញ្ច នានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ តំ កិស្ស ហេតុ អយោនិ ហេសា ភូមិជ ផលស្ស អធិគមាយ ។

(៧៨) សេយ្យថាបិ ភូមិជ បុរិសោ តេលត្ថិកោ តេលគវេសី តេលបរិយេសនំ ចរមានោ វាលិកំ ទោណិយា អាកិរិត្វា ឧទកេន បរិប្ផោសកំ បរិប្ផោសកំ បីឡេយ្យ អាសញ្ចេបិ ករិត្វា វាលិកំ ទោណិយា អាកិរិត្វា ឧទកេន បរិប្ផោសកំ បរិប្ផោសកំ បីឡេយ្យ អភព្វោ តេលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា វាលិកំ ទោណិយា អាកិរិត្វា ឧទកេន ប-រិប្ផោសកំ បរិប្ផោសកំ បីឡេយ្យ អភព្វោ តេលស្ស អធិគមាយ អាសញ្ច អនាសញ្ចេបិ ករិត្វា វាលិកំ ទោណិយា អាកិរិត្វា ឧទកេន បរិប្ផោសកំ បរិប្ផោស-កំ បីឡេយ្យ អភព្វោ តេលស្ស អធិគមាយ នេវ-សញ្ច នានាសញ្ចេបិ ករិត្វា វាលិកំ ទោណិយា អាកិរិត្វា



ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយវិញទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានចំនង ដែលនាំឲ្យត្រាស់ដឹងនូវផល ។

(៧៨) ម្នាលភូមិជៈ ដូចបុរសដែលត្រូវការដោយប្រេង ស្វែងរកប្រេង ត្រាច់ទៅកាន់ទីស្វែងរកប្រេង ក៏យកដីខ្សាច់មកដាក់ក្នុងស្នូក ហើយយកទឹកមកប្រស់ព្រំ ច្របាច់រឿយ ៗ បើទុកជាធ្វើនូវបំណង ហើយយកដីខ្សាច់មកដាក់ក្នុងស្នូក ហើយយកទឹកមកប្រស់ព្រំ ច្របាច់រឿយ ៗ ក៏មិនគួរដើម្បីបាននូវប្រេងឡើយ បើទុកជាមិនធ្វើនូវបំណង ហើយយកដីខ្សាច់មកដាក់ក្នុងស្នូក ហើយយកទឹកមកប្រស់ព្រំ ច្របាច់រឿយ ៗ ក៏មិនគួរដើម្បីបាននូវប្រេងដែរ បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយយកដីខ្សាច់មកដាក់ក្នុងស្នូក ហើយយកទឹកមកប្រស់ព្រំ ច្របាច់រឿយ ៗ ក៏មិនគួរដើម្បីបាននូវប្រេងដែរ បើទុកជាមិនធ្វើ នូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកដីខ្សាច់មកដាក់ក្នុងស្នូក

ឧទកេន បរិប្ផោសកំ បរិប្ផោសកំ បីឡេយ្យ អភព្វោ តេលស្ស អធិគមាយ តំ កិស្ស ហេតុ អយោនិសោ ភូមិជ តេលស្ស អធិគមាយ ឯវមេវ ខោ ភូមិជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា មិច្ឆាទិដ្ឋិនោ មិច្ឆាសង្កប្បា មិច្ឆាវាចា មិច្ឆាកម្មន្តា មិច្ឆាអាជីវា មិច្ឆាវាយាមា មិច្ឆាសតី មិច្ឆាសមាធិនោ តេ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អាសញ្ច អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ នេវាសំនានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ តំ កិស្ស ហេតុ អយោនិសោ ភូមិជ ផលស្ស អធិគមាយ ។



ហើយយកទឹកមកប្រស់ព្រំ ច្របាច់រឿយៗ ក៏មិនគួរដើម្បីបាននូវប្រេងដែរ សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ម្នាលភូមិជៈ ព្រោះគ្មានទំនងដែលគួរឲ្យបានប្រេងឡើយ សេចក្ដីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិខុស មានសេចក្ដីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានព្យាយាមខុស មានសតិខុស មានសមាធិខុស សមណៈ ឬព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ បើទុកជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ម្នាលភូមិជៈ ព្រោះគ្មានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលឡើយ ។

(៨៥) សេយ្យថាបិ ភូមិជ បុរិសោ ខីរត្ថិកោ ខីរគវេសី ខីរបរិយេសនំ ចរមានោ គាវឹ តរុណវច្ឆំ វិសាណតោ អាវិញ្ឆេយ្យ អាសញ្ចេបិ ករិត្វា គាវឹ តរុណវច្ឆំ វិសាណតោ អាវិញ្ឆេយ្យ អភព្វោ ខីរស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា ។ បេ ។ នេវាសញ្ចំ នានាសញ្ចេបិ ករិត្វា គាវឹ តរុណវច្ឆំ វិសាណតោ អាវិញ្ឆេយ្យ អភព្វោ ខីរស្ស អធិគមាយ តំ កិស្ស ហេតុ អយោនិសោ ភូមិជ ខីរស្ស អធិគមាយ ឯវមេវ ខោ ភូមិជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា មិច្ឆាទិដ្ឋិនោ ។ បេ ។ មិច្ឆាសមាធិនោ តេ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា... អាសញ្ច អនាសញ្ចេបិ ករិត្វា... នេវាសញ្ចំ នានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ តំ កិស្ស ហេតុ អយោនិសោ ភូមិជ ផលស្ស អធិគមាយ ។



(៨៥) ម្នាលភូមិជៈ ពុំនោះសោត ដូចបុរស ដែលត្រូវការដោយទឹកដោះស្រស់ ស្វែងរកទឹកដោះស្រស់ ត្រាច់ទៅកាន់ទីស្វែងរកទឹកដោះស្រស់ គឺទាញរមួលស្នែងមេគោដែលមានកូនខ្ចី បើទុកជាធ្វើនូវបំណង ហើយទាញរមួលស្នែងមេគោដែលមានកូនខ្ចី ក៏មិនគួរដើម្បីបាននូវទឹកដោះស្រស់ឡើយ បើទុកជាមិនធ្វើនូវបំណង ។បេ។ បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយទាញរមួលស្នែងមេគោដែលមានកូនខ្ចី ក៏មិនគួរដើម្បីបាននូវទឹកដោះស្រស់ដែរ សេចក្តីនោះព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនង ដែលនាំឲ្យបាននូវទឹកដោះស្រស់ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យ ដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានមិច្ឆាទិដ្ឋិ ។បេ។ មានមិច្ឆាសមាធិ សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ បើទុកជាមិនធ្វើនូវបំណង... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះជាគ្មានទំនង ដើម្បីឲ្យត្រាស់ដឹងនូវផលឡើយ ។

(៨០) សេយ្យថាបិ ភូមិជ បុរិសោ នវនីតត្ថិកោ នវនីតគវេសី នវនីតបរិយេសនំ ចរមានោ ឧទកំ កលសេ អាសិញ្ចិត្វា មត្ថេន អាវិញ្ឆេយ្យ អាសញ្ចេបិ ករិត្វា ឧទកំ កលសេ អាសិញ្ចិត្វា មត្ថេន អាវិញ្ឆេយ្យ អភព្វោ នវនីតស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា... អាសញ្ច អនាសញ្ចេបិ ករិត្វា... នេវាសំនានាសញ្ចេបិ ករិត្វា ឧទកំ កលសេ អាសិញ្ចិត្វា មត្ថេន អាវិញ្ឆេយ្យ អភព្វោ នវនីតស្ស អធិគមាយ តំ កិស្ស ហេតុ អយោនិសោ ភូមិជ នវនីតស្ស អធិគមាយ ឯវមេវ ខោ ភូមិជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា មិច្ឆាទិដ្ឋិនោ ។បេ។ មិច្ឆាសមាធិនោ តេ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា... អាសញ្ច អនាសញ្ចេបិ ករិត្វា... នេវាសំនានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា



(៨០) ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយទឹកដោះខាប់ ស្វែងរកទឹកដោះខាប់ ត្រាច់ទៅកាន់ទីស្វែងរកទឹកដោះខាប់ ហើយយកទឹកមកស្រោចលើក្អមហើយវាយ ដោយឈើសម្រាប់វាយ បើទុកជាធ្វើនូវបំណង ហើយយកទឹកមកស្រោចលើក្អម ហើយវាយដោយឈើសម្រាប់វាយ ក៏មិនគួរដើម្បីបាននូវទឹកដោះខាប់ឡើយ បើទុកជាមិនធ្វើនូវបំណង... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកទឹកមកស្រោចលើក្អម ហើយវាយ ដោយឈើសម្រាប់វាយ ក៏មិនគួរដើម្បីបាននូវទឹកដោះខាប់ដែរ សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ម្នាលភូមិជៈ ព្រោះគន្លងមិនមែនដែលគួរឲ្យបានទឹកដោះខាប់ សេចក្ដីនេះមានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិខុស ។បេ។ មានសមាធិខុស សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ .. បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរ

ផលស្ស អធិគមាយ តំ កិស្ស ហេតុ អយោនិសោ ហិ ភូមិជ ផលស្ស អធិគមាយ ។

(៨១) សេយ្យថាបិ ភូមិជ បុរិសោ អគ្គិត្ថិកោ អគ្គិគវេសី អគ្គិបរិយេសនំ ចរមានោ អល្លំ កដ្ឋំ សស្នេហំ ឧត្តរារណឹ អាទាយ អភិមន្ថេយ្យ អា-សញ្ចេបិ ករិត្វា អល្លំ កដ្ឋំ សស្នេហំ ឧត្តរារណឹ អាទាយ អភិមន្ថេយ្យ អភព្វោ អគ្គិស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា ... អាសញ្ច អនាសញ្ចេបិ ក-រិត្វា ... នេវាសំ នានាសញ្ចេបិ ករិត្វា អល្លំ កដ្ឋំ សស្នេហំ ឧត្តរារណឹ អាទាយ អភិមន្ថេយ្យ អភព្វោ អគ្គិស្ស អធិគមាយ តំ កិស្ស ហេតុ អយោនិសោ ហិ ភូមិជ អគ្គិស្ស អធិគមាយ ឯវមេវ ខោ ភូមិជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា មិច្ឆាទិដ្ឋិនោ ។ បេ ។ មិច្ឆាសមាធិនោ តេ អាសញ្ចេបិ ករិត្វា



ដើម្បីត្រាស់ដឹងនូវផលផ្លែ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ដ៏ចម្រើន ព្រោះគ្មានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលឡើយ ។

(៨១) ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយភ្លើង ស្វែងរកភ្លើង ត្រាច់ទៅកាន់ទីស្វែងរកភ្លើង ក៏កាន់យកនូវឈើពិនួតខាងលើទៅកួតនឹងឈើស្រស់ ដែលនៅមានជ័រ បើទុកជាធ្វើនូវបំណង ហើយកាន់យកនូវឈើពិនួតខាងលើ ទៅកួតនឹងឈើស្រស់ដែលនៅមានជ័រ ក៏មិនគួរដើម្បីបាននូវភ្លើងឡើយ បើទុកជាមិនធ្វើនូវបំណង... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយកាន់យកនូវឈើពិនួតខាងលើ ទៅកួតនឹងឈើស្រស់ដែលនៅមានជ័រ ក៏មិនគួរដើម្បីបាននូវភ្លើងផង សេចក្តីនោះព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនងដែលនាំឲ្យបាននូវភ្លើង សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងពួកសមណៈឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិខុស ។បេ។ មានសមាធិខុស សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង

ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា... អាសញ្ច អនាសញ្ចេបិ ករិត្វា... នេវាសំ នានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ អភព្វា ផលស្ស អធិគមាយ តំ កិស្ស ហេតុ អយោនិ ហេសា ភូមិជ ផលស្ស អធិគមាយ ។

(៨២) យេ ច ខោ[១] កេចិ ភូមិជ សមណា វា ព្រាហ្មណា វា សម្មាទិដ្ឋិនោ[២] សម្មាសង្កប្បា សម្មាវាចា សម្មាកម្មន្តា សម្មាវាយាមា សម្មាសតី សម្មាសមាធិនោ តេ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ អាសញ្ច អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ នេវាសំ នានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ តំ កិស្ស ហេតុ យោនិ ហេសា ភូមិជ ផលស្ស អធិគមាយ ។

១ ឱ. ម. យេហិ ។ ២ ឱ. សម្មាទិដ្ឋី ។



ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ បើទុកជាមិនធ្វើនូវបំណង... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលឡើយ ។

(៨៦) ម្នាលភូមិជៈ លុះតែពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានព្យាយាមត្រូវ មានសតិត្រូវ មានសមាធិត្រូវ សមណព្រាហ្មណ៍ទាំងនោះ បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផល បើទុកជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលបាន ។

(៨៣) សេយ្យថាបិ ភូមិជ បុរិសោ តេលត្ថិកោ តេលគវេសី តេលបរិយេសនំ ចរមានោ តិលបិដ្ឋំ[១] ទោណិយា អាកិរិត្វា ឧទកេន បរិប្ផោសកំ បរិប្ផោសកំ បីឡេយ្យ អាសញ្ចេបិ ករិត្វា តិលបិដ្ឋំ ទោណិយា អាកិរិត្វា ឧទកេន បរិប្ផោសកំ បរិប្ផោសកំ បីឡេយ្យ ភព្វោ តេលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា... អាសញ្ច អនាសញ្ចេបិ ករិត្វា... នេវាសំ នានាសញ្ចេបិ ករិត្វា តិលបិដ្ឋំ ទោណិយា អាកិរិត្វា ឧទកេន បរិប្ផោសកំ បរិប្ផោសកំ បីឡេយ្យ ភព្វោ តេលស្ស អធិគមាយ តំ កិស្ស ហេតុ យោនិសោ ភូមិជ តេលស្ស អធិគមាយ ឯវមេវ ខោ ភូមិជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា សម្មាទិដ្ឋិនោ ។បេ។ សម្មាសមាធិនោ តេ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា... អាសញ្ច អនាសញ្ចេបិ ករិត្វា... នេវាសំ នានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ

១ ម. តិលបិដ្ឋំ ។



(៨៣) ម្នាលភូមិជៈ ដូចបុរសដែលត្រូវការដោយប្រេង ស្វែងរកប្រេង ត្រាច់ទៅកាន់ទីស្វែងរកប្រេង ក៏យកម្សៅល្ងមកដាក់ក្នុងស្នូក ហើយយកទឹកមកប្រោសព្រំ ច្របាច់រឿយ ៗ បើទុកជាធ្វើនូវបំណង ហើយយកម្សៅល្ងមកដាក់ក្នុងស្នូក ហើយយកទឹកមកប្រោសព្រំ ច្របាច់រឿយ ៗ ក៏គួរដើម្បីបាននូវប្រេង បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកម្សៅល្ងមកដាក់ក្នុងស្នូក ហើយយកទឹកមកប្រោសព្រំ ច្របាច់រឿយ ៗ ក៏គួរដើម្បីបាននូវប្រេងដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនងដែលនាំឲ្យបាននូវប្រេង សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យ ដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ ។បេ។ មានសមាធិត្រូវ ពួកសមណព្រាហ្មណ៍នោះ បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ គួរដើម្បីត្រាស់ដឹងនូវផល បើទុកជាមិនធ្វើនូវបំណង .. បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ

ភព្វា ផលស្ស អធិគមាយ តំ កិស្ស ហេតុ យោនិ ហេសា ភូមិជ ផលស្ស អធិគមាយ ។

(៤៦) សេយ្យថាបិ ភូមិជ បុរិសោ ខីរត្ថិកោ ខីរគវេសី ខីរបរិយេសនំ ចរមានោ គាវឹ តរុណវច្ឆំ ថនតោ អាវិញ្ឆេយ្យ អាសញ្ចេបិ ករិត្វា គាវឹ តរុណវច្ឆំ ថនតោ អាវិញ្ឆេយ្យ ភព្វោ ខីរស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា អាសញ្ច អនាសញ្ចេបិ ករិត្វា នេវាសំនានាសញ្ចេបិ ករិត្វា គាវឹ តរុណវច្ឆំ ថនតោ អាវិញ្ឆេយ្យ ភព្វោ ខីរស្ស អធិគមាយ តំ កិស្ស ហេតុ យោនិ ហេសា ភូមិជ ខីរស្ស អធិគមាយ ឯវមេវ ខោ ភូមិជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា សម្មាទិដ្ឋិនោ ។ បេ ។ សម្មាសមាធិនោ តេ អាសញ្ចេបិ ករិត្វា ... អនាសញ្ចេបិ ករិត្វា ... នេវាសំនានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ តំ កិស្ស ហេតុ យោនិ ហេសា ភូមិជ ផលស្ស អធិគមាយ



ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ម្នាលភូមិជៈ ព្រោះមានទំនងដែលនាំឲ្យត្រាស់ដឹងនូវផល ។

(៤៦) ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយទឹកដោះស្រស់ ស្វែងរកទឹកដោះស្រស់ ត្រាច់ទៅកាន់ទីស្វែងរកទឹកដោះស្រស់ ក៏ចាប់មួលដោះមេគោដែលមានកូនខ្ចី បើធ្វើនូវបំណង ហើយចាប់មួលដោះមេគោមានកូនខ្ចី ក៏គួរដើម្បីបាននូវទឹកដោះស្រស់ បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងផង មិនធ្វើនូវបំណងផង ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយចាប់មួលដោះមេគោដែលមានកូនខ្ចី ក៏គួរដើម្បីបាននូវទឹកដោះស្រស់ដែរ សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ម្នាលភូមិជៈ ព្រោះមានទំនងដែលនាំឲ្យបាននូវទឹកដោះស្រស់ សេចក្ដីនេះមានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងនោះគឺសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ ។ បេ ។ មានសមាធិត្រូវ សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងផង មិនធ្វើនូវបំណងផង ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ម្នាលភូមិជៈ ព្រោះមានទំនងគួរឲ្យត្រាស់ដឹងនូវផលបាន ។

(៨៩) សេយ្យថាបិ ភូមិជ បុរិសោ នវនីតត្ថិកោ នវនីតគវេសី នវនីតបរិយេសនំ ចរមានោ ទធឹ កលសេ អាសិញ្ចិត្វា មន្ថេន អាវិញ្ឆេយ្យ អាសញ្ចេបិ ករិត្វា ទធឹ កលសេ អាសិញ្ចិត្វា មន្ថេន អាវិញ្ឆេយ្យ ភព្វោ នវនីតស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា... អាសញ្ច អនាសញ្ចេបិ ករិត្វា... នេវាសំនានាសញ្ចេបិ ករិត្វា ទធឹ កលសេ អាសិញ្ចិត្វា មន្ថេន អាវិញ្ឆេយ្យ ភព្វោ នវនីតស្ស អធិគមាយ តំ កិស្ស ហេតុ យោនិសោ ភូមិជ នវនីតស្ស អធិគមាយ ឯវមេវ ខោ ភូមិជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា សម្មាទិដ្ឋិនោ ។ បេ ។ សម្មាសមាធិនោ តេ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា... អាសញ្ច អនាសញ្ចេបិ ករិត្វា... នេវាសំនានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ តំ កិស្ស ហេតុ យោនិសោ ភូមិជ ផលស្ស អធិគមាយ ។



(៨៩) ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយទឹកដោះខាប់ ស្វែងរកទឹកដោះខាប់ ត្រាច់ទៅកាន់ទីស្វែងរកទឹកដោះខាប់ ហើយយកទឹកដោះជូរមកស្រោចលើកក់ ហើយវៃដោយឈើសម្រាប់វៃ បើទុកជាធ្វើនូវបំណង ហើយយកទឹកដោះជូរមកស្រោចលើកក់ រួចវៃដោយឈើសម្រាប់វៃ ក៏គួរដើម្បីបាននូវទឹកដោះខាប់ បើទុកជាមិនធ្វើនូវបំណង... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកទឹកដោះជូរមកស្រោចលើកក់ ហើយវៃដោយឈើសម្រាប់វៃ ក៏គួរដើម្បីបាននូវទឹកដោះខាប់ដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនងដែលនាំឲ្យបាននូវទឹកដោះខាប់ សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ ។ បេ ។ មានសមាធិត្រូវ សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផល បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ...បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលបាន ។

(៤៦) សេយ្យថាបិ ភូមិជ បុរិសោ អគ្គិត្ថិកោ អគ្គិគវេសី អគ្គិបរិយេសនំ ចរមានោ សុក្ខំ កដ្ឋំ កោឡាបំ ឧត្តរារណឹ អាទាយ អភិមន្ថេយ្យ ភព្វោ អគ្គិស្ស អភិនិព្វត្តាយ អាសញ្ចេបិ ករិត្វា... អនាសញ្ចេបិ ករិត្វា... អាសញ្ច អនាសញ្ចេបិ ករិត្វា... នេវាសំនានាសញ្ចេបិ ករិត្វា សុក្ខំ កដ្ឋំ កោឡាបំ ឧត្តរារណឹ អាទាយ អភិមន្ថេយ្យ ភព្វោ អគ្គិស្ស អភិនិព្វត្តាយ តំ កិស្ស ហេតុ យោនិសោ ភូមិជ អគ្គិស្ស អភិនិព្វត្តាយ។ ឯវមេវ ខោ ភូមិជ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា សម្មាទិដ្ឋិនោ សម្មាសង្កប្បា ។ បេ ។ សម្មាសមាធិនោ តេ អាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ អាសញ្ច អនាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា ផលស្ស អធិគមាយ នេវាសំនានាសញ្ចេបិ ករិត្វា ព្រហ្មចរិយំ ចរន្តិ ភព្វា



(៤៦) ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយភ្លើង ស្វែងរកភ្លើង ត្រាច់ទៅកាន់ទីស្វែងរកភ្លើង ហើយកាន់យកឈើពំនួតខាងលើ ទៅកួតនឹងឈើស្ងួតខ្លះ ក៏គួរដើម្បីបានឡើងភ្លើង បើទុកជាធ្វើនូវបំណង ... បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកឈើពំនួតខាងលើ ទៅកួតនឹងឈើស្ងួតខ្លះ ក៏គួរដើម្បីបានឡើងភ្លើងដែរ សេចក្ដីនោះ ព្រោះហេតុដូចម្ដេច ម្នាលភូមិជៈ ព្រោះមានចំណង ដែលនាំឲ្យបានឡើងភ្លើង សេចក្ដីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យ ដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ មានសេចក្ដីត្រិះរិះត្រូវ ។ បេ ។ មានសមាធិត្រូវ សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹង នូវផល បើទុកជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរ

ផលស្ស អធិគមាយ តំ កិស្ស ហេតុ យោនិ ហេសា ភូមិជ ផលស្ស អធិគមាយ ។

(៨៧) សចេ តំ[១] ភូមិជ ជយសេនស្ស រាជកុមារស្ស ឥមា ចតស្សោ ឧបមា បដិភាសេយ្យុំ អនច្ឆរិយំ តេ ជយសេនោ រាជកុមារោ បសីទេយ្យ បសន្នោ ច តេ បសន្នាការំ ករេយ្យាតិ ។ កុតោ បន មំ ភន្តេ ជយសេនស្ស រាជកុមារស្ស ឥមា ចតស្សោ ឧបមា បដិភាសិស្សន្តិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា សេយ្យថាបិ ភគវន្តំ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា ភូមិជោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ភូមិជសុត្តំ ឆដ្ឋំ និដ្ឋិតំ

១ ម. សចេ តេតំ ។ អថ បន គន្ថិបាឋោ យុត្តតរោ ។



ដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលបាន ។

(៨៧) ម្នាលភូមិជៈ បើអ្នកពោលសំដែងនូវឧបមាទាំង ៤ នេះ ដល់ជយសេនរាជកុមារបាន សេចក្តីអស្ចារ្យរបស់អ្នក គឺនឹងកើតមាន ឯជយសេនរាជកុមារ ក៏មុខជាជ្រះថ្លានឹងអ្នក លុះជ្រះថ្លាហើយ នឹងធ្វើនូវអាការជ្រះថ្លាដល់អ្នកទៀត ។ បពិត្រព្រះអង្គដ៏ចំរើន ចុះខ្ញុំព្រះអង្គ អាចនឹងសំដែងដល់ជយសេនរាជកុមារ នូវសេចក្តីឧបមាទាំង ៤ នេះ ដែលជាអស្ចារ្យ ខ្ញុំព្រះអង្គមិនធ្លាប់ស្តាប់មកក្នុងកាលមុនសោះ ដូចជាព្រះមានព្រះភាគ អំពីណាបាន ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ព្រះភូមិជៈមានអាយុ ក៏មានសេចក្តីត្រេកអរ រីករាយនឹងភាសិត នៃព្រះមានព្រះភាគ ។

ចប់ ភូមិជសូត្រ ទី ៦ ។

## សត្តមំ អនុរុទ្ធសុត្តំ

(៨៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ បញ្ចកង្គោ ថបតិ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេនាយស្មា អនុរុទ្ធោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន អាយស្មតោ អនុរុទ្ធស្ស បាទេ សិរសា វន្ទាហិ បញ្ចកង្គោ ភន្តេ ថបតិ អាយស្មតោ អនុរុទ្ធស្ស បាទេ សិរសា វន្ទតីតិ(១) ឯវញ្ច វទេហិ អធិវាសេតុ កិរ ភន្តេ អាយស្មា អនុរុទ្ធោ បញ្ចកង្គស្ស ថបតិស្ស ស្វាតនាយ អត្តចតុត្ថោ ភត្តំ យេន ច កិរ ភន្តេ អាយស្មា អនុរុទ្ធោ បគេវតរំ អាគច្ឆេយ្យ បញ្ចកង្គោ ភន្តេ(២) ថបតិ ពហុកិច្ចោ ពហុករណីយោ រាជករណីយេនាតិ ។

១ ឱ. ឥតិសទ្ទោ នត្ថិ ។ ២ ឱ. ភន្តេតិ ន ទិស្សតិ ។

## អនុរុទ្ធសូត្រ ទី ៧

(៨៨) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចឥរិយាបថ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង បញ្ចកង្គថបតិ(១) បានហៅបុរសម្នាក់មកថា នែបុរសដ៏ចំរើន អ្នកចូរមក ចូរអ្នកទៅរកព្រះអនុរុទ្ធមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំបាទានៃព្រះអនុរុទ្ធមានអាយុ ដោយត្បូង តាមពាក្យរបស់យើងថា បពិត្រលោកដ៏ចំរើន បញ្ចកង្គថបតិ សូមថ្វាយបង្គំបាទា នៃព្រះអនុរុទ្ធមានអាយុ ដោយត្បូង រួចហើយអ្នកចូរពោលយ៉ាងនេះទៀតថា បពិត្រលោកដ៏ចំរើន សូមព្រះអនុរុទ្ធមានអាយុ មានខ្លួនជាគំរប់ ៤ ទទួលភត្តរបស់បញ្ចកង្គថបតិ ដើម្បីឆាន់ក្នុងថ្ងៃស្អែក បពិត្រលោកដ៏ចំរើន សូមព្រះអនុរុទ្ធមានអាយុ ប្រញាប់និមន្តមកអំពីព្រឹកឲ្យបាន បពិត្រលោកដ៏ចំរើន ព្រោះថាបញ្ចកង្គថបតិ គាត់មានកិច្ចច្រើន មានការងារច្រើន ដោយព្រះរាជកិច្ច ។

១ ជាងឈើប្រកបដោយអង្គ ៥ គឺកាំបិតព្រា ១ ពូថៅ ១ ពន្លាក ១ អន្លុង ១ ស្តេកបន្ទាត់ ១ ។ អដ្ឋកថា ។

ឯវំ ភន្តេតិ ខោ សោ បុរិសោ[១] បញ្ចកង្គស្ស ថបតិស្ស បដិស្សុត្វា យេនាយស្មា អនុរុទ្ធោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អនុរុទ្ធំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច បញ្ចកង្គោ ភន្តេ ថបតិ អាយស្មតោ អនុរុទ្ធស្ស បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ អធិវាសេតុ កិរ ភន្តេ អាយស្មា អនុរុទ្ធោ បញ្ចកង្គស្ស ថបតិស្ស ស្វាតនាយ អត្តចតុត្ថោ ភត្តំ យេន ច កិរ ភន្តេ អាយស្មា អនុរុទ្ធោ បគេវតរំ អាគច្ឆេយ្យ បញ្ចកង្គោ ភន្តេ ថបតិ ពហុកិច្ចោ ពហុករណីយោ រាជករណីយេនាតិ ។ អធិវាសេសិ ខោ អាយស្មា អនុរុទ្ធោ តុណ្ហីភាវេន ។

១ ម. សោ បុរិសោតិ ទិស្សតិ ។



បុរសនោះ ក៏ទទួលពាក្យបញ្ចកង្គថបតីថា បាទលោកម្ចាស់ ហើយក៏ចូលទៅរកព្រះអនុរុទ្ធមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអនុរុទ្ធមានអាយុ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះបុរសនោះអង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រលោកដ៏ចម្រើន បញ្ចកង្គថបតិ សូមថ្វាយបង្គំបាទ នៃព្រះអនុរុទ្ធមានអាយុ ដោយត្បូង ហើយពោលយ៉ាងនេះទៀតថា បពិត្រលោកដ៏ចម្រើន សូមព្រះអនុរុទ្ធមានអាយុ មានខ្លួនជាគំរប់ ៤ ទទួលភត្តរបស់បញ្ចកង្គថបតិ ដើម្បីឆាន់ក្នុងថ្ងៃស្អែក បពិត្រលោកដ៏ចម្រើន សូមព្រះអនុរុទ្ធមានអាយុ ប្រញាប់និមន្តទៅអំពីព្រឹកឲ្យបាន បពិត្រលោកដ៏ចម្រើន ព្រោះថា បញ្ចកង្គថបតិ គាត់មានកិច្ចច្រើន មានការងារច្រើន ដោយព្រះរាជកិច្ច ។ ព្រះអនុរុទ្ធមានអាយុ ក៏ទទួលនិមន្ត ដោយតុណ្ហីភាព ។

(៨៤) អថខោ អាយស្មា អនុរុទ្ធោ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន បញ្ចកង្គស្ស ថបតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ បញ្ចកង្គោ ថបតិ អាយស្មន្តំ អនុរុទ្ធំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ បញ្ចកង្គោ ថបតិ អាយស្មន្តំ អនុរុទ្ធំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បញ្ចកង្គោ ថបតិ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច ឥធ មំ ភន្តេ ថេរា ភិក្ខូ ឧបសង្កមិត្វា ឯវមាហំសុ អប្បមាណំ គហបតិ ចេតោវិមុត្តឹ ភាវេហីតិ ឯកច្ចេ ថេរា ឯវមាហំសុ មហគ្គតំ គហបតិ ចេតោវិមុត្តឹ ភាវេហីតិ យា ចាយំ ភន្តេ អប្បមាណា ចេតោវិមុត្តិ យា ច មហគ្គតា ចេតោវិមុត្តិ ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ឧទាហុ ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។ តេនហិ គហបតិ



(៨៤) គ្រានោះ ព្រះអនុរុទ្ធមានអាយុ លុះកន្លងរាត្រីនោះទៅហើយ ក៏ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់លំនៅរបស់បញ្ចកង្គថបតិ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលទុក ។ លំដាប់នោះ បញ្ចកង្គថបតិ ញុំាងព្រះអនុរុទ្ធមានអាយុ ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារ ដ៏ឧត្តម ដោយដៃខ្លួន ត្រាតែព្រះអនុរុទ្ធហាមឃាត់ ។ ឯបញ្ចកង្គថបតិ កំណត់ដឹងថា ព្រះអនុរុទ្ធមានអាយុឆាន់រួចហើយ លែងលូកព្រះហស្ត ទៅក្នុងបាត្រទៀតហើយ ក៏កាន់យកនូវអាសនៈមួយដ៏ទាប ហើយអង្គុយក្នុងទីសមគួរ ។ លុះបញ្ចកង្គថបតិ អង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះអនុរុទ្ធមានអាយុដូច្នេះថា បពិត្រលោកដ៏ចំរើន ពួកភិក្ខុជាថេរៈ ក្នុងសាសនានេះ ចូលមករកខ្ញុំហើយពោលយ៉ាងនេះថា ម្នាលគហបតី អ្នកចូរចំរើននូវអប្បមាណចេតោវិមុត្តិទៅ ព្រះថេរៈពួកខ្លះពោលយ៉ាងនេះថា ម្នាលគហបតិ អ្នកចូរចំរើននូវមហគ្គតចេតោវិមុត្តិទៅ បពិត្រលោកដ៏ចំរើន ចុះអប្បមាណចេតោវិមុត្តិណាក្តី មហគ្គតចេតោវិមុត្តិណាក្តី ធម៌ទាំងពីរនេះ មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈទេ ។ ម្នាលគហបតី បើដូច្នោះ

តញ្ញេវេត្ថ[១] បដិភាតុ អបណ្ណកន្តេ ឥតោ ភវិស្សតីតិ ។ មយ្ហំ ខោ ភន្តេ ឯវំ ហោតិ យា ចាយំ អប្បមាណា ចេតោវិមុត្តិ យា ច មហគ្គតា ចេតោវិមុត្តិ ឥមេ ធម្មា ឯកត្ថា ព្យញ្ជនមេវ នានន្តិ ។

(៩០) យា ចាយំ គហបតិ អប្បមាណា ចេតោវិមុត្តិ យា ច មហគ្គតា ចេតោវិមុត្តិ ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច តទមិនាបេតំ គហបតិ បរិយាយេន វេទិតព្វំ យថា ឥមេ[២] ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ។ កតមា ច គហបតិ អប្បមាណា ចេតោវិមុត្តិ ។ ឥធ គហបតិ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។

១ ឱ. ម. តំយេវេត្ថ ។ ២ ឱ. ម. តំយេវេត្ថ ។



អ្នកចូរបំភ្លឺនូវសេចក្តីនោះ ក្នុងប្រស្នានុ៎ះមកមើល បើអ្នក (សំដែង) នឹងមិនមានសេចក្តីខុសក្នុងប្រស្នានេះឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំមានសេចក្តីយល់ចិត្តយ៉ាងនេះថា អប្បមាណចេតោវិមុត្តិណាក្តី មហគ្គតចេតោវិមុត្តិណាក្តី ធម៌ទាំងពីរនេះ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។

(៩០) ម្នាលគហបតី អប្បមាណចេតោវិមុត្តិណាក្តី មហគ្គតចេតោវិមុត្តិណាក្តី ធម៌ទាំងពីរនេះ មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ម្នាលគហបតី សេចក្តីនោះ អ្នកគប្បីដឹងដោយបរិយាយនេះចុះ ថា តាមពិត ធម៌ទាំងពីរនេះ មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។ ម្នាលគហបតី អប្បមាណចេតោវិមុត្តិ តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ផ្សាយទៅកាន់ទិស ទី ២ ទី ៣ ទី ៤ ដូចគ្នា សូម្បីក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ក៏ជាអ្នកមានចិត្តប្រកបដោយមេត្តា ជាចិត្តដ៏ទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនឯងទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ។

ករុណាសហគតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យា-បជ្ឈេន ផរិត្វា វិហរតិ អយំ វុច្ចតិ គហបតិ អប្បមាណា ចេតោវិមុត្តិ ។

(៤១) កតមា ច គហបតិ មហគ្គតា ចេតោ-វិមុត្តិ ។ ឥធ គហបតិ ភិក្ខុ យាវតា ឯកំ រុក្ខមូលំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ វុច្ចតិ គហបតិ មហគ្គតា ចេតោវិមុត្តិ ។ ឥធ បន[1] គហបតិ ភិក្ខុ យាវតា ទ្វេ វា តីណិ វា រុក្ខ-មូលានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ

១ ឱ. ន ទិស្សតិ ។



មានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ផ្សាយទៅកាន់ទិសទី ២ ទី ៣ ទី ៤ ដូចគ្នា សូម្បីក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ក៏ជាអ្នកមានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅ កាន់សត្វលោកទាំងពួង ដោយការយកខ្លួនឯងទៅប្រៀបផ្ទឹម នឹងសត្វទាំងពួង ក្នុងទីទាំងពួង ម្នាលគហបតី នេះហៅថា អប្បមាណចេតោវិមុត្តិ ។

(៤១) ម្នាលគហបតី ចុះមហគ្គតចេតោវិមុត្តិ តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់ រុក្ខមូល ១[1] ជាកំណត់ ថាជាមហគ្គតៈ គឺទីដែលត្រូវយកចិត្តទុកដាក់ ម្នាលគហបតី នេះលោក ហៅថា មហគ្គតចេតោវិមុត្តិ ។ ម្នាលគហបតី មួយទៀត ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់រុក្ខមូល ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី

១ ក្នុងវេលាថ្ងៃត្រង់ ម្លប់ដើមឈើមានកំណត់ធំទូលាយត្រឹមណា ទីត្រឹមនោះ ហៅថារុក្ខមូល ១ យោគីកំណត់រុក្ខមូល ១ នោះដោយកសិណនិមិត្តហើយ ពិភាវនាគ្រាន់តែកើតមហគ្គតជ្ឈានឡើង ក្នុងកសិណនិមិត្តនោះ ។ ឯមហគ្គតជ្ឈាន គឺរូបាវចរជ្ឈាន និងអរូបាវចរជ្ឈាន ។

អយំ(១) វុច្ចតិ គហបតិ មហគ្គតា ចេតោវិមុត្តិ ។ ឥធ គហបតិ ភិក្ខុ យាវតា ឯកំ គាមក្ខេត្តំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ វុច្ចតិ គហបតិ មហគ្គតា ចេតោវិមុត្តិ ។ ឥធ បន គហបតិ ភិក្ខុ យាវតា ទ្វេ វា តីណិ វា គាម-ក្ខេត្តានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ វុច្ចតិ គហបតិ មហគ្គតា ចេតោវិមុត្តិ ។ ឥធ គហបតិ ភិក្ខុ យាវតា ឯកំ មហារជ្ជំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ វុច្ចតិ គហបតិ មហគ្គតា ចេតោវិមុត្តិ ។ ឥធ បន គហបតិ ភិក្ខុ យាវតា ទ្វេ វា តីណិ វា មហារជ្ជានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ វុច្ចតិ គហបតិ មហគ្គ-តា ចេតោវិមុត្តិ ។ ឥធ បន គហបតិ ភិក្ខុ

១ ម. អយម្បិ ។



នេះលោកហៅថា មហគ្គតាចេតោវិមុត្តិដែរ ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្តបង្អោនចិត្តទៅកាន់គាមក្ខេត្ត ១ ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី នេះហៅថា មហគ្គតាចេតោវិមុត្តិដែរ ។ ម្នាលគហបតី មួយទៀត ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់គាមក្ខេត្ត ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី នេះហៅថា មហគ្គតាចេតោវិមុត្តិដែរ ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ១ ម្នាលគហបតី នេះហៅថា មហគ្គតាចេតោវិមុត្តិដែរ ។ ម្នាលគហបតី មួយទៀត ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី នេះហៅថា មហគ្គតាចេតោ-វិមុត្តិដែរ ។ ម្នាលគហបតី មួយទៀត ភិក្ខុក្នុងសាសនានេះ

យាវតា សមុទ្ទបរិយន្តំ បឋវឹ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ វុច្ចតិ គហបតិ មហគ្គតា ចេតោវិមុត្តិ ។ ឥមិនា ខោ ឯតំ គហបតិ បរិយាយេន វេទិតព្វំ យថា ឥមេ ធម្មា នានត្ថា ចេវ នានាព្យញ្ជនា ច ។

(៤៦) ចតស្សោ ខោ ឥមា គហបតិ ភវូបបត្តិយោ[១] ។ កតមា ចតស្សោ ។ ឥធ គហបតិ ឯកច្ចោ បរិត្តាភាតិ[២] ផរិត្វា អធិមុច្ចិត្វា វិហរតិ ។ សោ កាយស្ស ភេទា បរម្មរណា បរិត្តាភានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ ឥធ បន គហបតិ ឯកច្ចោ អប្បមាណាភាតិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ។ សោ កាយស្ស ភេទា

១ ម. ភវុប្បត្តិយោ ។ ២ ម. ម. បរិត្តាភាតិ ។



ផ្សាយចិត្ត បង្អោនចិត្តទៅ កាន់សមុទ្រជាទីបំផុត ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី នេះហៅថា មហគ្គតាចេតោវិមុត្តិដែរ ។ ម្នាលគហបតី សេចក្តីនេះឯង ដែលអ្នកគប្បីដឹងដោយបរិយាយនេះថា ធម៌ទាំងពីរនេះឯង មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។

(៤៦) ម្នាលគហបតី កិរិយាកើតក្នុងភពនេះមាន ៤ យ៉ាង ។ ៤ យ៉ាង តើដូចម្តេច ។ ម្នាលគហបតី បុគ្គលខ្លះក្នុងលោកនេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់បរិត្តាភផ្សាន[១] ។ បុគ្គលនោះ លុះខន្ធកាយបែកធ្លាយទៅខាងមុខបន្ទាប់អំពីមរណៈ គឺទៅកើតជាមួយនឹងពួកបរិត្តាភទេវតា[២] ។ ម្នាលគហបតី មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់អប្បមាណាភផ្សាន[៣] ។ បុគ្គលនោះ លុះខន្ធកាយបែកធ្លាយ

១ ឈានដែលជាហេតុនាំឲ្យកើតក្នុងបរិត្តាភព្រហ្មលោក បានដល់ទុតិយជ្ឈានយ៉ាងខាប ។ ឯក្នុងប្រយោគនេះបានសេចក្តីថា ចំរើនបរិត្តកជ្ឈានប៉ុណ្ណោះឯង ។ ២ ទេវតាមានរស្មីតិចឬទេវតាឋិតនៅក្នុងបរិត្តាភព្រហ្មលោក ។ ៣ ឈានដែលជាហេតុនាំឲ្យកើត ក្នុងអប្បមាណាភព្រហ្មលោក បានដល់ទុតិយជ្ឈានយ៉ាងកណ្តាល ។

បរម្មរណា អប្បមាណាភានំ ទេវានំ សហព្យតំ
ឧបបជ្ជតិ ។ ឥធ គហបតិ ឯកច្ចោ សង្កិលិដ្ឋាភ-
ន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ។ សោ កាយស្ស
ភេទា បរម្មរណា សង្កិលិដ្ឋាភានំ ទេវានំ សហព្យតំ
ឧបបជ្ជតិ ។ ឥធ បន គហបតិ ឯកច្ចោ បរិសុទ្ធា-
ភន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ។ សោ កាយស្ស



ទៅខាងមុខ បន្ទាប់អំពីមរណៈ ក៏ទៅកើតជាមួយ នឹងពួកអប្បមាណាភ-
ទេវតា[1] ។ ម្នាលគហបតី បុគ្គលខ្លះ ក្នុងលោកនេះ ផ្សាយចិត្ត
បង្អោនចិត្តទៅកាន់សង្កិលិដ្ឋាភកសិណ ។ បុគ្គលនោះ លុះធាតុកាយបែក
ធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏ទៅកើតជាមួយនឹងពួកសង្កិលិដ្ឋាភ-
ទេវតា[2] ។ ម្នាលគហបតី មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ផ្សាយ
ចិត្ត បង្អោនចិត្តទៅកាន់បរិសុទ្ធាភកសិណ ។ បុគ្គលនោះ លុះធាតុកាយ

១ ទេវតាមានពន្លឺប្រមាណមិនបាន ឬទេវតាដែលនៅក្នុងអប្បមាណាភព្រហ្មលោក ។
២ ទេវតាមានពន្លឺស្រអាប់ ។

ភេទា បរម្មរណា បរិសុទ្ធាភានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ ឥមា ខោ គហបតិ ចតស្សោ ភវូបបត្តិយោ ។

(៤៣) ហោតិ ខោ សោ គហបតិ សមយោ យំ តា ទេវតា ឯកជ្ឈំ សន្និបតន្តិ តាសំ ឯកជ្ឈំ សន្និបតិតានំ វណ្ណនានត្តំ ហិ ខោ បញ្ញាយតិ នោ ច អាភានានត្តំ ។ សេយ្យថាបិ គហបតិ បុរិសោ



ប៉ែកឆ្ងាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏ទៅកើតជាមួយ នឹងពួកបរិសុទ្ធាភទេវតា(១) ។ ម្នាលគហបតី កិរិយាកើតក្នុងភព មាន ៤ យ៉ាងនេះឯង ។

(៤៣) ម្នាលគហបតី មានសម័យដែលពួកទេវតាប្រជុំគ្នា ក្នុងទីមួយ ឯពួកទេវតាដែលប្រជុំគ្នា ក្នុងទីមួយនោះ ប្រាកដជាមានសម្បុរផ្សេងគ្នា តែមិនមែនមានពន្លឺផ្សេងគ្នាទេ ។ ម្នាលគហបតី ដូចបុរស

---

១ ទេវតាមានពន្លឺថ្លា ។ ពួកបរិត្តាភទេវតា (ទេវតាមានពន្លឺតិច) មានពន្លឺស្រអាប់ខ្លះ មានពន្លឺថ្លាខ្លះ យោគីណាផ្សាយកសិណ ក្នុងកសិណប្រមាណប៉ុនចង្អេរក្តី ប៉ុនថាសក្តី ហើយញ៉ាំងសមាបត្តិឲ្យកើតបានស្ទាត់ជំនាញ ដោយអាការទាំង ៥ តែមិនបរិសុទ្ធដោយបច្ចនីកធម៌ (ធម៌ជាសត្រូវ) យោគីនោះប្រើប្រាស់សមាបត្តិដែល[illegible] ឋិតនៅក្នុងឈានដែលមិនស្ទាត់ស្ទាញ លុះធ្វើមរណកាលទៅ ក៏ទៅកើតជាបរិត្តាភទេវតា ពន្លឺរបស់ទេវតានោះតិចផង ស្រអាប់ផង ។ យោគីណា ស្ទាត់ស្ទាញដោយអាការទាំង ៥ ហើយបរិសុទ្ធដោយបច្ចនីកធម៌ ប្រើប្រាស់សមាបត្តិដ៏បរិសុទ្ធ ឋិតនៅក្នុងឈានដែលស្ទាត់ស្ទាញ លុះធ្វើមរណកាលទៅ ក៏ទៅកើតជាបរិត្តាភទេវតា ពន្លឺរបស់ទេវតានោះតិចតែថ្លា ។ អប្បមាណាភទេវតា (ទេវតាមានពន្លឺប្រមាណមិនបាន) មានពន្លឺស្រអាប់ ១ ពួក មានពន្លឺថ្លា ១ ពួក សេចក្ដីទូទៅគ្នានឹងខាងដើម ប្លែកគ្នាតែត្រង់ផ្សាយកសិណ ក្នុងកសិណដែលផ្សាយប្រមាណមិនបានប៉ុណ្ណោះ ។

សម្ពហុលានិ តេលប្បទីបានិ ឯកំ ឃរំ បវេសេយ្យ តេសំ ឯកំ ឃរំ បវេសិតានំ អច្ចិនានត្តំ ហិ ខោ បញ្ញាយេថ នោ ច អាភានានត្តំ ឯវមេវ ខោ គហបតិ ហោតិ ខោ[១] សោ សមយោ យំ តា ទេវតា ឯកជ្ឈំ សន្និបតន្តិ តាសំ ឯកជ្ឈំ សន្និបតិតានំ វណ្ណនានត្តំ ហិ ខោ បញ្ញាយតិ នោ ច អាភានានត្តំ ។

(៤៦) ហោតិ ខោ សោ គហបតិ សមយោ យំ តា ទេវតា តតោ វិបក្កមន្តិ តាសំ តតោ វិបក្កមន្តីនំ វណ្ណនានត្តញ្ចេវ បញ្ញាយតិ អាភានានត្តញ្ច ។ សេយ្យថាបិ គហបតិ បុរិសោ តានិ សម្ពហុលានិ តេលប្បទីបានិ តម្ហា ឃរា នីហរេយ្យ តេសំ តតោ នីហតានំ[២] អច្ចិនានត្តញ្ចេវ បញ្ញាយេថ អាភានានត្តញ្ច

១. ភេសត្ថោ ខន្តុំ ។ ២ នីហរិតានន្តិ ឆាយា មញ្ញេ ការេយ្យ ។



ដែលញ៉ាំងប្រទីបប្រេងជាច្រើន ឲ្យចូលទៅកាន់ផ្ទះមួយ ឯប្រទីបប្រេងទាំងនោះ ដែលចូលទៅកាន់ផ្ទះមួយ ប្រាកដជាមានអណ្តាតភ្លើងផ្សេងគ្នា តែមិនមែនមានពន្លឺផ្សេងគ្នាទេ មានឧបមាយ៉ាងណាមិញ ម្នាលគហបតី មានឧបមេយ្យដូចយ៉ាងសម័យ ដែលពួកទេវតាប្រជុំគ្នាក្នុងទីមួយ ឯពួកទេវតាដែលប្រជុំគ្នាក្នុងទីមួយនោះ ប្រាកដជាមានសម្បុរផ្សេងគ្នា តែមិនមែនមានពន្លឺផ្សេងគ្នាទេ ។

(៤៦) ម្នាលគហបតី សម័យ ដែលពួកទេវតាចេញទៅអំពីទីប្រជុំនោះ ឯពួកទេវតានោះ កាលដែលចេញទៅ អំពីទីប្រជុំនោះ ប្រាកដជាមានសម្បុរក៏ផ្សេងគ្នា មានពន្លឺក៏ផ្សេងគ្នា ។ ម្នាលគហបតី ដូចបុរសនាំយកនូវប្រទីបប្រេង ដ៏ច្រើនទាំងនោះ ចេញអំពីផ្ទះនោះ ឯប្រទីបប្រេងទាំងនោះ កាលដែលគេនាំចេញអំពីផ្ទះនោះ ប្រាកដជាមានអណ្តាតភ្លើងផ្សេងគ្នា មានពន្លឺក៏ផ្សេងគ្នា មានឧបមាយ៉ាងណាមិញ

ឯវមេវ ខោ គហបតិ ហោតិ ខោ សោ សមយោ យំ តា ទេវតា តតោ វិបក្កមន្តិ តាសំ តតោ វិបក្កមន្តីនំ វណ្ណនានត្តញ្ចេវ បញ្ញាយតិ អាភានានត្តញ្ច ។

(៨៥) ន ខោ គហបតិ តាសំ ទេវតានំ ឯវំ ហោតិ ឥទំ អម្ហាកំ និច្ចន្តិ វា ធុវន្តិ វា សស្សតន្តិ វា ។ អបិច យត្ថ យត្ថ តា[1] ទេវតា អភិនិវិសន្តិ តត្ថ តត្ថ តា ទេវតា អភិរមន្តិ ។ សេយ្យថាបិ គហបតិ មក្ខិកានំ កាជេន វា បិដកេន វា ហរិយមានានំ ន ឯវំ ហោតិ ឥទំ អម្ហាកំ និច្ចន្តិ វា ធុវន្តិ វា សស្សតន្តិ វា ។ អបិច យត្ថ យត្ថ តា មក្ខិកា អភិនិវិសន្តិ តត្ថ តត្ថ តា មក្ខិកា អភិរមន្តិ ឯវមេវ ខោ គហបតិ តាសំ ទេវតានំ ន ឯវំ ហោតិ ឥទំ អម្ហាកំ និច្ចន្តិ វា ធុវន្តិ វា សស្សតន្តិ វា ។ អបិច យត្ថ យត្ថ តា ទេវតា អភិនិវិសន្តិ តត្ថ តត្ថ តា ទេវតា អភិរមន្តិ ។

១ ឱ, តា ។



ម្នាលគហបតី មានឧបមេយ្យដូចយ៉ាងសម័យដែលពួកទេវតា ចេញទៅអំពីទីប្រជុំនោះ ឯពួកទេវតានោះ កាលដែលចេញទៅអំពីទីប្រជុំនោះ ប្រាកដជាមានសម្បុរផ្សេងគ្នា មានពន្លឺក៏ផ្សេងគ្នា ។

(៨៥) ម្នាលគហបតី ឯទេវតាទាំងនោះ មិនមានសេចក្ដីត្រិះរិះយ៉ាងនេះថា ទីរបស់យើងនេះ ទៀងទាត់ ឋិតថេរមាំមួន ដូច្នេះឡើយ ។ មួយទៀត ពួកទេវតាណា នៅអាស្រ័យក្នុងទីណា ៗ ទេវតាទាំងនោះ រមែងត្រេកអរ ក្នុងទីនោះ ៗ ឯង ។ ម្នាលគហបតី ដូចហ្វូងរុយ ដែលគេនាំទៅដោយអម្រែកក្ដី ដោយកញ្ជើក្ដី តែងមិនមានសេចក្ដីត្រិះរិះយ៉ាងនេះថា ទីរបស់យើងនេះ ទៀងទាត់ ឋិតថេរមាំមួន ដូច្នេះឡើយ ។ មួយវិញទៀត រុយទាំងនោះ នៅអាស្រ័យក្នុងទីណា ៗ រុយទាំងនោះ រមែងត្រេកអរក្នុងទីនោះ ៗ ឯង មានឧបមាយ៉ាងណាមិញ ម្នាលគហបតី មានឧបមេយ្យដូចយ៉ាងនោះ ទេវតាទាំងនោះ តែងមិនមានសេចក្ដីត្រិះរិះយ៉ាងនេះថា ទីរបស់យើងនេះ ទៀងទាត់ ឋិតថេរមាំមួន ដូច្នេះឡើយ ។ មួយវិញទៀត ពួកទេវតាណា នៅអាស្រ័យក្នុងទីណា ៗ ទេវតាទាំងនោះ រមែងត្រេកអរក្នុងទីនោះ ៗ ។

(៩៦) ឯវំ វុត្តេ អាយស្មា អភិយោ កច្ចានោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច សាធុ ភន្តេ អនុរុទ្ធ អត្ថិ ច មេ ឯត្ថ ឧត្តរឹ បដិបុច្ឆិតព្វំ យា តា ភន្តេ ទេវតា អាភា សព្វា តា បរិត្តាភា ឧទាហុ សន្តេត្ថ ឯកច្ចា ទេវតា អប្បមាណាភាតិ ។ តទង្គេន ខោ អាវុសោ កច្ចាន សន្តេត្ថ ឯកច្ចា ទេវតា បរិត្តាភា សន្តិ បនេត្ថ ឯកច្ចា ទេវតា អប្បមាណាភាតិ ។ កោ នុ ខោ ភន្តេ អនុរុទ្ធ ហេតុ កោ បច្ចយោ យេន តាសំ ទេវតានំ ឯកំ ទេវនិកាយំ ឧបបន្នានំ សន្តេត្ថ ឯកច្ចា ទេវតា បរិត្តាភា សន្តិ បនេត្ថ ឯកច្ចា ទេវតា អប្បមាណាភាតិ ។

(៩៧) តេនហាវុសោ[១] កច្ចាន តញ្ញេវេត្ថ[២] បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ តំ កឹ មញ្ញសិ អាវុសោ កច្ចាន យ្វាយំ ភិក្ខុ យាវតា ឯកំ រុក្ខមូលំ មហគ្គតន្តិ

១ ម. តេនហាវុសោ ។ ២ ម. តំយេវេត្ថ ។



(៩៦) កាលបើព្រះអនុរុទ្ធ ពោលយ៉ាងនេះហើយ ព្រះអភិយកច្ចានៈ មានអាយុ ក៏ពោលនឹងព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ពាក្យរបស់លោកម្ចាស់ប្រពៃហើយ តែខ្ញុំត្រូវការសួរនូវប្រស្នាខ្ពស់ទៅទៀត បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ពួកទេវតាណា ដែលមានពន្លឺ ទេវតាទាំងនោះ មានពន្លឺតិចទាំងអស់ឬ ឬក៏មានពួកទេវតាដែលមានពន្លឺប្រមាណមិនបាន ក្នុងទីនុ៎ះខ្លះដែរ ។ ព្រះអនុរុទ្ធឆ្លើយថា ម្នាលអាវុសោកច្ចានៈ ដោយហេតុនោះៗ ទេវតាដែលមានពន្លឺតិច ក៏មានក្នុងទីនុ៎ះខ្លះ ទេវតាដែលមានពន្លឺប្រមាណមិនបាន ក៏មានក្នុងទីនុ៎ះខ្លះដែរ ។ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យទេវតាទាំងនោះ ចូលទៅកើត ក្នុងពួកនៃទេវតាដូចគ្នា តែទេវតាពួកខ្លះក្នុងទីនុ៎ះ មានពន្លឺតិចក៏មាន ទេវតាពួកខ្លះក្នុងទីនុ៎ះ មានពន្លឺប្រមាណមិនបានក៏មាន ។

(៩៧) ម្នាលអាវុសោ កច្ចានៈ បើដូច្នោះ ខ្ញុំនឹងត្រឡប់សួរលោក ក្នុងប្រស្នានុ៎ះវិញ បើប្រស្នានោះ គាប់ចិត្តលោក យ៉ាងណា លោកគប្បីដោះស្រាយ នូវប្រស្នានោះ យ៉ាងនោះចុះ ។ ម្នាលអាវុសោ កច្ចានៈ លោកសំគាល់នូវសេចក្តីនោះ ថាដូចម្តេច ភិក្ខុណាដែលកំពុង ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់គល់ឈើ ១

ផរិត្វា អធិមុច្ចិត្វា វិហរតិ យោ ចាយំ ភិក្ខុ យាវតា ទ្វេ វា តីណិ វា រុក្ខមូលានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ឥមាសំ ទ្វិន្នំ ចិត្តភាវនានំ កតមា ចិត្តភាវនា មហគ្គតតរាតិ ។ យាយំ ភន្តេ ភិក្ខុ យាវតា ទ្វេ វា តីណិ វា រុក្ខមូលានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ ឥមាសំ ទ្វិន្នំ ចិត្តភាវនានំ មហគ្គតតរាតិ ។

(៤៨) តំ កឹ មញ្ញសិ អាវុសោ កច្ចាន យោយំ ភិក្ខុ យាវតា ទ្វេ វា តីណិ វា រុក្ខមូលានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ យោ ចាយំ ភិក្ខុ យាវតា ឯកំ គាមក្ខេត្តំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ឥមាសំ ទ្វិន្នំ ចិត្តភាវនានំ កតមា ចិត្តភាវនា មហគ្គតតរាតិ ។ យាយំ ភន្តេ ភិក្ខុ យាវតា ឯកំ គាមក្ខេត្តំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ ឥមាសំ ទ្វិន្នំ ចិត្តភាវនានំ មហគ្គតតរាតិ ។



ជាកំណត់ ថាជាទីមហគ្គតៈ (ទីធំ គឺទីក្រៅយកចិត្តទុកដាក់) និងត្រង់ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់រុក្ខមូល ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ បណ្តាចិត្តភាវនាទាំង ២ នេះ តើចិត្តភាវនាណា ដែលចាត់ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចំរើន បណ្តាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនា ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្តទៅកាន់រុក្ខមូល ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។

(៤៨) ម្នាលអាវុសោ កច្ចានៈ លោកសំគាល់នូវសេចក្តីនោះដូចម្តេច គឺត្រង់ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់រុក្ខមូល ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ និងត្រង់ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់គាមក្ខេត្ត ១ ជាកំណត់ ថាជាទីមហគ្គតៈ បណ្តាចិត្តភាវនាទាំង ២ នេះ តើចិត្តភាវនាណា ដែលចាត់ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចំរើន បណ្តាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនា ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់គាមក្ខេត្ត ១ ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈ ខ្ពង់ខ្ពស់ជាង ។

(៩៩) តំ កឹ មញ្ញសិ អាវុសោ កច្ចាន យ្វាយំ ភិក្ខុ យាវតា ឯកំ រុក្ខមូលំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ យោ ចាយំ ភិក្ខុ យាវតា ទ្វេ វា តីណិ វា រុក្ខមូលានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ឥមាសំ ឧភិន្នំ ចិត្តភាវនានំ កតមា ចិត្តភាវនា មហគ្គតតរាតិ ។ យ្វាយំ ភន្តេ ភិក្ខុ យាវតា ទ្វេ វា តីណិ វា រុក្ខមូលានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ ឥមាសំ ឧភិន្នំ ចិត្តភាវនានំ មហគ្គតតរាតិ ។

(១០០) តំ កឹ មញ្ញសិ អាវុសោ កច្ចាន យ្វាយំ ភិក្ខុ យាវតា ទ្វេ វា តីណិ វា រុក្ខមូលានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ យោ ចាយំ ភិក្ខុ យាវតា ឯកំ គាមក្ខេត្តំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ឥមាសំ ឧភិន្នំ ចិត្តភាវនានំ



(៩៩) ម្នាលអាវុសោ កច្ចានៈ លោកសំគាល់នូវសេចក្តីនោះ ជាដូចម្តេច តើត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់គល់រុក្ខ ១ ជាកំណត់ ថាជាចិត្តមហគ្គតៈ និងត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់គល់រុក្ខ ២ ឬ ៣ ជាកំណត់ ថាជាចិត្តមហគ្គតៈ បណ្តាចិត្តភាវនាទាំង ២ នេះ តើចិត្តភាវនាណា ដែលជាក់ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចំរើន បណ្តាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនាដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់គល់រុក្ខ ២ ឬ ៣ ជាកំណត់ ថាជាចិត្តមហគ្គតៈ នេះឯង ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។

(១០០) ម្នាលអាវុសោ កច្ចានៈ លោកសំគាល់សេចក្តីនោះ ជាដូចម្តេច តើត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់គល់រុក្ខ ២ ឬ ៣ ជាកំណត់ ថាជាចិត្តមហគ្គតៈ និងត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់ដែនឃុំ ១ ជាកំណត់ ថាជាចិត្តមហគ្គតៈ បណ្តាចិត្តភាវនាទាំងពីរនេះ

កតមា ចេតោវិមុត្តិ មហគ្គតតរាតិ ។ យ្វាយំ ភន្តេ ភិក្ខុ យាវតា ឯកំ មហារជ្ជំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ ឥមាសំ ទ្វិន្នំ ចេតោវិមុត្តីនំ មហគ្គតតរាតិ ។

(៣០៣) តំ កិំ មញ្ញសិ អាវុសោ កច្ចាន យ្វាយំ ភិក្ខុ យាវតា ឯកំ មហារជ្ជំ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ យោ ចាយំ ភិក្ខុ យាវតា ទ្វេ វា តីណិ វា មហារជ្ជានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ឥមាសំ ទ្វិន្នំ ចេតោវិមុត្តីនំ កតមា ចេតោវិមុត្តិ មហគ្គតតរាតិ ។ យ្វាយំ ភន្តេ ភិក្ខុ យាវតា ទ្វេ វា តីណិ វា មហារជ្ជានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ ឥមាសំ ទ្វិន្នំ ចេតោវិមុត្តីនំ មហគ្គតតរាតិ ។



តើចេតោវិមុត្តិណា ដែលជាក់ជាមហគ្គតៈ ខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចម្រើន បណ្ដាចេតោវិមុត្តិទាំង ២ នេះ ចេតោវិមុត្តិដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់ដែនធំ ១ ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈ ខ្ពង់ខ្ពស់ជាង ។

[៣០៣] ម្នាលអាវុសោ កច្ចានៈ លោកសំគាល់នូវសេចក្ដីនោះ ដូចម្ដេច គឺត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់ដែនធំ ១ ជាកំណត់ ថាជាទីមហគ្គតៈ និងត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់ដែនធំ ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ បណ្ដាចេតោវិមុត្តិទាំង ២ នេះ តើចេតោវិមុត្តិណា ដែលជាក់ជាមហគ្គតៈ ខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចម្រើន បណ្ដាចេតោវិមុត្តិទាំង ២ នេះ ចេតោវិមុត្តិ ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់ដែនធំ ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈ ខ្ពង់ខ្ពស់ជាង ។

(១០៦) តំ កឹ មញ្ញសិ អាវុសោ កច្ចាន យោយំ ភិក្ខុ យាវតា ទ្វេ វា តីណិ វា មហារជ្ជានិ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ យោ វាយំ ភិក្ខុ យាវតា សមុទ្ទបរិយន្តំ បឋវឹ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ឥមាសំ ឧភិន្នំ ចិត្តភាវនានំ កតមា ចិត្តភាវនា មហគ្គតតរាតិ ។ យោយំ ភន្តេ ភិក្ខុ យាវតា សមុទ្ទបរិយន្តំ បឋវឹ មហគ្គតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ អយំ ឥមាសំ ឧភិន្នំ ចិត្តភាវនានំ មហគ្គតតរាតិ ។ អយំ ខោ អាវុសោ កច្ចាន ហេតុ អយំ បច្ចយោ យេន តាសំ ទេវតានំ ឯកំ ទេវនិកាយំ ឧបបន្នានំ សន្តេកេច្ចា ទេវតា បរិត្តាភា សន្តិ បនេកេច្ចា ទេវតា អប្បមាណាភាតិ ។



(១០៦) ម្នាលអាវុសោ កច្ចានៈ លោកសំគាល់នូវសេចក្តីនោះ ជាដូចម្តេច គឺត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់ផែនដី ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ និងត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់ផែនដីមានសមុទ្រជាទីបំផុត ជាកំណត់ ថាជាទីមហគ្គតៈ បណ្តាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនាណា ដែលចាត់ជាមហគ្គតៈ ខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចម្រើន បណ្តាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនា ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់ផែនដី មានសមុទ្រជាទីបំផុត ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈ ខ្ពង់ខ្ពស់ជាង ។ ម្នាលអាវុសោ កច្ចានៈ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យទេវតាទាំងនោះ ចូលទៅកើតក្នុងពួកទេវតាតែមួយពួក ប៉ុន្តែទេវតាខ្លះ ក្នុងទីនោះ មានពន្លឺតិច ក៏មាន ទេវតាខ្លះក្នុងទីនោះ មានពន្លឺប្រមាណមិនបាន ក៏មាន ។

(១០៣) សាធុ ភន្តេ អនុរុទ្ធ អត្ថិ ច មេ ឯត្ថ ឧត្តរឹ បដិបុច្ឆិតព្វំ យាវតា ភន្តេ ទេវតា អាភា សព្វា តា សង្កិលិដ្ឋាភា ឧទាហុ សន្តេត្ថេកច្ចា ទេវតា បរិសុទ្ធាភាតិ ។ តទង្គេន ខោ អាវុសោ កច្ចាន សន្តេត្ថេកច្ចា ទេវតា សង្កិលិដ្ឋាភា សន្តិ បនេត្ថេកច្ចា ទេវតា បរិសុទ្ធាភាតិ ។ កោ នុ ខោ ភន្តេ អនុរុទ្ធ ហេតុ កោ បច្ចយោ យេន តាសំ ទេវតានំ ឯកំ ទេវនិកាយំ ឧបបន្នានំ សន្តេកច្ចា ទេវតា សង្កិលិដ្ឋាភា សន្តិ បនេកច្ចា ទេវតា បរិសុទ្ធាភាតិ ។

(១០៤) តេនហាវុសោ កច្ចាន ឧបមំ តេ ករិស្សាមិ ឧបមាយបិធេកច្ចេ វិញ្ញូ បុរិសា(១) ភាសិតស្ស អត្ថំ អាជានន្តិ(២) ។ សេយ្យថាបិ អាវុសោ កច្ចាន តេលប្បទីបស្ស ឈាយតោ តេលម្បិ អបរិសុទ្ធំ វដ្ដិបិ អបរិសុទ្ធា ។ សោ តេលស្សបិ អបរិសុទ្ធត្តា

១ ម. ឧបមាយបិធេកច្ចេ វិញ្ញូបុរិសាតិ ទិស្សតិ ។ ២ ម. អាជានាតិ ។



(១០៣) បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ពាក្យរបស់លោកម្ចាស់ ប្រពៃហើយ តែខ្ញុំនៅតែត្រូវការសួរក្នុងប្រស្នានុ៎ះ តទៅទៀត បពិត្រលោកដ៏ចម្រើន ទេវតាទាំងអម្បាលមាណ ដែលមានពន្លឺ តើទេវតាទាំងនោះ មានពន្លឺស្រអាប់ទាំងអស់ឬ ឬក៏មានទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺថ្លាផង ។ ម្នាលអាវុសោ កច្ចានៈ ដោយហេតុដូចពោលមកហើយនោះឯង ទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺស្រអាប់ក៏មាន ទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺថ្លាក៏មាន ។ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យទេវតាទាំងនោះ ចូលទៅកើតក្នុងពួកនៃទេវតាតែមួយពួកស្មើគ្នា ប៉ុន្តែទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺស្រអាប់ក៏មាន ទេវតាពួកខ្លះ ក្នុងទីនុ៎ះ មានពន្លឺថ្លាក៏មាន ។

(១០៤) ម្នាលអាវុសោ កច្ចានៈ បើដូច្នោះ ខ្ញុំនឹងធ្វើនូវសេចក្តីឧបមាដល់លោក ព្រោះថាវិញ្ញូបុរស ពួកខ្លះ ក្នុងលោកនេះ តែងដឹងច្បាស់នូវសេចក្តីនៃភាសិត ដោយសារពាក្យឧបមា ។ ម្នាលអាវុសោ កច្ចានៈ ដូចប្រទីបប្រេង ដែលកំពុងឆេះ មានប្រេងមិនបរិសុទ្ធខ្លះ មានប្រឆេះមិនស្អាតខ្លះ ។ ប្រទីបប្រេងនោះឯង ព្រោះតែប្រេងមិនបរិសុទ្ធក៏មាន

វដ្ដិយាបិ អបរិសុទ្ធត្តា អន្ធន្ធំ(១) វិយ ឈាយតិ ឯវមេវ ខោ អាវុសោ កច្ចាន ឥធេកច្ចោ ភិក្ខុ សង្កិលិដ្ឋាភានិ ផរិត្វា អធិមុច្ចិត្វា វិហរតិ ។ តស្ស កាយទុដ្ឋុល្លម្បិ ន សុប្បដិប្បស្សទ្ធំ ហោតិ ថីនមិទ្ធម្បិ ន សុសមូហតំ ហោតិ ឧទ្ធច្ចកុក្កុច្ចម្បិ ន សុប្បដិវិនីតំ ហោតិ ។ សោ កាយទុដ្ឋុល្លស្សបិ ន សុប្បដិប្បស្សទ្ធត្តា ថីនមិទ្ធស្សបិ ន សុសមូហតត្តា ឧទ្ធច្ចកុក្កុច្ចស្សបិ ន សុប្បដិវិនីតត្តា អន្ធន្ធំ វិយ ឈាយតិ ។ សោ កាយស្ស ភេទា បរម្មរណា សង្កិលិដ្ឋាភានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ សេយ្យថាបិ អាវុសោ កច្ចាន តេលប្បទីបស្ស តេលម្បិ បរិសុទ្ធំ វដ្ដិបិ បរិសុទ្ធា ។

១ អន្ធន្ធំ កត្ថចិ បោត្ថកេ ទិស្សតិ ។



ព្រោះតែប្រេងមិនស្អាតក៏មាន ក៏ឆេះហាក់ដូចជាងងឹតស្រអាប់ មាន ឧបមាយ៉ាងណាមិញ ម្នាលអាវុសោ កច្ចានៈ មានឧបមេយ្យដូចយ៉ាងនេះ ភិក្ខុខ្លះ ក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់សង្កិលិដ្ឋាភដ្ឋាន (ឈានមានពន្លឺស្រអាប់) ។ ភិក្ខុនោះ មានសេចក្ដីក្ដៅក្ដួលនៃកាយ មិនបានស្ងប់រម្ងាប់ខ្លះ មានថីនមិទ្ធៈ មិនបានដកចោលខ្លះ មានឧទ្ធច្ចកុក្កុច្ចៈ មិនបានកំចាត់ចោលខ្លះ ។ ភិក្ខុនោះ ព្រោះតែសេចក្ដីក្ដៅក្ដួលនៃកាយ មិនបានស្ងប់រម្ងាប់ក៏មាន ព្រោះតែមានថីនមិទ្ធៈ មិនបានដកចោលក៏មាន ព្រោះតែមានឧទ្ធច្ចកុក្កុច្ចៈ មិនបានកំចាត់ចោលក៏មាន ក៏ចម្រើនឈានហាក់ដូចជាងងឹតស្រអាប់ ។ ភិក្ខុនោះ លុះបែកធ្លាយនៃកាយស្លាប់ទៅ ខាងមុខបន្ទាប់អំពីមរណៈ តែងទៅកើតជាមួយនឹងពួកទេវតាដែលមានពន្លឺស្រអាប់ ។ ម្នាលអាវុសោ កច្ចានៈ មួយទៀត ដូចប្រទីបប្រេង ដែលកំពុងឆេះ មានប្រេងបរិសុទ្ធផង មានប្រឆេះស្អាតផង ។

សោ តេលស្ស ច បរិសុទ្ធត្តា វដ្ដិយា ច បរិសុទ្ធត្តា អនច្ចិមំ វិយ ឈាយតិ ឯវមេវ ខោ អាវុសោ កច្ចាន យ្វាយំ ភិក្ខុ បរិសុទ្ធាភំ ផរិត្វា អធិមុច្ចិត្វា វិហរតិ ។ តស្ស កាយទុដ្ឋុល្លម្បិ សុប្បដិប្បស្សទ្ធំ ហោតិ ថីនមិទ្ធម្បិ សុសមូហតំ ហោតិ ឧទ្ធច្ចកុក្កុច្ចម្បិ សុប្បដិវិនីតំ ហោតិ ។ សោ កាយទុដ្ឋុល្លស្ស ច សុប្បដិប្បស្សទ្ធត្តា ថីនមិទ្ធស្ស ច សុសមូហតត្តា ឧទ្ធច្ចកុក្កុច្ចស្ស ច សុប្បដិវិនីតត្តា អនច្ចិមំ វិយ ឈាយតិ ។ សោ កាយស្ស ភេទា បរម្មរណា បរិសុទ្ធាភានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អយំ ខោ អាវុសោ កច្ចាន ហេតុ អយំ បច្ចយោ យេន តាសំ ទេវតានំ ឯកំ ទេវនិកាយំ ឧបបន្នានំ សន្តេត្ថេកច្ចា ទេវតា សង្កិលិដ្ឋាភា សន្តេត្ថេកច្ចា ទេវតា បរិសុទ្ធាភាតិ ។



ប្រទីបប្រេងនោះ ព្រោះតែប្រេងបរិសុទ្ធផង ព្រោះតែប្រទេះស្អាតផង ក៏ឆេះហាក់ដូចជាមិនងងឹតស្រអាប់ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោ កច្ចានៈ មានឧបមេយ្យដូចយ៉ាងភិក្ខុពួកខ្លះ ក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់បរិសុទ្ធាភជ្ឈាន (ឈានមានពន្លឺថ្លា) ។ ភិក្ខុនោះ មានសេចក្ដីឆ្អាំឆ្អន់នៃកាយស្ងប់រម្ងាប់ផង មានថីនមិទ្ធៈដកចោលហើយផង មានឧទ្ធច្ចកុក្កុច្ចៈកំចាត់ចោលហើយផង ។ ភិក្ខុនោះ ព្រោះតែមានសេចក្ដីឆ្អាំឆ្អន់នៃកាយស្ងប់រម្ងាប់ហើយផង ព្រោះតែមានថីនមិទ្ធៈដកចោលហើយផង ព្រោះតែមានឧទ្ធច្ចកុក្កុច្ចៈកំចាត់ចោលហើយផង រមែងចម្រើនឈាន ហាក់ដូចជាមិនងងឹតស្រអាប់ ។ ភិក្ខុនោះ លុះបែកធ្លាយនៃកាយស្លាប់ទៅ ខាងមុខបន្ទាប់អំពីមរណៈ តែងទៅកើត ជាមួយនឹងពួកទេវតាមានពន្លឺថ្លា ។ ម្នាលអាវុសោ កច្ចានៈ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យទេវតាទាំងនោះ ទៅកើតក្នុងពួកនៃទេវតាតែមួយពួកទេ ប៉ុន្តែទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺស្រអាប់ក៏មាន ទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺថ្លាក៏មាន ។

(១០៨) ឯវំ វុត្តេ អាយស្មា អភិយោ កច្ចានោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច សាធុ ភន្តេ អនុរុទ្ធ ន ភន្តេ អាយស្មា អនុរុទ្ធោ ឯវមាហ ឯវំ មេ សុតន្តិ វា ឯវំ អរហតិ ភវិតុន្តិ វា អថ ច បន ភន្តេ អាយស្មា អនុរុទ្ធោ ឯវម្បិ តា[១] ទេវតា ឥតិបិ តា[២] ទេវតាឥច្ចេវ ភាសតិ តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ អទ្ធា អាយស្មតា អនុរុទ្ធេន តាហិ ទេវតាហិ សទ្ធឹ សន្និវុត្ថបុព្វញ្ចេវ សល្លបិតបុព្វញ្ច សាកច្ឆា ច សមាបជ្ជិតបុព្វាតិ ។ អទ្ធា ខោ[៣] អយំ អាវុសោ កច្ចាន អាសជ្ជ ឧបនីយ វាចា ភាសិតា អបិច តេ អហំ ព្យាករិស្សាមិ ទីឃរត្តំ ខោ មេ អាវុសោ កច្ចាន តាហិ ទេវតាហិ សទ្ធឹ សន្និវុត្ថបុព្វញ្ច សល្លបិតបុព្វញ្ច សាកច្ឆា ច សមាបជ្ជិតបុព្វាតិ ។

១-២ ឱ. តាតិ ទិស្សតិ ។ ៣ ឱ. ខោ ឥតិ ទិស្សតិ ។



[១០៨] កាលបើព្រះអនុរុទ្ធមានអាយុ ពោលយ៉ាងនេះហើយ អភិយកច្ចានៈមានអាយុ ក៏ពោលទៅនឹងព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ពាក្យរបស់លោកប្រពៃហើយ បពិត្រលោកដ៏ចម្រើន ព្រះអនុរុទ្ធមានអាយុ មិនបានពោលយ៉ាងនេះថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ឬថាសេចក្តីយ៉ាងនេះគួរនឹងមាន ទេ បពិត្រលោកដ៏ចម្រើន តែថាព្រះអនុរុទ្ធមានអាយុ សំដែងតែពីទេវតានោះ យ៉ាងនេះខ្លះ សំដែងតែពីទេវតានោះ ដូច្នេះខ្លះ បពិត្រលោកដ៏ចម្រើន ខ្ញុំមានសេចក្តីយល់ចិត្តយ៉ាងនេះថា ព្រះអនុរុទ្ធមានអាយុធ្លាប់នៅរួម ធ្លាប់និយាយរួម ធ្លាប់សាកច្ឆារួម ធ្លាប់ចូលគំនិតរួម ជាមួយនឹងទេវតាទាំងនោះឯង ។ ម្នាលអាវុសោកច្ចានៈ ពាក្យនេះ លោកបានពោលហើយ ដោយត្រឹមត្រូវពិត បើដូច្នោះ ខ្ញុំនឹងប្រាប់លោក ម្នាលអាវុសោកច្ចានៈ ខ្ញុំធ្លាប់នៅរួម ធ្លាប់និយាយរួម ធ្លាប់សាកច្ឆារួម ធ្លាប់ចូលគំនិតរួម ជាមួយទេវតាទាំងនោះឯង អស់កាលជាយូរអង្វែង ពិតមែន ។

(១០៦) ឯវំ វុត្តេ អាយស្មា អភិយោ កច្ចានោ បញ្ចកង្គំ ថបតឹ ឯតទវោច លាភា តេ គហបតិ សុលទ្ធំ តេ គហបតិ យំ ត្វញ្ចេវ តំ កង្ខាធម្មំ បហាសិ ឥមញ្ច ធម្មបរិយាយំ អលត្ថម្ហា សវនាយាតិ ។

អនុរុទ្ធសុត្តំ សត្តមំ និដ្ឋិតំ ។

---



(១០៦) កាលបើព្រះអនុរុទ្ធ មានអាយុ ពោលយ៉ាងនេះហើយ អភិយកច្ចានៈ មានអាយុ ក៏ពោលទៅនឹងបញ្ចកង្គថបតិ ដូច្នេះថា ម្នាលគហបតី អ្នកពេញជាមានលាភ ម្នាលគហបតី អត្តភាពជាមនុស្ស អ្នកពេញជាបានដោយល្អហើយ ព្រោះថា អ្នកបានលះបង់នូវធម៌កង្ខា ( សេចក្ដីសង្ស័យ ) នោះ ព្រោះថា យើងទាំងឡាយ បានស្ដាប់នូវធម្មបរិយាយនេះ ។

ចប់ អនុរុទ្ធសូត្រ ទី ៧ ។

# អដ្ឋមំ ឧបក្កិលេសសុត្តំ

(១០៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន កោសម្ពិយំ ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ។

(១០៨) អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ឥធ ភន្តេ កោសម្ពិយំ ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ សាធុ ភន្តេ ភគវា យេន តេ ភិក្ខូ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ភគវា យេន

# ឧបក្កិលេសសូត្រ ទី ៨

(១០៧) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង ពួកភិក្ខុ ក្នុងក្រុងកោសម្ពី កើតមានការបង្កហេតុ កើតមានជម្លោះ ដល់នូវការទាស់ទែងគ្នា ចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ ។

(១០៨) គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ ឯភិក្ខុនោះ លុះឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុ ក្នុងក្រុងកោសម្ពីនេះ កើតមានការបង្កហេតុ កើតមានជម្លោះ ដល់នូវការទាស់ទែងគ្នា ចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ស្តេចចូលទៅកាន់សំណាក់ភិក្ខុទាំងនោះ ដោយសេចក្តីអនុគ្រោះ ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះមានព្រះភាគ

តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច អលំ ភិក្ខវេ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទំ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច អាគមេតុ ភន្តេ ភគវា ធម្មស្សាមិ អប្បោស្សុក្កោ ភន្តេ ភគវា ទិដ្ឋធម្មសុខវិហារំ អនុយុត្តោ វិហរតុ មយមេតេន ភណ្ឌនេន កលហេន វិគ្គហេន វិវាទេន បញ្ញាយិស្សាមាតិ ។

(១០៨) ទុតិយម្បិ ខោ ភគវា តេ ភិក្ខូ ឯតទវោច អលំ ភិក្ខវេ មា ភណ្ឌនំ មា កលហំ មា វិគ្គហំ មា វិវាទំ ។ ទុតិយម្បិ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច អាគមេតុ ភន្តេ ភគវា ធម្មស្សាមិ



ស្តេចចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏ត្រាស់ហៅភិក្ខុទាំងនោះ ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយ កុំធ្វើនូវការបង្កហេតុ កុំធ្វើនូវជម្លោះ កុំធ្វើនូវសេចក្តីប្រកាន់ខុសគ្នា កុំធ្វើនូវការទាស់ទែងគ្នាឡើយ ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅយ៉ាងនេះហើយ ភិក្ខុមួយរូប ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ជាធម្មស្សាមី ទ្រង់ឈប់សិនចុះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបនូវកិរិយានៅជាសុខក្នុងបច្ចុប្បន្នចុះ យើងខ្ញុំទាំងឡាយ នឹងប្រាកដដោយការបង្កហេតុ ដោយជម្លោះ ដោយសេចក្តីប្រកាន់ខុសគ្នា ដោយការទាស់ទែងគ្នានុ៎ះ មិនលែងទេ ។

(១០៨) ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅ នូវភិក្ខុទាំងនោះ ជាគំរប់ពីរដង ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយ កុំធ្វើនូវការបង្កហេតុ កុំធ្វើនូវជម្លោះ កុំធ្វើនូវសេចក្តីប្រកាន់ខុសគ្នា កុំធ្វើនូវការទាស់ទែងគ្នាឡើយ ។ ភិក្ខុនោះ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ជាគំរប់ពីរដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ជាធម្មស្សាមី ទ្រង់ឈប់សិនចុះ

អប្បោស្សុក្កោ ភន្តេ ភគវា ទិដ្ឋធម្មសុខវិហារំ អ-
នុយុត្តោ វិហរតុ មយមេតេន ភណ្ឌនេន កល-
ហេន វិគ្គហេន វិវាទេន បញ្ញាយិស្សាមាតិ ។

(១១០) ទុតិយម្បិ ខោ ភគវា តេ ភិក្ខូ ឯតទ-
វោច អលំ ភិក្ខវេ មា ភណ្ឌនំ មា កលហំ
មា វិគ្គហំ មា វិវាទន្តិ ។ ទុតិយម្បិ ខោ សោ
ភិក្ខុ ភគវន្តំ ឯតទវោច អាគមេតុ ភន្តេ ភគវា
ធម្មស្សាមិ អប្បោស្សុក្កោ ភន្តេ ភគវា ទិដ្ឋធម្មសុ-
ខវិហារំ អនុយុត្តោ វិហរតុ មយមេតេន ភណ្ឌនេន
កលហេន វិគ្គហេន វិវាទេន បញ្ញាយិស្សាមាតិ ។



បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបខ្លួនក្នុងការនៅជាសុខក្នុងបច្ចុប្បន្នចុះ យើងខ្ញុំទាំងឡាយ នឹងប្រាកដ ដោយការបង្កហេតុ ដោយជម្លោះ ដោយសេចក្តីប្រកាន់ខុសគ្នា ដោយការពោលទទឹងគ្នានុ៎ះ មិនលែងឡើយ ។

(១១០) ព្រះមានព្រះភាគ ទ្រង់ត្រាស់ឃាត់នូវភិក្ខុទាំងនោះជាគម្រប់ ២ ដងថា ម្នាលភិក្ខុទាំងឡាយកុំឡើយ អ្នកទាំងឡាយ កុំធ្វើនូវការបង្កហេតុ កុំធ្វើនូវជម្លោះ កុំធ្វើនូវសេចក្តីប្រកាន់ខុសគ្នា កុំធ្វើនូវការពោលទទឹងគ្នាឡើយ ។ ភិក្ខុនោះ ក៏ក្រាបបង្គំទូលឃាត់ព្រះមានព្រះភាគជាគម្រប់ ២ ដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ជាធម្មស្សាមី ទ្រង់ឈប់សិនចុះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបខ្លួនក្នុងការនៅជាសុខ ក្នុងបច្ចុប្បន្នចុះ យើងខ្ញុំទាំងឡាយ នឹងប្រាកដ ដោយការបង្កហេតុ ដោយជម្លោះ ដោយសេចក្តីប្រកាន់ខុសគ្នា ដោយការពោលទទឹងគ្នានុ៎ះ មិនលែងទេ ។

(១១១) អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កោសម្ពឹ បិណ្ឌាយ បាវិសិ ។ កោសម្ពិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ សេនាសនំ សំសាមេត្វា បត្តចីវរំ អាទាយ ឋិតកោវ ឥមា គាថា អភាសិ

បុថុសទ្ទោ សមជនោ
ន ពាលោ កោចិ មញ្ញថ
សង្ឃស្មឹ ភិជ្ជមានស្មឹ
នាញ្ញំ ភិយ្យោ អមញ្ញថ[១]
បរិមុដ្ឋា បណ្ឌិតាភាសា

១ ឱ. ម. អមញ្ញន្តិ ទិស្សតិ ។



(១១១) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់ក្រុងកោសម្ពី ដើម្បីបិណ្ឌបាត្រ ។ លុះព្រះមានព្រះភាគ ទ្រង់ស្តេចទៅក្នុងក្រុងកោសម្ពី ដើម្បីបិណ្ឌបាត្រ ត្រឡប់អំពីបិណ្ឌបាត្រ ក្នុងបច្ឆាភត្ត ហើយ ទ្រង់រៀបចំសេនាសនៈ ហើយកាន់យកបាត្រនិងចីវរ ទ្រង់ព្រះស្ថិត (ឈរ) សំដែងនូវព្រះគាថាទាំងនេះថា

ជនមានសំឡេងខ្លាំង ( ទៅរកគ្នា ) ផង ជនធ្វើនូវសេចក្តី
បង្កហេតុប្រហែលគ្នាផង សូម្បីជនណាមួយ ដឹងខ្លួនថា
ពាក្យអញ ជាបុគ្គលពាល ក៏គ្មានឡើយ កាលបើសង្ឃ
កំពុងតែបែកគ្នា ក៏មិនបានដឹងហេតុដទៃទៀតក្រៅពីនេះ[១]
ពួកជនដែលភ្លេចស្មារតី ហើយធ្វើពុតខ្លួនដូចជាអ្នកប្រាជ្ញ

១ មិនដឹងថាសង្ឃបែកគ្នា ព្រោះតែអាត្មាអញ ។

វាចាគោចរភាណិនោ
យាវិច្ឆន្តិ មុខាយាមំ
យេន នីតា ន តំ វិទូ
អក្កោច្ឆិ មំ អវធិ មំ
អជិនិ មំ អហាសិ មេ
យេ ច[១] តំ ឧបនយ្ហន្តិ
វេរំ តេសំ ន សម្មតិ
អក្កោច្ឆិ មំ អវធិ មំ
អជិនិ មំ អហាសិ មេ
យេ ច តំ នុបនយ្ហន្តិ
វេរំ តេសូបសម្មតិ
ន ហិ វេរេន វេរានិ
សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ
ឯស ធម្មោ សនន្តនោ

១ ម. ចសទ្ទោ នត្ថិ ។



មានសំដីជាអារម្មណ៍ ពោលនូវពាក្យតាមប្រក្រតី ចង់ហាមាត់និយាយប៉ុន្មាន ក៏និយាយប៉ុណ្ណោះទៅ កាលបើជម្លោះណា នាំទៅហើយ ក៏មិនដឹងច្បាស់ នូវជម្លោះនោះឡើយ[១] ពួកជនណា ចងនូវសេចក្តីក្រោធនោះទុកដោយគិតថា ជនឯណោះ បានជេរអាត្មាអញ ជនឯណោះ បានវាយអាត្មាអញ ជនឯណោះ បានផ្ចាញ់អាត្មាអញ ជនឯណោះ បានលួចទ្រព្យរបស់អាត្មាអញ ពៀររបស់ជនទាំងនោះមិនរម្ងាប់ទេ លុះតែពួកជនណា មិនចងសេចក្តីក្រោធនោះទុកដោយគិតថា ជនឯណោះ បានជេរអាត្មាអញ ជនឯណោះ បានវាយអាត្មាអញ ជនឯណោះ បានផ្ចាញ់អាត្មាអញ ជនឯណោះបានលួចទ្រព្យរបស់អាត្មាអញដូច្នេះ ពៀររបស់ជនទាំងនោះ ទើបរម្ងាប់ទៅបាន ធម្មតាពៀរក្នុងលោកនេះ មិនដែលរម្ងាប់ ដោយការចងពៀរគ្នាណាឡើយ ការរម្ងាប់ពៀរទៅបាន តែដោយការមិនចងពៀរ ធម៌នុះជាប្រវេណី

១ បានសេចក្តីថា ជនពាលទាំងនោះ កាលបើសង្ឃទ្រុលទ្រោមបែកគ្នាក្នុងជម្លោះណា ក៏មិនស្គាល់សេចក្តីឈ្លោះនោះជា ប្រកបដោយទោសឡើយ ។

បរេ ច ន វិជានន្តិ
មយមេត្ថ យមាមសេ
យេ ច តត្ថ វិជានន្តិ
តតោ សម្មន្តិ មេធគា
អដ្ឋិច្ឆិន្នា បាណហរា
គវស្សធនហារិនោ[1]
រដ្ឋំ វិលុម្បមានានំ
តេសម្បិ ហោតិ សង្គតិ
កស្មា តុម្ហាក នោ សិយា
សចេ លភេថ និបកំ សហាយំ
សទ្ធិំចរំ សាធុវិហារិ ធីរំ
អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតីមា

១ ឱ. ម. គវស្សធនហារិនោ ។



ពួកជនដទៃ[1] តែងមិនដឹងច្បាស់ថា យើងនឹងវិនាស ក្នុងកណ្តាលជំនុំសង្ឃនេះឡើយ បណ្ឌិតទាំងឡាយណា ដឹងច្បាស់ក្នុងជំនុំសង្ឃនោះ ជម្លោះ តែងរម្ងាប់អំពីសំណាក់បណ្ឌិតទាំងនោះ គម្បាលដ្ឋិនាកាប់កា របស់ទីយោក្កុតារ គេកាត់ពោល ទាំងជីវិត គេកំសម្លាប់ពោល ទាំងគោសេះ និងទ្រព្យ គេកំនាំយកទៅ ទាំងដែន គេកំបង្ខាំងដណ្តើមយកផង ស្តេចទាំងនោះ ម្តេចនឹងមានសេចក្តីព្រមព្រៀងគ្នាបាន ចុះអ្នកទាំងឡាយ ហេតុអ្វី ក៏គ្មានសេចក្តីព្រមព្រៀងគ្នាសោះ បើបុគ្គលបាននូវសំឡាញ់ មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន[2] ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នា បុគ្គលនោះ គាបសង្កត់នូវសេចក្តីអន្តរាយទាំងពួងបាន គប្បីជាអ្នកមានសេចក្តីត្រេកអរ មានស្មារតី ត្រាច់ទៅជាមួយនឹងសំឡាញ់នោះចុះ

១ ពួកភិក្ខុដែលឈ្លោះគ្នា ។ ២ អដ្ឋកថាមជ្ឈិមត្រាថា បុគ្គលមានប្រាជ្ញាដើររក្សាសីលឲ្យបរិសុទ្ធ ពិចារណាបច្ច័យមានចីវរជាដើម កំណត់ដឹងនូវសេចក្តីសប្បាយ ៥ យ៉ាង មានសប្បាយដោយអាវាសជាដើម ឈ្មោះថាអ្នកមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ។

នោ ចេ លភេថ និបកំ សហាយំ

សទ្ធិំចរំ សាធុវិហារិ ធីរំ

រាជាវ រដ្ឋំ វិជិតំ បហាយ

ឯកោ ចរេ មាតង្គរញ្ញេវ នាគោ

ឯកស្ស ចរិតំ សេយ្យោ

នត្ថិ ពាលេ សហាយតា

ឯកោ ចរេ ន ច បាបានិ កយិរា

អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោតិ ។





បើបុគ្គល មិនបានបុគ្គលសំឡាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នាទេ បុគ្គលនោះ គួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាព្រះរាជាលះបង់ដែន ដែលខ្លួនឈ្នះហើយ (ត្រាច់ទៅម្នាក់ឯង) ពុំនោះសោត ប្រៀបដូចដំរីប្រសើរ (ត្រាច់ទៅម្នាក់ឯង) ក្នុងព្រៃ ការត្រាច់ទៅ នៃបុគ្គលម្នាក់ឯង ហៅថាល្អប្រសើរ ព្រោះបុគ្គលពាលគ្មានសហាយគុណ[(១)] ទេ មួយទៀត បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង តែជាមិនគួរធ្វើនូវអំពើលាមកឡើយ ដូចដំរីប្រសើរ មានសេចក្តីខ្វល់ខ្វាយតិច (ត្រាច់ទៅតែម្នាក់ឯង) ក្នុងព្រៃ ។

---

១– អង្គធម៌ជាសម្បទាគឺ ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ និងអមតមហានិព្វាន ឈ្មោះថាសហាយគុណ ។

(១០៦) អថខោ ភគវា ឋិតកោវ ឥមា គាថា ភាសិត្វា យេន ពាលកលោណការគាមោ តេនុបសង្កមិ ។ តេន ខោ បន សមយេន អាយស្មា ភគុ ពាលកលោណការគាមេ វិហរតិ ។ អទ្ទសា ខោ អាយស្មា ភគុ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន អាសនំ បញ្ញបេសិ ឧទកញ្ច បាទានំ[១] ។ និសីទិ ភគវា បញ្ញត្តេ អាសនេ និសជ្ជ បាទេ បក្ខាលេសិ ។ អាយស្មាបិ ខោ ភគុ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ភគុំ ភគវា ឯតទវោច កច្ចិ ភិក្ខុ ខមនីយំ កច្ចិ យាបនីយំ កច្ចិ បិណ្ឌកេន ន កិលមសីតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា ន ចាហំ ភន្តេ បិណ្ឌកេន កិលមាមីតិ ។

១ បាទានំ ធោវនន្តិ កត្ថចិ អដ្ឋកថាបោត្ថកេ ទិស្សតិ ។



(១០៦) លុះព្រះមានព្រះភាគ ទ្រង់ព្រះស្ថិត (ឈរ) ពោលគាថា ទាំងនេះរួចហើយ ក៏ទ្រង់ស្តេចទៅ ឯពាលកលោណការគ្រាម ។ សម័យនោះឯង ក៏ដល់ព្រះភគុមានអាយុ គង់នៅក្នុងពាលកលោណការគ្រាមនោះដែរ ។ ឯព្រះភគុមានអាយុ បានឃើញព្រះមានព្រះភាគ ទ្រង់ស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏រៀបក្រាលអាសនៈ រួចតម្កល់ទឹកសម្រាប់លាងព្រះបាទ ។ ព្រះមានព្រះភាគ ក៏ទ្រង់គង់លើអាសនៈ ដែលព្រះភគុមានអាយុក្រាលថ្វាយ លុះគង់ហើយទើបទ្រង់លាងព្រះបាទ ។ ចំណែកព្រះភគុមានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះភគុមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលភិក្ខុ អ្នកល្មមអត់ធន់បានខ្លះឬ ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានខ្លះឬ អ្នកមិនលំបាក ដោយបិណ្ឌបាតខ្លះឬ ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមអត់ធន់បាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស មួយទៀត ខ្ញុំព្រះអង្គមិនលំបាក ដោយបិណ្ឌបាតទេ ។

អថខោ ភគវា អាយស្មន្តំ ភគុំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា យេន បាចីនវំសទាយោ តេនុបសង្កមិ ។

(១១៣) តេន ខោ បន សមយេន អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិម្ពិលោ[1] បាចីនវំសទាយេ វិហរន្តិ ។ អទ្ទសា ខោ ទាយបាលោ[2] ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ភគវន្តំ ឯតទវោច មា សមណ ឯតំ ទាយំ បាវិសិ សន្តេត្ថ តយោ កុលបុត្តា អត្តកាមរូបា វិហរន្តិ មា តេសំ អផាសុមកាសីតិ ។ អស្សោសិ ខោ អាយស្មា អនុរុទ្ធោ ទាយបាលស្ស ភគវតា សទ្ធឹ មន្តយមានស្ស សុត្វាន ទាយបាលំ ឯតទវោច មា អាវុសោ ទាយបាល ភគវន្តំ វារេសិ សត្ថា នោ ភគវា អនុប្បត្តោតិ ។

១ កិម្ពិលោតិបិ ។ ២. ទាយបាលោ ។



វេលានោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ព្រះភគុមានអាយុ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ទ្រង់ក្រោកចាកអាសនៈ ស្ដេចទៅកាន់ព្រៃឈ្មោះបាចីនវំសៈ ។

(១១៣) សម័យនោះឯង ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិម្ពិលៈមានអាយុ គង់នៅក្នុងព្រៃឈ្មោះបាចីនវំសៈនោះ ។ ឯនាយទាយបាល (បុរសជាអ្នករក្សាព្រៃ) បានឃើញព្រះមានព្រះភាគ ទ្រង់ស្ដេចមកអំពីចម្ងាយ លុះឃើញហើយ ក៏ក្រាបបង្គំទូល ព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះសមណៈ ព្រះអង្គកុំស្ដេចចូលទៅកាន់ព្រៃនេះឡើយ ព្រោះមានពួកកុលបុត្រ៣រូប មានសភាពជាអ្នកស្រឡាញ់ខ្លួន នៅក្នុងព្រៃនេះ ព្រះអង្គកុំធ្វើឲ្យកុលបុត្រទាំងនោះ មានសេចក្ដីមិនសប្បាយឡើយ ។ ឯព្រះអនុរុទ្ធមានអាយុ បានឮពាក្យនាយទាយបាល កំពុងនិយាយជាមួយនឹងព្រះមានព្រះភាគ លុះឮហើយ ក៏និយាយទៅនឹងនាយទាយបាល ដូច្នេះថា ម្នាលនាយទាយបាលមានអាយុ អ្នកកុំឃាត់ព្រះមានព្រះភាគឡើយ ព្រោះព្រះមានព្រះភាគជាគ្រូ របស់យើង ព្រះអង្គទ្រង់ស្ដេចមកដល់ហើយ ។

អថខោ អាយស្មា អនុរុទ្ធោ យេនាយស្មា ច នន្ទិយោ អាយស្មា ច កិម្ពិលោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តញ្ច នន្ទិយំ អាយស្មន្តញ្ច កិម្ពិលំ ឯតទវោច អភិក្កមថាយស្មន្តោ អភិក្កមថាយស្មន្តោ សត្ថា នោ ភគវា អនុប្បត្តោតិ ។ អថខោ អាយស្មា ច អនុរុទ្ធោ អាយស្មា ច នន្ទិយោ អាយស្មា ច កិម្ពិលោ ភគវន្តំ បច្ចុគ្គន្ត្វា ឯកោ ភគវតោ បត្តចីវរំ បដិគ្គហេសិ ឯកោ អាសនំ បញ្ញាបេសិ ឯកោ បាទោទកំ ឧបដ្ឋបេសិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ និសជ្ជ ខោ ភគវា បាទេ បក្ខាលេសិ ។ តេបិ ខោ អាយស្មន្តោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។



លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ ចូលទៅរកព្រះនន្ទិយៈមានអាយុ និងព្រះកិម្ពិលៈមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះនន្ទិយៈមានអាយុ និងព្រះកិម្ពិលៈមានអាយុ ដូច្នេះថា នែលោកមានអាយុទាំងឡាយ ចូរលោកទាំងឡាយដើរទៅទទួល នែលោកមានអាយុទាំងឡាយ ចូរលោកទាំងឡាយ ដើរទៅទទួល ព្រោះព្រះមានព្រះភាគជាគ្រូរបស់យើង ព្រះអង្គទ្រង់ស្តេចមកដល់ហើយ ។ គ្រានោះ ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិម្ពិលៈ មានអាយុ ក៏ក្រោកទៅទទួលព្រះមានព្រះភាគ មួយអង្គទទួលបាត្រនិងចីវរនៃព្រះមានព្រះភាគ មួយអង្គរៀបក្រាលអាសនៈ មួយអង្គទៀតតម្កល់ទឹកសម្រាប់លាងព្រះបាទ ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈ ដែលព្រះថេរៈនោះក្រាលថ្វាយ លុះគង់ហើយ ទ្រង់លាងព្រះបាទ ។ ចំណែកលោកមានអាយុទាំងនោះ ក៏នាំគ្នាក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយក្នុងទីសមគួរ ។

(១១៦) ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អនុរុទ្ធំ ភគវា ឯតទវោច កច្ចិ វោ អនុរុទ្ធា ខមនីយំ កច្ចិ យាបនីយំ កច្ចិ បិណ្ឌកេន ន កិលមថាតិ ។ ខមនីយំ ភគវា យាបនីយំ ភគវា ន មយំ ភន្តេ បិណ្ឌកេន កិលមាមាតិ ។ កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរថាតិ ។ តគ្ឃ មយំ ភន្តេ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរាមាតិ ។ យថាកថំ បន តុម្ហេ អនុរុទ្ធា សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរថាតិ ។



(១១៦) លុះព្រះអនុរុទ្ធមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលអនុរុទ្ធទាំងឡាយ[1] អ្នកល្មមអត់ធន់បានទេឬ ល្មមញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅបានស្រួលទេឬ អ្នកទាំងឡាយ មិនលំបាកដោយបិណ្ឌបាតទេឬ ។ ឯព្រះថេរៈទាំង ៣ អង្គ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ យើងខ្ញុំព្រះអង្គ ល្មមអត់ធន់បាន បពិត្រព្រះមានព្រះភាគ យើងខ្ញុំព្រះអង្គ ល្មមញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំព្រះអង្គមិនលំបាកដោយបិណ្ឌបាតទេ ។ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយ បានព្រមព្រៀងស្មោះស្ម័គ្រនឹងគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយនឹងទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ដែរឬ ។ ព្រះករុណាព្រះអង្គ យើងខ្ញុំព្រះអង្គព្រមព្រៀង ស្មោះស្ម័គ្រនឹងគ្នា មិនវិវាទគ្នាទេ ដូចជាទឹកដោះលាយនឹងទឹក សំឡឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់បាន ។ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយ បានព្រមព្រៀង ស្មោះស្ម័គ្រនឹងគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយនឹងទឹក មើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ តើដោយហេតុដូចម្តេចខ្លះ ។

---

១– ទ្រង់ត្រាស់ហៅដូច្នេះ គោរពសំដៅយកព្រះនាមនៃព្រះថេរៈទាំង ៣ ព្រះអង្គ មានអនុរុទ្ធជាដើម ។

(១០៨) ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ លាភា វត មេ សុលទ្ធំ វត មេ យោហំ ឯវរូបេហិ ស-ព្រហ្មចារីហិ សទ្ធឹ វិហរាមីតិ តស្ស មយ្ហំ ភន្តេ ឥមេសុ អាយស្មន្តេសុ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ យន្នូនាហំ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តេយ្យន្តិ សោ ខោ អហំ ភន្តេ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តាមិ នានា ហិ ខោ នោ ភន្តេ កាយា ឯកញ្ច បន មញ្ញេ ចិត្តន្តិ ។



(១០៨) សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា លាភអញ ហ្ន៎ អញជាមានលាភ អត្តភាពជាមនុស្ស ហ្ន៎ អញជាលាភអញបានដោយល្អ ព្រោះថាអញបាននៅជាមួយនឹងសព្រហ្មចារីបុគ្គល មានសភាពយ៉ាងនេះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានតម្កល់កាយកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខនិងទីកំបាំងមុខ បានតម្កល់វចីកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខនិងទីកំបាំងមុខ បានតម្កល់មនោកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខនិងទីកំបាំងមុខ ចំពោះលោកមានអាយុអម្បាលនេះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអញ ដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្ត នៃលោកមានអាយុទាំងនេះវិញ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គក៏បានដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្ត នៃលោកមានអាយុទាំងនេះទៅ សូមទ្រង់ព្រះមេត្តាប្រោស ទោះបើរាងកាយរបស់យើងខ្ញុំព្រះអង្គទាំងឡាយ ផ្សេងគ្នាពិតមែន ប៉ុន្តែចិត្តហាក់ដូចតែមួយ ។

(១១៦) អាយស្មាបិ ខោ នន្ទិយោ អាយស្មាបិ ខោ កិម្ពិលោ ភគវន្តំ ឯតទវោចុំ(១) មយ្ហម្បិ ខោ ភន្តេ ឯវំ ហោតិ លាភា វត មេ សុលទ្ធំ វត មេ យោហំ ឯវរូបេហិ សព្រហ្មចារីហិ សទ្ធឹ វិហរាមីតិ តស្ស មយ្ហំ ភន្តេ ឥមេសុ អាយស្មន្តេសុ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ អាវិ ចេវ រហោ ច តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ យន្នូនាហំ សកំ ចិត្តំ និក្ខិ-បិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តេយ្យន្តិ សោ ខោ អហំ ភន្តេ សកំ ចិត្តំ និក្ខិបិត្វា ឥមេសំយេវ អាយស្មន្តានំ ចិត្តស្ស វសេន វត្តាមិ នានា ហិ ខោ នោ ភន្តេ កាយា

១ ម. ឯតទវោចាតិបិ ទិស្សតិ ។



(១១៦) ឯព្រះនន្ទិយៈ មានអាយុ និងព្រះកិម្ពិលៈ មានអាយុ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រេកអរ យ៉ាងនេះថា លាភអញ ហៅពេញ ជាមានលាភ អត្តភាពជាមនុស្ស ហៅពេញជាអញបានដោយល្អ ព្រោះថា អញបាននៅជាមួយនឹងសព្រហ្មចារីបុគ្គល មានសភាពយ៉ាងនេះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានតម្កល់កាយ-កម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខនិងទីកំបាំងមុខ បានតម្កល់វចីកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខនិងទីកំបាំងមុខ បានតម្កល់មនោកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខនិងទីកំបាំងមុខ ចំពោះលោកមានអាយុអម្បាលនេះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអញ ដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្ត នៃលោកមានអាយុទាំងនេះវិញចុះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គក៏បានដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្ត នៃលោកមានអាយុទាំងនេះវិញទៅ សូមទ្រង់ព្រះមេត្តាប្រោស ទោះបីកាយរបស់យើងខ្ញុំផ្សេងគ្នាក៏ពិតមែន

ឯកញ្ច បន មញ្ញេ ចិត្តន្តិ ។ ឯវំ ខោ មយំ ភន្តេ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ វិហរាមាតិ ។

(១១៧) សាធុ សាធុ អនុរុទ្ធា កច្ចិ បន វោ អនុរុទ្ធា អប្បមត្តា អាតាបិនោ បហិតត្តា វិហរថាតិ ។ តគ្ឃ មយំ ភន្តេ អប្បមត្តា អាតាបិនោ បហិតត្តា វិហរាមាតិ ។ យថាកថំ បន តុម្ហេ អនុរុទ្ធា អប្ប-មត្តា អាតាបិនោ បហិតត្តា វិហរថាតិ ។

(១១៨) ឥធ ភន្តេ អម្ហាកំ យោ បឋមំ គាមតោ បិណ្ឌាយ បដិក្កមតិ សោ អាសនានិ បញ្ញាបេតិ បានីយំ បរិភោជនីយំ ឧបដ្ឋបេតិ អ-វក្ការបាតឹ ឧបដ្ឋបេតិ យោ បច្ឆា គាមតោ បិណ្ឌាយ បដិក្កមតិ សចេ ហោតិ ភុត្តាវសេសោ



ប៉ុន្តែចិត្តហាក់ដូចតែមួយ ។ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំព្រះអង្គព្រមព្រៀងគ្នា រីករាយគ្នា មិនទាស់គ្នា ដូចជាទឹកដោះលាយនឹងទឹក មើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់បាន ដោយហេតុយ៉ាងនេះឯង ។

(១១៧) ម្នាលអនុរុទ្ធទាំងឡាយ ប្រពៃហើយ ប្រពៃហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយ មិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន នៅដែរឬ ។ ព្រះករុណាព្រះអង្គ យើងខ្ញុំព្រះអង្គ មិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយ ដែលមិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន តើដោយហេតុដូចម្តេច ។

(១១៨) សូមទ្រង់ព្រះមេត្តាប្រោស បណ្តាយើងខ្ញុំព្រះអង្គដែលនៅក្នុងទីនេះ បើលោកអង្គណា ត្រឡប់មកអំពីបិណ្ឌបាត ក្នុងស្រុកមុនគេ លោកអង្គនោះ រៀបចំក្រាលអាសនៈ តម្កល់ទឹកឆាន់និងទឹកប្រើប្រាស់ តម្កល់ភាជន៍សម្រាប់ផ្ទេរ លោកអង្គណាត្រឡប់មកអំពីបិណ្ឌបាតក្នុងស្រុក ក្រោយគេ បើមានរបស់ដែលសល់ពីឆាន់

សចេ អាកង្ខតិ ភុញ្ជតិ នោ ចេ អាកង្ខតិ អប្បហរិតេ វា ឆឌ្ឌេតិ អប្បាណកេ វា ឧទកេ ឱបិលាបេតិ សោ អាសនានិ បដិសាមេតិ បានីយំ បរិភោជនីយំ បដិសាមេតិ អវក្ការបាតឹ[១] បដិសាមេតិ ភត្តគ្គំ សម្មជ្ជតិ យោ បស្សតិ បានីយឃដំ វា វច្ចឃដំ វា រិត្តំ តុច្ឆំ សោ ឧបដ្ឋបេតិ សចាស្ស[២] ហោតិ អវិសយ្ហំ ហត្ថវិការេន ទុតិយំ អាមន្តេត្វា ហត្ថ-វិលង្ឃកេន[៣] បានីយឃដំ វា បរិភោជនីយឃដំ វា ឧបដ្ឋបេម ន ត្វេវ មយំ ភន្តេ តប្បច្ចយា វាចំ ភិន្ទាម បញ្ចាហិកំ ខោ បន មយំ ភន្តេ សព្វរត្តិ-យំ ធម្មិយា កថាយ សន្និសីទាម ឯវំ ខោ មយំ ភន្តេ អប្បមត្តា អាតាបិនោ បហិតត្តា វិហរាមាតិ ។

១ ឱ. ម. អវក្ការបាតឹ ធោវិត្វាតិ ទិស្សតិ ។ ២ អវិសយ្ហំ កត្វបិ អសក្កំ ហោតីតិ ទិស្សតិ ។ ៣ ហត្ថវិលង្ឃកេនាតិបិ ទិស្សតិ ។



បើលោកនោះចង់ឆាន់ក៏ឆាន់ចុះ បើមិនចង់ឆាន់ទេ ចាក់ចោលទៅក្នុងទីគ្មានស្មៅស្រស់ក៏បាន ឬបន្សាបទៅក្នុងទឹក ដែលគ្មានសត្វតូចក៏បាន រួចលោកនោះរៀបចំទុកដាក់អាសនៈ រៀបចំទុកដាក់ទឹកសម្រាប់ឆាន់និងទឹកសម្រាប់ប្រើប្រាស់ រៀបចំទុកដាក់ភាជន៍សម្រាប់ផ្ទេរ ហើយបោសសំអាតរោងភត្ត បើលោកណា ឃើញក្អមសម្រាប់ដាក់ទឹកឆាន់ក្តី ក្អមសម្រាប់ដាក់ទឹកលាងវច្ចៈក្តី នៅរលីងទទេ លោកនោះ ក៏តម្កល់ទុកឲ្យមានឡើង បើលោកនោះ មិនអាចនឹងលើកដោយដៃបានទេ យើងខ្ញុំក៏ហៅភិក្ខុមកជួយលើកដោយដៃ ហើយតម្កល់ទុកក្អម សម្រាប់ដាក់ទឹកឆាន់ ឬក្អមសម្រាប់ដាក់ទឹកប្រើប្រាស់ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំព្រះអង្គ មិនដែលបញ្ចេញវាចា ព្រោះហេតុប៉ុណ្ណោះឡើយ សូមទ្រង់ព្រះមេត្តាប្រោស មួយទៀត គ្រប់ប្រាំថ្ងៃហើយ[១] យើងខ្ញុំតែងអង្គុយប្រជុំគ្នាដោយធម្មីកថា អស់រាត្រីទាំងមូល គឺអស់មួយយប់ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំព្រះអង្គ មិនបានប្រហែសធ្វេស ព្យា-យាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

១– បានសេចក្តីថា ៥ ថ្ងៃ ប្រជុំគ្នាម្តង ។

(១៥៩) សាធុ សាធុ អនុរុទ្ធា អត្ថិ បន វោ អនុរុទ្ធា ឯវំ អប្បមត្តានំ អាតាបីនំ បហិតត្តានំ វិហរតំ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសោ អធិគតោ ផាសុវិហារោតិ ។ ឥធ មយំ ភន្តេ អប្បមត្តា អាតាបិនោ បហិតត្តា វិហរន្តា ឱភាសញ្ចេវ សញ្ជានាម ទស្សនញ្ច រូបានំ សោ ខោ បន នោ ឱភាសោ នចិរស្សេវ អន្តរធាយតិ ទស្សនញ្ច រូបានំ តញ្ច និមិត្តំ នប្បដិវិជ្ឈាមាតិ ។

(១៦០) តំ ខោ បន វោ អនុរុទ្ធា និមិត្តំ បដិវិជ្ឈិតព្វំ អហម្បិ សុទំ អនុរុទ្ធា បុព្វេវ សម្ពោធា អនភិសម្ពុទ្ធោ ពោធិសត្តោវ សមានោ ឱភាសញ្ចេវ សញ្ជានាមិ ទស្សនញ្ច រូបានំ ។



(១៥៩) ម្នាលអនុរុទ្ធទាំងឡាយ ប្រពៃហើយ ប្រពៃហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះកាលដែលអ្នកទាំងឡាយ មិនធ្វេសប្រហែស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង៤ យ៉ាងនេះ តើអ្នកទាំងឡាយត្រាស់ដឹងនូវផាសុវិហារធម៌ដ៏វិសេស គឺញាណទស្សនៈដ៏ប្រសើរ ដែលអាចកំចាត់បង់នូវកិលេសដ៏ក្រៃលែងជាងមនុស្សធម៌ មានខ្លះទេ ។ សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះ យើងខ្ញុំព្រះអង្គមិនធ្វេសប្រហែស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ប៉ុន្តែឯពន្លឺ និងការឃើញរូបទាំងឡាយនោះ របស់យើងខ្ញុំព្រះអង្គ មិននៅយូរប៉ុន្មាន ក៏បាត់ទៅវិញ ឯយើងខ្ញុំព្រះអង្គ ក៏មិនបានត្រាស់ដឹងនូវនិមិត្តនោះទេ ។

(១៦០) ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយ គប្បីត្រាស់ដឹងនូវនិមិត្តនោះជាប្រាកដ ម្នាលអនុរុទ្ធទាំងឡាយ ក្នុងកាលមុន អំពីការត្រាស់ដឹង តថាគត មិនទាន់បានត្រាស់ដឹង នៅជាពោធិសត្វនៅឡើយ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ។

សោ ខោ បន មេ ឱភាសោ នចិរស្សេវ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានន្តិ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ វិចិកិច្ឆា ខោ មេ ឧទបាទិ វិចិកិច្ឆាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតីតិ ។

(១២១) សោ ខោ អហំ អនុរុទ្ធា អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ឱភាសញ្ច សញ្ជានាមិ ទស្សនញ្ច រូបានំ ។ សោ ខោ បន មេ ឱភាសោ នចិរស្សេវ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានន្តិ ។



ប៉ុន្តែឯពន្លឺ និងការឃើញរូបទាំងឡាយនោះ របស់តថាគត មិននៅយូរប៉ុន្មាន ក៏បាត់ទៅវិញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះ ដូច្នេះថា ចុះមានហេតុអ្វី បច្ច័យអ្វី ដែលនាំឲ្យពន្លឺនិងការឃើញរូបទាំងឡាយ របស់អាត្មាអញបាត់បង់ទៅ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា វិចិកិច្ឆា (សេចក្តីសង្ស័យ) កើតឡើងដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានវិចិកិច្ឆាជាហេតុ (ជាទោស) កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ វិចិកិច្ឆានឹងកើតឡើងមិនបាន ដល់អាត្មាអញទៀត យ៉ាងណា អាត្មាអញនឹងធ្វើ យ៉ាងនោះ ។

(១២១) ម្នាលអនុរុទ្ធទាំងឡាយ តថាគត មិនបានប្រហែសធ្វេស ព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅ កាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ។ ឯពន្លឺ និងការឃើញរូបទាំងឡាយនោះ របស់តថាគត មិននៅយូរប៉ុន្មាន ក៏បាត់ទៅវិញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា ចុះមានហេតុអ្វី បច្ច័យអ្វី ដែលនាំឲ្យពន្លឺនិងការឃើញរូបទាំងឡាយ របស់អាត្មាអញ បាត់បង់ទៅ ។

តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ អមនសិការោ ខោ មេ ឧទបាទិ អមនសិការាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោតិ ។

(១៦៦) សោ ខោ អហំ អនុរុទ្ធា ។បេ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ ថីនមិទ្ធំ ខោ មេ ឧទបាទិ ថីនមិទ្ធាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោ ន ថីនមិទ្ធន្តិ ។



ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា អមនសិ-ការៈ (ការមិនធ្វើទុកក្នុងចិត្ត) កើតឡើងហើយដល់អាត្មាអញ ឯសមាធិ របស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានអមនសិការៈជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ វិចិកិច្ឆា និងអមនសិការៈ កើតឡើងមិនបាន ដល់អាត្មាអញទៀត យ៉ាងណា អាត្មាអញនឹងធ្វើ យ៉ាងនោះ ។

(១៦៦) ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ថីនមិទ្ធៈ (សេចក្តីងងុយ និងងោកងក់) កើតឡើងហើយដល់អាត្មាអញ ឯសមាធិ របស់អាត្មាអញក៏ឃ្លាតទៅ ព្រោះតែមានថីនមិទ្ធៈជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ វិចិកិច្ឆា អមនសិការៈ និងថីនមិទ្ធៈ កើតឡើងមិនបាន ដល់អាត្មាអញទៀត យ៉ាងណា អាត្មាអញនឹងធ្វើ យ៉ាងនោះ ។

(១៤៣) សោ ខោ អហំ អនុរុទ្ធា ។ បេ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ ឆម្ភិតត្តំ ខោ មេ ឧទបាទិ ឆម្ភិតត្តាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សេយ្យថាបិ អនុរុទ្ធា បុរិសោ អទ្ធានមគ្គប្បដិបន្នោ តស្ស ឧភតោបស្សេ វធកា ឧប្បជ្ជេយ្យុំ តស្ស តតោនិទានំ[១] ឆម្ភិតត្តំ ឧប្បជ្ជេយ្យ ឯវមេវ ខោ មេ អនុរុទ្ធា ឆម្ភិតត្តំ ឧទបាទិ ឆម្ភិតត្តាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ អនុរុទ្ធា តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោ ន ថីនមិទ្ធំ ន ឆម្ភិតត្តន្តិ ។

១ ម. ឧភតោនិទានំ ។



(១៦៣) ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។ បេ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះ ដូច្នេះថា សេចក្តីខ្ទក់កាយ កើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីខ្ទក់កាយជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ ម្នាលអនុរុទ្ធទាំងឡាយ ដូចបុរសដើរផ្លូវឆ្ងាយ ហើយមានពេជ្ឈឃាតនៅតាមផ្លូវទាំងពីរខាង នៃបុរសនោះ ឯសេចក្តីខ្ទក់កាយ ក៏កើតឡើងដល់បុរសនោះ ព្រោះតែនាយពេជ្ឈឃាតនោះជាហេតុ យ៉ាងណាមិញ ម្នាលអនុរុទ្ធទាំងឡាយ សេចក្តីខ្ទក់កាយ កើតឡើងហើយដល់តថាគត ឯសមាធិរបស់តថាគត ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីខ្ទក់កាយជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់ទៅដែរ ក៏យ៉ាងនោះឯង ។ វិចិកិច្ឆា អមនសិការៈ ថីនមិទ្ធៈ និងសេចក្តីខ្ទក់កាយ កើតឡើងមិនបាន ដល់តថាគតទៀត យ៉ាងណា តថាគតនឹងធ្វើ យ៉ាងនោះៗ

(១៤៤) សោ ខោ អហំ អនុរុទ្ធា ។ បេ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ ឧព្ពិលំ ខោ មេ ឧទបាទិ ឧព្ពិលាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សេយ្យថាបិ អនុរុទ្ធា បុរិសោ ឯកំ និធិមុខំ(១) គវេសន្តោ សកិទេវ បញ្ច និធិមុខានិ(២) អធិគច្ឆេយ្យ តស្ស តតោនិទានំ ឧព្ពិលំ ឧប្បជ្ជេយ្យ ឯវមេវ ខោ មេ អនុរុទ្ធា ឧព្ពិលំ ឧទបាទិ ឧព្ពិលាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោ ន ថីនមិទ្ធំ ន ឆម្ភិតត្តំ ន ឧព្ពិលន្តិ ។

---

១ និធិកុម្ភំ ។ ២ និធិកុម្ភានិ ។



(១៤៤) ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។ បេ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីឆ្មើងឆ្មៃកើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីឆ្មើងឆ្មៃជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ ម្នាលអនុរុទ្ធទាំងឡាយ ដូចបុរសស្វែងរកកំណប់ទ្រព្យមួយ ស្រាប់តែបានកំណប់ទ្រព្យ ៥ តែម្តង សេចក្តីឆ្មើងឆ្មៃ គប្បីកើតឡើងដល់បុរសនោះ ព្រោះតែបានកំណប់ទ្រព្យនោះជាហេតុ យ៉ាងណាមិញ ម្នាលអនុរុទ្ធទាំងឡាយ សេចក្តីឆ្មើងឆ្មៃកើតឡើងហើយដល់តថាគត ឯសមាធិរបស់តថាគតក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីឆ្មើងឆ្មៃជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ក៏យ៉ាងនោះឯង ។ វិចិកិច្ឆា អមនសិការៈ ថីនមិទ្ធៈ សេចក្តីខ្ញាក់កាយ និងសេចក្តីឆ្មើងឆ្មៃ កើតឡើងមិនបាន ដល់តថាគតទៀត យ៉ាងណា តថាគតនឹងធ្វើ យ៉ាងនោះ ។

(១៦៥) សោ ខោ អហំ អនុរុទ្ធា ។បេ។ តស្ស មយ្ហំ អនុរុទ្ធា ឯតរហោសិ ទុដ្ឋុល្លំ ខោ មេ ឧទបាទិ ទុដ្ឋុល្លាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោ ន ថីនមិទ្ធំ ន ឆម្ភិតត្តំ ន ឧប្បិលំ ន ទុដ្ឋុល្លន្តិ ។

(១៦៦) សោ ខោ អហំ អនុរុទ្ធា ។បេ។ តស្ស មយ្ហំ អនុរុទ្ធា ឯតរហោសិ អច្ចារទ្ធវីរិយំ ខោ មេ ឧទបាទិ អច្ចារទ្ធវីរិយាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។



(១៦៥) ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីក្រវល់ក្រវាយកាយ កើតឡើងហើយដល់តថាគតឯង ឯសមាធិរបស់តថាគតឯង ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីក្រវល់ក្រវាយកាយជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ វិចិកិច្ឆា អមនសិការៈ ថីនមិទ្ធៈ សេចក្តីរន្ធត់កាយ សេចក្តីឆ្អើនឆ្អៃ និងសេចក្តីក្រវល់ក្រវាយកាយ កើតឡើងមិនបាន ដល់តថាគតទៀត យ៉ាងណា តថាគតនឹងធ្វើ យ៉ាងនោះ ។

(១៦៦) ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីព្យាយាមតឹងហួសពេករបស់តថាគតឯងកើតឡើងហើយ ឯសមាធិរបស់តថាគតឯង ក៏ឃ្លាតទៅព្រោះតែមានសេចក្តីព្យាយាមតឹងហួសពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។

សេយ្យថាបិ អនុរុទ្ធា បុរិសោ ឧភោហិ ហត្ថេហិ វដ្ដកំ គាឡ្ហំ គណ្ហេយ្យ សោ តត្ថេវ មតមេយ្យ ឯវមេវ ខោ មេ អនុរុទ្ធា អច្ចារទ្ធវីរិយំ ឧទបាទិ អច្ចារទ្ធវីរិយាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោ ន ថីនមិទ្ធំ ន ឆម្ភិតត្តំ ន ឧព្ពិលំ ន ទុដ្ឋុល្លំ ន អច្ចារទ្ធវីរិយន្តិ ។

(១៦៧) សោ ខោ អហំ អនុរុទ្ធា ។បេ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ អតិលីនវីរិយំ ខោ មេ ឧទបាទិ អតិលីនវីរិយាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សេយ្យថាបិ អនុរុទ្ធា បុរិសោ វដ្ដកំ សិថិលំ គណ្ហេយ្យ សោ តស្ស ហត្ថតោ ឧប្បតេយ្យ



ម្នាលអនុរុទ្ធទាំងឡាយ ដូចបុរសចាប់សត្វតាបក្តាប់តឹងពេក ដោយដៃទាំងពីរ សត្វតាបនោះ គប្បីស្លាប់ក្នុងដៃនោះមិនខាន យ៉ាងណាមិញ ម្នាលអនុរុទ្ធទាំងឡាយ សេចក្តីព្យាយាមតឹងហួសពេក របស់តថាគតកើតឡើងហើយ ឯសមាធិរបស់តថាគត ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីព្យាយាមតឹងហួសពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយបាត់បង់ទៅដែរ ក៏យ៉ាងនោះឯង ។ វិចិកិច្ឆា អមនសិការៈ ថីនមិទ្ធៈ សេចក្តីខ្នើតកាយ សេចក្តីធ្មើចិត្ត សេចក្តីក្រវល់ក្រវាយកាយ និងសេចក្តីព្យាយាមតឹងហួសពេក កើតឡើងមិនបាន ដល់តថាគតទៀត យ៉ាងណា តថាគតនឹងធ្វើ យ៉ាងនោះ ។

(១៦៧) ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីព្យាយាមធូរពេក របស់អាត្មាអញកើតឡើងហើយ ឯសមាធិ របស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីព្យាយាមធូរពេកជាហេតុ កាលបើសមាធិ ឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ ម្នាលអនុរុទ្ធទាំងឡាយ ដូចបុរសចាប់សត្វតាបស្រាលពេក សត្វតាបនោះ គប្បីហើរទៅអំពីដៃនៃបុរសនោះបាន យ៉ាងណាមិញ

ឯវមេវ ខោ មេ អនុរុទ្ធា អតិលីនវីរិយំ ឧទបាទិ អតិលីនវីរិយាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោ ន ថីនមិទ្ធំ ន ឆម្ភិតត្តំ ន ឧប្បិលំ ន ទុដ្ឋុល្លំ ន អច្ចារទ្ធវីរិយំ ន អតិលីនវីរិយន្តិ ។

(១៦៨) សោ ខោ អហំ អនុរុទ្ធា ។ បេ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ អភិជប្បា ខោ មេ ឧទបាទិ អភិជប្បាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោ ន ថីនមិទ្ធំ ន ឆម្ភិតត្តំ ន ឧប្បិលំ ន ទុដ្ឋុល្លំ ន អច្ចារទ្ធវីរិយំ ន អតិលីនវីរិយំ ន អភិជប្បាតិ ។



ម្នាលអនុរុទ្ធទាំងឡាយ សេចក្ដីព្យាយាមធូរពេក របស់តថាគតកើតឡើងហើយ ឯសមាធិរបស់តថាគតក៏ឃ្លាតទៅ ព្រោះតែមានសេចក្ដីព្យាយាមធូរពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយក៏បាត់ទៅដែរ យ៉ាងនោះឯង ។ វិចិកិច្ឆា អមនសិការៈ ថីនមិទ្ធៈ សេចក្ដីខ្ទក់កាយ សេចក្ដីឆ្អើនខ្ទៃ សេចក្ដីក្រហល់ក្រហាយកាយ សេចក្ដីព្យាយាមតឹងពេក និងសេចក្ដីព្យាយាមធូរពេក កើតឡើងមិនបាន ដល់តថាគតទៀត យ៉ាងណា តថាគតនឹងធ្វើ យ៉ាងនោះ ។

(១៦៨) ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្ដីត្រិះរិះ ដូច្នេះថា សេចក្ដីប្រាថ្នាហួសពេក (តណ្ហា) របស់អាត្មាអញ កើតឡើងហើយ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានសេចក្ដីប្រាថ្នាហួសពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់ទៅដែរ ។ វិចិកិច្ឆា អមនសិការៈ ថីនមិទ្ធៈ សេចក្ដីខ្ទក់កាយ សេចក្ដីឆ្អើនខ្ទៃ សេចក្ដីក្រហល់ក្រហាយកាយ សេចក្ដីព្យាយាមតឹងពេក សេចក្ដីព្យាយាមធូរពេក និងសេចក្ដីប្រាថ្នាហួសពេក កើតឡើងមិនបានដល់អាត្មាអញទៀត យ៉ាងណា អាត្មាអញនឹងធ្វើ យ៉ាងនោះ ។

(១២៩) សោ ខោ អហំ អនុរុទ្ធា ។ បេ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ នានត្តសញ្ញា ខោ មេ ឧទបាទិ នានត្តសញ្ញាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោ ន ថីនមិទ្ធំ ន ឆម្ភិតត្តំ ន ឧព្ពិលំ ន ទុដ្ឋុល្លំ ន អច្ចារទ្ធវីរិយំ ន អតិលីនវីរិយំ ន អភិជប្បា ន នានត្តសញ្ញាតិ ។

(១៣០) សោ ខោ អហំ អនុរុទ្ធា អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ឱភាសញ្ចេវ សញ្ជានាមិ ទស្សនញ្ច រូបានំ ។ សោ ខោ បន មេ ឱភាសោ នចិរស្សេវ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេន មេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានន្តិ ។



(១២៩) ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះដូច្នេះថា នានត្តសញ្ញា (សេចក្តីសំគាល់ផ្សេងៗ) កើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញក៏ឃ្លាតទៅ ព្រោះតែមាននានត្តសញ្ញាជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនៃការឃើញរូបទាំងឡាយ ក៏បាត់ទៅដែរ ។ វិចិកិច្ឆា អមនសិការៈ ថីនមិទ្ធៈ សេចក្តីតក់កាយ សេចក្តីត្មើនិត្ន សេចក្តីក្រវល់ក្រវាយកាយ សេចក្តីព្យាយាមតឹងពេក សេចក្តីព្យាយាមធូរពេក សេចក្តីប្រាថ្នាហួសពេក និងនានត្តសញ្ញា កើតឡើងមិនបានទៀតដល់អាត្មាអញ យ៉ាងណា អាត្មាអញនឹងធ្វើ យ៉ាងនោះ ។

(១៣០) ម្នាលអនុរុទ្ធទាំងឡាយ តថាគត មិនបានប្រហែសធ្វេស ព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តទៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ។ ប៉ុន្តែ ពន្លឺនៃការឃើញរូបទាំងឡាយនោះ របស់តថាគត មិនទៅយូរប៉ុន្មាន ក៏បាត់ទៅវិញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះ ដូច្នេះថា តើមានហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យពន្លឺនៃការឃើញរូបទាំងឡាយ របស់អាត្មាអញបាត់ទៅ ។

តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ អតិនិជ្ឈាយិតត្តំ ខោ មេ រូបានំ ឧទបាទិ អតិនិជ្ឈាយិតត្តាធិករណញ្ច បន មេ សមាធិ ចវិ សមាធិម្ហិ ចុតេ ឱភាសោ អន្តរធាយតិ ទស្សនញ្ច រូបានំ ។ សោហំ តថា ករិស្សាមិ យថា មេ បុន ន វិចិកិច្ឆា ឧប្បជ្ជិស្សតិ ន អមនសិការោ ន ថីនមិទ្ធំ ន ឆម្ភិតត្តំ ន ឧប្បិលំ ន ទុដ្ឋុល្លំ ន អច្ចារទ្ធវីរិយំ ន អតិលីនវីរិយំ ន អភិជប្បា ន នានត្តសញ្ញា ន អតិនិជ្ឈាយិតត្តំ រូបានន្តិ ។

(២៣១) សោ ខោ អហំ អនុរុទ្ធា វិចិកិច្ឆា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា វិចិកិច្ឆំ ចិត្តស្ស ឧបក្កិលេសំ បជហឹ ។ អមនសិការោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អមនសិការំ ចិត្តស្ស ឧបក្កិលេសំ បជហឹ ។ ថីនមិទ្ធំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា



ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះ ដូច្នេះថា ការសំឡឹងមើលនូវរូបក្រៃពេក កើតឡើងហើយដល់តថាគតឯង ឯសមាធិរបស់តថា-គតឯងក៏ឃ្លាតទៅ ព្រោះតែមានការសំឡឹងមើល នូវរូបក្រៃពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់ទៅវិញ ។ វិចិកិច្ឆា អមនសិការៈ ថីនមិទ្ធៈ សេចក្តីរន្ធត់កាយ សេចក្តីត្រេកអរ សេចក្តីក្រហល់ក្រហាយកាយ សេចក្តីព្យាយាមតឹងពេក សេចក្តីព្យាយាមធូរពេក សេចក្តីប្រាថ្នាហួសពេក នានត្តសញ្ញា និងការសំឡឹងមើលនូវរូបក្រៃពេក កើតឡើងមិនបាន ដល់តថាគតឯង យ៉ាងណា តថាគតអញនឹងធ្វើ យ៉ាងនោះ ។

(១៣១) ម្នាលអនុរុទ្ធទាំងឡាយ តថាគតដឹងច្បាស់ថា វិចិកិច្ឆា ជាឧបក្កិលេស (គ្រឿងសៅហ្មង) របស់ចិត្ត ហើយក៏បានលះបង់នូវវិចិកិច្ឆា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា អមនសិការៈជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវអមនសិការៈ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ថីនមិទ្ធៈ ជាឧបក្កិលេស របស់ចិត្ត

ថីនមិទ្ធំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ ឆម្ភិតត្តំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ឆម្ភិតត្តំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ ឧព្ពិលំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ឧព្ពិលំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ ទុដ្ឋុល្លំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ទុដ្ឋុល្លំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ អច្ចារទ្ធវីរិយំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អច្ចារទ្ធវីរិយំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ អតិលីនវីរិយំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អតិលីនវីរិយំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ អភិជប្បា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អភិជប្បំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ នានត្តសញ្ញា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា នានត្តសញ្ញា ចិត្តស្ស ឧបក្កិលេសំ បជហតិ ។ អតិនិជ្ឈាយិតត្តំ រូបានំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អតិនិជ្ឈាយិតត្តំ រូបានំ ចិត្តស្ស ឧបក្កិលេសំ បជហតិ ។



ហើយក៏បានលះបង់ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីខ្ទក់កាយ ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីខ្ទក់កាយ ជាឧបក្កិលេស របស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីឆ្មើងឆ្មៃ ជាឧបក្កិលេស របស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីឆ្មើងឆ្មៃ ជាឧបក្កិលេស របស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេស របស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេស របស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេស របស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា នានត្តសញ្ញា ជាឧបក្កិលេស របស់ចិត្ត ហើយក៏បានលះបង់នូវនានត្តសញ្ញា ជាឧបក្កិលេស របស់ចិត្តចេញ ។ ដឹងច្បាស់ថា ការសំឡឹងមើលនូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវការសំឡឹងមើលនូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។

(១៣៦) សោ ខោ អហំ អនុរុទ្ធា អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ឱភាសំ ហិ ខោ សញ្ជានាមិ ន ច រូបានិ បស្សាមិ រូបានិ ហិ ខោ បស្សាមិ ន ច ឱភាសំ សញ្ជានាមិ កេវលម្បិ រត្តឹ កេវលម្បិ ទិវសំ កេវលម្បិ រត្តិន្ទិវំ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេនាហំ ឱភាសំ ហិ ខោ សញ្ជានាមិ ន ច រូបានិ បស្សាមិ រូបានិ ហិ ខោ បស្សាមិ ន ច ឱភាសំ សញ្ជានាមិ កេវលម្បិ រត្តឹ កេវលម្បិ ទិវសំ កេវលម្បិ រត្តិន្ទិវន្តិ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ យស្មឹ ខោ អហំ សមយេ រូបនិមិត្តំ អមនសិការិត្វា ឱភាសនិមិត្តំ មនសិករោមិ ឱភាសំ ហិ ខោ តស្មឹ សមយេ សញ្ជានាមិ ន ច រូបានិ បស្សាមិ យស្មឹ បនាហំ សមយេ ឱភាសនិមិត្តំ អមនសិការិត្វា



(១៣៦) ម្នាលអនុរុទ្ធទាំងឡាយ តថាគត មិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅ កាន់ព្រះនិព្វាន ប្រព្រឹត្តទៅគ្រប់ឥរិយាបថ ស្គាល់ច្បាស់នូវពន្លឺ តែមិនបានឃើញរូបទាំងឡាយទេ បានឃើញរូបទាំងឡាយ តែមិនបានស្គាល់ច្បាស់នូវពន្លឺទេ ហេតុអស់មួយយប់ក៏មាន ហេតុអស់មួយថ្ងៃក៏មាន ហេតុអស់មួយយប់ មួយថ្ងៃក៏មាន ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្ដីត្រិះរិះ ដូច្នេះថា ចុះមានហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យអាត្មាអញ ស្គាល់ច្បាស់នូវពន្លឺ តែមិនបានឃើញរូបទាំងឡាយ បានឃើញនូវរូបទាំងឡាយ តែមិនបានស្គាល់ច្បាស់នូវពន្លឺ ហេតុអស់មួយយប់ក៏មាន ហេតុអស់មួយថ្ងៃក៏មាន ហេតុអស់មួយយប់ មួយថ្ងៃក៏មាន ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្ដីត្រិះរិះ ដូច្នេះថា សម័យណា អាត្មាអញ មិនបានធ្វើទុកក្នុងចិត្ត នូវរូបនិមិត្ត តែបានធ្វើទុកក្នុងចិត្តនូវឱភាសនិមិត្ត (ពន្លឺ) ប៉ុណ្ណោះ សម័យនោះ អាត្មាអញស្គាល់ច្បាស់នូវពន្លឺ តែមិនបានឃើញរូបទាំងឡាយ មួយទៀត សម័យណា អាត្មាអញ មិនបានធ្វើទុកក្នុងចិត្ត នូវឱភាសនិមិត្ត

រូបនិមិត្តំ មនសិករោមិ រូបានិ ហិ ខោ យស្មិំ សមយេ បស្សាមិ ន ច ឱភាសំ សញ្ជានាមិ កេវលម្បិ រត្តិំ កេវលម្បិ ទិវសំ កេវលម្បិ រត្តិន្ទិវំ ។

(២៣៣) សោ ខោ អហំ អនុរុទ្ធា អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ បរិត្តញ្ចេវ ឱភាសំ សញ្ជានាមិ បរិត្តានិ ច រូបានិ បស្សាមិ អប្បមាណញ្ចេវ ឱភាសំ សញ្ជានាមិ អប្បមាណានិ ច រូបានិ បស្សាមិ កេវលម្បិ រត្តិំ កេវលម្បិ ទិវសំ កេវលម្បិ រត្តិន្ទិវំ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ យេនាហំ បរិត្តញ្ចេវ ឱភាសំ សញ្ជានាមិ បរិត្តានិ ច រូបានិ បស្សាមិ អប្បមាណញ្ចេវ ឱភាសំ សញ្ជានាមិ អប្បមាណានិ ច រូបានិ បស្សាមិ កេវលម្បិ រត្តិំ កេវលម្បិ ទិវសំ



តែបានធ្វើទុកក្នុងចិត្តនូវរូបនិមិត្ត (ប៉ុណ្ណោះ) សម័យនោះ អាត្មាអញ បានឃើញរូបទាំងឡាយ តែមិនបានស្គាល់ច្បាស់នូវពន្លឺឡើយ រហូតអស់មួយយប់ ក៏មាន រហូតអស់មួយថ្ងៃ ក៏មាន រហូតអស់មួយយប់ មួយថ្ងៃក៏មាន ។

(១៧៣) ម្នាលអនុរុទ្ធទាំងឡាយ តថាគត មិនបានប្រមាទ មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅ កាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់ពន្លឺ មានប្រមាណតិចផង ឃើញរូបទាំងឡាយ មានប្រមាណតិចផង ស្គាល់ច្បាស់ពន្លឺប្រមាណ មិនបានផង ឃើញរូបទាំងឡាយ ប្រមាណមិនបានផង រហូតអស់មួយ យប់ក៏មាន រហូតអស់មួយថ្ងៃក៏មាន រហូតអស់មួយយប់ មួយថ្ងៃក៏ មាន ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះ ដូច្នេះថា ចុះមានហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យអាត្មាអញស្គាល់ពន្លឺ មានប្រមាណតិចផង ឃើញរូបទាំងឡាយមានប្រមាណតិចផង ស្គាល់ ច្បាស់នូវពន្លឺ ប្រមាណមិនបានផង ឃើញរូបទាំងឡាយ ប្រមាណ មិនបានផង រហូតអស់មួយយប់ក៏មាន រហូតអស់មួយថ្ងៃក៏មាន រហូត

កេវលម្បិ រត្តិន្ទិវំ ។ តស្ស មយ្ហំ អនុរុទ្ធា ឯត-ទហោសិ យស្មឹ ខោ សមយេ បរិត្តោ មេ(១) សមាធិ ហោតិ បរិត្តំ មេ តស្មឹ(២) សមយេ ចក្ខុ ហោតិ សោហំ បរិត្តេន ចក្ខុនា បរិត្តញ្ចេវ ឱភាសំ សញ្ជា-នាមិ បរិត្តានិ ច រូបានិ បស្សាមិ យស្មឹ បន សមយេ អប្បមាណោ មេ សមាធិ ហោតិ អប្ប-មាណំ មេ តស្មឹ សមយេ ចក្ខុ ហោតិ សោហំ អប្បមាណេន ចក្ខុនា អប្បមាណញ្ចេវ ឱភាសំ សញ្ជានាមិ អប្បមាណានិ ច រូបានិ បស្សាមិ កេវលម្បិ រត្តឹ កេវលម្បិ ទិវសំ កេវលម្បិ រត្តិន្ទិវំ ។ យោ ខោ មេ អនុរុទ្ធា វិចិកិច្ឆា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា វិចិកិច្ឆា ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ អមនសិការោ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា

១ ម. ប. មេតិ នត្ថិ ។ ២ ម. តស្មឹ ។



អស់មួយយប់ មួយថ្ងៃក៏មាន ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគត មានសេចក្តីត្រិះរិះ ដូច្នេះថា សម័យណា សមាធិរបស់តថាគត មានប្រមាណតិច(១) សម័យនោះ ចក្ខុរបស់តថាគត ក៏មានប្រមាណតិច(២)ដែរ ព្រោះតែចក្ខុមានប្រមាណតិច បានជាតថាគតស្គាល់ច្បាស់ពន្លឺ មានប្រមាណតិចផង ឃើញរូបទាំងឡាយ មានប្រមាណតិចផង មួយទៀត សម័យណា សមាធិរបស់តថាគត ប្រមាណមិនបាន សម័យនោះ ចក្ខុរបស់តថាគត ប្រមាណមិនបានដែរ ព្រោះតែចក្ខុប្រមាណមិនបាន បានជាតថាគត ស្គាល់ច្បាស់ពន្លឺប្រមាណមិនបានផង ឃើញរូបទាំងឡាយ ប្រមាណមិនបានផង រហូតអស់មួយយប់ក៏មាន រហូតអស់មួយថ្ងៃក៏មាន រហូតអស់មួយយប់ មួយថ្ងៃក៏មាន ។ ម្នាលអនុរុទ្ធទាំងឡាយ កាលណាបើតថាគតដឹងច្បាស់ថា វិចិកិច្ឆា ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់វិចិកិច្ឆា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា អមនសិការៈ ជាឧបក្កិលេសរបស់ចិត្តហើយ

១– សមាធិដែលថោកថយ ។ ២– ចក្ខុដែលអាប់អន់ ។

អមនសិការោ ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ ថីនមិទ្ធំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ថីនមិទ្ធំ ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ ឆម្ភិតត្តំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ឆម្ភិតត្តំ ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ ឧព្ពិលំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ឧព្ពិលំ ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ ទុដ្ឋុល្លំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា ទុដ្ឋុល្លំ ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ អច្ចារទ្ធវីរិយំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អច្ចារទ្ធវីរិយំ ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ អតិលីនវីរិយំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អតិលីនវីរិយំ ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ អភិជប្បា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អភិជប្បា ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។



ក៏បានលះបង់អមនសិការៈ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីខ្ទក់កាយ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីខ្ទក់កាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីឆ្មើងឆ្មៃ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីឆ្មើងឆ្មៃ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។

នានត្តសញ្ញា ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា នានត្តសញ្ញា ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ អតិនិជ្ឈាយិតត្តំ រូបានំ ចិត្តស្ស ឧបក្កិលេសោតិ ឥតិ វិទិត្វា អតិនិជ្ឈាយិតត្តំ រូបានំ ចិត្តស្ស ឧបក្កិលេសោ បហីនោ អហោសិ ។ តស្ស មយ្ហំ អនុរុទ្ធា ឯតទហោសិ យេ ខោ មេ ចិត្តស្ស ឧបក្កិលេសា តេ មេ បហីនា ហន្ទាទាហំ តិវិធេន សមាធឹ ភាវេសិន្តិ[1] ។

(១៣៦) សោ ខោ អហំ អនុរុទ្ធា សវិតក្កម្បិ សវិចារំ សមាធឹ ភាវេសឹ ។ អវិតក្កម្បិ វិចារមត្តំ សមាធឹ ភាវេសឹ ។ អវិតក្កម្បិ អវិចារំ សមាធឹ ភាវេសឹ ។ សប្បីតិកម្បិ សមាធឹ ភាវេសឹ ។ និប្បីតិកម្បិ សមាធឹ ភាវេសឹ ។ សាតសហ-គតម្បិ សមាធឹ ភាវេសឹ ។ ឧបេក្ខាសហគតម្បិ សមាធឹ ភាវេសឹ ។ យតោ ខោ មេ អនុរុទ្ធា

[1] ឱ, ម, ភាវេមិតិ ។



ដឹងច្បាស់ថា នានត្តសញ្ញា ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់នានត្តសញ្ញា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ការសំឡឹងមើលនូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់ការសំឡឹងមើលនូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ឧបក្កិលេសណា របស់ចិត្តនៃតថាគតឯង ឧបក្កិលេសទាំងនោះ តថាគតឯងបានលះបង់អស់ហើយ បើដូច្នោះមានតែតថាគតឯង ចម្រើននូវសមាធិ ៣ ប្រការ ក្នុងកាលឥឡូវនេះ ។

(១៣៦) ម្នាលអនុរុទ្ធទាំងឡាយ តថាគតក៏បានចម្រើននូវសមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈផង ។ បានចម្រើន នូវសមាធិ មិនមានវិតក្កៈ មានតែវិចារៈផង ។ បានចម្រើននូវសមាធិ មិនមានវិតក្កៈទាំងមិនមានវិចារៈផង ។ បានចម្រើននូវសមាធិ ប្រកបដោយបីតិផង ។ បានចម្រើននូវសមាធិ មិនមានបីតិផង ។ បានចម្រើននូវសមាធិ ប្រកបដោយសេចក្តីសប្បាយផង ។ បានចម្រើននូវសមាធិ ប្រកបដោយឧបេក្ខាផង ។ ម្នាលអនុរុទ្ធទាំងឡាយ កាលបើតថាគត

សវិតក្កោបិ[១] សវិចារោ សមាធិ ភាវិតោ អហោសិ ។ អវិតក្កោបិ[២] វិចារមត្តោ សមាធិ ភាវិតោ អហោសិ ។ អវិតក្កោបិ អវិចារោ សមាធិ ភាវិតោ អហោសិ ។ សប្បីតិកោបិ សមាធិ ភាវិតោ អហោសិ ។ និប្បីតិកោបិ សមាធិ ភាវិតោ អហោសិ ។ សាតសហគតោបិ សមាធិ ភាវិតោ អហោសិ ។ ឧបេក្ខាសហគតោបិ សមាធិ ភាវិតោ អហោសិ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អនុរុទ្ធោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ឧបក្កិលេសសុត្តំ អដ្ឋមំ និដ្ឋិតំ ។

១-២ ម. អបិសទ្ទោ នត្ថិ ។



បានចំរើនសមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈខ្លះហើយ ។ បានចំរើនសមាធិ មិនមានវិតក្កៈ មានតែវិចារៈខ្លះហើយ ។ បានចំរើនសមាធិ មិនមានវិតក្កៈ ទាំងមិនមានវិចារៈខ្លះហើយ ។ បានចំរើនសមាធិ ប្រកបដោយបីតិខ្លះហើយ ។ បានចំរើនសមាធិមិនមានបីតិខ្លះហើយ ។ បានចំរើនសមាធិ ប្រកបដោយសេចក្តីសប្បាយខ្លះហើយ ។ បានចំរើនសមាធិ ប្រកបដោយឧបេក្ខាខ្លះហើយ ។ សេចក្តីដឹង និងសេចក្តីឃើញ ក៏កើតឡើងដល់តថាគតថា វិមុត្តិរបស់តថាគត ជាធម្មជាតិមិនកម្រើក ជាតិរបស់តថាគតនេះ មានក្នុងទីបំផុត ឥឡូវនេះ សេចក្តីកើតទៀតមិនមានឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអនុរុទ្ធមានអាយុ ក៏មានសេចក្តីត្រេកអរ រីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ឧបក្កិលេសសូត្រ ទី ៨ ។

## នវមំ ពាលបណ្ឌិតសុត្តំ

(៤៣៥) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(៤៣៦) ភគវា ឯតទវោច តីណិមានិ ភិក្ខវេ ពាលស្ស ពាលលក្ខណានិ ពាលនិមិត្តានិ ពាលាបទានានិ ។ កតមានិ តីណិ ។ ឥធ ភិក្ខវេ ពាលោ ទុច្ចិន្តិតចិន្តី ច ហោតិ ទុព្ភាសិតភាសី ច[១] ទុក្កដកម្មការី ច[២] ។ នោ ចេតំ ភិក្ខវេ ពាលោ

---
១-២ ឱសក្កា នត្ថិ ។

## ពាលបណ្ឌិតសូត្រ ទី ៩

(១៣៥) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាលព្រះមានព្រះភាគ គង់នៅក្នុងវត្តនោះ បានត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(១៣៦) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មានហេតុជាគ្រឿងចំណាំថាពាល មានហេតុជាគ្រឿងសំគាល់ថាពាល មានចរិតជាពាល ៣ យ៉ាងនេះ ។ ហេតុ ៣ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ក្នុងលោកនេះ ជាអ្នកគិតគំនិតអាក្រក់ ១ និយាយស្តីអាក្រក់ ១ ធ្វើអំពើអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ បុគ្គលពាល ជាអ្នកមិន

ទុច្ចិន្តិតចិន្តី ច អភវិស្ស ទុព្ភាសិតភាសី ច ទុក្កដកម្មការី ច ។ កេន[១] នំ បណ្ឌិតា ជានេយ្យុំ ពាលោ អយំ ភវំ អសប្បុរិសោតិ ។ យស្មា ច ខោ ភិក្ខវេ ពាលោ ទុច្ចិន្តិតចិន្តី ច ហោតិ ទុព្ភាសិតភាសី ច ទុក្កដកម្មការី ច តស្មា នំ បណ្ឌិតា ជានន្តិ ពាលោ អយំ ភវំ អសប្បុរិសោតិ ។ ស ខោ ភិក្ខវេ ពាលោ តិវិធំ ទិដ្ឋេវ ធម្មេ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។

(១៣៧) សចេ ភិក្ខវេ ពាលោ សភាយំ វា និសិន្នោ ហោតិ រថិយាយ វា និសិន្នោ ហោតិ សិង្ឃាដកេ វា និសិន្នោ ហោតិ តត្រ ចេ ជនា តជ្ជំ តស្សារុប្បំ កថំ មន្តេន្តិ ។ សចេ ភិក្ខវេ ពាលោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ

១ ម. តេន ។



គិតគំនិតអាក្រក់ផង មិនចេះនិយាយសំដីអាក្រក់ផង មិនធ្វើអំពើអាក្រក់ផង ទេ ។ តើពួកបណ្ឌិតណា នឹងស្គាល់គេថា អ្នកដ៏ចម្រើននេះ ជាមនុស្សពាល ជាអសប្បុរស ដូច្នេះបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងជាអ្នកគិតគំនិតអាក្រក់ផង និយាយសំដីអាក្រក់ផង ធ្វើអំពើអាក្រក់ផង ព្រោះហេតុណា ហេតុនោះបានជា បណ្ឌិតទាំងឡាយស្គាល់គេថា អ្នកដ៏ចម្រើននេះ ជាមនុស្សពាល ជាអសប្បុរសបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង តែងទទួលទុក្ខ ទោមនស្ស ៣ យ៉ាង ក្នុងបច្ចុប្បន្ននេះ ។

(១៣៧) ម្នាលភិក្ខុទាំងឡាយ បើបុគ្គលពាល អង្គុយក្នុងសាលាក្ដី អង្គុយក្នុងច្រកក្ដី អង្គុយក្នុងផ្លូវបែកជា ៤ ក្ដី ចំណែកពួកជនដែលអង្គុយក្នុងទីបរិស័ទនោះ តែងប្រឹក្សាពាក្យ (ថ្លែងអំពីទោស) ដែលកើតអំពីអំពើនោះ សមគួរដល់អំពើនោះ[១] ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលពាល ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ

១– ប្រឹក្សាអំពីទោសរបស់បញ្ចវេរដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននិងបរលោក ។ អដ្ឋកថា ។

កាមេសុមិច្ឆាចារី ហោតិ មុសាវាទី ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋាយី ហោតិ តត្រ ភិក្ខវេ ពាលស្ស ឯវំ ហោតិ យំ ខោ ជនោ តជ្ជំ តស្សារុប្បំ កថំ មន្តេតិ សំវិជ្ជន្តេវ តេ ធម្មា មយិ អហញ្ច តេសុ ធម្មេសុ សន្ទិស្សាមីតិ ។ ឥទំ ភិក្ខវេ ពាលោ បឋមំ ទិដ្ឋេវ ធម្មេ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។

(១៣៨) បុន ចបរំ ភិក្ខវេ ពាលោ បស្សតិ រាជានោ ចោរំ អាគុចារឹ គហេត្វា វិវិធា កម្មការណា ការេន្តេ កសាហិបិ តាឡេន្តេ វេត្តេហិបិ តាឡេន្តេ អឌ្ឍទណ្ឌកេហិបិ តាឡេន្តេ ហត្ថម្បិ ឆិន្ទន្តេ បាទម្បិ ឆិន្ទន្តេ ហត្ថបាទម្បិ ឆិន្ទន្តេ កណ្ណម្បិ ឆិន្ទន្តេ នាសម្បិ ឆិន្ទន្តេ



ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ និយាយកុហក ជាអ្នកតាំងនៅក្នុងសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងគិតក្នុងពាក្យដែលអ្នកផងនិយាយនោះ យ៉ាងនេះថា អ្នកផងតែងប្រើពាក្យណា ដែលកើតអំពីអំពើនោះ សមគួរដល់អំពើនោះ ធម៌ទាំងឡាយនោះ ក៏មាននៅក្នុងអញផង ខ្លួនអញសោត ក៏ប្រាកដក្នុងធម៌ទាំងនោះផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងទទួលទុក្ខ ទោមនស្ស ទី ១ នេះ ក្នុងបច្ចុប្បន្ន ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពាលឃើញព្រះរាជាទាំងឡាយ ចាប់ចោរ ដែលប្រព្រឹត្តអាក្រក់បានហើយ ក្រោកបង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ឲ្យកាត់ទាំងដៃទាំងជើងខ្លះ ឲ្យកាត់ស្លឹកត្រចៀកខ្លះ ឲ្យកាត់ច្រមុះខ្លះ

កណ្ណនាសម្បិ ឆិន្ទន្តិ ពិលង្គថាលិកម្បិ ករោន្តិ សង្ខមុណ្ឌិកម្បិ ករោន្តិ រាហុមុខម្បិ ករោន្តិ ជោតិមាលិកម្បិ ករោន្តិ ហត្ថប្បជោតិកម្បិ ករោន្តិ ឯរកវត្តិកម្បិ ករោន្តិ ចីរកវាសិកម្បិ ករោន្តិ ឯណេយ្យកម្បិ ករោន្តិ ពលិសមំសិកម្បិ ករោន្តិ កហាបណកម្បិ ករោន្តិ ខារាបតច្ឆិកម្បិ ករោន្តិ បលិឃបរិវត្តិកម្បិ ករោន្តិ បលាលបីឋកម្បិ ករោន្តិ តត្តេនបិ តេលេន ឱសិញ្ចន្តិ សុនខេហិបិ ខាទាបេន្តិ



ខ្លះកាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ឲ្យធ្វើពិលង្គថាលិកកម្ម[១] គឺអំពើដែលគេធ្វើក្បាលឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ឲ្យធ្វើនូវសង្ខមុណ្ឌិកកម្ម[២] គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសំបកស័ង្ខខ្លះ ឲ្យធ្វើរាហុមុខកម្ម[៣] គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូខ្លះ ឲ្យធ្វើនូវជោតិមាលិកកម្ម[៤] គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ឲ្យធ្វើនូវហត្ថប្បជោតិកកម្ម[៥] គឺអំពើដែលគេដុតដៃខ្លះ ឲ្យធ្វើនូវឯរកវត្តិកកម្ម[៦] គឺអំពើដែលគេធ្វើដូចជាគេពន្លាត់ស្បែកពស់ខ្លះ ឲ្យធ្វើនូវចីរកវាសិកកម្ម[៧] គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សំបកឈើខ្លះ ឲ្យធ្វើនូវឯណេយ្យកកម្ម[៨] គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វក្រោយខ្លះ ឲ្យធ្វើនូវពលិសមំសិកកម្ម[៩] គឺអំពើដែលគេឆ្កឹះសាច់ដោយកាំ ឬសន្ទូចខ្លះ ឲ្យធ្វើនូវកហាបណកកម្ម[១០] គឺអំពើដែលគេធ្វើឲ្យខ្លួនសាច់ប្រមាណប៉ុនកហាបណៈមួយ ៗ ខ្លះ ឲ្យធ្វើនូវខារាបតច្ឆិកកម្ម[១១] គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ឲ្យធ្វើនូវពលិឃបរិវត្តិកកម្ម[១២] គឺអំពើដែលគេធ្វើ ឲ្យដូចជាបង្វិលដើមគល់ ឬសសរគោលខ្លះ ឲ្យធ្វើនូវបលាលបីឋកកម្ម[១៣] គឺអំពើដែលគេធ្វើ ឲ្យដូចជាកណ្ដាប់ចំបើងខ្លះ ឲ្យស្រោចដោយប្រេងដ៏ក្ដៅខ្លះ ឲ្យឆ្កែខាំខ្លះ

១ ។ល។ ១៣ មើលន័យលក្ខណៈក្នុងមហាទុក្ខក្ខន្ធសូត្រ ក្នុងគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ បឋមភាគ ទំព័រ ៣៤០ ៣៤១ ។

ជីវន្តម្បិ សូលេ ឧត្តាសេន្តេ អសិនាបិ សីសំ ឆិន្ទន្តេ ។ តត្រ ភិក្ខវេ ពាលស្ស ឯវំ ហោតិ យថារូបានំ ខោ បាបកានំ កម្មានំ ហេតុ រាជានោ ចោរំ អាគុចារឹ គហេត្វា វិវិធា កម្មការណា ការេន្តិ កសាហិបិ តាឡេន្តិ ។ បេ ។ អសិនាបិ សីសំ ឆិន្ទន្តិ ។ សំវិជ្ជន្តេ តេ ធម្មា មយិ អហញ្ច តេសុ ធម្មេសុ សន្ទិស្សាមិ ។ មញ្ចេបិ(១) រាជានោ ជានេយ្យុំ មម្បិ រាជានោ គហេត្វា វិវិធា កម្មការណា ការេយ្យុំ កសាហិបិ តាឡេយ្យុំ ។ បេ ។ ជីវន្តម្បិ សូលេ ឧត្តាសេយ្យុំ អសិនាបិ សីសំ ឆិន្ទេយ្យុន្តិ ។ ឥទម្បិ ភិក្ខវេ ពាលោ ទិដ្ឋេវ ធម្មេ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។

១ ឱ. មហត្ថំ ។



ឲ្យដេកផ្ងារលើឈើអណ្តែតទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលតែងត្រិះរិះក្នុងគំនិតនោះ យ៉ាងនេះ ថា ព្រះរាជាទាំងឡាយ ចាប់ចោរដែលប្រព្រឹត្តអាក្រក់បានហើយ ក្រោយបង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ។ បេ ។ ឲ្យកាត់ក្បាលដោយដាវខ្លះ ព្រោះហេតុតែបាបកម្ម មានសភាពយ៉ាងណាៗ ។ ធម៌ទាំងឡាយនោះ ក៏មាននៅក្នុងអាត្មាអញផង ខ្លួនអញសោត ក៏ប្រាកដក្នុងធម៌ទាំងនោះផង ។ បើព្រះរាជាទាំងឡាយ ជ្រាបនូវអញហើយ មុខជាព្រះរាជាទ្រង់ចាប់អញ ហើយក្រោយបង្គាប់ ឲ្យធ្វើកម្មករណ៍ផ្សេងៗ មិនខាន គឺឲ្យវាយដោយរំពាត់ខ្លះ ។ បេ ។ ឲ្យដេកផ្ងារលើឈើអណ្តែតទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងទទួលទុក្ខ ទោមនស្ស ទី២ នេះឯង ក្នុងបច្ចុប្បន្ន ។

(១៣៨) បុន ចបរំ ភិក្ខវេ ពាលំ បីឋសមារុឡ្ហំ វា មញ្ចសមារុឡ្ហំ វា ឆមាយំ វា សេមានំ យានិស្ស បុព្វេ បាបកានិ កម្មានិ កតានិ កាយេន ទុច្ចរិតានិ វាចាយ ទុច្ចរិតានិ មនសា ទុច្ចរិតានិ តានិស្ស តម្ហិ សមយេ ឱលម្ពន្តិ អជ្ឈោលម្ពន្តិ អភិប្បលម្ពន្តិ ។ សេយ្យថាបិ ភិក្ខវេ មហតំ[១] បព្វតកូដានំ ឆាយា សាយណ្ហសមយំ បឋវិយា ឱលម្ពន្តិ អជ្ឈោលម្ពន្តិ អភិប្បលម្ពន្តិ ឯវមេវ ខោ ភិក្ខវេ ពាលំ បីឋសមារុឡ្ហំ វា មញ្ចសមារុឡ្ហំ វា ឆមាយំ វា សេមានំ យានិស្ស បុព្វេ បាបកានិ កម្មានិ កតានិ កាយេន ទុច្ចរិតានិ វាចាយ ទុច្ចរិតានិ មនសា ទុច្ចរិតានិ តានិស្ស តម្ហិ សមយេ ឱលម្ពន្តិ អជ្ឈោលម្ពន្តិ អភិប្បលម្ពន្តិ ។ តត្រ ភិក្ខវេ ពាលស្ស ឯវំ ហោតិ អកតំ វត មេ

១ ឱ. មហន្តានំ ។



(១៣៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពាល កាលឡើងកាន់តាំងក្តី ឡើងកាន់គ្រែក្តី ដេកលើផែនដីក្តី អំពើអាក្រក់ទាំងឡាយ គឺ ការប្រព្រឹត្តអាក្រក់ដោយកាយ ប្រព្រឹត្តអាក្រក់ដោយវាចា ប្រព្រឹត្តអាក្រក់ដោយចិត្តណា ដែលខ្លួនធ្វើទុកក្នុងកាលមុន អំពើអាក្រក់ទាំងនោះឯង តែងគ្របផ្តាប់ សន្ធប់សង្កិន រួបរឹតរេ ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ ស្រមោលនៃកំពូលភ្នំធំ តែងក្រាលពាសពាល គ្របលើផែនដី ក្នុងវេលាថ្ងៃរសៀល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចបុគ្គលពាល កាលឡើងកាន់តាំងក្តី ឡើងកាន់គ្រែក្តី ដេកលើផែនដីក្តី អំពើអាក្រក់ទាំងឡាយ គឺ ការប្រព្រឹត្តអាក្រក់ដោយកាយ ប្រព្រឹត្តអាក្រក់ដោយវាចា ប្រព្រឹត្តអាក្រក់ដោយចិត្តណា ដែលធ្វើទុកក្នុងកាលមុន អំពើអាក្រក់នោះឯង តែងគ្របផ្តាប់ សន្ធប់សង្កិន រួបរឹតរេ ក្នុងសម័យនោះ ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងគិតក្នុងអារម្មណ៍ ដែលប្រាកដក្នុងចក្ខុទ្វារនោះ យ៉ាងនេះថា អើហ្ន៎ អាត្មាអញមិនបានធ្វើ

កល្យាណំ អកតំ កុសលំ អកតំ ភីរុត្តាណំ កតំ បាបំ កតំ លុទ្ទំ កតំ កិព្វិសំ យាវតា ភោតិ អកតកល្យាណានំ អកតកុសលានំ អកតភីរុត្តាណានំ កតបាបានំ កតលុទ្ទានំ កតកិព្វិសានំ គតិ តំ គតឹ បេច្ច គច្ឆាមីតិ ។ សោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ។ ឥទំ ខោ ភិក្ខវេ ពាលោ តតិយំ ទិដ្ឋេវ ធម្មេ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។

(១៦០) ស ខោ ភិក្ខវេ ពាលោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ យំ ខោ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ ឯកន្តំ អនិដ្ឋំ ឯកន្តំ អកន្តំ ឯកន្តំ អមនាបន្តិ និរយមេវ តំ



អំពើល្អ មិនបានធ្វើកុសល មិនបានធ្វើបុណ្យ សម្រាប់ការពារភ័យទុកសោះ អាត្មាអញធ្វើតែបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើក្តៅក្រហាយទុក ពួកជនដែលមិនបានធ្វើអំពើល្អ មិនបានធ្វើកុសល មិនបានធ្វើបុណ្យ សម្រាប់ការពារភ័យទុក ជាអ្នកបានធ្វើតែអំពើបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើក្តៅក្រហាយទុក រមែងមានគតិណា អាត្មាអញនឹងទៅកាន់គតិនោះ ក្នុងបរលោក ។ បុគ្គលពាលនោះ តែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងទទួលទុក្ខទោមនស្ស ទី ៣ នេះឯង ក្នុងបច្ចុប្បន្ន ។

(១៦០) ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាតនរក ។ ម្នាលភិក្ខុទាំងឡាយ អ្នកដទៃដែលនិយាយតាមហេតុ តែងនិយាយចំពោះទីណាថា ជាទីមិនគួរប្រាថ្នាតែមួយយ៉ាង មិនគួរត្រេកអរតែមួយយ៉ាង មិនគួរពេញចិត្តតែមួយយ៉ាង ដូច្នេះ ទីនោះ គឺនរកនុ៎ះឯង

សម្មា វទមានោ វទេយ្យ ឯកន្តំ អនិដ្ឋំ ឯកន្តំ អកន្តំ ឯកន្តំ អមនាបន្តិ ។ យាវញ្ចិទំ ភិក្ខវេ ឧបមាបិ ន សុករា យាវ ទុក្ខា និរយាតិ ។

(១៤១) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច សក្កា បន[១] ភន្តេ ឧបមា កាតុន្តិ ។ សក្កា ភិក្ខូតិ ភគវា អវោច សេយ្យថាបិ ភិក្ខវេ ចោរំ អាគុចារឹ គហេត្វា រញ្ញោ ទស្សេយ្យុំ អយំ តេ ទេវ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ ។ តមេនំ រាជា ឯវំ វទេយ្យ គច្ឆថ ភោ ឥមំ បុរិសំ បុព្វណ្ហសមយំ សត្តិសតេន ហនថាតិ ។ តមេនំ បុព្វណ្ហសមយំ សត្តិសតេន ហនេយ្យុំ ។

១ ឱ. បន មេតិ ទិស្សតិ ។



ដែលអ្នកផងនិយាយតាមហេតុ តែងនិយាយថា ជាទីមិនគួរប្រាថ្នាតែមួយយ៉ាង មិនគួរត្រេកអរតែមួយយ៉ាង មិនគួរគាប់ចិត្តតែមួយយ៉ាង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មិនងាយនឹងធ្វើឧបមា ឲ្យដល់កម្រិតនរក ដែលមានទុក្ខបានឡើយ ។

(១៤១) កាលបើព្រះអង្គទ្រង់ត្រាស់ យ៉ាងនេះហើយ មានភិក្ខុមួយរូប ក្រាបបង្គំទូលសួរសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គអាចនឹងធ្វើសេចក្តីឧបមាបានឬទេ ។ ព្រះមានព្រះភាគ ត្រាស់តបថា ម្នាលភិក្ខុ តថាគតអាចនឹងធ្វើបាន រួចទ្រង់សំដែងថា ម្នាលភិក្ខុទាំងឡាយ ដូចពួកជនចាប់នូវចោរប្រព្រឹត្តអាក្រក់បានហើយ នាំមកថ្វាយព្រះរាជាទូលថា បពិត្រព្រះសម្មតិទេព អ្នកនេះជាចោរ ប្រព្រឹត្តអាក្រក់ចំពោះព្រះអង្គ បើទ្រង់សព្វព្រះហឫទ័យនឹងដាក់អាជ្ញាណា ដល់ចោរនេះ សូមទ្រង់ដាក់អាជ្ញាទោសចុះ ។ ព្រះរាជាមានព្រះឱង្ការ យ៉ាងនេះថា នែប្រិយស្គ ចូរអ្នកទាំងឡាយ ទៅយកលំពែងមួយរយ ចាក់បុរសនេះ ក្នុងវេលាព្រឹកព្រហាមចុះ ។ ពួកជនក៏យកលំពែងមួយរយ ចាក់បុរសនោះ ក្នុងវេលាព្រឹកព្រហាម ។

អថ រាជា មជ្ឈន្តិកសមយំ ឯវំ វទេយ្យ អម្ភោ កថំ សោ បុរិសោតិ ។ តថេវ ទេវ ជីវតីតិ ។ តមេនំ រាជា ឯវំ វទេយ្យ គច្ឆថ ភោ តំ បុរិសំ មជ្ឈន្តិកសមយំ សត្តិសតេន ហនថាតិ ។ តមេនំ មជ្ឈន្តិកសមយំ សត្តិសតេន ហនេយ្យុំ ។ អថ រាជា សាយណ្ហសមយំ ឯវំ វទេយ្យ អម្ភោ កថំ សោ បុរិសោតិ ។ តថេវ ទេវ ជីវតីតិ ។ តមេនំ រាជា ឯវំ វទេយ្យ គច្ឆថ ភោ តំ បុរិសំ សាយណ្ហសមយំ សត្តិសតេន ហនថាតិ ។ តមេនំ សាយណ្ហសមយំ សត្តិសតេន ហនេយ្យុំ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ បុរិសោ ទិវសំ តីហិ សត្តិសតេហិ ហញ្ញមានោ តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទិយេថាតិ ។ ឯកិស្សាបិ ភន្តេ សត្តិយា ហញ្ញមានោ សោ បុរិសោ តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទិយេថ កោ បន វាទោ តីហិ សត្តិសតេហីតិ ។



លុះវេលាថ្ងៃត្រង់ ព្រះរាជាមានព្រះឱង្ការសួរ យ៉ាងនេះថា នែប្រាស្តន ចុះបុរសនោះ តើដូចម្តេចទៅ ។ ពួករាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសនោះរស់នៅឡើយទេ ។ ព្រះរាជាត្រាស់បង្គាប់ យ៉ាងនេះថា នែប្រាស្តន ចូរអ្នកទាំងឡាយ ទៅយកលំពែងមួយរយ ចាក់បុរសនោះ ក្នុងវេលាថ្ងៃត្រង់ចុះ ។ ពួករាជបុរស យកលំពែងមួយរយ ចាក់បុរសនោះ ក្នុងវេលាថ្ងៃត្រង់ ។ លុះវេលាថ្ងៃរសៀល ព្រះរាជាក៏មានព្រះឱង្ការសួរ យ៉ាងនេះថា នែប្រាស្តន ចុះបុរសនោះ តើដូចម្តេចទៅ ។ ពួករាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសនោះរស់នៅឡើយទេ ។ ព្រះរាជាមានព្រះឱង្ការបង្គាប់ យ៉ាងនេះថា នែប្រាស្តន ចូរអ្នកទាំងឡាយ ទៅយកលំពែងមួយរយ ចាក់បុរសនោះ ក្នុងវេលាថ្ងៃរសៀលចុះ ។ លុះវេលាថ្ងៃរសៀល ពួករាជបុរស ក៏យកលំពែងមួយរយ ចាក់បុរសនោះទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់សេចក្តីនោះ ថាដូចម្តេច បុរសនោះកាលបើគេចាក់ ដោយលំពែងបីរយ តើនឹងទទួលទុក្ខ ទោមនស្ស ព្រោះលំពែងនោះជាហេតុ ដែរឬទេ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន បុរសនោះសូម្បីគេចាក់ដោយលំពែងតែមួយ ក៏ទទួលទុក្ខ ទោមនស្ស ព្រោះលំពែងនោះជាហេតុទៅហើយ ចាំបាច់និយាយថ្វីដល់ទៅចាក់ ដោយលំពែងបីរយ ។

(១៦២) អថខោ ភគវា បរិត្តំ បាណិមត្តំ បាសាណំ គហេត្វា ភិក្ខូ អាមន្តេសិ តំ កឹ មញ្ញថ ភិក្ខវេ កតមោ នុ ខោ មហន្តតរោ យោ ចាយំ មយា បរិត្តោ បាណិមត្តោ បាសាណោ គហិតោ ហិមវា បព្វតរាជាតិ ។ អប្បមត្តកោ(១) អយំ ភន្តេ ភគវតា បរិត្តោ បាណិមត្តោ បាសាណោ គហិតោ ហិមវន្តំ បព្វតរាជានំ ឧបនិធាយ សង្ខម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតីតិ ។ ឯវមេវ(២) ភិក្ខវេ យំ(៣) បុរិសោ តីហិ សត្តិសតេហិ ហញ្ញមានោ តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ តំ នេរយិកស្ស ទុក្ខស្ស ឧបនិធាយ សង្ខម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតិ ។

---

១ ឱ. អប្បមត្តោ ខោតិ ទិស្សតិ ។ ២ ឱ. ម. ឯវមេវ ខោ ។ ៣ ឱ. ម យំ សោ ។



(១៦២) គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចាប់ថ្មតូច ប្រមាណប៉ុនបាតដៃ ហើយត្រាស់សួរភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះ ថាដូចម្តេច ថ្មតូចប្រមាណប៉ុនបាតដៃ ដែលតថាគតកំពុងកាន់នេះ និងស្តេចភ្នំហិមពាន្ត តើណាធំជាង ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ថ្មតូចប្រមាណប៉ុនបាតដៃ ដែលព្រះអង្គកំពុងកាន់នេះ តូចពេកណាស់ ប្រៀបផ្ទឹមនឹងស្តេចភ្នំហិមពាន្តនោះ មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូចជាបុរសដែលគេចាក់ដោយលំពែងបីរយ រមែងវេទទុក្ខ ទោមនស្សណា ព្រោះលំពែងនោះជាហេតុ ។ ទុក្ខនោះឯង ប្រៀបផ្ទឹមនឹងទុក្ខ របស់នរក ក៏មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ។

(១៦៣) តមេនំ ភិក្ខវេ និរយបាលា បញ្ចវិធពន្ធនំ នាម ការណំ ការេន្តិ ។ តត្តំ អយោខីលំ ហត្ថេ គមេន្តិ តត្តំ អយោខីលំ ទុតិយេ ហត្ថេ គមេន្តិ តត្តំ អយោខីលំ បាទេ គមេន្តិ តត្តំ អយោខីលំ ទុតិយេ បាទេ គមេន្តិ តត្តំ អយោខីលំ មជ្ឈេ ឧរស្មឹ គមេន្តិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ តមេនំ ភិក្ខវេ និរយបាលា សំវេសេត្វា កុឋារីហិ(១) តច្ឆន្តិ ។ សោ តត្ថ ទុក្ខា តិព្វា ។ បេ ។ ព្យន្តីហោតិ តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា វាសីហិ តច្ឆន្តិ ។

១ ម. កុឋារីហិ ។



(១៦៣) ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល តែងធ្វើកម្មករណ៍ឈ្មោះ បញ្ចវិធពន្ធនៈ (ចំណង៥ប្រការ) ចំពោះសត្វនរកនោះ ។ គឺដោត (សត្វនរកនោះ) ហើយបោះដែកគោលដ៏ក្តៅ ត្រង់ដៃ (ខាងស្តាំ)១ បោះដែកគោលដ៏ក្តៅ ត្រង់ដៃខាងឆ្វេង១ បោះដែកគោលដ៏ក្តៅ ត្រង់ជើង (ខាងស្តាំ)១ បោះដែកគោលដ៏ក្តៅ ត្រង់ជើងខាងឆ្វេង១ បោះដែកគោលដ៏ក្តៅ ចំកណ្តាលទ្រូង១ ។ សត្វនោះរងទុក្ខវេទនា ក្លាខ្លាំង ក្តៅក្រហាយ ក្នុងទីនោះ បើបាបកម្មនោះ មិនទាន់អស់ដរាបណា ក៏មិនធ្វើមរណកាល ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ លុះពួកនិរយបាល ផ្តួលសត្វនរកនោះ ឲ្យដេកហើយ ទើបយកដឹងចាំង ។ សត្វនោះ ក៏រងទុក្ខវេទនា ក្លាខ្លាំង ក្នុងទីនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលចាប់សត្វនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយប្រាសដោយកាំបិតព្រា ។

សោ តត្ថ ទុក្ខា តិព្វា ។ បេ ។ ព្យន្តីហោតិ ។ តមេនំ ភិក្ខវេ និរយបាលា រថេ យោជេត្វា អាទិត្តាយ បឋវិយា សម្បជ្ជលិតាយ សជោ-តិភូតាយ សារេន្តិបិ បច្ចាសារេន្តិបិ[១] ។ សោ តត្ថ ទុក្ខា តិព្វា ។ បេ ។ ព្យន្តីហោតិ ។ តមេនំ ភិក្ខវេ និរយបាលា មហន្តំ អង្គារបព្វតំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អារោបេន្តិបិ ឱរោបេន្តិបិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាប-កម្មំ ព្យន្តីហោតិ ។ តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា តត្តាយ លោហកុម្ភិយា បក្ខិបន្តិ អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូ-តាយ ។ សោ តត្ថ ផេណុទ្ទេហកំ បច្ចតិ ។ សោ

១ កត្ថចិ អដ្ឋកំ ពោត្ថកេ ហរេន្តិបិ បច្ចាហរេន្តិបីតិ ទិស្សតិ ។



សត្វនោះ ក៏សោយទុក្ខវេទនា ក្លាខ្លាំង ក្នុងទីនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ទឹមសត្វនោះនឹងរថ ហើយបរទៅបរមកលើផ្ទៃផែនដី ដែលភ្លើងកំពុងឆេះសព្វ ក៏សន្ធោសន្ធៅ ព្រោលផ្លោ ។ សត្វនោះ ក៏សោយទុក្ខវេទនា ក្លាខ្លាំង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយ-បាល ប្រើសត្វនោះឲ្យឡើងផង ឲ្យចុះមកវិញផង នូវភ្នំរងើកភ្លើងដ៏ធំ ដែលកំពុងឆេះក្តៅសព្វ ក៏សន្ធោសន្ធៅ ព្រោលផ្លោ ។ សត្វនោះ សោយទុក្ខវេទនា ក្លាខ្លាំង ក្តៅផ្សាក្នុងទីនោះ បើបាបកម្មនោះ មិនទាន់អស់ដរាបណា គឺមិនធ្វើមរណកាលដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់សត្វនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ទំលាក់ទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះក្តៅសព្វ ក៏សន្ធោសន្ធៅ ព្រោលផ្លោ ។ សត្វនោះ ឆេះឆ្អិនក៏ស្លុលពពុះ ក្នុងខ្ទះទង់ដែងនោះ ។ កាលសត្វនោះ

តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិម្បិ ឧទ្ធំ គច្ឆតិ សកិម្បិ អធោ គច្ឆតិ សកិម្បិ តិរិយំ គច្ឆតិ ។ សោ តត្ថ ទុក្ខា តិព្វា ខរា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ តមេនំ ភិក្ខវេ និរយបាលា មហានិរយេ បក្ខិបន្តិ ។ សោ ខោ បន ភិក្ខវេ មហានិរយោ

ចតុក្កណ្ណោ ចតុទ្វារោ
វិភត្តោ ភាគសោ មិតោ
អយោបាការបរិយន្តោ
អយសា បដិកុជ្ជិតោ ។
តស្ស អយោមយា ភូមិ
ជលិតា តេជសា យុតា
សមន្តា យោជនសតំ
ផរិត្វា តិដ្ឋតិ សព្វទា ។

អនេកបរិយាយេនបិ ខោ អហំ ភិក្ខវេ និរយកថំ កថេយ្យំ ។ យាវញ្ចិទំ ភិក្ខវេ ន សុករំ អក្ខានេន បាបុណិតុំ យាវ ទុក្ខា និរយា ។



នោះនឹងពុះសុសលពពុះ ក្នុងខ្ទះទង់ដែងនោះ ខ្លះកាលអណ្តែតឡើងលើផ្ទៃ ខ្លះកាលអណ្តែតចុះក្រោមផ្ទៃ ខ្លះកាលអណ្តែតទទឹងផ្ទៃ ។ សត្វនោះ សោយទុក្ខវេទនា ក្លាខ្លាំង ក្តៅក្រហាយក្នុងខ្ទះទង់ដែងនោះ បើបាបកម្មនោះ មិនទាន់អស់ ដរាបណា ក៏មិនទាន់ធ្វើមរណកាលដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏បោះបង់សត្វនោះ ទៅក្នុងមហានរក ។ ម្នាលភិក្ខុទាំងឡាយ មហានរកនោះសោត

មានជ្រុងបួន មានទ្វារបួន ចែកចែកដោយចំណែក ។ មាន
របងដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ។ ផ្ទៃក្រោមនៃម-
ហានរកនោះសុទ្ធតែដែក មានភ្លើងឆេះព្រោលព្រាលផ្សាយ
ទៅបានមួយរយយោជន៍ជុំវិញ តាំងនៅសព្វ ៗ កាល ។

ម្នាលភិក្ខុទាំងឡាយ តថាគតនិយាយ រឿងរ៉ាវ នរក ដោយអនេកបរិយាយទៅ ក៏បាន ។ ម្នាលភិក្ខុទាំងឡាយ តែដំណើរដែលតថាគតពណ៌នាទៅ មិនងាយនឹងដល់កម្រិតនរក ដែលមានទុក្ខបានឡើយ ។

(១៦៦) សន្តិ ភិក្ខវេ តិរច្ឆានគតា បាណា តិណភក្ខា ។ តេ អល្លានិបិ តិណានិ ទន្តុល្លេហកំ[1] ខាទន្តិ ។ កតមេ ច ភិក្ខវេ តិរច្ឆានគតា បាណា តិណភក្ខា[2] អស្សា គោណា គទ្រភា អជា មិគា យេ វា បនញ្ញេបិ កេចិ តិរច្ឆានគតា បាណា តិណភក្ខា ។ ស ខោ សោ ភិក្ខវេ ពាលោ ឥធ បុព្វេ រសាទោ ឥធ បាបានិ កម្មានិ ករិត្វា កាយស្ស ភេទា បរម្មរណា តេសំ សត្តានំ សហព្យតំ ឧបបជ្ជតិ យេ តេ សត្តា តិណភក្ខា ។

(១៦៧) សន្តិ ភិក្ខវេ តិរច្ឆានគតា បាណា គូថភក្ខា ។ តេ ទូរតោ វ គូថគន្ធំ ឃាយិត្វា ធាវន្តិ ឯត្ថ ភុញ្ជិស្សាម ឯត្ថ ភុញ្ជិស្សាមាតិ ។ សេយ្យថាបិ នាម ព្រាហ្មណា អាហុតិគន្ធេន ធាវន្តិ ឯត្ថ ភុញ្ជិស្សាម ឯត្ថ ភុញ្ជិស្សាមាតិ ឯវមេវ ខោ សន្តិ ភិក្ខវេ តិរច្ឆានគតា បាណា

១ ឱ. អល្លានិបិ តិណានិ សុក្ខានិ ទន្តុល្លេហកន្តិ ទិស្សតិ ។ ម. អល្លានិបិ តិណានិ សុក្ខានិបិ តិណានិ ទន្តុល្លេហកន្តិ ទិស្សតិ ។ ២ ម. ឯត្ថន្តរេ ហត្ថីតិ ទិស្សតិ ។



(១៦៦) ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន (ខ្លះ) មានស្មៅជាអាហារ ។ ពួកសត្វតិរច្ឆានទាំងនោះ រមែងស៊ីស្មៅស្រស់ ខ្ទើប ក្តាំដោយធ្មេញ ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកសត្វតិរច្ឆាន ដែលមានស្មៅជាអាហារ តើអ្វីខ្លះ គឺ សេះ គោ លា ពពែ ម្រឹគ ឬសត្វតិរច្ឆានណាមួយ ដទៃទៀត ដែលមានស្មៅជាអាហារដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ជាអ្នកជាប់នឹងរសអាហារ ក្នុងកាលពីមុន ក្នុងលោកនេះ ហើយធ្វើកម្មដ៏លាមក ក្នុងលោកនេះ លុះបែកធ្លាយនៃកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកសត្វ ដែលមានស្មៅជាអាហារនោះ ។

(១៦៧) ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន (ខ្លះ) មានលាមកជាអាហារ ។ ពួកសត្វតិរច្ឆានទាំងនោះ គ្រាន់តែធុំក្លិនលាមកអំពីចម្ងាយ ក៏ស្ទុះទៅដោយគិតថា យើងនឹងស៊ី ក្នុងទីនុ៎ះ យើងនឹងស៊ី ក្នុងទីនុ៎ះ ។ ពួកព្រាហ្មណ៍ តែងស្ទុះទៅតាមក្លិននៃគ្រឿងបូជា ដោយគិតថា យើងនឹងបរិភោគ ក្នុងទីនុ៎ះ យើងនឹងបរិភោគ ក្នុងទីនុ៎ះ សេចក្តីនេះ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆាន

គូថភក្ខា តេ ទូរតោ វ គូថគន្ធំ ឃាយិត្វា ធាវន្តិ ឯត្ថ ភុញ្ជិស្សាម ឯត្ថ ភុញ្ជិស្សាមាតិ ។ កតមេ ច ភិក្ខវេ តិរច្ឆានគតា បាណា គូថភក្ខា កុក្កុដា សូករា សោណា សិង្គាលា យេ វា បនញ្ញេបិ កេចិ តិរច្ឆានគតា បាណា គូថភក្ខា ។ ស ខោ សោ ភិក្ខវេ ពាលោ ឥធ បុព្វេ រសាទោ ឥធ បាបានិ កម្មានិ ករិត្វា កាយស្ស ភេទា បរម្មរណា តេសំ សត្តានំ សហព្យតំ ឧបបជ្ជតិ យេ តេ សត្តា គូថភក្ខា ។

(១៦៦) សន្តិ ភិក្ខវេ តិរច្ឆានគតា បាណា អន្ធការេ ជាយន្តិ អន្ធការេ ជីយន្តិ អន្ធការេ មីយន្តិ ។ កតមេ ច ភិក្ខវេ តិរច្ឆានគតា បាណា អន្ធការេ ជាយន្តិ អន្ធការេ ជីយន្តិ អន្ធការេ មីយន្តិ កីដា បដង្គា(១) គណ្ឌុប្បាទា យេ វា បនញ្ញេបិ កេចិ តិរច្ឆានគតា បាណា អន្ធការេ ជាយន្តិ អន្ធការេ ជីយន្តិ អន្ធការេ មីយន្តិ ។

---
១ ម. ពុឡុក ។



ដែលមានលាមកជាអាហារ ពួកសត្វតិរច្ឆានទាំងនោះ គ្រាន់តែធំក្លិនលាមក អំពីចម្ងាយ ក៏ស្ទុះទៅដោយគិតថា យើងនឹងស៊ីក្នុងទីនុ៎ះ យើងនឹងស៊ីក្នុងទីនុ៎ះ ក៏មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆានដែលមានលាមកជាអាហារ តើដូចម្តេច គឺមាន់ ជ្រូក ឆ្កែ ចចក ឬពួកសត្វតិរច្ឆានណាមួយក្រៅពីនេះទៀត ដែលមានលាមកជាអាហារដូចគ្នា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ជាអ្នកជាប់ចិត្តនឹងរសអាហារក្នុងកាលមុន ក្នុងលោកនេះ ហើយធ្វើនូវកម្មដ៏លាមកក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកសត្វដែលមានលាមកជាអាហារនោះ ។

(១៦៦) ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន កើតក្នុងទីងងឹត ចាស់ក្នុងទីងងឹត ស្លាប់ក្នុងទីងងឹត ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកសត្វតិរច្ឆាន កើតក្នុងទីងងឹត ចាស់ក្នុងទីងងឹត ស្លាប់ក្នុងទីងងឹត តើដូចម្តេច គឺ កន្លាត ពក ដង្កូវ ឬពួកសត្វតិរច្ឆានណាមួយក្រៅពីនេះទៀត ដែលកើតក្នុងទីងងឹត ចាស់ក្នុងទីងងឹត ស្លាប់ក្នុងទីងងឹតដែរ ។

ស ចេ សោ ភិក្ខវេ ពាលោ ឥធ បុព្វេ រសាទោ ឥធ បាបានិ កម្មានិ ករិត្វា កាយស្ស ភេទា បរម្មរណា តេសំ សត្តានំ សហព្យតំ ឧបបជ្ជតិ យេ តេ សត្តា អន្ធការេ ជាយន្តិ អន្ធការេ ជីយន្តិ អន្ធការេ មីយន្តិ ។

(១៤៧) សន្តិ ភិក្ខវេ តិរច្ឆានគតា បាណា ឧទកស្មឹ ជាយន្តិ ឧទកស្មឹ ជីយន្តិ ឧទកស្មឹ មីយន្តិ ។ កតមេ ច ភិក្ខវេ តិរច្ឆានគតា បាណា ឧទកស្មឹ ជាយន្តិ ឧទកស្មឹ ជីយន្តិ ឧទកស្មឹ មីយន្តិ មច្ឆា កច្ឆបា សុំសុមារា យេ វា បនញ្ញេបិ កេចិ តិរច្ឆានគតា បាណា ឧទកស្មឹ ជាយន្តិ ឧទកស្មឹ ជីយន្តិ ឧទកស្មឹ មីយន្តិ ។ ស ចេ សោ ភិក្ខវេ ពាលោ ឥធ បុព្វេ រសាទោ ឥធ បាបានិ កម្មានិ ករិត្វា កាយស្ស ភេទា បរម្មរណា តេសំ សត្តានំ សហព្យតំ ឧបបជ្ជតិ យេ តេ សត្តា ឧទកស្មឹ ជាយន្តិ ឧទកស្មឹ ជីយន្តិ ឧទកស្មឹ មីយន្តិ ។



ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ជាអ្នកជាប់ចំណីរសអាហារ ក្នុងកាលមុន ក្នុងលោកនេះ ហើយធ្វើកម្មដ៏លាមក ក្នុងលោកនេះ លុះបែកធ្លាយនៃកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកសត្វ ដែលកើតក្នុងទីងងឹត ចាស់ក្នុងទីងងឹត ស្លាប់ក្នុងទីងងឹតនោះ ។

(១៤៧) ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន កើតក្នុងទឹក ចាស់ក្នុងទឹក ស្លាប់ក្នុងទឹក ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកសត្វតិរច្ឆាន កើតក្នុងទឹក ចាស់ក្នុងទឹក ស្លាប់ក្នុងទឹក តើអ្វីខ្លះ គឺ ត្រី អណ្តើក ក្រពើ ឬពួកសត្វតិរច្ឆានណាមួយក្រៅពីនេះទៀត ដែលកើតក្នុងទឹក ចាស់ក្នុងទឹក ស្លាប់ក្នុងទឹកដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ជាអ្នកជាប់ចំណីរសអាហារក្នុងកាលមុន ក្នុងលោកនេះ ហើយធ្វើនូវកម្មដ៏លាមក ក្នុងលោកនេះ លុះបែកធ្លាយនៃកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកសត្វ ដែលកើតក្នុងទឹក ចាស់ក្នុងទឹក ស្លាប់ក្នុងទឹកនោះ ។

(១៥៨) សន្តិ ភិក្ខវេ តិរច្ឆានគតា បាណា អសុចិស្មឹ ជាយន្តិ អសុចិស្មឹ ជីយន្តិ អសុចិស្មឹ មីយន្តិ ។ កតមេ ច ភិក្ខវេ តិរច្ឆានគតា បាណា អសុចិស្មឹ ជាយន្តិ អសុចិស្មឹ ជីយន្តិ អសុចិស្មឹ មីយន្តិ ។ យេ តេ ភិក្ខវេ សត្តា បូតិមច្ឆេ វា ជាយន្តិ បូតិមច្ឆេ វា ជីយន្តិ បូតិមច្ឆេ វា មីយន្តិ បូតិកុណបេ វា ... បូតិកុម្មាសេ វា ... ចន្ទនិកាយ វា ... ឱលិគល្លេ វា ជាយន្តិ ។ បេ ។ យេ វា បនញ្ញេបិ កេចិ តិរច្ឆានគតា បាណា អសុចិស្មឹ ជាយន្តិ អសុចិស្មឹ ជីយន្តិ អសុចិស្មឹ មីយន្តិ ។ ស ខោ សោ ភិក្ខវេ ពាលោ ឥធ បុព្វេ រសាទោ ឥធ បាបានិ កម្មានិ ករិត្វា កាយស្ស ភេទា បរម្មរណា តេសំ សត្តានំ សហព្យតំ ឧបបជ្ជតិ យេ តេ សត្តា អសុចិស្មឹ ជាយន្តិ អសុចិស្មឹ ជីយន្តិ



(១៥៨) ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន កើតក្នុងទីមិនស្អាត ចាស់ក្នុងទីមិនស្អាត ស្លាប់ក្នុងទីមិនស្អាត ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆាន កើតក្នុងទីមិនស្អាត ចាស់ក្នុងទីមិនស្អាត ស្លាប់ក្នុងទីមិនស្អាត តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ ដែលកើត ក្នុងត្រីស្អុយក៏មាន ចាស់ក្នុងត្រីស្អុយក៏មាន ស្លាប់ក្នុងត្រីស្អុយក៏មាន ក្នុងសាកសពស្អុយក៏មាន ... ក្នុងនំស្អុយក៏មាន ... ក្នុងរណ្តៅជ្រាំក៏មាន ... កើតក្នុងប្រឡាយបង្ហូរជ្រាំក៏មាន ។ បេ ។ ឬក៏ពួកសត្វតិរច្ឆានណាមួយក្រៅពីនេះទៀត ដែលកើតក្នុងទីមិនស្អាត ចាស់ក្នុងទីមិនស្អាត ស្លាប់ក្នុងទីមិនស្អាតដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ជាអ្នកជាប់នឹងរសអាហារក្នុងកាលមុន ក្នុងលោកនេះ ហើយធ្វើនូវកម្មដ៏លាមក ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកសត្វ ដែលកើតក្នុងទីមិនស្អាត

អសុចិស្មឹ មិយន្តិ ។ អនេកបរិយាយេនបិ ខោ អហំ ភិក្ខវេ តិរច្ឆានយោនិកថំ កថេយ្យំ ។ យាវញ្ចិទំ ភិក្ខវេ ន សុករា អក្ខានេន បាបុណិតុំ យាវ ទុក្ខា តិរច្ឆានយោនិ ។

(១៦៨) សេយ្យថាបិ ភិក្ខវេ បុរិសោ ឯកច្ឆិគ្គលំ យុគំ មហាសមុទ្ទេ[១] បក្ខិបេយ្យ ។ តមេនំ បុរត្ថិមោ វាតោ បច្ឆិមេន សំហរេយ្យ បច្ឆិមោ វាតោ បុរត្ថិមេន សំហរេយ្យ ឧត្តរោ វាតោ ទក្ខិណេន សំហរេយ្យ ទក្ខិណោ វាតោ ឧត្តរេន សំហរេយ្យ ។ តត្រាស្ស[២] កាណោ កច្ឆបោ សោ វស្សសតស្ស អច្ចយេន សកឹ ឧម្មុជ្ជេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ កាណោ កច្ឆបោ អមុស្មឹ ឯកច្ឆិគ្គលេ យុគេ គីវំ បវេសេយ្យាតិ ។

១ ម. សមុទ្ទេ ។ ២ ម. តត្រាយំ ។



ចាស់ក្នុងទឹកមិនស្អាត ស្លាប់ក្នុងទឹកមិនស្អាតនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង រៀបរាប់នូវកំណើត នៃសត្វតិរច្ឆាន ដោយអនេក-បរិយាយទៅក៏បាន ។ ម្នាលភិក្ខុទាំងឡាយ តែដំណើរដែលតថាគតពោលទៅ ក៏មិនងាយនឹងដល់ទម្រាំតែកំណើតសត្វតិរច្ឆាន ដែលមានទុក្ខបានឡើយ ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ ដូចបុរសដាក់នឹម ដែលមានរន្ធតែមួយ ទៅក្នុងមហាសមុទ្រ ។ ខ្យល់ពីទិសកើតបក់បន្សាត់នឹមនោះទៅទិសលិច ខ្យល់ពីទិសលិចបក់បន្សាត់ទៅទិសកើត ខ្យល់ពីទិសជើងបក់បន្សាត់ទៅទិសត្បូង ខ្យល់ពីទិសត្បូងបក់បន្សាត់ទៅទិសជើង ។ ក្នុងមហាសមុទ្រនោះ មានអណ្តើកខ្វាក់មួយ អណ្តើកនោះ អំណើះទៅមួយរយឆ្នាំ ទើបងើបឡើងម្តង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ សំគាល់សេចក្តីនោះ ដូចម្តេច អណ្តើកខ្វាក់នោះ គេគាប់នឹងប្រកកចូលទៅក្នុងនឹម ដែលមានរន្ធតែមួយនោះបាន ឬទេ ។

នោ ហេតំ ភន្តេ(១) យទិ នូន(២) ភន្តេ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេនាតិ ។ ខិប្បតរំ ខោ សោ ភិក្ខវេ កាណោ កច្ឆបោ អមុស្មឹ ឯកច្ឆិគ្គឡេ យុគេ គីវំ បវេសេយ្យ ។ អតោ(៣) ទុល្លភតរាហំ ភិក្ខវេ មនុស្សត្តំ វទាមិ សកឹ វិនិបាតគតេន ពាលេន ។ តំ កិស្ស ហេតុ ។ ន ហេត្ថ ភិក្ខវេ អត្ថិ ធម្មចរិយា សមចរិយា កុសលកិរិយា បុញ្ញកិរិយា អញ្ញមញ្ញខាទិកា ឯត្ថ ភិក្ខវេ វត្តតិ ទុព្ពលខាទិកា(៤) ។

(១៨០) ស ខោ សោ ភិក្ខវេ ពាលោ សចេ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន មនុស្សត្តំ អាគច្ឆតិ យានិ តានិ នីចកុលានិ ចណ្ឌាលកុលំ វា នេសាទកុលំ វា វេនកុលំ វា រថការកុលំ

១ ឱ. នោ ហេតំ ភន្តេតិ ន ទិស្សតិ ។ ២ ម. បន ។ ៣ ម. អហោ ។ ៤ ម. ទុព្វលខាទិកា ។



ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនបានទេ បពិត្រព្រះអង្គដ៏ចម្រើន បើក្រែងតែកន្លងកាលយូរអង្វែង យូរអង្វែងណាស់ (ទើបអណ្ដើកនោះ ប្រកកបូលទៅក្នុងរន្ធនឹមនោះបាន) ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អណ្ដើកខ្វាក់នោះ ប្រកកក្បាលទៅក្នុងនឹម ដែលមានរន្ធតែមួយនោះ ទុកជាជាប់ណាស់ផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលពាល ទៅកើតជាវិនិបាតម្ដងហើយ កម្រនឹងបានអត្តភាពមកជាមនុស្សវិញ ជាងអណ្ដើកខ្វាក់នោះទៅទៀត ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថាក្នុងវិនិបាតនោះ មិនមានការប្រព្រឹត្តធម៌ដ៏ស្មើ មិនមានការធ្វើកុសល មិនមានការធ្វើបុណ្យទេ ម្នាលភិក្ខុទាំងឡាយ មានតែការទំពាស៊ីនូវគ្នានឹងគ្នា សម្លាប់គ្នាដែលមានកម្លាំងថយ កើតមានទៅក្នុងវិនិបាតនោះ ។

(១៨០) ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ប្រសិនបើដំណើរកាល យូរអង្វែងទៅ ម្ដងៗ ទើបបានមកកាន់អត្តភាពជាមនុស្ស ក្នុងកាលជាខាងក្រោយ តែងកើតក្នុងត្រកូលថោកទាប គឺ ត្រកូលចណ្ឌាល ត្រកូលអ្នកនេសាទ ត្រកូលអ្នកត្បាញផែង ត្រកូលអ្នកធ្វើរថ

វា បុក្កុសកុលេ វា តថារូបេ កុលេ បច្ចាជាយតិ ទលិទ្ទេ អប្បន្នបានភោជនេ កសិរវុត្តិកេ យត្ថ កសិរេន ឃាសច្ឆាទោ លព្ភតិ ។ សោ ច ហោតិ ទុព្ពណ្ណោ ទុទ្ទសិកោ ឱកោដិមកោ ពវ្ហាពាធោ[១] កាណោ វា កុណី វា ខញ្ជោ វា[២] បក្ខហតោ វា ន លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថបទីបេយ្យស្ស ។ សោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។

១ ម. ពហ្វាពាធោ ។ ២ ម. ខុជ្ជោ ។



ត្រកូលអ្នកកើបសម្រាម ជាត្រកូលកំសត់ ដែលមានបាយ ទឹក ភោជន ប្រព្រឹត្តទៅដោយលំបាក ជាត្រកូលរកបាយស៊ី នឹងសំលៀកសំពត់ បានដោយក្រជាប់ក្រដួស ។ បុគ្គលនោះឯង ជាមនុស្សមានសម្បុរអាក្រក់ មិនគួរអ្នកផងនឹងរមៀលមើល ជាមនុស្សតឿ មានរោគច្រើន ជាមនុស្សខ្វាក់ ក្ញីក ខ្វក ខ្វិន ជាអ្នកមិនបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ទីនៅអាស្រ័យ គ្រឿងប្រទីបឡើយ ។ បុគ្គលនោះ ប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយចិត្ត ។ បុគ្គលនោះ លុះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។

(១៨១) សេយ្យថាបិ ភិក្ខវេ អក្ខធុត្តោ បឋមេ-
នេវ កលិគ្គហេន បុត្តម្បិ ជីយេថ ទារម្បិ ជីយេថ
សព្វំ សាបតេយ្យម្បិ ជីយេថ ឧត្តរិម្បិ អនុពន្ធំ[១]
និគច្ឆេយ្យ ។ អប្បមត្តកោ សោ ភិក្ខវេ កលិគ្គហោ
យំ សោ អក្ខធុត្តោ បឋមេនេវ កលិគ្គហេន បុត្តម្បិ
ជីយេថ ទារម្បិ ជីយេថ សព្វំ សាបតេយ្យម្បិ ជី-
យេថ ឧត្តរិម្បិ អនុពន្ធំ និគច្ឆេយ្យ ។ អថខោ
អយមេវ តតោ មហន្តតរោ កលិគ្គហោ យំ សោ
ពាលោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ
ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា ប-
រម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។
អយំ[២] ភិក្ខវេ កេវលា បរិបូរា ពាលភូមីតិ ។

---
១ ឱ. អនុពន្ធំ ទិស្សតិ ។ ម. អធិពន្ធំ ទិស្សតិ ។ ២ ឱ. អយម្បិ ។



(១៨១) ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងអ្នកលេងល្បែងភ្នាល់ ដែលធ្វើកូនឲ្យហិនហោចទៅផង ធ្វើប្រពន្ធឲ្យហិនហោចទៅផង ធ្វើសម្បត្តិទាំងពួងឲ្យហិនហោចទៅផង ដោយការចាញ់ជាដំបូង តទៅមុខ ក៏ដល់នូវការជាប់ណុំខ្លួនឯងទៀត ។ ម្នាលភិក្ខុទាំងឡាយ គ្រាន់តែហេតុដែលអ្នកលេង ល្បែងភ្នាល់នោះ ធ្វើកូនឲ្យហិនហោចទៅផង ធ្វើប្រពន្ធឲ្យហិនហោចទៅផង ធ្វើសម្បត្តិទាំងពួងឲ្យហិនហោចទៅផង ដោយការចាញ់ជាដំបូង តទៅមុខ ក៏ដល់នូវការជាប់ណុំខ្លួនឯងទៀតនោះ ឈ្មោះថាចាញ់បន្តិចបន្តួច ។ ចំណែកខាងបុគ្គលពាលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះដល់បែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេត អសុរកាយ នរក នេះឯង រឹតឈ្មោះថាការចាញ់យ៉ាងធំ ជាងនោះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាពាលភូមិ ដ៏បរិបូណ៌គ្រប់គ្រាន់ ។

(១៨២) តីណិមានិ ភិក្ខវេ បណ្ឌិតស្ស បណ្ឌិតលក្ខណានិ បណ្ឌិតនិមិត្តានិ បណ្ឌិតាបទានានិ ។ កតមានិ តីណិ ។ ឥធ ភិក្ខវេ បណ្ឌិតោ សុចិន្តិតចិន្តី ច ហោតិ សុភាសិតភាសី ច សុកតកម្មការី ច ។ នោ ចេតំ ភិក្ខវេ បណ្ឌិតោ សុចិន្តិតចិន្តី ច អភវិស្ស សុភាសិតភាសី ច សុកតកម្មការី ច ។ កេន នំ បណ្ឌិតា ជានេយ្យុំ បណ្ឌិតោ អយំ ភវំ សប្បុរិសោតិ ។ យស្មា ច ខោ ភិក្ខវេ បណ្ឌិតោ សុចិន្តិតចិន្តី ច ហោតិ សុភាសិតភាសី ច សុកតកម្មការី ច តស្មា នំ បណ្ឌិតា ជានន្តិ បណ្ឌិតោ អយំ ភវំ សប្បុរិសោតិ ។ ស ខោ សោ ភិក្ខវេ បណ្ឌិតោ តីហិ ទិដ្ឋេវ ធម្មេ សុខំ សោមនស្សំ បដិសំវេទេតិ ។





(១៨៦) ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត មានហេតុជាគ្រឿងចំណាំថាជាបណ្ឌិត មានហេតុជាគ្រឿងសំគាល់ថាជាបណ្ឌិត មានចរិតជាបណ្ឌិត ៣ យ៉ាងនេះ ។ ហេតុ ៣ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតក្នុងលោកនេះ ជាអ្នកគិតគំនិតល្អ ១ និយាយសំដីល្អ ១ ធ្វើអំពើល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើជនជាបណ្ឌិតនោះ ជាអ្នកមិនគិតគំនិតល្អផង មិននិយាយសំដីល្អផង មិនធ្វើអំពើល្អផងទេ ។ តើពួកអ្នកប្រាជ្ញណា ដឹងស្គាល់ជនជាបណ្ឌិតនោះថា អ្នកដ៏ចម្រើននេះ ជាបណ្ឌិត ជាសប្បុរស ដូច្នេះបាន ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត ជាអ្នកគិតគំនិតល្អផង និយាយសំដីល្អផង ធ្វើអំពើល្អផង ព្រោះហេតុណា ហេតុនោះ បានជាពួកអ្នកប្រាជ្ញ ស្គាល់ជនជាបណ្ឌិតនោះថា អ្នកនេះជាបណ្ឌិត ជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតនោះឯង តែងទទួលនូវសេចក្តីសុខ សោមនស្ស ៣ យ៉ាង ក្នុងបច្ចុប្បន្ននេះ ។

(១៨៣) សចេ ភិក្ខវេ បណ្ឌិតោ សភាយំ ចេ និសិន្នោ ហោតិ រថិយាយ ចេ និសិន្នោ ហោតិ សិង្ឃាដកេ ចេ និសិន្នោ ហោតិ តត្រ ចេ ជនោ តជ្ជំ តស្សារុប្បំ កថំ មន្តេតិ ។ សចេ ភិក្ខវេ បណ្ឌិតោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ តត្រ ភិក្ខវេ បណ្ឌិតស្ស ឯវំ ហោតិ យំ ខោ ជនោ តជ្ជំ តស្សារុប្បំ កថំ មន្តេតិ សំវិជ្ជន្តេ តេ ធម្មា មយិ អហញ្ច តេសុ ធម្មេសុ សន្ទិស្សាមីតិ ។ ឥទំ ភិក្ខវេ បណ្ឌិតោ បឋមំ ទិដ្ឋេវ ធម្មេ សុខំ សោមនស្សំ បដិសំវេទេតិ ។





(១៨៣) ម្នាលភិក្ខុទាំងឡាយ ប្រសិនបើជនជាបណ្ឌិត អង្គុយក្នុងសាលាក្តី អង្គុយក្នុងច្រកក្តី អង្គុយក្នុងផ្លូវបែកជា ៤ ក្តី ចំណែកអ្នកជនដែលអង្គុយក្នុងបរិស័ទនោះ តែងប្រើក្យាពាក្យ (ជួនអំពីតាស) ដែលកើតអំពីអំពើនោះ ដ៏សមគួរដល់អំពើនោះ ។ ម្នាលភិក្ខុទាំងឡាយ បើជនជាបណ្ឌិត ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវសុរានិងមេរ័យ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតនោះ តែងគិតក្នុងពាក្យ ដែលអ្នកជននិយាយនោះថា អ្នកជនតែងប្រើក្យាពាក្យណា ដែលកើតអំពីអំពើនោះ ដ៏សមគួរដល់អំពើនោះ ធម៌ទាំងឡាយនោះ មាននៅក្នុងអាត្មាអញ ខ្លួនអញសោត ក៏ប្រាកដក្នុងធម៌ទាំងនោះផង ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត តែងទទួលនូវសេចក្តីសុខ សោមនស្ស ទី ១ នេះ ក្នុងបច្ចុប្បន្ន ។

(១៨៦) បុន ចបរំ ភិក្ខវេ បណ្ឌិតោ បស្សតិ រាជានោ ចោរំ អាគុចារឹ គហេត្វា វិវិធា កម្មការណា ការេន្តេ កសាហិបិ តាឡេន្តេ វេត្តេហិបិ តាឡេន្តេ អឌ្ឍទណ្ឌកេហិបិ តាឡេន្តេ ហត្ថម្បិ ឆិន្ទន្តេ បាទម្បិ ឆិន្ទន្តេ ហត្ថបាទម្បិ ឆិន្ទន្តេ កណ្ណម្បិ ឆិន្ទន្តេ នាសម្បិ ឆិន្ទន្តេ កណ្ណនាសម្បិ ឆិន្ទន្តេ ពិលង្គថាលិកម្បិ ករោន្តេ សង្ខមុណ្ឌិកម្បិ ករោន្តេ រាហុមុខម្បិ ករោន្តេ ជោតិមាលិកម្បិ ករោន្តេ ហត្ថប្បជ្ជោតិកម្បិ ករោន្តេ ឯរកវត្តិកម្បិ ករោន្តេ ចីរកវាសិកម្បិ ករោន្តេ ឯណេយ្យកម្បិ ករោន្តេ



(១៨៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត ជនជាបណ្ឌិតឃើញពួកស្ដេចទាំងឡាយ កាលចាប់នូវចោរដែលប្រព្រឹត្តអាក្រក់បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេង ៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្ដៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ឲ្យកាត់ទាំងដៃទាំងជើងខ្លះ ឲ្យកាត់ស្លឹកត្រចៀកខ្លះ ឲ្យកាត់ច្រមុះខ្លះ ឲ្យកាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ឲ្យធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ[១] ឲ្យធ្វើនូវសង្ខមុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យលើងដូចជាសំបកស័ង្ខខ្លះ[២] ឲ្យធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូខ្លះ[៣] ឲ្យធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ[៤] ឲ្យធ្វើនូវហត្ថប្បជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ[៥] ឲ្យធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាពន្លាត់ស្បែកពពែខ្លះ[៦] ឲ្យធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សំបកឈើខ្លះ[៧] ឲ្យធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វក្រោយខ្លះ[៨]

---

១ ដល់ ៨ មើលន័យសេចក្ដីក្នុងមហាទុក្ខក្ខន្ធសូត្រ ក្នុងគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ បឋមភាគ ត្រង់ទំព័រ ៣២០-៣២១ ។

ពលិសមំសិកម្បិ ករោន្តេ កហាបណកម្បិ ករោន្តេ ខារាបតច្ឆិកម្បិ ករោន្តេ បលិឃបរិវត្តិកម្បិ ករោន្តេ បលាលបីឋកម្បិ ករោន្តេ តត្តេនបិ តេលេន ឱសិញ្ចន្តេ សុនខេហិបិ ខាទាបេន្តេ ជីវន្តម្បិ សូលេ ឧត្តាសេន្តេ អសិនាបិ សីសំ ឆិន្ទន្តេ ។ តស្ស ក៏ត្វា បណ្ឌិតស្ស ឯវំ ហោតិ យថារូបានំ ខោ បាបកានំ កម្មានំ ហេតុ រាជានោ ចោរំ អាគុចារឹ គហេត្វា វិវិធា កម្មការណា ការេន្តិ កសាហិបិ តាឡេន្តិ វេត្តេហិបិ តាឡេន្តិ អឌ្ឍទណ្ឌកេហិបិ តាឡេន្តិ ហត្ថម្បិ ឆិ បាទម្បិ ឆិន្ទន្តិ ហត្ថបាទម្បិ ឆិន្ទន្តិ កណ្ណម្បិ ឆិ



ឲ្យធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេថ្ពក់មាត់ ដោយកាំបិតសន្ទូច(១) ខ្លះ ឲ្យធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខ្លួនសរីរៈប្រមាណ ប៉ុនកហាបណៈមួយៗខ្លះ(២) ឲ្យធ្វើនូវខារាបតច្ឆិកកម្ម គឺអំពើដែលគេយកទឹកអំបិលស្រោចខ្លះ(៣) ឲ្យធ្វើនូវបលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាបង្វិលដើមគល់ ឬសសរគោលខ្លះ(៤) ឲ្យធ្វើបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្ដាប់ចំបើងខ្លះ(៥) ឲ្យស្រោចដោយប្រេងដ៏ក្ដៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដោតស្រួចលើឈើស្រួចទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតតែងគិតឃើញ ក្នុងអំពើទាំងនោះយ៉ាងនេះថា ព្រះរាជាទាំងឡាយ ចាប់ចោរដែលប្រព្រឹត្តអាក្រក់ធ្ងន់ហើយ ក្រោយបង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ឲ្យកាត់ទាំងដៃទាំងជើងខ្លះ ឲ្យកាត់ស្លឹកត្រចៀកខ្លះ

---

១ ។ ល ។ ៥ មើលសេចក្ដីពន្យល់ក្នុងមហាទុក្ខក្ខន្ធសូត្រ ក្នុងគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក៍ បឋមភាគ ត្រង់ទំព័រ ៣២០-៣២១ ។

ណាសម្បិ ឆិន្ទន្តិ កណ្ណនាសម្បិ ឆិន្ទន្តិ ពិលង្គថាលិ-
កម្បិ ករោន្តិ សង្ខមុណ្ឌិកម្បិ ករោន្តិ រាហុមុខម្បិ
ករោន្តិ ជោតិមាលិកម្បិ ករោន្តិ ហត្ថប្បជ្ជោតិកម្បិ
ករោន្តិ ឯរកវត្តិកម្បិ ករោន្តិ ចីរកវាសិកម្បិ
ករោន្តិ ឯណេយ្យកម្បិ ករោន្តិ ពឡិស-
មំសិកម្បិ ករោន្តិ កហាបណិកម្បិ ករោ-



ឲ្យកាត់ច្រមុះខ្លះ ឲ្យកាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ឲ្យធ្វើពិលង្គថា-
លិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ឲ្យធ្វើនូវសង្ខ-
មុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យលើងដូចជាសំបកស័ង្ខខ្លះ ឲ្យធ្វើ
នូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូខ្លះ ឲ្យធ្វើនូវ
ជោតិមាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ឲ្យធ្វើ
នូវហត្ថប្បជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ឲ្យធ្វើនូវឯរកវត្តិកកម្ម គឺ
អំពើដែលគេធ្វើឲ្យដូចជាពន្លាត់ស្បែកពស់ខ្លះ ឲ្យធ្វើនូវចីរកវាសិកកម្ម គឺ
អំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សំបកឈើខ្លះ ឲ្យធ្វើនូវឯណេយ្យ-
កកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាទើនព្រាយខ្លះ ឲ្យធ្វើនូវពឡិសមំសិក-
កម្ម គឺអំពើដែលគេចក់សាច់ដោយការឡូសន្ទូចខ្លះ ឲ្យធ្វើនូវកហាបណក-
កម្ម គឺអំពើដែលគេធ្វើឲ្យខូចសរីរៈ ប្រមាណប៉ុនកហាបណៈមួយៗខ្លះ

តាឡច្ឆិកម្បិ ការេន្តិ បលិឃបរិវត្តិកម្បិ ការេន្តិ បលាលបីឋកម្បិ ការេន្តិ តត្តេនបិ តេលេន ឱសិញ្ចន្តិ សុនខេហិបិ ខាទាបេន្តិ ជីវន្តម្បិ សូលេ ឧត្តាសេន្តិ អសិនាបិ សីសំ ឆិន្ទន្តិ ។ ន តេ ធម្មា មយិ សំវិជ្ជន្តិ[១] អហញ្ច ន តេសុ ធម្មេសុ សន្ទិស្សាមីតិ ។ ឥទម្បិ[២] ភិក្ខវេ បណ្ឌិតោ ទុតិយំ ទិដ្ឋេវ ធម្មេ សុខំ សោមនស្សំ បដិសំវេទេតិ ។

(១៨៨) បុន ចបរំ ភិក្ខវេ បណ្ឌិតំ បីឋសមារូឡ្ហំ វា មញ្ចសមារូឡ្ហំ វា ឆមាយំ វា សេមានំ យានិស្ស បុព្វេ កល្យាណានិ កម្មានិ កតានិ កាយេន សុចរិតានិ វាចាយ សុចរិតានិ មនសា សុចរិតានិ

១ ម. សំវិជ្ជន្តេ ។ ២ ម. ឥទំ ។



ឲ្យធ្វើនូវតាឡច្ឆិកកម្ម គឺអំពើដែលគេយកចបកាប់ស្បែកខ្លួន ឲ្យធ្វើនូវបលិឃបរិវត្តិកកម្ម គឺអំពើដែល គេធ្វើឲ្យដូចជាបង្វិលលើធ្នល់ ចោះសរតោលខ្លួន ឲ្យធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លួន ឲ្យស្រោចដោយប្រេងដ៏ក្តៅខ្លួន ឲ្យឆ្កែខាំខ្លួន ឲ្យដេកចុះលើឈើអណ្តែតទាំងរស់ខ្លួន ឲ្យកាត់ក្បាលដោយដាវខ្លួន ព្រោះហេតុបាបកម្មមានសភាពយ៉ាងណាៗ ។ ធម៌ទាំងឡាយនោះ មិនមានក្នុងអាត្មាអញ ទាំងអាត្មាអញសោត ក៏មិនប្រាកដក្នុងធម៌ទាំងឡាយនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត រមែងទទួលសេចក្តីសុខសោមនស្ស ទី ២ នេះឯង ក្នុងបច្ចុប្បន្ន ។

(១៨៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត ជនជាបណ្ឌិត កាលឡើងកាន់តាំងក្តី ឡើងកាន់គ្រែក្តី ដេកលើផែនដីក្តី អំពើល្អទាំងឡាយ គឺការប្រព្រឹត្តល្អដោយកាយ ការប្រព្រឹត្តល្អដោយវាចា ការប្រព្រឹត្តល្អដោយចិត្ត ណា ដែលជនជាបណ្ឌិតនោះ ធ្វើទុកក្នុងកាលមុន

តានិស្ស តម្ហិ សមយេ ឱលម្ពន្តិ អជ្ឈោល-
ម្ពន្តិ អភិប្បលម្ពន្តិ ។ សេយ្យថាបិ ភិក្ខវេ មហតំ
បព្វតកូដានំ ឆាយា សាយណ្ហសមយំ បឋវិយា
ឱលម្ពន្តិ អជ្ឈោលម្ពន្តិ អភិប្បលម្ពន្តិ ឯវមេវ ខោ
ភិក្ខវេ បណ្ឌិតំ បីឋសមារុឡ្ហំ វា មញ្ចសមារុឡ្ហំ
វា ឆមាយំ វា សេមានំ យានិស្ស បុព្វេ កល្យាណានិ
កម្មានិ កតានិ កាយេន សុចរិតានិ វាចាយ សុចរិ-
តានិ មនសា សុចរិតានិ តានិស្ស តម្ហិ សមយេ
ឱលម្ពន្តិ អជ្ឈោលម្ពន្តិ អភិប្បលម្ពន្តិ ។ តត្រ ភិក្ខវេ
បណ្ឌិតស្ស ឯវំ ហោតិ អកតំ វត មេ បាបំ អកតំ
លុទ្ទំ អកតំ កិព្វិសំ កតំ កល្យាណំ កតំ
កុសលំ កតំ ភីរុត្តាណំ យាវតា ភោ អកត-
បាបានំ អកតលុទ្ទានំ អកតកិព្វិសានំ កតក-
ល្យាណានំ កតកុសលានំ កតភីរុត្តាណានំ គតិ
តំ គតិំ បេច្ច គច្ឆាមីតិ ។ សោ ន សោចតិ



អំពើល្អទាំងនោះឯង តែងគ្របដណ្តប់ គ្រោបគ្រង ទំនុកបម្រុងនូវ
ជនជាបណ្ឌិតនោះ ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ ស្រមោល
នៃកំពូលភ្នំធំ តែងក្រោល កល់ដាល គ្របលើផែនដី ក្នុងវេលាថ្ងៃ
រសៀល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យ
ដូចជនជាបណ្ឌិត កាលឡើងកាន់តាំងក្តី ឡើងកាន់គ្រែក្តី ដេកលើ
ផែនដីក្តី អំពើល្អទាំងឡាយ គឺការប្រព្រឹត្តល្អដោយកាយ ការប្រព្រឹត្តល្អ
ដោយវាចា ការប្រព្រឹត្តល្អដោយចិត្តណា ដែលជនជាបណ្ឌិតនោះ ធ្វើ
ទុកក្នុងកាលមុន អំពើល្អទាំងនោះឯង តែងគ្របដណ្តប់ គ្រោបគ្រង
ទំនុកបម្រុង នូវជនជាបណ្ឌិតនោះ ក្នុងសម័យនោះ ដូច្នោះឯង ។
ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត តែងគិតក្នុងអារម្មណ៍ ដែលប្រាកដ
ក្នុងចក្ខុទ្វារនោះ យ៉ាងនេះថា អើហ្ន៎ អាត្មាអញ មិនបានធ្វើបាប មិនបាន
ធ្វើអំពើសាក្រក់ មិនបានធ្វើអំពើក្តៅក្រហាយទុកទេ អាត្មាអញ ធ្វើតែ
អំពើល្អ ធ្វើតែអំពើកុសល ធ្វើតែបុណ្យសម្រាប់ការពារភ័យ ពួកជន
ដែលមិនបានធ្វើបាប មិនបានធ្វើអំពើសាក្រក់ មិនបានធ្វើអំពើក្តៅ
ក្រហាយទុក ជាអ្នកធ្វើតែអំពើល្អ ធ្វើតែកុសល ធ្វើតែបុណ្យសម្រាប់
ការពារភ័យ រមែងមានគតិ យ៉ាងណា អាត្មាអញ នឹងទៅកាន់គតិ
នោះ ក្នុងបរលោក ។ ជនជាបណ្ឌិតនោះ តែងមិនក្រៀមក្រំចិត្ត

ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។ ឥទម្បិ ភិក្ខវេ បណ្ឌិតោ តតិយំ ទិដ្ឋេវ ធម្មេ សុខំ សោមនស្សំ បដិសំវេទេតិ ។

(១៨៦) ស ខោ សោ ភិក្ខវេ បណ្ឌិតោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ យំ ខោ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ ឯកន្តំ ឥដ្ឋំ ឯកន្តំ កន្តំ ឯកន្តំ មនាបន្តិ សគ្គមេវ តំ សម្មា វទមានោ វទេយ្យ ឯកន្តំ ឥដ្ឋំ ឯកន្តំ កន្តំ ឯកន្តំ មនាបន្តិ ។ យាវញ្ចិទំ ភិក្ខវេ ឧបមាបិ ន សុករា យាវ សុខា សគ្គាតិ



មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងទ្រហោយំ មិនដល់នូវសេចក្តីវង្វេង ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត តែងទទួលសេចក្តីសុខ សោមនស្ស ទី ៣ នេះឯង ក្នុងបច្ចុប្បន្ន ។

(១៨៦) ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតនោះឯង បាន ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ អ្នកផងដែលនិយាយតាមហេតុ តែងនិយាយចំពោះទីណា ថាជាទីគួរប្រាថ្នាតែមួយយ៉ាង គួរត្រេកអរតែមួយយ៉ាង គួរពេញចិត្តតែមួយយ៉ាងដូច្នេះ ទីនោះគឺឋានសួគ៌នោះឯង ដែលអ្នកផងនិយាយតាមហេតុ តែងនិយាយថា ជាទីគួរប្រាថ្នាតែមួយយ៉ាង គួរត្រេកអរតែមួយយ៉ាង គួរពេញចិត្តតែមួយយ៉ាង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមាមិនងាយនឹងធ្វើបាន ឲ្យដល់កម្រិតឋានសួគ៌ ដែលមានសេចក្តីសុខប៉ុណ្ណោះឡើយ ។

(១៨៧) ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច សក្កា បន ភន្តេ ឧបមា កាតុន្តិ ។ សក្កា ភិក្ខូតិ ភគវា អវោច សេយ្យថាបិ ភិក្ខវេ រាជា ចក្កវត្តិ សត្តហិ រតនេហិ សមន្នាគតោ ចតូហិ ច ឥទ្ធីហិ តតោនិទានំ សុខំ សោមនស្សំ បដិសំវេទេតិ ។ កតមេហិ សត្តហិ ។

(១៨៨) ឥធ ភិក្ខវេ រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស តទហុបោសថេ បណ្ណរសេ សីសំន្ហាតស្ស ឧបោសថិកស្ស ឧបរិបាសាទវរគតស្ស ទិព្វំ ចក្ករតនំ បាតុភវតិ សហស្សារំ សនេមិកំ សនាភិកំ សព្វាការបរិបូរំ ។ ទិស្វាន រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ឯវំ ហោតិ សុតំ ខោ បន មេតំ យស្ស រញ្ញោ មុទ្ធាវសិត្តស្ស តទហុបោសថេ បណ្ណរសេ សីសន្ហាតស្ស ឧបោសថិកស្ស



(១៨៧) កាលបើព្រះអង្គត្រាស់យ៉ាងនេះហើយ មានភិក្ខុមួយរូប ក្រាបបង្គំទូលសួរសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ចុះព្រះអង្គអាចនឹងធ្វើឧបមាបាន ឬទេ ។ ព្រះមានព្រះភាគត្រាស់តបថា ម្នាលភិក្ខុ តថាគតអាចនឹងធ្វើបាន ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដូចស្តេចចក្រពត្តិ ទ្រង់ប្រកបដោយរតនៈ ៧ ប្រការ និង ដោយឫទ្ធិ ៤ យ៉ាង ហើយទ្រង់សោយសេចក្តីសុខ សោមនស្ស ព្រោះរតនៈនិងឫទ្ធិនោះជាហេតុ ។ រតនៈទាំង ៧ ប្រការនោះ តើដូចម្តេចខ្លះ ។

(១៨៨) ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ក្សត្រិយ៍ជាព្រះរាជាបានមុទ្ធាភិសេកហើយ ទ្រង់កក់ព្រះសិរ្សក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថ ហើយរក្សាឧបោសថ គង់នៅលើប្រាសាទដ៏ប្រសើរ ចក្ករតនៈជាទិព្វ មានកាំមួយពាន់ ព្រមទាំងខ្នងកង់និងដុំ បរិបូណ៌ដោយអាការសព្វគ្រប់ ក៏កើតប្រាកដឡើង ។ ក្សត្រិយ៍ជាព្រះរាជាបានមុទ្ធាភិសេក ទ្រង់ទតឃើញហើយ ទើបទ្រង់ព្រះតម្រិះដូច្នេះថា អាត្មាអញ ក៏ធ្លាប់បានឮរឿងនេះមកហើយថា ក្សត្រិយ៍អង្គណាជាព្រះរាជាបានមុទ្ធាភិសេកហើយ ទ្រង់កក់ព្រះសិរ្ស ក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថ ហើយរក្សាឧបោសថ

ឧបរិបាសាទវរគតស្ស ទិព្វំ ចក្ករតនំ បាតុរហោសិ សហស្សារំ សនេមិកំ សនាភិកំ សព្វាការបរិបូរំ សោ ហោតិ រាជា ចក្កវត្តិ អស្សំ នុ ខោ អហំ រាជា ចក្កវត្តីតិ ។ អថខោ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ ឧដ្ឋាយាសនា វាមេន ហត្ថេន ភិង្ការំ គហេត្វា ទក្ខិណេន ហត្ថេន ចក្ករតនំ អព្ភុក្កិរតិ បវត្តតុ ភវំ ចក្ករតនំ អភិវិជិនាតុ ភវំ ចក្ករតនន្តិ ។ អថខោ តំ ភិក្ខវេ ចក្ករតនំ បុរត្ថិមំ ទិសំ បវត្តតិ អន្វទេវ រាជា ចក្កវត្តិ សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យស្មឹ ខោ បន ភិក្ខវេ បទេសេ ចក្ករតនំ បតិដ្ឋាតិ តត្ថ រាជា ចក្កវត្តិ វាសំ ឧបេតិ សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យេ ខោ បន ភិក្ខវេ បុរត្ថិមាយ ទិសាយ បដិរាជានោ តេ រាជានំ ចក្កវត្តិំ ឧបសង្កមិត្វា ឯវមាហំសុ ឯហិ ខោ មហារាជ



គង់នៅលើប្រាសាទដ៏ប្រសើរ ចក្ករតនៈជាទិព្វ មានកាំមួយពាន់ព្រម ទាំងខ្នងកង់ទាំងផ្ចិត បរិបូណ៌ដោយអាការទាំងពួង ក៏កើតប្រាកដឡើង ព្រះរាជាអង្គនោះ នឹងបានជាស្ដេចចក្រពត្តិ ឬហ្ន៎ តើអញបានជាស្ដេចចក្រពត្តិហើយតើ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ក្សត្រិយ៍ជាព្រះរាជាបានមុទ្ធាភិសេកហើយ ទ្រង់ក្រោកចាកអាសនៈហើយ ទើបយកព្រះហស្តខាងឆ្វេងចាប់កុណ្ឌី យកព្រះហស្តខាងស្ដាំ ប្រោះព្រំចក្ករតនៈ ហើយត្រាស់ថា ចក្ករតនៈដ៏ចម្រើន ចូរវិលទៅ ចក្ករតនៈដ៏ចម្រើន ចូរមានជ័យជំនះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ចក្ករតនៈនោះឯង ក៏អណ្ដែតក្រសែតទៅកាន់ទិសខាងកើត ទើបព្រះបាទចក្រពត្តិ ទ្រង់ស្ដេចទៅតាមក្រោយ ព្រមដោយចតុរង្គិនីសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្ករតនៈប្រតិស្ឋាន ក្នុងប្រទេសណា ព្រះបាទចក្រពត្តិព្រមទាំងចតុ-រង្គិនីសេនា ក៏ចូលទៅកាន់ព្រះរាជនិវេសន៍ ក្នុងប្រទេសនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកពួកស្ដេចណា ដែលជាសត្រូវតាំងនៅក្នុងទិសខាងកើត ព្រះរាជាទាំងនោះ ក៏ស្ដេចចូលទៅគាល់ព្រះបាទចក្រពត្តិហើយ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ស្ដេចមកចុះ

ស្វាគតំ មហារាជ សកន្តេ មហារាជ អនុសាស មហារាជាតិ ។ រាជា ចក្កវត្តិ ឯវមាហ- បាណោ ន ហន្តព្វោ អទិន្នំ នាទាតព្វំ កាមេសុ មិច្ឆា ន ចរិតព្វា មុសា ន ភាសិតព្វា មជ្ជំ ន បាតព្វំ យថាភុត្តញ្ច ភុញ្ជថាតិ ។ យេ ខោ បន ភិក្ខវេ បុរត្ថិមាយ ទិសាយ បដិរាជានោ តេ រញ្ញោ ចក្កវត្តិស្ស អនុយន្តា[១] អហេសុំ[២] ។ អថ ខោ តំ ភិក្ខវេ ចក្ករតនំ បុរត្ថិមំ សមុទ្ទំ អជ្ឈោគាហេត្វា បច្ចុត្តរិត្វា ទក្ខិណំ ទិសំ បវត្តតិ ។ បេ ។ ទក្ខិណំ ទិសំ សមុទ្ទំ អជ្ឈោគាហេត្វា បច្ចុត្តរិត្វា បច្ឆិមំ ទិសំ បវត្តតិ ។ បេ ។ បច្ឆិមំ ទិសំ សមុទ្ទំ អជ្ឈោគាហេត្វា បច្ចុត្តរិត្វា ឧត្តរំ ទិសំ បវត្តតិ អន្វទេវ រាជា ចក្កវត្តិ សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យស្មឹ ខោ បន ភិក្ខវេ បទេសេ ចក្ករតនំ បតិដ្ឋាតិ តត្ថ រាជា ចក្កវ-

១ ម. អនុយុត្តា ។ ២ ម. ភវឹ ។



បពិត្រមហារាជ ទ្រង់ស្តេចមកល្អហើយ បពិត្រមហារាជ រាជសម្បត្តិរបស់ទ្រង់ព្រះអង្គ ជារបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិ ក៏មានព្រះបន្ទូលយ៉ាងនេះថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វ មិនត្រូវកាន់យកទ្រព្យ ដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាទេ មិនត្រូវផឹកទឹកស្រវឹងឡើយ អ្នកទាំងឡាយ ចូរបរិភោគតែរបស់ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកស្តេចណា ដែលជាសត្រូវនៅក្នុងទិសខាងកើត ស្តេចទាំងនោះ ក៏ត្រឡប់ជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ចក្រកែវនោះ ក៏ចុះកាន់សមុទ្រទិសខាងកើត ហើយងើបឡើងវិលទៅកាន់ទិសខាងត្បូង ។ បេ ។ ចុះកាន់សមុទ្រទិសខាងត្បូង ហើយងើបឡើងវិលទៅកាន់ទិសខាងលិច ។ បេ ។ ចុះកាន់សមុទ្រទិសខាងលិច ហើយងើបឡើងវិលទៅ កាន់ទិសខាងជើង ព្រះបាទចក្រពត្តិ ក៏ស្តេចទៅតាមខាងក្រោយ ព្រមដោយចតុរង្គិនីសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្រកែវប្រតិស្ឋានទៅ ក្នុងប្រទេសណា ព្រះបាទចក្រពត្តិស្តេច

វាសំ ឧបេតិ សទ្ធិំ ចតុរង្គិនិយា សេនាយ ។ យេ ខោ បន ភិក្ខវេ ឧត្តរាយ ទិសាយ បដិរាជានោ តេ រាជានំ ចក្កវត្តិំ ឧបសង្កមិត្វា ឯវមាហំសុ ឯហិ ខោ មហារាជ ស្វាគតំ មហារាជ សកន្តេ មហារាជ អនុសាស មហារាជាតិ ។ រាជា ចក្កវត្តិ ឯវមាហ បាណោ ន ហន្តព្វោ អទិន្នំ នាទាតព្វំ កាមេសុ មិច្ឆា ន ចរិតព្វា មុសា ន ភាសិតព្វា មជ្ជំ ន បាតព្វំ យថាភុត្តញ្ច ភុញ្ជថាតិ ។ យេ ខោ បន ភិក្ខវេ ឧត្តរាយ ទិសាយ បដិរាជានោ តេ រញ្ញោ ចក្កវត្តិស្ស អនុយន្តា អហេសុំ ។ អថខោ តំ ភិក្ខវេ ចក្ករតនំ សមុទ្ទបរិយន្តំ បឋវឹ អភិវិជិនិត្វា



ក៏ទ្រង់ប្រថាប់នៅក្នុងទីប្រទេសនោះ ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកស្តេចណា ជាសេកសត្រូវនៅក្នុងទិសខាងជើង ស្តេចទាំងនោះ ក៏នាំគ្នាចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូល យ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចមកចុះ បពិត្រមហារាជ ទ្រង់ស្តេចមកល្អហើយ បពិត្រមហារាជ ភោគសម្បត្តិរបស់ខ្ញុំព្រះអង្គ ជាព្រះរាជទ្រព្យ របស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិទ្រង់ក៏មានព្រះរាជ-ឱង្ការយ៉ាងនេះថា អ្នកទាំងឡាយមិនត្រូវសម្លាប់សត្វ មិនត្រូវកាន់យកទ្រព្យដែលគេមិនបានឱ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវាទ មិនត្រូវផឹកទឹកស្រវឹងឡើយ អ្នកទាំងឡាយចូរបរិភោគតែរបស់ ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ពួកស្តេចណា ជាសេកសត្រូវក្នុងទិសខាងជើង ស្តេចទាំងនោះ ក៏ត្រឡប់ជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ តពីនោះមក ចក្ករតន៍នោះក៏បណ្តើរបន្ទើ ដែលមានសមុទ្រជាព្រំប្រទល់

តមេនំ(១) រាជធានឹ បច្ចាគន្ត្វា រញ្ញោ ចក្កវត្តិស្ស អន្តេបុរទ្វារេ អក្ខាហតំ មញ្ញេ តិដ្ឋតិ រញ្ញោ ចក្កវត្តិស្ស អន្តេបុរទ្វារំ ឧបសោភយមានំ ។ រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស ឯវរូបំ ចក្ករតនំ បាតុភវតិ ។

(១៨៤) បុន ចបរំ ភិក្ខវេ រញ្ញោ ចក្កវត្តិស្ស ហត្ថិរតនំ បាតុភវតិ ។ សព្វសេតោ សត្តប្បតិដ្ឋោ ឥទ្ធិមា វេហាសង្គមោ ឧបោសថោ នាម នាគរាជា ។ ទិស្វាន រញ្ញោ ចក្កវត្តិស្ស ចិត្តំ បសីទតិ ភទ្ទកំ វត ភោ ហត្ថិយានំ សចេ ទមថំ ឧបេយ្យាតិ ។ អថ ខោ តំ ភិក្ខវេ ហត្ថិរតនំ សេយ្យថាបិ នាម ភទ្ទោ ហត្ថាជានីយោ ទីឃរត្តំ សុបរិទន្តោ ឯវមេវ ទមថំ ឧបេតិ ។ ភូតបុព្វំ ភិក្ខវេ រាជា ចក្កវត្តិ តមេវ ហត្ថិរតនំ វីមំសមានោ បុព្វណ្ហសមយំ អភិរុហិត្វា សមុទ្ទបរិយន្តំ បថវឹ អនុយាយិត្វា

១ ឱ. តមេវ ។



វិលត្រឡប់មកកាន់រាជធានីនោះវិញ ហើយឋិតនៅ (ក្នុងរបៀងនៃសាលាវិនិច្ឆ័យ) ទៀបទ្វារនៃព្រះបរមរាជវាំង របស់ព្រះបាទចក្រពត្តិ (នៅនឹងថ្កល់) ហាក់ដូចជាបាក់ភ្លៅ ហើយបំភ្លឺទ្វារ ក្នុងព្រះបរមរាជវាំងនៃព្រះបាទចក្រពត្តិ (ឲ្យភ្លឺព្រោងព្រាត) ។ ម្នាលភិក្ខុទាំងឡាយ ចក្ករតនៈបែបនេះ កែងកើតឡើងប្រាកដដល់ស្តេចចក្រពត្តិ ។

(១៨៤) ម្នាលភិក្ខុទាំងឡាយ មួយទៀត ហត្ថិរតនៈ (ដំរីកែវ) ក៏កើតប្រាកដ ដល់ស្តេចចក្រពត្តិ ។ ( ដំរីកែវនោះ ) ជាស្តេចដំរីឈ្មោះឧបោសថ មានសម្បុរសសុទ្ធ មានអវយវៈគួបចំសមល្មមទាំងអស់ ជាដំរីមានឫទ្ធិ អាចហោះទៅលើអាកាសបាន ។ លុះព្រះបាទចក្រពត្តិ ទ្រង់ទតឃើញហើយ ក៏មានព្រះហឫទ័យជ្រះថ្លាថា អើយានដំរីល្អណាស់តើហ្ន៎ ប្រសិនបើចូលទៅបង្ហាត់បាន ( ជាការប្រពៃ ) ។ ម្នាលភិក្ខុទាំងឡាយ ឯហត្ថិរតនៈនោះ ក៏ដល់នូវការបង្ហាត់បាន ដូចជាដំរីអាជានេយ្យដ៏ល្អ ដែលគេបង្ហាត់បានរបៀបល្អយូរអង្វែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ កាលទ្រង់ទីល្បងមើលហត្ថិរតនៈនោះឯង មុនដំបូង ទ្រង់ឡើងគង់ (លើហត្ថិរតនៈនោះ) ក្នុងវេលាព្រឹកព្រហាម ហើយស្តេចទៅត្រួតត្រានូវផែនដី មានសមុទ្រជាព្រំប្រទល់

តមេវ រាជធានឹ បច្ចាគន្ត្វា បាតរាសមកាសិ ។ រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស ឯវរូបំ ហត្ថិរតនំ បាតុភវតិ ។

(១៦០) បុន ចបរំ ភិក្ខវេ រញ្ញោ ចក្កវត្តិស្ស អស្សរតនំ បាតុភវតិ ។ សព្វសេតោ កាឡសីសោ មុញ្ជកេសោ ឥទ្ធិមា វេហាសង្គមោ វលាហកោ នាម (១) អស្សរាជា ។ តំ ទិស្វាន រញ្ញោ ចក្កវត្តិស្ស ចិត្តំ បសីទតិ ភទ្ទកំ វត ភោ អស្សយានំ សចេ ទមថំ ឧបេយ្យាតិ ។ អថខោ តំ ភិក្ខវេ អស្សរតនំ

១ ឱ. វលាហកោ នាម ។



រួចហើយស្តេចត្រឡប់មកសោយព្រះក្រយាហារ ក្នុងវេលាព្រឹក ឯរាជ-ធានីរបស់ព្រះអង្គនោះវិញទាន់ ។ ម្នាលភិក្ខុទាំងឡាយ ហត្ថិរតនមានសភាពយ៉ាងនេះ តែងកើតឡើងប្រាកដ ដល់ស្តេចចក្រពត្តិ ។

(១៦០) ម្នាលភិក្ខុទាំងឡាយ មួយទៀត អស្សរតនៈ (សេះកែវ) ក៏កើតឡើងប្រាកដ ដល់ស្តេចចក្រពត្តិ ។ (អស្សរតនៈនោះ) ជាស្តេចសេះឈ្មោះវលាហកៈ មានសម្បុរសសុទ្ធ មានសម្បុរត្រង់ក្បាល ខ្មៅ (រាវើម) ដូចជាសម្បុរនៃក្អែក មានសក់ (សក់សេះ) ដូចជាបណ្តូលស្មៅយាប្លង់ ជាសេះមានឫទ្ធិ អាចហោះទៅលើអាកាសបាន ។ លុះស្តេចចក្រពត្តិទ្រង់ទតឃើញហើយ ក៏មានព្រះហឫទ័យជ្រះថ្លាថា អើយានសេះ ល្អណាស់ហ្ន៎ ប្រសិនបើចូលទៅបង្ហាត់បាន (ជាការប្រពៃ) ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ អស្សរតនៈនោះ

សេយ្យថាបិ នាម ភទ្រោ អស្សាជានីយោ ទីឃរត្តំ សុបរិទន្តោ ឯវមេវ សមំ ឧបេតិ ។ ភូតបុព្វំ ភិក្ខវេ រាជា ចក្កវត្តិ តមេវ អស្សរតនំ វីមំសមានោ បុព្វណ្ហសមយំ អភិរុហិត្វា សមុទ្ទបរិយន្តំ បឋវឹ អនុបរិយាយិត្វា តមេវ រាជធានឹ បច្ចាគន្ត្វា បាតរាសមកាសិ ។ រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស ឯវរូបំ អស្សរតនំ បាតុភវតិ ។

(១៦១) បុន ចបរំ ភិក្ខវេ រញ្ញោ ចក្កវត្តិស្ស មណិរតនំ បាតុភវតិ ។ សោ ហោតិ មណិវេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ ។ តស្ស ខោ បន ភិក្ខវេ មណិរតនស្ស អាភា សមន្តា យោជនំ ផុដា ហោតិ ។ ភូតបុព្វំ ភិក្ខវេ រាជា ចក្កវត្តិ តមេវ មណិរតនំ វីមំសមានោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា មណឹ ធជគ្គំ អារោបេត្វា រត្តន្ធការតិមិសាយ បាយាសិ ។ យេ ខោ បន ភិក្ខវេ សមន្តា គាមា អហេសុំ



ក៏ដល់នូវការបង្ហាត់បាន ដូចជាសេះអាជានេយ្យដ៏ល្អ ដែលគេបង្ហាត់បានរបៀបល្អយូរអង្វែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ កាលទ្រង់ពិនិត្យមើលអស្សរតនៈនោះឯង មុនដំបូង ទ្រង់ឡើងគង់ (លើអស្សរតនៈ) ក្នុងវេលាព្រឹកព្រហាម ហើយស្តេចទៅត្រួតត្រាផែនដីដែលមានសមុទ្រជាព្រំប្រទល់ រួចហើយស្តេចត្រឡប់មកសោយព្រះស្ងោយ ក្នុងវេលាព្រឹក ឯរាជធានីរបស់ព្រះអង្គនោះវិញបាន ។ ម្នាលភិក្ខុទាំងឡាយ អស្សរតនៈមានសភាពយ៉ាងនេះ តែងកើតប្រាកដដល់ស្តេចចក្រពត្តិ ។

(១៦១) ម្នាលភិក្ខុទាំងឡាយ មួយទៀត មណិរតនៈក៏កើតប្រាកដដល់ស្តេចចក្រពត្តិ ។ មណិរតនៈនោះជាកែវពិទូរ្យ មានជាតិដ៏ល្អ មានជ្រុង ៨ ដែលជាងច្នៃល្អហើយ ។ ម្នាលភិក្ខុទាំងឡាយ មណិរតនៈនោះឯង មានពន្លឺផ្សាយទៅបានមួយយោជន៍ជុំវិញ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ កាលទ្រង់ពិនិត្យមើលនូវមណិរតនៈនោះឯង មុនដំបូង ទ្រង់ប្រជុំអស់ចតុរង្គសេនាមក ហើយទ្រង់ស្ទួយកែវមណីឡើងទៅកាន់ចុងទង់ជ័យ ហើយទ្រង់ត្រាច់ទៅក្នុងទីងងឹតអន្ធការក្នុងរាត្រី ។ ម្នាលភិក្ខុទាំងឡាយ ចំណែកអ្នកស្រុកទាំងឡាយណា ដែលនៅជិតខាង

តេ តេន ឱភាសេន[១] កម្មន្តេ បយោជេសុំ ទិវាតិ មញ្ញមានា ។ រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស ឯវរូបំ មណិរតនំ បាតុភវតិ ។

(១៦៦) បុន ចបរំ ភិក្ខវេ រញ្ញោ ចក្កវត្តិស្ស ឥត្ថីរតនំ បាតុភវតិ ។ សា[២] អភិរូបា ទស្ស-នីយា បាសាទិកា បរមាយ វណ្ណបោក្ខរតាយ សមន្នាគតា នាតិទីឃា នាតិរស្សា នាតិកិសា នាតិថូលា នាតិកាឡិកា[៣] នាច្ចោទាតា អតិក្កន្តា មានុសំ វណ្ណំ អប្បត្តា ទិព្វំ វណ្ណំ ។ តស្ស ខោ បន ភិក្ខវេ ឥត្ថីរតនស្ស ឯវរូបោ កាយសម្ផ-ស្សោ ហោតិ សេយ្យថាបិ នាម តូលបិចុនោ វា កប្បាសបិចុនោ វា ។ តស្ស ខោ បន ភិក្ខវេ ឥត្ថីរតនស្ស សីតេ ឧណ្ហានិ គត្តានិ ហោន្តិ

១ ម. មណិតោភាសេន ។ ២ ម. សាតិ ខ ទិស្សតិ ។ ៣ ម. នាតិកាឡី ។



អ្នកស្រុកទាំងនោះ សំគាល់ថាជាវេលាថ្ងៃ ក៏នាំគ្នាប្រកបការងារដោយ-ពន្លឺ ( កែវ ) នោះឯង ។ ម្នាលភិក្ខុទាំងឡាយ មណិរតនៈមាន សភាពយ៉ាងនេះ តែងកើតប្រាកដ ដល់ស្តេចចក្រពត្តិ ។

(១៦៦) ម្នាលភិក្ខុទាំងឡាយ តទៅទៀត ឥត្ថីរតន៍[១] (ស្រីកែវ) ក៏កើតប្រាកដ ដល់ស្តេចចក្រពត្តិ ។ ស្រីកែវនោះមានរូប ឆោមល្អ គួរឲ្យអ្នកផងពិតពិលរមិលមើល គួរជ្រះថ្លា ប្រកបដោយ សម្បុរល្អក្រៃលែង មិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ ពេក មិនខ្មៅពេក មិនសពេក លើសលែងជាងពណ៌សម្បុររបស់ស្រី មនុស្ស តែមិនដល់សម្បុរទិព្វទេ ។ ម្នាលភិក្ខុទាំងឡាយ ឥត្ថីរតនៈនោះ ឯង មានកាយសម្ផស្ស ( ទន់ល្មូក ) ដូចជាសំឡីគរ ឬសំឡីកប្បាស ។ ម្នាលភិក្ខុទាំងឡាយ ឯឥត្ថីរតនៈនោះឯង ក្នុងវេលាត្រជាក់ មានខ្លួនក្តៅ

១– មើលមហាសុទស្សនសូត្រ ទីឃនិកាយមហាវគ្គ ភាគ ១៣ ទំព័រ ១២ ត្រង់នយលក្ខណៈ លេខ ១ ។

ឧណ្ហេ សីតានិ គត្តានិ ហោន្តិ ។ តស្ស ខោ បន ភិក្ខវេ ឥត្ថិរតនស្ស កាយតោ ចន្ទនគន្ធោ វាយតិ មុខតោ ឧប្បលគន្ធោ វាយតិ ។ តំ ខោ បន ភិក្ខវេ ឥត្ថិរតនំ[១] ចក្កវត្តិស្ស បុព្វុដ្ឋាយិនី ហោតិ បច្ឆានិបាតិនី កឹការបដិស្សាវិនី មនាបចារិនី បិយវាទិនី ។ តំ ខោ បន ភិក្ខវេ ឥត្ថិរតនំ រាជានំ ចក្កវត្តឹ មនសាបិ នោ អតិចរតិ កុតោ បន កាយេន ។ រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស ឯវរូបំ ឥត្ថិរតនំ បាតុភវតិ ។

(២៦៣) បុន ចបរំ ភិក្ខវេ រញ្ញោ ចក្កវត្តិស្ស គហបតិរតនំ បាតុភវតិ ។ តស្ស កម្មវិបាកជំ ទិព្វំ ចក្ខុ បាតុភវតិ យេន និធឹ បស្សតិ

១ ម. ឯត្ថន្តរេ រញ្ញោតិ ទិស្សតិ ។



ក្នុងវេលាក្ដៅ មានខ្លួនត្រជាក់ ។ ម្នាលភិក្ខុទាំងឡាយ មិនតែប៉ុណ្ណោះ ទៀត ឥត្ថីរតន៍នោះឯង មានក្លិនខ្លឹមចន្ទន៍ផ្សាយចេញអំពីកាយ មានក្លិនផ្កាឧប្បលផ្សាយចេញអំពីមាត់ ។ ម្នាលភិក្ខុទាំងឡាយ ឥត្ថីរតន៍នោះឯង ជាស្ត្រីតែងក្រោកឡើងមុន តែងផ្ទំក្រោយ[១] យកចិត្តទុកដាក់ធ្វើការផ្សេងៗ ប្រព្រឹត្តគាប់ព្រះហឫទ័យ ពោលតែពាក្យជាទីពេញព្រះហឫទ័យ របស់ស្ដេចចក្រពត្តិ ។ ម្នាលភិក្ខុទាំងឡាយ ឥត្ថីរតន៍នោះឯង សូម្បីតែចិត្តក៏មិនប្រព្រឹត្តកន្លងស្ដេចចក្រពត្តិទៅហើយ ម្ដេចឡើយនឹងប្រព្រឹត្តកន្លងដោយកាយបាន ។ ម្នាលភិក្ខុទាំងឡាយ ឥត្ថីរតន៍មានសភាពយ៉ាងនេះឯង តែងកើតប្រាកដដល់ស្ដេចចក្រពត្តិ ។

(១៦៣) ម្នាលភិក្ខុទាំងឡាយ តទៅទៀត គហបតិរតន៍[២] ( គហបតិកែវ ) ក៏កើតប្រាកដដល់ស្ដេចចក្រពត្តិ ។ ឯគហបតិរតន៍នោះ មានទិព្វចក្ខុ កើតអំពីផលនៃកុសលកម្ម តាមមើលឃើញកំណប់ទ្រព្យ

១ មើលមហាសុទស្សនសូត្រ ទីឃនិកាយ មហាវគ្គ ភាគ ១៧ ទំព័រ ១២ ខ្សែលក្ខណៈលេខ ២ ។ ២ មើលមហាសុទស្សនសូត្រ ទីឃនិកាយ មហាវគ្គ ភាគ ១៧ ទំព័រ ១៣ ត្រង់ខ្សែលក្ខណៈលេខ ១ ។

សស្សាមិកម្បិ អស្សាមិកម្បិ ។ សោ រាជានំ ចក្កវត្តិំ ឧបសង្កមិត្វា ឯវមាហ អប្បោស្សុក្កោ ត្វំ ទេវ ហោហិ អហន្តេ ធនេន ធនករណីយំ ករិស្សាមីតិ ។ ភូតបុព្វំ ភិក្ខវេ ចក្កវត្តិ តមេវ គហបតិរតនំ វីមំសមានោ នាវំ អភិរូហិត្វា មជ្ឈេ គង្គាយ នទិយា សោតំ ឱគាហិត្វា(១) គហបតិរតនំ ឯតទវោច អត្ថោ មេ គហបតិ ហិរញ្ញសុវណ្ណេនាតិ ។ តេនហិ មហារាជ ឯកំ(២) តីរំ នាវា ឧបេតូតិ ។ ឥធេវ មេ គហបតិ អត្ថោ ហិរញ្ញសុវណ្ណេនាតិ ។ អថខោ តំ(៣) ភិក្ខវេ គហបតិរតនំ ឧភោហិ ហត្ថេហិ ឧទកេ(៤) ឱមសិត្វា បូរំ ហិរញ្ញសុវណ្ណស្ស កុម្ភឹ ឧទ្ធរិត្វា រាជានំ ចក្កវត្តឹ ឯតទវោច(៥) អលមេត្តាវតា មហារាជ

១ ម. ឱគាហេត្វា ។ ២ ម. ឯកំ វា ឯកំ វតី ទិស្សតិ ។ ៣ ម. តំ ។ ៤ ម. ឧទកំ ។ ៥ ម. ឯតទាហ ។



ដែលមានម្ចាស់និងមិនមានម្ចាស់បាន ។ គហបតិរតននោះ ចូលទៅគាល់ស្ដេចចក្រពត្តិ ក៏ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំមានសេចក្ដីខ្វល់ខ្វាយឡើយ ខ្ញុំព្រះអង្គនឹងចាត់ចែងការ ដែលគួរធ្វើដោយទ្រព្យថ្វាយ ដោយព្រះរាជទ្រព្យព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិកាលទ្រង់នឹងល្បងមើលគហបតិរតននោះឯង មុនដម្បូង ទ្រង់ប្រថាប់លើព្រះទីនាំងនាវា សំដៅទៅកាន់ខ្សែទឹកក្នុងកណ្ដាលទន្លេគង្គា ទើបទ្រង់ត្រាស់នឹងគហបតិរតននោះយ៉ាងនេះថា ម្នាលគហបតីយើងមានសេចក្ដីត្រូវការ ដោយប្រាក់និងមាស ។ គហបតិរតននោះក្រាបបង្គំទូលតបថា បពិត្រមហារាជ បើដូច្នោះ សូមទ្រង់បែរនាវាទៅកាន់ត្រើយច្រាំងម្ខាង ។ ទ្រង់មានព្រះរាជឱង្ការថា គហបតី យើងមានសេចក្ដីត្រូវការនឹងប្រាក់និងមាសត្រង់ទីនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង គហបតិរតននោះលូកដៃទាំងពីរចុះទៅក្នុងទឹក ចាប់លើកយកឆ្នាំងដែលពេញ ដោយប្រាក់និងមាស ហើយក្រាបទូលស្ដេចចក្រពត្តិថា បពិត្រមហារាជ ល្មមហើយដោយប្រាក់និងមាសប៉ុណ្ណោះ

កតមេត្តាវតា មហារាជ បូជិតមេត្តាវតា មហារាជាតិ ។ រាជា ចក្កវត្តិ ឯវមាហ អលមេត្តាវតា គហបតិ កតមេត្តាវតា គហបតិ បូជិតមេត្តាវតា គហបតីតិ ។ រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស ឯវរូបំ គហបតិរតនំ បាតុភវតិ ។

(១៦៤) បុន ចបរំ ភិក្ខវេ រញ្ញោ ចក្កវត្តិស្ស បរិណាយករតនំ បាតុភវតិ ។ បណ្ឌិតោ ព្យត្តោ មេធាវី បដិពលោ រាជានំ ចក្កវត្តឹ ឧបយាបេតព្វំ ឧបយាបេតុំ អបយាបេតព្វំ អបយាបេតុំ ឋបេតព្វំ ឋបេតុំ ។ សោ រាជានំ ចក្កវត្តឹ ឧបសង្កមិត្វា ឯវមាហ អប្បោស្សុក្កោ ត្វំ ទេវ ហោហិ



បពិត្រមហារាជ ប្រាក់និងមាសប៉ុណ្ណេះ ល្មមធ្វើព្រះរាជកិច្ចបានហើយ បពិត្រមហារាជ ប្រាក់និងមាសប៉ុណ្ណេះ ខ្ញុំព្រះអង្គថ្វាយហើយ ។ ស្តេចចក្រពត្តិ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី ប្រាក់និងមាសប៉ុណ្ណេះល្មមហើយ ម្នាលគហបតី ប្រាក់និងមាសប៉ុណ្ណេះ ល្មមធ្វើកិច្ចបានហើយ ម្នាលគហបតី ប្រាក់និងមាសប៉ុណ្ណេះ អ្នកឯងថ្វាយយើងហើយ ។ ម្នាលភិក្ខុទាំងឡាយ គហបតិរ័ត្ន មានសភាពយ៉ាងនេះ តែងកើតប្រាកដ ដល់ស្តេចចក្រពត្តិ ។

(១៦៤) ម្នាលភិក្ខុទាំងឡាយ តទៅទៀត បរិនាយករតនៈ[១] (បរិនាយករ័ត្ន) ក៏កើតប្រាកដ ដល់ស្តេចចក្រពត្តិ ។ (បរិនាយករ័ត្ននោះ) ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញា អាចនឹង ដើម្បីញុំាងស្តេចចក្រពត្តិ ដែលគួរនាំឲ្យស្តេចចូលទៅ ឲ្យចូលទៅបាន ដើម្បីញុំាងស្តេចចក្រពត្តិ ដែលគួរនាំឲ្យស្តេចចេញទៅ ឲ្យចេញទៅបាន ដើម្បីញុំាងស្តេចចក្រពត្តិ ឲ្យតាំងនៅក្នុងទីដែលគួរតាំងបាន ។ បរិនាយករ័ត្ននោះ ចូលទៅគាល់ស្តេចចក្រពត្តិហើយ ទើបក្រាបបង្គំទូល យ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គ កុំមានសេចក្តីខ្វល់ខ្វាយឡើយ

១– មើលមហាសុទស្សនសូត្រ ទីឃនិកាយ មហាវគ្គ ភាគ ១៧ ទំព័រ ១៤ ត្រង់ខ្សែលក្ខណៈលេខ ១

អហំ អនុសាសិស្សាមីតិ ។ ឯវរូបំ ភិក្ខវេ រញ្ញោ ចក្កវត្តិស្ស បរិណាយករតនំ បាតុភវតិ ។ រាជា ភិក្ខវេ ចក្កវត្តិ ឥមេហិ រតនេហិ សមន្នាគតោ ហោតិ ។ កតមេហិ ចតូហិ ឥទ្ធីហិ ។

(១៦៥) ឥធ ភិក្ខវេ រាជា ចក្កវត្តិ អភិរូបោ ហោតិ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ អតិវិយ អញ្ញេហិ មនុស្សេហិ ។ រាជា ភិក្ខវេ ចក្កវត្តិ ឥមាយ បឋមាយ ឥទ្ធិយា សមន្នាគតោ ហោតិ ។

(១៦៦) បុន ចបរំ ភិក្ខវេ រាជា ចក្កវត្តិ ទីឃាយុកោ ហោតិ ចិរដ្ឋិតិកោ អតិវិយ អញ្ញេហិ មនុស្សេហិ ។ រាជា ភិក្ខវេ ចក្កវត្តិ ឥមាយ ទុតិយាយ ឥទ្ធិយា សមន្នាគតោ ហោតិ ។

(១៦៧) បុន ចបរំ ភិក្ខវេ រាជា ចក្កវត្តិ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ អតិវិយ



ខ្ញុំព្រះអង្គនឹងប្រៀនប្រដៅថ្វាយ ។ ម្នាលភិក្ខុទាំងឡាយ បរិនាយកកែវ មានសភាពយ៉ាងនេះ តែងកើតប្រាកដដល់ស្តេចចក្រពត្តិ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ ទ្រង់ប្រកបដោយរតនៈ (៧ ប្រការ) នេះផង ។ ស្តេចចក្រពត្តិ ទ្រង់ប្រកបដោយឫទ្ធិ ៤ យ៉ាង តើដូចម្តេចខ្លះ ។

(១៦៥) ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិមានព្រះរូបល្អ គួរឲ្យអ្នកផងពិតពិលរមិលមើល គួរឲ្យជ្រះថ្លា ទ្រង់ប្រកបដោយព្រះវណ្ណដ៏ល្អក្រៃលែង ជាងមនុស្សឯទៀត ក្នុងលោកនេះ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ ទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិ ទី ១ ។

(១៦៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្តេចចក្រពត្តិ មានព្រះជន្មាយុវែង ទ្រង់ឋិតនៅ អស់កាលយូរអង្វែង ក្រៃលែងជាងមនុស្សទាំងឡាយឯទៀត ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិ ទី ២ ។

(១៦៧) ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្តេចចក្រពត្តិ ទ្រង់មិនមានអាពាធ មិនមានទុក្ខ ប្រកបដោយភ្លើងធាតុ ដែលកើតអំពីកម្ម មានវិបាកស្មើគ្នា គឺ មិនត្រជាក់ពេក មិនក្តៅពេក លើសជាង

អញ្ញេហិ មនុស្សេហិ ។ រាជា ភិក្ខវេ ចក្កវត្តិ ឥមាយ ចតុត្ថិយា ឥទ្ធិយា សមន្នាគតោ ហោតិ ។

(១៦៨) បុន ចបរំ ភិក្ខវេ រាជា ចក្កវត្តិ ព្រាហ្ម-ណគហបតិកានំ បិយោ ហោតិ មនាបោ ។ សេយ្យ-ថាបិ ភិក្ខវេ បិតា បុត្តានំ បិយោ ហោតិ មនាបោ ឯវមេវ ខោ ភិក្ខវេ រាជា ចក្កវត្តិ ព្រាហ្មណគហប-តិកានំ បិយោ ហោតិ មនាបោ ។ រញ្ញោ ភិក្ខវេ ចក្កវត្តិស្ស ព្រាហ្មណគហបតិកា បិយា ហោន្តិ មនាបា ។ សេយ្យថាបិ ភិក្ខវេ បិតុ បុត្តា បិយា ហោន្តិ មនាបា ឯវមេវ ខោ ភិក្ខវេ រញ្ញោ ចក្កវត្តិស្ស ព្រាហ្មណគហបតិកា បិយា ហោន្តិ មនាបា ។ ភូតបុព្វំ ភិក្ខវេ រាជា ចក្កវត្តិ ចតុរង្គិនិយា សេនាយ ឧយ្យានភូមឹ និយ្យាសិ ។ អថ ខោ ភិក្ខវេ ព្រាហ្មណ-គហបតិកា រាជានំ ចក្កវត្តឹ ឧបសង្កមិត្វា ឯវមាហំសុ



មនុស្សដទៃ ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិ ទ្រង់ប្រកបដោយឫទ្ធិ នេះជាគម្រប់ ទី ៤ ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ស្ដេចចក្រពត្តិទ្រង់ជាទីស្រឡាញ់ ជាទីពេញចិត្តនៃព្រាហ្មណ៍និងគហបតីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បិតាជាទីស្រឡាញ់ពេញចិត្ត នៃកូនទាំងឡាយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិ ទ្រង់ជាទីស្រឡាញ់ពេញចិត្ត នៃព្រាហ្មណ៍និងគហបតីទាំងឡាយ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងព្រាហ្មណ៍ និងគហបតីទាំងឡាយ ក៏ជាទីស្រឡាញ់ពេញព្រះហឫទ័យនៃស្ដេចចក្រពត្តិដែរ ។ ម្នាលភិក្ខុទាំងឡាយ កូនទាំងឡាយ ជាទីស្រឡាញ់ពេញចិត្តនៃបិតា យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍និងគហបតីទាំងឡាយ ក៏ជាទីស្រឡាញ់ពេញព្រះហឫទ័យនៃស្ដេចចក្រពត្តិ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិ កាលមុនដម្បូង ទ្រង់ស្ដេចទៅកាន់ទីឧទ្យាន ដោយចតុរង្គ-សេនា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រាហ្មណ៍និងគហបតីទាំងឡាយ ចូលទៅគាល់ស្ដេចចក្រពត្តិ ក្រាបបង្គំទូល យ៉ាងនេះថា

អតរមានោ ទេវ យាហិ យថា តំ មយំ ចិរតរំ បស្សេយ្យាមាតិ ។ រាជាបិ ភិក្ខវេ ចក្កវត្តិ សារថឹ អាមន្តេសិ អតរមានោ សារថិ បេសេហិ យថាហំ ព្រាហ្មណគហបតិកេ ចិរតរំ បស្សេយ្យន្តិ ។ រាជា ភិក្ខវេ ចក្កវត្តិ ឥមាយ ចតុត្ថាយ ឥទ្ធិយា សមន្នាគតោ ហោតិ ។ រាជា ភិក្ខវេ ចក្កវត្តិ ឥមាហិ ចតូហិ ឥទ្ធីហិ សមន្នាគតោ ហោតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ ខោ រាជា ចក្កវត្តិ ឥមេហិ សត្តហិ រតនេហិ សមន្នាគតោ ឥមាហិ ចតូហិ ច ឥទ្ធីហិ តតោនិទានំ សុខំ សោមនស្សំ បដិសំវេទិយេថាតិ ។ ឯកមេកេនបិ(១) ភន្តេ រតនេន សមន្នាគតោ រាជា ចក្កវត្តិ តតោនិទានំ សុខំ សោមនស្សំ បដិសំវេទិយេថ កោ បន វាទោ សត្តហិ រតនេហិ ចតូហិ ច ឥទ្ធីហីតិ ។

១ ម. ឯកមេកេនាបិ ទិស្សតិ ។



បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំស្ដេចទៅ ដោយរួសរាន់ឡើយ សូមឱ្យយើងខ្ញុំព្រះអង្គឃើញព្រះអង្គ អស់កាលយូរ ។

ម្នាលភិក្ខុទាំងឡាយ ឯស្ដេចចក្រពត្តិ ទ្រង់ត្រាស់នឹងសារថីថា ម្នាលសារថី អ្នកកុំបររថទៅ ដោយរួសរាន់ឡើយ ។ សុំឱ្យខ្ញុំឃើញព្រាហ្មណ៍និងគហបតីទាំងឡាយ អស់កាលយូរ ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិ ទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិ ទី៤ ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិ ទ្រង់ប្រកបដោយឫទ្ធិ ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះ ជាដូចម្ដេច ស្ដេចចក្រពត្តិ ប្រកបដោយរតនៈទាំង ៧ ប្រការនេះផង ដោយឫទ្ធិ ៤ យ៉ាងនេះផង តើទ្រង់សោយនូវសេចក្ដីសុខសោមនស្ស ព្រោះរតនៈនិងឫទ្ធិនោះជាហេតុដែរឬទេ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ស្ដេចចក្រពត្តិសូម្បីប្រកបដោយរតនៈតែមួយ ។ ក៏គង់សោយសេចក្ដីសុខសោមនស្ស ព្រោះរតនៈនោះ ជាហេតុទៅហើយ ចាំបាច់និយាយថ្វី ដល់ទៅប្រកបដោយរតនៈទាំង ៧ ប្រការ និងឫទ្ធិ ៤ យ៉ាង(នោះ) ។

(១៦៨) អថខោ ភគវា បរិត្តំ បាណិមត្តំ បាសាណំ គហេត្វា ភិក្ខូ អាមន្តេសិ តំ កឹ មញ្ញថ ភិក្ខវេ កតមោ នុ ខោ មហន្តតរោ យោ ចាយំ មយា បរិត្តោ បាណិមត្តោ បាសាណោ គហិតោ[១] ហិមវា វា បព្វតរាជាតិ ។ អប្បមត្តកោ អយំ ភន្តេ ភគវតា បរិត្តោ បាណិមត្តោ បាសាណោ គហិតោ ហិមវន្តំ បព្វតរាជានំ ឧបនិធាយ សង្ខម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតីតិ ។ ឯវមេវ ខោ ភិក្ខវេ អយំ រាជា ចក្កវត្តិ សត្តហិ រតនេហិ សមន្នាគតោ ចតូហិ ច ឥទ្ធីហិ តតោនិទានំ សុខំ សោមនស្សំ បដិសំវេទេតិ ។ តំ ទិព្វស្ស សុខស្ស ឧបនិធាយ សង្ខម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតិ ។

១ ម. និក្ខិត្តោ យោ បាឋោ ទិស្សតិ ។



(១៦៨) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចាប់ដុំថ្មតូចប្រមាណប៉ុនបាតដៃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្ដីនោះ ដូចម្ដេច ដុំថ្មតូចប្រមាណប៉ុនបាតដៃ ដែលតថាគតកាន់នេះ និងភ្នំហិមពាន្ត តើណាធំជាង ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដុំថ្មតូចប្រមាណប៉ុនបាតដៃ ដែលព្រះអង្គកាន់នេះតូចពេកណាស់បើប្រៀបផ្ទឹមនឹងភ្នំហិមពាន្ត មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិ ប្រកបដោយរតនៈទាំង ៧ ប្រការ និងឫទ្ធិ ៤ យ៉ាង ទ្រង់សោយសេចក្ដីសុខ សោមនស្សណា ព្រោះរតនៈ និងឫទ្ធិនោះជាហេតុ ។ សេចក្ដីសុខនោះ ប្រៀបផ្ទឹមនឹងសេចក្ដីសុខទិព្វ មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ក៏ដូច្នោះដែរ ។

(៤៧០) ស ខោ សោ ភិក្ខវេ បណ្ឌិតោ សចេ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន មនុស្សត្តំ អាគច្ឆតិ យានិ តានិ ឧច្ចាកុលានិ ខត្តិយមហាសាលកុលំ វា ព្រាហ្មណមហាសាលកុលំ វា គហបតិមហាសាលកុលំ វា តថារូបេ កុលេ បច្ចាជាយតិ អឌ្ឍេ មហទ្ធនេ មហាភោគេ បហូតជាតរូបរជតេ បហូតវិត្តូបករណេ បហូតធនធញ្ញេ ។ សោ ច ហោតិ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណពោក្ខរតាយ សមន្នាគតោ លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថបទីបេយ្យស្ស ។ សោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ ។ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ



(៤៧០) ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតនោះ បើអំណើរកាលយូរអង្វែងទៅមួយ ៗ ក៏មកកាន់អត្តភាពជាមនុស្ស ក្នុងកាលជាខាងក្រោយ តែងកើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាលខ្លះ ត្រកូលព្រាហ្មណមហាសាលខ្លះ ត្រកូលគហបតីមហាសាលខ្លះ ជាត្រកូលស្តុកស្តម្ភមាំមួន មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន មានប្រាក់មាសច្រើន មានគ្រឿងឧបករណ៍ច្រើន មានធញ្ញជាតជាទ្រព្យច្រើន ៗ មួយទៀត ជនជាបណ្ឌិតនោះមានរូបល្អ គួរពិតពិលរមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អដ៏ក្រៃលែង ជាអ្នកបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ទីនៅអាស្រ័យ និងគ្រឿងប្រទីប ៗ ជនជាបណ្ឌិតនោះ តែងប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ៗ លុះជនជាបណ្ឌិតនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ហើយដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ៗ

(៦៧៦) សេយ្យថាបិ ភិក្ខវេ អក្ខធុត្តោ បឋមេនេវ កដគ្គហេន មហន្តំ ភោគក្ខន្ធំ អធិគច្ឆេយ្យ ។ អប្បមត្តកោ សោ ភិក្ខវេ កដគ្គហោ យំ សោ[១] សោ អក្ខធុត្តោ បឋមេនេវ កដគ្គហេន មហន្តំ ភោគក្ខន្ធំ អធិគច្ឆេយ្យ ។ អថខោ អយមេវ តតោ មហន្តតរោ កដគ្គហោ យំ សោ បណ្ឌិតោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ អយំ ភិក្ខវេ កេវលា បរិបូរា បណ្ឌិតភូមីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ពាលបណ្ឌិតសុត្តំ នវមំ និដ្ឋិតំ ។

១ ឱ. ម. កលិគ្គហោ ។



(៦៧៦) ម្នាលភិក្ខុទាំងឡាយ ដូចអ្នកលេងល្បែងភ្នាល់ បាននូវកងទ្រព្យសម្បត្តិច្រើន ដោយការឈ្នះជាដំបូងប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ហេតុដែលអ្នកលេងល្បែងភ្នាល់នោះ បាននូវកងទ្រព្យសម្បត្តិច្រើន ដោយការឈ្នះជាដំបូងប៉ុណ្ណោះនោះ ឈ្មោះថាជាការឈ្នះដែលបន្តិចបន្តួចទេ ។ បំណែកខាងដែលជាបណ្ឌិតនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោកនេះឯង ទើបឈ្មោះថាការឈ្នះធំជាងនោះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាបណ្ឌិតភូមិ ដ៏បរិបូណ៌គ្រប់គ្រាន់ ។ លុះព្រះមានព្រះភាគ ត្រាស់ព្រះសូត្រនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ពាលបណ្ឌិតសូត្រ ទី ៩ ។

## ទសមំ ទេវទូតសុត្តំ

(១៣២) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១៣៣) ភគវា ឯតទវោច សេយ្យថាបិ ភិក្ខវេ ទ្វេ អគារា សទ្វារា[១] តត្ថ[២] ចក្ខុមា បុរិសោ មជ្ឈេ ឋិតោ បស្សេយ្យ មនុស្សេ គេហំ បវិសន្តេបិ និក្ខមន្តេបិ អនុសញ្ចរន្តេបិ អនុវិចរន្តេបិ ឯវមេវ ខោ អហំ ភិក្ខវេ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ

១ ម. សទ្វារានិ ទិស្សតិ ។ ២ ម. តត្ថ ។

## ទេវទូតសូត្រ ទី ១០

(១៣២) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាលព្រះមានព្រះភាគ គង់នៅក្នុងវត្តនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(១៣៣) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មានផ្ទះពីរ ប្រកបដោយទ្វារ ក្នុងផ្ទះនោះ មានបុរសភ្នែកភ្លឺម្នាក់ ឈរចំកណ្តាល គប្បីមើលឃើញពួកមនុស្ស ដែលកំពុងចូលទៅកាន់ផ្ទះក្តី ចេញអំពីផ្ទះក្តី កំពុងសញ្ចរទៅមកក្តី កំពុងត្រាច់ទៅមកក្តី សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចតថាគត មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងលើសចក្ខុរបស់នៃមនុស្សធម្មតា រមែងឃើញពួកសត្វលោកដែលច្យុត ដែលកើត

ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាមិ ឥមេ វត ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា មនុស្សេសុ ឧបបន្នា ឥមេ វត ភោន្តោ សត្តា កាយ-ទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទ-កា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ



ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយនៃកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ចំណែកសត្វទាំងឡាយនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយនៃកាយស្លាប់ទៅ ក៏ទៅកើតក្នុងមនុស្ស-លោក អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ

កាយស្ស ភេទា បរម្មរណា បិត្តិវិសយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា តិរច្ឆានយោនឹ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នាតិ ។

(១៧៦) តមេនំ ភិក្ខវេ និរយបាលា នានាពាហាសុ គហេត្វា យមស្ស រញ្ញោ ទស្សេន្តិ អយំ ទេវ បុរិសោ អមេត្តេយ្យោ[១] អសាមញ្ញោ អព្រហ្មញ្ញោ ន កុលេ ជេដ្ឋាបចាយី ឥមស្ស ទេវោ ទណ្ឌំ បណេតូតិ ។

១. អមេត្តេយ្យោ អបេត្តេយ្យោ តិបិ ។



បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតប្រេតវិស័យ ចំណែកសត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ចំណែកពួកសត្វនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។

(១៧៦) ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះត្រង់ដើមដៃផ្សេងៗ នាំយកទៅថ្វាយព្រះយមរាជ (១) ទូលក្រាបបង្គំថា បពិត្រព្រះសម្មតិទេព បុរសនេះ ជាអ្នកមិនគោរពមាតាបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនកោតក្រែងក្នុងត្រកូលរៀមច្បងទេ សូមទ្រង់ដាក់អាជ្ញាដល់បុរសនេះចុះ ។

១– ស្ដេចនោះ ចាំស្ដេចវេមានិកប្រេត ព្រោះវេមានិកប្រេតនេះ ក្នុងកាលខ្លះ សោយទិព្វ–សម្បត្តិ គឺមានវិមានឧទ្យានជាទិព្វ របាំជាទិព្វ ស្រីរាំជាទិព្វ ក្នុងទិព្វវិមាន ក្នុងកាល ក្លាយទៅជាព្រះយមរាជ សោយកម្មវិបាក ។ អដ្ឋកថា ។

(១៧៨) តមេនំ ភិក្ខវេ យមោ រាជា បឋមំ ទេវទូតំ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ បឋមំ ទេវទូតំ បាតុភូតន្តិ ។ សោ ឯវមាហ នាទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ទហរំ កុមារំ មន្ទំ ឧត្តានសេយ្យកំ សកេ មុត្តករីសេ បលិបន្នំ សេមានន្តិ ។ សោ ឯវមាហ អទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស តស្ស តេ វិញ្ញុស្ស សតោ មហល្លកស្ស ឯតទហោសិ[១] អហម្បិ ខោម្ហិ ជាតិធម្មោ ជាតឹ អនតីតោ ហន្ទាហំ កល្យាណំ ករោមិ កាយេន វាចាយ មនសាតិ ។ សោ ឯវមាហ នាសក្ខិស្សំ ភន្តេ

១ ឱ. ម. បញ្ចមេសុ ឥទេសុ ន ឯតទហោសិ ។



(១៧៨) ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជសាកសួរដេញដោល សួរបញ្ចូលល្បី នូវទេវទូតទី ១ នឹងបុរសនោះថា នែបុរស អ្នកឯងមិនបានឃើញទេវទូតទី ១ ដែលកើតប្រាកដក្នុងមនុស្សលោក ទេឬ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រាស់សួរបុរសនោះយ៉ាងនេះវិញថា ម្នាលបុរស អ្នកឯងមិនបានឃើញកូនខ្ចី កំពុងដេកផ្ងារ ដេកប្រាក់ក្នុងទឹកមូត្រនិងលាមក របស់ខ្លួន ក្នុងមនុស្សលោក ទេឬ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីឡើង ហើយផងចាស់ តើមានគំនិតថា អាត្មាអញឯង មានជាតិជាធម្មតា មិនកន្លងនូវជាតិទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច

បមាណសង្ខំ គច្ឆតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស បមាទវតាយ ន កល្យាណមកាសិ កាយេន វាចាយ មនសា តគ្ឃ ត្វំ អម្ភោ បុរិស តថា ករិស្សន្តិ យថាតំ បមត្តំ តំ ខោ បន តេ ឯតំ បាបកម្មំ នេវ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ តយាវេតំ បាបកម្មំ កតំ ត្វញ្ញេវេតស្ស វិបាកំ បដិសំវេទិស្សសីតិ ។



( នឹងគិតឃើញ ដូច្នេះ ) បានឡើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជមានព្រះបន្ទូលតបនឹងបុរសនោះ យ៉ាងនេះថា ម្នាលបុរស ព្រោះតែសេចក្ដីប្រមាទ, បានជាអ្នកឯង មិនបានធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯង មានសេចក្ដីប្រមាទ យ៉ាងណា ពួកនិរយបាល នឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាក នៃបាបកម្មនោះវិញ ។

(១៧៦) តមេនំ ភិក្ខវេ យមោ រាជា បឋមំ ទេវទូតំ សមនុយុញ្ជិត្វា សមនុគ្គាហិត្វា សមនុភាសិត្វា ទុតិយំ ទេវទូតំ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ទុតិយំ ទេវទូតំ បាតុភូតន្តិ ។ សោ ឯវមាហ នាទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ឥត្ថឹ វា បុរិសំ វា អសីតិកំ វា នវុតិកំ វា វស្សសតិកំ វា ជាតិយា ជិណ្ណំ គោបានសិវង្កំ ភោគ្គំ ទណ្ឌបរាយនំ បវេធមានំ គច្ឆន្តំ អាតុរំ គតយោព្វនំ ខណ្ឌទន្តំ បលិតកេសំ វិលូនំ ខលិតំ សិរំ វលិនំ តិលកាហតគត្តន្តិ ។ សោ ឯវមាហ អទ្ទសំ ភន្តេតិ ។



(១៧៦) ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ១ នឹងបុរសនោះរួចហើយ ទើបសាកសួរដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ២ ទៀតថា ម្នាលបុរស អ្នកឯងមិនបានឃើញទេវទូតទី ២ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រាស់សួរបុរសនោះយ៉ាងនេះវិញថា នែបុរស ចុះអ្នកឯងមិនបានឃើញស្ត្រីឬបុរសដែលមានអាយុ ៨០ ឆ្នាំ ៩០ ឆ្នាំ ឬ ១០០ ឆ្នាំ ដែលចាស់គ្រាំគ្រាអំពីកំណើត មានខ្នងពីងពីរកោងដូចជាបង្កង់ផ្ទះ មានកាយកោង កាន់ឈើច្រត់ដើរទៅញ័រខ្លួន ក្តៅអន្ទះសា មានវ័យប្រព្រឹត្តហួសហើយ មានធ្មេញបាក់ មានសក់ស្កូវ មានក្បាលពក មានក្បាលទំពែក មានស្បែកជ្រួញជ្រីវ មានខ្លួនសៅហ្មងដោយប្រជ្រុយ ក្នុងមនុស្សលោកទេឬ ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។

តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស តស្ស តេ វិញ្ញុស្ស សតោ មហល្លកស្ស ឯតទហោសិ អហម្បិ ខោម្ហិ ជរាធម្មោ ជរំ អនតីតោ ហន្ទាហំ កល្យាណំ ករោមិ កាយេន វាចាយ មនសាតិ ។ សោ ឯវមាហ នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស បមាទវតាយ ន កល្យាណមការាសិ កាយេន វាចាយ មនសា តគ្ឃ ត្វំ អម្ភោ បុរិស តថា ករិស្សន្តិ យថាតំ បមត្តំ តំ ខោ បន តេ ឯតំ បាបកម្មំ នេវ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ តយាវេតំ បាបកម្មំ កតំ ត្វញ្ញេវេតស្ស វិបាកំ បដិសំវេទិស្សសីតិ ។



ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីឡើងហូតដល់ចាស់ កើតមានគំនិតថា អាត្មាអញឯង មានសេចក្តីគ្រាំគ្រាជាធម្មតា មិនកន្លងនូវសេចក្តីគ្រាំគ្រាទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះទេឬ ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច ( នឹងគិតឃើញ ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជក៏ត្រាស់តបបុរសយ៉ាងនេះថា ម្នាលបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯង មិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត នែបុរស បើអ្នកឯង មានសេចក្តីប្រមាទយ៉ាងណា ពួកនិរយបាលនឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្រអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាក នៃបាបកម្មនោះវិញ ។

(១៧៧) តមេនំ ភិក្ខវេ យមោ រាជា ទុតិយំ ទេវទូតំ សមនុយុញ្ជិត្វា សមនុគ្គាហិត្វា សមនុភាសិត្វា តតិយំ ទេវទូតំ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ តតិយំ ទេវទូតំ បាតុភូតន្តិ ។ សោ ឯវមាហ នាទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ឥត្ថឹ វា បុរិសំ វា អាពាធិកំ ទុក្ខិតំ ពាឡ្ហគិលានំ សកេ មុត្តករីសេ បលិបន្នំ សេមានំ អញ្ញេហិ វុដ្ឋាបិយមានំ អញ្ញេហិ បវេសិយមានន្តិ(១) ។ សោ ឯវមាហ អទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស តស្ស តេ វិញ្ញុស្ស សតោ មហល្លកស្ស ន ឯតទហោសិ អហម្បិ ខោ ព្យាធិធម្មោ

១ ឱ. ម. សំវេសិយមានន្តិ ទិស្សតិ ។



(១៧៧) ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ២ នឹងបុរសនោះរួចហើយ ទើបសាកសួរដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ៣ ទៀតថា ម្នាលបុរស អ្នកឯងមិនបានឃើញនូវទេវទូតទី ៣ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រាស់សួរបុរសនោះ យ៉ាងនេះវិញថា នែបុរស អ្នកឯងមិនបានឃើញនូវស្ត្រីឬបុរសដែលមានជម្ងឺ ដល់នូវសេចក្តីលំបាក ឈឺធ្ងន់ កំពុងដេកត្រាំក្នុងទឹកមូត្រនិងលាមករបស់ខ្លួន លុះតែមានពួកជនដទៃគ្រាហ៍ទើបក្រោករួច មានពួកជនដទៃគ្រាហ៍ទើបចូលមកបាន ក្នុងមនុស្សលោកទេឬ ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីឡើងហើយដល់ចាស់ ក៏មិនគិតថា សូម្បីអញឯង មានជម្ងឺជាធម្មតា

ព្យាធឹ អនតីតោ ហន្ទាហំ កល្យាណំ ករោមិ កាយេន វាចាយ មនសាតិ ។ សោ ឯវមាហ នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស បមាទវតាយ ន កល្យាណមកាសិ កាយេន វាចាយ មនសា តគ្ឃ ត្វំ អម្ភោ បុរិស តថា ករិស្សន្តិ យថាតំ បមត្តំ តំ ខោ បនេតំ បាបកម្មំ នេវ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ តយាវេតំ បាបកម្មំ កតំ ត្វញ្ញេវេតស្ស វិបាកំ បដិសំវេទិស្សសីតិ ។



មិនកន្លងនូវជម្ងឺទៅបានទេហើយ បើដូច្នោះ គួរតែអាត្មាអញ ធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបាន (មិនគិតឃើញ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ ត្រាស់ពន្យល់បុរសនោះយ៉ាងនេះថា នែបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនបានធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ម្នាលបុរស បើអ្នកឯងមានសេចក្តីប្រមាទ យ៉ាងណា ពួកនិរយបាលនឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិន មែនពួកមិត្រអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ បាបកម្មនុ៎ះ អ្នកឯង ធ្វើខ្លួនឯង អ្នកឯង នឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ ។

(១៧៨) តមេនំ ភិក្ខវេ យមោ រាជា តតិយំ ទេវទូតំ សមនុយុញ្ជិត្វា សមនុគ្គាហិត្វា សមនុភាសិត្វា ចតុត្ថំ ទេវទូតំ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ចតុត្ថំ ទេវទូតំ បាតុភូតន្តិ ។ សោ ឯវមាហ នាទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ រាជានោ ចោរំ អាគុចារឹ គហេត្វា វិវិធា កម្មការណា ការេន្តេ កសាហិបិ តាឡេន្តេ វេត្តេហិបិ តាឡេន្តេ អឌ្ឍទណ្ឌកេហិបិ តាឡេន្តេ ហត្ថម្បិ ឆិន្ទន្តេ បាទម្បិ ឆិន្ទន្តេ ហត្ថបាទម្បិ ឆិន្ទន្តេ កណ្ណម្បិ ឆិន្ទន្តេ នាសម្បិ ឆិន្ទន្តេ



(១៧៨) ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល សួរបញ្ជាក់ នូវទេវទូតទី ៣ នឹងបុរសនោះហើយ ទើបសាកសួរ ដេញដោល សួរបញ្ជាក់ នូវទេវទូតទី ៤ ទៀតថា នែបុរស អ្នកឯងមិនបានឃើញនូវទេវទូត ទី ៤ ដែលកើតប្រាកដ ក្នុងមនុស្សលោកទេឬ ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជត្រាស់ប្រាប់បុរសនោះយ៉ាងនេះវិញថា នែបុរស ចុះអ្នកឯងមិនបានឃើញពួកព្រះរាជាទាំងឡាយ កាលចាប់ចោរ ដែលប្រព្រឹត្តអាក្រក់បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេង ៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ឲ្យកាត់ទាំងដៃទាំងជើងខ្លះ ឲ្យកាត់ស្លឹកត្រចៀកខ្លះ ឲ្យកាត់ច្រមុះខ្លះ

កណ្ណនាសម្បិ ឆិន្ទន្តិ ពិលង្គថាលិកម្បិ ការេន្តិ សង្ខមុណ្ឌិកម្បិ ការេន្តិ រាហុមុខម្បិ ការេន្តិ ជោតិមាលិកម្បិ ការេន្តិ ហត្ថប្បជោតិកម្បិ ការេន្តិ ឯរកវត្តិកម្បិ ការេន្តិ ចីរកវាសិកម្បិ ការេន្តិ ឯណេយ្យកម្បិ ការេន្តិ ពឡិសមំសិកម្បិ ការេន្តិ កហាបណកម្បិ ការេន្តិ ខារាបតច្ឆិកម្បិ ការេន្តិ បលិឃបរិវត្តិកម្បិ ការេន្តិ



ឲ្យកាត់ត្រចៀកកាត់ច្រមុះខ្លះ ឲ្យធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ(១) ឲ្យធ្វើនូវសង្ខមុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យលើនដូចជាសំបកស័ង្ខខ្លះ(២) ឲ្យធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ ឲ្យដូចជាមាត់រាហុខ្លះ(៣) ឲ្យធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ(៤) ឲ្យធ្វើនូវហត្ថប្បជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ(៥) ឲ្យធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាពន្លាត់ស្បែកពពែខ្លះ(៦) ឲ្យធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ(៧) ឲ្យធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាម្រឹគសត្វព្រៃខ្លះ(៨) ឲ្យធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេដោតមាត់ដោយកាំ ឬសន្ទូចខ្លះ(៩) ឲ្យធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខ្លួនសរីរៈប្រមាណប៉ុនកហាបណៈមួយ ១ ខ្លះ(១០) ឲ្យធ្វើនូវខារាបតច្ឆិកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ(១១) ឲ្យធ្វើនូវបលិឃបរិវត្តិកកម្ម គឺអំពើដែលធ្វើឲ្យដូចជាបង្វិលលើទីតូល ឬសសរគោលខ្លះ(១២)

---

១ ។ ល ។ ១២ មើលនយសព្ទក្នុងមហាទុក្ខក្ខន្ធសូត្រ គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសកៈ បឋមភាគ ទំព័រ ៣២០-៣២១ ។

បលាលបីឋកម្បិ ករោន្តេ តត្តេនបិ តេលេន ឱសិញ្ច-
ន្តេ សុនខេហិបិ ខាទាបេន្តេ ជីវន្តម្បិ សូលេ
ឧត្តាសេន្តេ អសិនាបិ សីសំ ឆិន្ទន្តេតិ ។ សោ
ឯវមាហ អទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ
រាជា ឯវមាហ អម្ភោ បុរិស តស្ស តេ វិញ្ញុស្ស
សតោ មហល្លកស្ស ឯតទហោសិ យេ កិរ ភោ
បាបកានិ កម្មានិ ករោន្តិ តេ ទិដ្ឋេវ ធម្មេ
ឯវរូបា វិវិធា កម្មការណា ករីយន្តិ កិមង្គំ បន
បរត្ថ ហន្ទាហំ កល្យាណំ ករោមិ កាយេន
វាចាយ មនសាតិ ។ សោ ឯវមាហ នាសក្ខិស្សំ
ភន្តេ បមាទស្សំ ភន្តេតិ ។ តមេនំ ភិក្ខវេ
យមោ រាជា ឯវមាហ អម្ភោ បុរិស បមាទ-
វតាយ ន កល្យាណមកាសិ កាយេន វាចាយ



ឲ្យដេកលើបលាលបីឋកកម្ម គឺគរគ៏ដែលគេធ្វើឲ្យដូចជាកណ្ដាប់ចំបើងខ្លះ(១) ឲ្យស្រោចប្រេងដែលក្ដៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្ដាតទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ដូច្នេះដែរឬទេ ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ សួរបុរសនោះ យ៉ាងនេះទៀត ថា នែបុរស កាលអ្នកឯងនោះ ដឹងក្ដីឡើង រហូតដល់ចាស់ កើតមានគំនិតថា បានឮថា អ្នកណាធ្វើនូវបាបកម្មទាំងឡាយ អ្នកនោះ គេនឹងធ្វើកម្មករណ៍ផ្សេងៗ យ៉ាងនេះវិញ ក្នុងបច្ចុប្បន្ននេះឯង ចាំបាច់និយាយថ្វី ក្នុងបរលោក បើដូច្នោះ គួរតែអាត្មាអញធ្វើអំពើល្អដោយកាយ ដោយវាចាដោយចិត្ត ដូច្នេះដែរឬទេ ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹងគិតឃើញ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ ក៏ត្រាស់តបបុរសនោះ យ៉ាងនេះថា នែបុរស ព្រោះតែសេចក្ដីប្រមាទ ទើបអ្នកឯងមិនធ្វើអំពើល្អ ដោយកាយ ដោយវាចា

---

១ មើលនយលក្ខណៈ ក្នុងមហាទុក្ខក្ខន្ធសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសកៈ បឋមភាគ ទំព័រ ៤២០–៣៤១ ។

មនសា តគ្ឃ ត្វំ អម្ភោ បុរិស តថា ករិស្សន្តិ យថាតំ បមត្តំ តំ ខោ បន តេ ឯតំ បាបកម្មំ នេវ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ តយាវេតំ បាបកម្មំ កតំ ត្វញ្ញេវេតស្ស វិបាកំ បដិសំវេទិស្សសីតិ ។

(១៣៩) តមេនំ ភិក្ខវេ យមោ រាជា ចតុត្ថំ ទេវទូតំ សមនុយុញ្ជិត្វា សមនុគ្គាហិត្វា សមនុភាសិត្វា បញ្ចមំ ទេវទូតំ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ បញ្ចមំ ទេវទូតំ បាតុភូតន្តិ ។ សោ ឯវមាហ នាទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ឥត្ថឹ វា បុរិសំ វា ឯកាហមតំ វា ទ្វីហមតំ វា តីហមតំ វា



ដោយចិត្ត ម្នាលបុរស បើអ្នកឯង មានសេចក្តីប្រមាទ យ៉ាងណា ពួកនិរយបាល នឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ឯបាបកម្មរបស់អ្នកឯងនុ៎ះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្រអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ បាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ ។

(១៣៩) ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល ស្តីបន្ទោស នូវទេវទូតទី ៤ នឹងបុរសនោះរួចហើយ ទើបសាកសួរ ដេញដោល ស្តីបន្ទោស នូវទេវទូតទី ៥ ទៀតថា នែបុរស អ្នកឯងមិនបានឃើញនូវទេវទូតទី ៥ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ មិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ ត្រាស់សួរបុរសនោះ យ៉ាងនេះវិញថា នែបុរស អ្នកឯងមិនបានឃើញ ស្ត្រីឬបុរសដែលស្លាប់អស់មួយថ្ងៃ ឬស្លាប់អស់ពីរថ្ងៃ ឬក៏ស្លាប់អស់បីថ្ងៃ

ខុទ្ទមាគតំ វិលិតំ វិបុក្កាជាគត្តិ ។ សោ ឯវមាហ អទ្ទសំ ភន្តេ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស តស្ស តេ វិញ្ញុស្ស សតោ មហល្លកស្ស ឯតទហោសិ អហម្បិ ខោម្ហិ ជរាធម្មោ ជរំ អនតីតោ ហន្ទាហំ កល្យាណំ ករោមិ កាយេន វាចាយ មនសាតិ ។ សោ ឯវមាហ នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស បមាទតាយ ន កល្យាណមកាសិ កាយេន វាចាយ មនសា តគ្ឃ ត្វំ អម្ភោ បុរិស តថា ករិស្សន្តិ យថា តំ បមត្តំ តំ ខោ បន តេ ឯតំ បាបកម្មំ នេវ មាតរា កតំ ន បិតរា កតំ



កំពុងតែហើមប៉ោង មានសម្បុរខៀវ ដោយច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេង ៗ ទេឬ ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជស្តីបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីទៅហើយហួតដល់ចាស់ មិនមានគំនិតថា អាត្មាអញឯង មានសេចក្តីចាស់ជាធម្មតា មិនកន្លងសេចក្តីចាស់ទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញ ធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹងនឹកឃើញ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ ត្រាស់ពន្យល់បុរសនោះ យ៉ាងនេះថា នែបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯង មានសេចក្តីប្រមាទ យ៉ាងណា ពួកនិរយបាលនឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ

ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ តយាវេតំ បាបកម្មំ កតំ ត្វញ្ញេវេតស្ស វិបាកំ បដិសំវេទិស្សសីតិ ។ តមេនំ ភិក្ខវេ យមោ រាជា បញ្ចមំ ទេវទូតំ សមនុយុញ្ជិត្វា សមនុគ្គាហិត្វា សមនុភាសិត្វា តុណ្ហី ហោតិ ។



មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្រអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ បាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជបានសាកសួរ ដេញដោល សួរល្បងល្បើ នូវទេវទូតទី៥ នឹងបុរសនោះរួចហើយ ក៏ទ្រង់នៅស្ងៀម[1] ។

---

១ សត្វណាដែលព្រះយមរាជសួរស្ទាបដេញដោលអំពីទេវទូតទាំង ៥ នោះ សត្វណាដែលមិនសួរស្ទាបដេញដោល ។ សត្វដែលធ្វើបាបកម្មច្រើន ត្រូវទៅកើតក្នុងនរកតែម្តង ព្រះយមរាជមិនបាច់សួរទេ ចំណែកសត្វដែលធ្វើបាបកម្មតិច ត្រូវយមរាជសួរដេញដោលអំពីទេវទូត រឿងនេះដូចគ្នានឹងរាជបុរសដែលចាប់ចោរបាន ព្រមទាំងទ្រព្យជាតិសក្ខី ហើយយកមកដាក់ទោសតែម្តងមិនបាច់ជំនុំជំរះ ចំណែកចោរណាដែលចាប់បានល្មមនឹងសាកសួរ ក៏យកទៅសាលាវិនិច្ឆ័យឲ្យសាកសួរមើលសិន ។ គឺថាមែន សត្វដែលធ្វើបាបកម្មតិច ខ្លះកាលនឹកឃើញកម្មការខ្លួនឯង ខ្លះកាលទាល់តែមានគេរំលឹក ទើបនឹកឃើញ ចំណែកសត្វដែលនឹកមិនឃើញដោយខ្លួនឯង ព្រះយមរាជតែងសួរនូវទេវទូតទាំង ៥ ។ ក្នុងទេវទូតទាំង ៥ នោះ សត្វខ្លះនឹកឃើញត្រង់ទេវទូតទី១ ខ្លះនឹកឃើញត្រង់ទេវទូតទី២ ឬទី៣ ជាដើម ឯសត្វដែលនឹកមិនឃើញត្រង់ទេវទូតគ្រប់ទាំង ៥ នោះ ព្រះយមរាជតែងជួយនឹកពីដោយព្រះអង្គឯង បើនឹកទៅឃើញថាមានធ្វើអំពើកុសលខ្លះ ទ្រង់ក៏ប្រាប់សត្វនោះឲ្យយល់ឡើង បើទ្រង់នឹកមើលមិនឃើញទេក៏នៅស្ងៀម នឹកក្នុងព្រះហឫទ័យថា សេចក្ដីនេះមុខជានឹងបានទុក្ខធំ ។ អដ្ឋកថា ។

(១៨០) តមេនំ ភិក្ខវេ និរយបាលា បញ្ចវិធពន្ធនំ នាម កម្មការណំ ការេន្តិ តត្តំ អយោខិលំ ហត្ថេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ ហត្ថេ គមេន្តិ តត្តំ អយោខិលំ បាទេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ បាទេ គមេន្តិ តត្តំ អយោខិលំ មជ្ឈេ ឧរស្មឹ គមេន្តិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។

(១៨១) តមេនំ ភិក្ខវេ និរយបាលា សំវេសេត្វា កុឋារីហិ តច្ឆន្តិ ។ តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា វាសីហិ តច្ឆន្តិ ។ តមេនំ ភិក្ខវេ និរយបាលា រថេ យោជេត្វា តត្តាយ ភូមិយា[១] អាទិត្តាយ[២] សម្បជ្ជលិតាយ សជោតិភូតាយ សារេន្តិបិ បច្ចាសារេន្តិបិ ។ តមេនំ ភិក្ខវេ និរយបាលា មហន្តំ អង្គារបព្វតំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អារោបេន្តិបិ ឱរោបេន្តិបិ ។

១ ឱ. ម. តត្តាយ ភូមិយាតិ ន ទិស្សតិ ។ ២ ឱ. ម. អាទិត្តាយ បឋវិយាតិ ទិស្សតិ ។



(១៨០) ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ធ្វើនូវកម្មករណ៍ ឈ្មោះបញ្ចវិធពន្ធនៈ (ចំណងប្រាំប្រការ) ចំពោះបុរសនោះ គឺផ្តេក (បុរសនោះ) ហើយបោះដែកគោលដ៏ក្តៅត្រង់ដៃ (ខាងស្តាំ) ១ បោះដែកគោលដ៏ក្តៅ ត្រង់ដៃខាងឆ្វេង ១ បោះដែកគោលដ៏ក្តៅ ត្រង់ជើង (ខាងស្តាំ) ១ បោះដែកគោលដ៏ក្តៅត្រង់ជើងខាងឆ្វេង១ បោះដែកគោលដ៏ក្តៅចំកណ្តាលទ្រូង១ ។ បុរសនោះ ក៏សោយទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សា ក្នុងទីនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៨១) ម្នាលភិក្ខុទាំងឡាយ លុះពួកនិរយបាល ចាប់ផ្តេក បុរសនោះរួចហើយ ទើបចាំងដោយដឹង ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយច្រាសដោយកាំបិតក្រា ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ទឹមបុរសនោះនឹងរថ ហើយបរទៅបរមក លើប្រឹថពីដែលភ្លើងកំពុងឆេះក្តៅសព្វ ភ្លឺច្រាលឆ្អាល សន្ធោសន្ធៅ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ប្រើបុរសនោះឲ្យឡើងផង ឲ្យចុះអំពីភ្នំរងើកភ្លើងដ៏ធំ ដែលកំពុងក្តៅសព្វ ភ្លឺច្រាលឆ្អាល សន្ធោសន្ធៅ ។

តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា តត្តាយ លោហកុម្ភិយា បក្ខិបន្តិ អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូតាយ ។ សោ តត្ថ ផេណុទ្ទេហកំ បច្ចតិ ។ សោ តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិម្បិ ឧទ្ធំ គច្ឆតិ សកិម្បិ អធោ គច្ឆតិ សកិម្បិ តិរិយំ គច្ឆតិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។

(១៨៦ តមេនំ ភិក្ខវេ និរយបាលា មហានិរយេ បក្ខិបន្តិ ។ សោ ខោ បន ភិក្ខវេ មហានិរយោ

ចតុក្កណ្ណោ ចតុទ្វារោ
វិភត្តោ ភាគសោ មិតោ
អយោបាការបរិយន្តោ
អយសា បដិកុជ្ជិតោ ។



ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះ យកជើងទៅលើ យកក្បាលចុះក្រោម ហើយទម្លាក់ទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះរាលសព្វ ភ្លឺព្រោលព្រាល សន្ធោសន្ធៅ ។ បុរសនោះ ក៏ឆេះឆ្អិនកំសួលពពុះ ក្នុងខ្ទះទង់ដែងនោះ ។ កាលបុរសនោះ ឆេះឆ្អិនកំសួលពពុះ ក្នុងខ្ទះទង់ដែងនោះ ជួនកាលអណ្តែតឡើងលើម្តង ជួនកាលលិចចុះក្រោមម្តង ជួនកាលអណ្តែតទៅទទឹងម្តង ។ បុរសនោះ សោយទុក្ខវេទនា ក្លាខ្លាំង ក្តៅផ្សា ក្នុងខ្ទះទង់ដែងនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៨៦) ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏បោះបុរសនោះ ទៅក្នុងមហានរក (១) ។ ម្នាលភិក្ខុទាំងឡាយ មហានរកនោះឯងសោត

មានជ្រុងបួន មានទ្វារបួន ចែកចែកដោយចំណែក ។
មានកំពែងដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ។

១ ប្រែថា នរកធំឈ្មោះអវិចី ។ សព្ទនេះប្រែថា ទីគ្មានចន្លោះ គឺនរកនោះគ្មានចន្លោះ អណ្តាតភ្លើង គ្មានចន្លោះសត្វ គ្មានចន្លោះសេចក្តីទុក្ខ គឺពាសពេញដោយភ្លើង ពេញដោយសត្វនរក ។ វត្ថុក្នុងក៏ឥតមានស្បើយ ។ ចំណែកអវិចីមហានរកនោះ ទាំងបណ្តោយទាំងទទឹង ១០០ យោជន៍ស្មើគ្នា កំពែងនីមួយៗ ៩ យោជន៍ ផ្ទៃផែនដីខាងក្រោមក្រាលដោយលោហៈ ដំបូលក៏ប្រក់ដោយលោហៈ ។ អដ្ឋកថា ។

តស្ស អយោមយា ភូមិ
ជលិតា តេជសា យុតា
សមន្តា យោជនសតំ
ផរិត្វា តិដ្ឋតិ សព្វទា ។

តស្ស ខោ បន ភិក្ខវេ មហានិរយស្ស បុរត្ថិមាយ ភិត្តិយា អច្ចិ ឧដ្ឋហិត្វា បច្ឆិមាយ ភិត្តិយា បដិហញ្ញតិ ។ បច្ឆិមាយ ភិត្តិយា អច្ចិ ឧដ្ឋហិត្វា បុរត្ថិមាយ ភិត្តិយា បដិហញ្ញតិ ។ ឧត្តរាយ ភិត្តិយា អច្ចិ ឧដ្ឋហិត្វា ទក្ខិណាយ ភិត្តិយា បដិហញ្ញតិ ។ ទក្ខិណាយ ភិត្តិយា អច្ចិ ឧដ្ឋហិត្វា ឧត្តរាយ ភិត្តិយា បដិហញ្ញតិ ។ ហេដ្ឋា អច្ចិ ឧដ្ឋហិត្វា ឧបរិ បដិហញ្ញតិ ឧបរិតោ អច្ចិ ឧដ្ឋហិត្វា ហេដ្ឋា បដិហញ្ញតិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។



ផ្ទៃផែនដីខាងក្រោមនៃមហានរកនោះ សុទ្ធតែដែក មាន
ភ្លើងឆេះព្រោលព្រាល ផ្សាយទៅបានមួយរយយោជន៍ជុំវិញ
តាំងនៅសព្វ ៗ កាល ។

ម្នាលភិក្ខុទាំងឡាយ មហានរកនោះឯង មានអណ្តាតភ្លើងឆេះឡើងអំពីជញ្ជាំងខាងកើត ឆាបដល់ជញ្ជាំងខាងលិច ។ អណ្តាតភ្លើងឆេះឡើងអំពីជញ្ជាំងខាងលិច ឆាបដល់ជញ្ជាំងខាងកើត ។ អណ្តាតភ្លើង ឆេះឡើងអំពីជញ្ជាំងខាងជើង ឆាបដល់ជញ្ជាំងខាងត្បូង ។ អណ្តាតភ្លើង ឆេះឡើងអំពីជញ្ជាំងខាងត្បូង ឆាបដល់ជញ្ជាំងខាងជើង ។ អណ្តាតភ្លើង ឆេះឡើងអំពីខាងក្រោម ឆាបដល់ខាងលើ អណ្តាតភ្លើង ឆេះឡើងអំពីខាងលើ ឆាបដល់ខាងក្រោម ។ បុរសនោះ ក៏រងទុក្ខវេទនា ក្លាខ្លាំង ក្តៅផ្សាក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៨៣) ហោតិ(១) ខោ(២) សោ ភិក្ខវេ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន មហានិរយស្ស បុរត្ថិមទ្វារំ អបាបុរីយតិ ។ សោ តត្ថ សីឃេន ជវេន ធាវតិ ។ តស្ស សីឃេន ជវេន ធាវតោ ឆវិម្បិ ឌយ្ហតិ ចម្មម្បិ ឌយ្ហតិ មំសម្បិ ឌយ្ហតិ ន្ហារុម្បិ ឌយ្ហតិ អដ្ឋីនិបិ សម្បធូមាយន្តិ ឧព្ភតំ តាទិសមេវ ហោតិ ។ យតោ ច ខោ សោ ភិក្ខវេ ពហុសម្បត្តោ ហោតិ អថ តំ ទ្វារំ បិធីយតិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។

(១៨៤) ហោតិ ខោ សោ ភិក្ខវេ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន តស្ស មហានិរយស្ស បច្ឆិមទ្វារំ អបាបុរីយតិ ។ បេ ។ ឧត្តរទ្វារំ អបាបុរីយតិ ។ បេ ។ ទក្ខិណទ្វារំ អបាបុរីយតិ ។ សោ តត្ថ សីឃេន ជវេន ធាវតិ ។ តស្ស សីឃេន ជវេន ធាវតោ ឆវិម្បិ ឌយ្ហតិ ចម្មម្បិ ឌយ្ហតិ

១ ឱ. ម. ហោតិ ខ ទីឃស្សតិ ។ ២ ម. សោ ខោ ។





(១៨៣) ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តង ៗ មានសម័យដែលពួកនិរយបាល បើកទ្វារទិសកើតនៃមហានរកនោះ ។ បុរសនោះ ក៏ស្ទុះដើរហ័សទៅត្រង់ទ្វារនោះ ។ កាលដែលបុរសនោះ ស្ទុះទៅ ដោយសន្ទុះដើរហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងខ្ទោលឡើង កាលលើកជើងឡើងរួចទៅ ភ្លើងក៏នៅតែឆេះដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបុរសនោះទាំងនៅ (ក្នុងទីនោះ) ជាច្រើនឆ្នាំ ទ្វារនោះក៏និរយបាលបិទទៅវិញ ។ បុរសនោះ សោយទុក្ខវេទនា ក្លាខ្លាំង ក្តៅផ្សាក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៨៤) ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តង ៗ មានសម័យដែលពួកនិរយបាល បើកទ្វារទិសលិចនៃមហានរកនោះ ។ បេ ។ បើកទ្វារទិសជើង ។ បេ ។ បើកទ្វារទិសត្បូង ។ បុរសនោះ ក៏ស្ទុះដោយសន្ទុះដើរហ័ស ទៅត្រង់ទ្វារនោះ ។ កាលបុរសស្ទុះទៅដោយសន្ទុះដើរហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង

មំសម្បិ ឌយ្ហតិ ន្ហារុម្បិ ឌយ្ហតិ អដ្ឋីនិបិ សម្បធូមាយន្តិ ឧព្ភតំ តាទិសមេវ ហោតិ ។ យតោ ច ខោ សោ ភិក្ខវេ ពហុសម្បត្តោ ហោតិ អថ តំ ទ្វារំ បិធីយតិ ។ សោ តត្ថ ទុក្ខា តិព្វា ខរា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។

(១៨៨) ហោតិ ខោ សោ ភិក្ខវេ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន តស្ស មហានិរយស្ស បុរត្ថិមទ្វារំ អបាបុរីយតិ ។ សោ តត្ថ សីឃេន ជវេន ធាវតិ ។ តស្ស សីឃេន ជវេន ធាវតោ ឆវិម្បិ ឌយ្ហតិ ចម្មម្បិ ឌយ្ហតិ មំសម្បិ ឌយ្ហតិ ន្ហារុម្បិ ឌយ្ហតិ អដ្ឋីនិបិ សម្បធូមាយន្តិ ឧព្ភតំ តាទិសមេវ ហោតិ ។ សោ តេន ទ្វារេន និក្ខមតិ ។ តស្ស ខោ បន ភិក្ខវេ មហានិរយស្ស សមនន្តរាសហិតមេវ មហន្តោ គូថនិរយោ ។ សោ តត្ថ បតតិ ។ តស្មិំ ខោ បន ភិក្ខវេ គូថនិរយេ សូចិមុខា បាណា ឆវឹ ឆិន្ទន្តិ ឆវឹ ឆេត្វា ចម្មំ ឆិន្ទន្តិ ចម្មំ ឆេត្វា



ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលលើកជើងឡើងរក់ទៅ ភ្លើងក៏នៅតែឆេះ ប្រាកដដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបុរសនោះដល់ទៅ (ក្នុងទីនោះ) ជាច្រើនឆ្នាំ ទ្វារនោះក៏បិទមកវិញ ។ បុរសនោះរងទុក្ខវេទនាក្លាខ្លាំង ក្តៅក្រហាយក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៨៨) ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តង ៗ មានសម័យដែលពួកនិរយបាល បើកទ្វារខាងកើតនៃមហានរកនោះ ។ បុរសនោះ ក៏ស្ទុះទៅដោយសន្ទុះដ៏រហ័ស ទៅត្រង់ទ្វារនោះ ។ កាលបុរសនោះស្ទុះទៅដោយសន្ទុះដ៏រហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលលើកជើងឡើងរក់ទៅ ភ្លើងក៏នៅតែឆេះ ប្រាកដដូច្នោះឯង ។ បុរសនោះ ក៏ស្ទុះចេញទៅតាមទ្វារនោះ ។ ម្នាលភិក្ខុទាំងឡាយ មានគូថនរក(១) ដ៏ធំ ភ្ជាប់នៅបន្ទាប់គ្នានឹងមហានរកនោះឯង ។ បុរសនោះ ធ្លាក់ទៅក្នុងគូថនរកនោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងគូថនរកនោះសោត មានសត្វទាំងឡាយមាត់ស្រួចដូចម្ជុល កកេរស្បែកក្រៅ លុះកកេរស្បែកក្រៅហើយ កកេរស្បែកក្នុង លុះកកេរស្បែកក្នុងហើយ

---

១ ប្រែថា នរកពេញទៅដោយលាមក ។

មំសំ ឆិន្ទន្តិ មំសំ ឆេត្វា ន្ហារុំ ឆិន្ទន្តិ ន្ហារុំ ឆេត្វា អដ្ឋឹ ឆិន្ទន្តិ អដ្ឋឹ ឆេត្វា អដ្ឋិមិញ្ជំ ខាទន្តិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។

(១៨៦) តស្ស ខោ បន ភិក្ខវេ គូថនិរយស្ស សមនន្តរសហិតមេវ មហន្តោ កុក្កុឡនិរយោ ។ សោ តត្ថ បតតិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។

(១៨៧) តស្ស ខោ បន ភិក្ខវេ កុក្កុឡនិរយស្ស សមនន្តរសហិតមេវ មហន្តំ សិម្ពលិវនំ ឧទ្ធំ[១] យោជនសមុគ្គតំ[២] សោឡសង្គុលិកណ្ដកំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ ។ តំ តត្ថ អារោបេន្តិបិ ឱរោបេន្តិបិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។

១ ឱ. ឧទ្ធំ ។ ម. ឧគ្គតោ ។ ២ ឱ ម. យោជនុគ្គតំ ។



គេកាត់សាច់ លុះគេកាត់សាច់ហើយ គេកាត់សរសៃ លុះគេកាត់សរសៃហើយ គេកាត់ឆ្អឹង លុះគេកាត់ឆ្អឹងហើយ ទើបខាំស៊ីខួរក្នុងឆ្អឹង ។ បុរសនោះ សោយទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងគូថនរកនោះ បើបាបកម្ម មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៨៦) ម្នាលភិក្ខុទាំងឡាយ មានកុក្កុឡនរក[១] ដ៏ធំ តាំងនៅបន្ទាប់គ្នានឹងគូថនរកនោះឯង ។ បុរសនោះ ធ្លាក់ទៅក្នុងកុក្កុឡនរកនោះ ។ បុរសនោះ សោយទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងកុក្កុឡនរកនោះ បើបាបកម្ម មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៨៧) ម្នាលភិក្ខុទាំងឡាយ មានព្រៃរការដ៏ធំ ខ្ពស់ត្រដួចឡើងមួយយោជន៍ មានបន្លា ១៦ ធ្នាប់ ភ្លើងឆេះក្តៅសព្វ ភ្លឺព្រោងព្រោល សន្ធោសន្ធៅ តាំងនៅបន្ទាប់គ្នានឹងកុក្កុឡនរកនោះឯង ។ ពួកនិរយបាល តែងប្រើបុរសនោះឲ្យឡើងឲ្យចុះអំពីព្រៃរការនោះ ។ បុរសនោះ សោយទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាលើដើមរការនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

១ ប្រែថា នរកពេញទៅដោយផេះក្តៅ ។

(១៨៨) តស្ស ខោ បន ភិក្ខវេ សិម្ពលិវនស្ស សមនន្តរសហិតមេវ មហន្តំ អសិបត្តវនំ ។ សោ តត្ថ បវិសតិ ។ តស្ស វាតេរិតានិ បត្តានិ ហត្ថម្បិ ឆិន្ទន្តិ បាទម្បិ ឆិន្ទន្តិ ហត្ថបាទម្បិ ឆិន្ទន្តិ កណ្ណម្បិ ឆិន្ទន្តិ នាសម្បិ ឆិន្ទន្តិ កណ្ណនាសម្បិ ឆិន្ទន្តិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។

(១៨៩) តស្ស ខោ បន ភិក្ខវេ អសិបត្តវនស្ស សមនន្តរសហិតមេវ មហតី ខារោទកា នទី ។ សោ តត្ថ បតតិ ។ សោ តត្ថ អនុសោតម្បិ វុយ្ហតិ បដិសោតម្បិ វុយ្ហតិ អនុសោតបដិសោតម្បិ វុយ្ហតិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។



(១៨៨) ម្នាលភិក្ខុទាំងឡាយ មានព្រៃស្មៅសសិតធំ តាំងនៅបន្ទាប់គ្នានឹងព្រៃគរនោះឯង ។ បុរសនោះ ចូលទៅក្នុងព្រៃស្មៅសសិតនោះ ។ ខ្យល់បក់ស្លឹកសសិតនោះ មកកាត់ដៃ កាត់ជើង កាត់ទាំងដៃទាំងជើង កាត់ស្លឹកត្រចៀក កាត់ច្រមុះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះ (របស់បុរសនោះ) ។ បុរសនោះ សោយទុក្ខវេទនា ក្លាខ្លាំង ក្តៅផ្សា នៅក្នុងព្រៃសសិតនោះ ដរាបណាបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៨៩) ម្នាលភិក្ខុទាំងឡាយ មានស្ទឹងទឹកផ្សាធំ តាំងនៅបន្ទាប់គ្នានឹងព្រៃសសិតនោះឯង ។ បុរសនោះ ក៏ធ្លាក់ទៅក្នុងស្ទឹងនោះ ។ បុរសនោះ ជួនកាលអណ្តែតបណ្តោយខ្សែទឹក ជួនកាលអណ្តែតច្រាសខ្សែទឹក ជួនកាលអណ្តែតទាំងបណ្តោយខ្សែទឹកទាំងច្រាសខ្សែទឹក ក្នុងស្ទឹងនោះ ។ បុរសនោះ សោយទុក្ខវេទនា ក្លាខ្លាំង ក្តៅផ្សាក្នុងស្ទឹងនោះ ដរាបណាបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៩០) តមេនំ ភិក្ខវេ និរយបាលា ពឡិសេន ឧទ្ធរិត្វា ថលេ បតិដ្ឋាបេត្វា ឯវមាហំសុ អម្ភោ បុរិស កឹ ឥច្ឆសីតិ ។ សោ ឯវមាហ ជិឃច្ឆិតោស្មិ ភន្តេតិ ។ តមេនំ ភិក្ខវេ និរយបាលា តត្តេន អយោសង្កុនា មុខំ វិវរិត្វា អាទិត្តេន សម្បជ្ជលិតេន សជោតិភូតេន តត្តំ លោហគុឡំ មុខេ បក្ខិបន្តិ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ ។ សោ(១) តស្ស ឱដ្ឋម្បិ ឌហតិ មុខម្បិ ឌហតិ កណ្ឋម្បិ ឌហតិ ឧទរម្បិ(២) ឌហតិ អន្តម្បិ អន្តគុណម្បិ អាទាយ អធោភាគា និក្ខមតិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។

(១៩១) តមេនំ ភិក្ខវេ និរយបាលា ឯវមាហំសុ អម្ភោ បុរិស កឹ ឥច្ឆសីតិ ។ សោ ឯវមាហ បិបាសិ-

១ ឱ. សោតិ ន ទិស្សតិ ។ ម. តំ ។ ២ ឱ. ម. ឧរម្បិ ។



(១៩០) ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល យកសន្ទូច ស្ទូចបុរសនោះពត់ឡើង ដាក់មកលើគោក ហើយសួរយ៉ាងនេះថា នែបុរស អ្នកឯងប្រាថ្នាអ្វី ។ បុរសនោះឆ្លើយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន ខ្ញុំឃ្លានបាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏យកកន្លាស់ដែក ដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺព្រាលព្រោល សន្ធោសន្ធៅ មក បើកមាត់បុរសនោះ ហើយញាត់នូវដុំទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺព្រាលព្រោល សន្ធោសន្ធៅ ទៅក្នុងមាត់ ។ ដុំទង់ដែងនោះ ក៏ឆេះបបូរមាត់ ឆេះមាត់ ឆេះបំពង់ក ឆេះពោះ នាំយកទាំងពោះវៀនធំ ទាំងពោះវៀនតូច របស់បុរសនោះ ចេញមកខាងក្រោម ។ បុរសនោះ សោយទុក្ខវេទនា ក្លាខ្លាំង ក្តៅក្រហាយក្នុងនរកនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

(១៩១) ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល សួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស អ្នកឯងប្រាថ្នាអ្វី ។ បុរសនោះឆ្លើយយ៉ាង

តោស្មិ ភន្តេតិ ។ តមេនំ ភិក្ខវេ និរយបាលា តត្តេន អយោសង្កុនា មុខំ វិវរិត្វា អាទិត្តេន សម្បជ្ជលិតេន សជោតិភូតេន តត្តំ តម្ពលោហំ មុខេ អាសិញ្ចន្តិ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ ។ តំ តស្ស ឱដ្ឋម្បិ ទហតិ មុខម្បិ ទហតិ កណ្ឋម្បិ ទហតិ ឧទរម្បិ ទហតិ អន្តម្បិ អន្តគុណម្បិ អាទាយ អធោភាគា និក្ខមតិ ។ សោ តត្ថ ទុក្ខា តិព្វា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ តមេនំ ភិក្ខវេ និរយបាលា បុន មហានិរយេ បក្ខិបន្តិ ។

(១៩២) ភូតបុព្វំ ភិក្ខវេ យមស្ស រញ្ញោ ឯតទហោសិ យេ កិរ ភោ លោកេ បាបកានិ កម្មានិ ករោន្តិ តេ ឯវរូបា វិវិធា កម្មការណា ការិយន្តិ អហោ វតាហំ មនុស្សត្តំ លភេយ្យំ តថាគតោ ច លោកេ ឧប្បជ្ជេយ្យ អរហំ សម្មាសម្ពុទ្ធោ តញ្ចាហំ ភគវន្តំ បយិរុបាសេយ្យំ សោ ច



ទៅថា បពិត្រលោកដ៏ចំរើន ខ្ញុំស្រេកទឹក ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល យកកន្ទ្រៀវដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺព្រោងព្រាល សន្ធោសន្ធៅ មកបើកមាត់បុរសនោះ ហើយបន្តក់ទឹកទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺព្រោងព្រាល សន្ធោសន្ធៅ ទៅក្នុងមាត់ ។ ទឹកទង់ដែងនោះ ក៏ឆេះបបូរមាត់ ឆេះមាត់ ឆេះបំពង់ក ឆេះទ្រូង នាំយកពោះវៀនធំ ពោះវៀនតូច របស់បុរសនោះចេញមកខាងក្រោម ។ បុរសនោះ សោយទុក្ខវេទនា ក្លាខ្លាំង ក្តៅក្រហាយក្នុងនរកនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ច្រានទំលាក់បុរសនោះ ទៅក្នុងមហានរកវិញ ។

(១៩២) ម្នាលភិក្ខុទាំងឡាយ រឿងក៏រ ធ្លាប់មានមកហើយថា ព្រះយមរាជ មានសេចក្តីត្រិះរិះដូច្នេះថា បានឮថា សត្វទាំងឡាយណា ធ្វើបាបកម្ម ក្នុងលោក សត្វនោះឯង រមែងត្រូវគេធ្វើកម្មករណ៍ផ្សេងៗ មានសភាពយ៉ាងនេះ ឱហ្ន៎ តាក្អែញ សូមឲ្យបានអត្តភាពជាមនុស្ស ឲ្យទាន់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងក្នុងលោក សូមឲ្យតាក្អែញ ចូលទៅអង្គុយជិតព្រះមានព្រះភាគអង្គនោះ បើព្រះ

មេ ភគវា ធម្មំ ទេសេយ្យ តស្សាហំ ភគវតោ ធម្មំ អាជានេយ្យន្តិ ។ តំ ខោ បនាហំ ភិក្ខវេ អញ្ញស្ស កស្សចិ សមណស្ស វា ព្រាហ្មណស្ស វា សុត្វា វទាមិ អបិច ខោ[1] យទេវ មេ សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តមេវាហំ វទាមីតិ ។

(១៩៣) ឥទមវោច ភគវា ឥទំ វត្វាន[2] សុគ-តោ អថាបរំ ឯតទវោច សត្ថា

ចោទិតា ទេវទូតេហិ
យេ បមជ្ជន្តិ មាណវា
តេ ទីឃរត្តំ សោចន្តិ
ហីនកាយូបគា នរា
យេ ច ខោ ទេវទូតេហិ
សន្តោ សប្បុរិសា ឥធ
ចោទិតា នប្បមជ្ជន្តិ
អរិយធម្មេ កុទាចនំ
ឧបាទានេ ភយំ ទិស្វា
ជាតិមរណសម្ភវេ

១ ឱ. ម. [illegible] ។ ២ ឱ. [illegible] ។



មានព្រះភាគអង្គនោះ ទ្រង់សំដែងធម៌ព្រោះខ្ញុំគប្បី សូមឲ្យខ្ញុំដឹង យល់ច្បាស់ នូវធម៌របស់ព្រះមានព្រះភាគអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនមែនបានស្តាប់រឿងនោះឯង អំពីសមណៈ ឬព្រាហ្មណ៍ដទៃណាមួយ ហើយ (នាំមក) សំដែងទេ តាមដែលពិតនោះ តថាគត សំដែងរឿងដែលតថាគតដឹងខ្លួនឯង ឃើញខ្លួនឯង យល់ខ្លួនឯង តែមួយយ៉ាង ។

(១៩៣) លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ លុះព្រះសុគត ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ទើបព្រះសាស្តា ទ្រង់ត្រាស់និពន្ធគាថានេះទៀតថា

មាណពទាំងឡាយណា ដែលយមរាជ ដាស់តឿន ដោយទេវទូតទាំងឡាយហើយ ក៏នៅតែប្រមាទ មាណពទាំងនោះឯង ជាអ្នកបានខ្លួនកាយ ថោកទាប រមែងសោកសៅ អស់កាលយូរអង្វែង ចំណែកមាណពណា ក្នុងលោកនេះ ជាសប្បុរស មានសន្តានស្ងប់រម្ងាប់ ដែលយមរាជ ដាស់តឿន ដោយទេវទូតទាំងឡាយហើយ តែងមិនប្រមាទក្នុងអរិយធម៌ ក្នុងកាលណាឡើយ រមែងឃើញនូវភ័យក្នុងឧបាទាន ជាហេតុកើតឡើងនៃជាតិនិងមរណៈ

អនុបាទា វិមុច្ចន្តិ

ជាតិមរណសង្ខយេ

តេ ខេមប្បត្តា សុខិនោ

ទិដ្ឋធម្មាភិនិព្វុតា

សព្វវេរភយាតីតា

សព្វទុក្ខំ ឧបច្ចគុន្តិ ។

ទេវទូតសុត្តំ ទសមំ និដ្ឋិតំ ។

សុញ្ញតវគ្គោ តតិយោ ។

តស្សុទ្ទានំ

អព្ភុតោ សុញ្ញតគ្គហណោ

ពក្កុលវីរោ មហិជាមោ

អនុរុទ្ធកិលេសម្ពជិហត្ថា

បណ្ឌិតភូមិ ទេវទូតោ(១) ។

១ មរម៉ាយោត្តកេ តស្សុទ្ទានស្ស អព្ភុតោ...ទេវទូតោតិ ឆាយា ៥ ទិស្សន្តិ ។ មាមុរោត្តកេ តស្ស ឋានស្ស ទ្វារធិ ។ ទ្វិធាវសុញ្ញតា ហោតិ អព្ភុតធម្មពាកុលំ អចិរវតភូមិជនាមោ អនុរុទ្ធុបក្កិលេសំ ពាលបណ្ឌិតោ ទេវទូតញ្ច តេរសាតិ ទិស្សន្តិ ។



ដែលរួចផុត ក្នុងព្រះនិព្វាន ជាទីអស់ទៅនៃជាតិ និងមរណៈ ព្រោះមិនប្រកាន់មាំ ពួកជននោះឯង ជាអ្នកដល់នូវទីក្សេម មានសេចក្ដីសុខ រលត់កិលេសក្នុងបច្ចុប្បន្ន ជាអ្នកកន្លងផុតនូវពៀរ និងភ័យទាំងពួង បានកន្លងផុតនូវទុក្ខទាំងពួង ។

ចប់ ទេវទូតសូត្រ ទី ១០ ។

ចប់ សុញ្ញតវគ្គ ទី ៣ ។

## បញ្ជីឈ្មោះសូត្រ នៃសុញ្ញតវគ្គនោះគឺ

ចូឡសុញ្ញតសូត្រ មហាសុញ្ញតសូត្រ អច្ឆរិយព្ភូតធម្មសូត្រ ដ៏ប្រសើរ ពក្កុលត្ថេរច្ឆរិយព្ភូតធម្មសូត្រ ទន្តភូមិសូត្រ ភូមិជសូត្រ អនុរុទ្ធសូត្រ ឧបក្កិលេសសូត្រ ពាលបណ្ឌិតសូត្រ ទេវទូតសូត្រ ។

## មាតិកាបន្ទាប់

## សុញ្ញតវគ្គោ

### បឋមំ ចូឡសុញ្ញតសុត្តំ


| | | អង្គ |
|---|---|---|
| សុញ្ញតវគ្គស្ស ចូឡសុញ្ញតសុត្តេ | អរញ្ញសញ្ញា . . . | ៣ |
| | បឋវីសញ្ញា . . . | ៥ |
| | វិញ្ញាណញ្ចាយតនសញ្ញា . | ៧ |
| | អាកិញ្ចញ្ញាយតនសញ្ញា . . | ៩ |
| | នេវសញ្ញានាសញ្ញាយតនសញ្ញា | ១១ |
| | អនិមិត្តចេតោសមាធិ . . | ១៣ |
| | សុញ្ញតាវិហារោ . . . | ១៥ |


### ទុតិយំ មហាសុញ្ញតសុត្តំ


| | | |
|---|---|---|
| សុញ្ញតវគ្គស្ស មហាសុញ្ញតសុត្តេ | វិហារវិហរនាការោ . . . | ១៩ |
| | សុញ្ញតូបសម្បជ្ជ . . . | ២១ |
| | គន្តុំ គន្តុំ សម្បជានោ . . | ២៣ |
| | បញ្ចកាមគុណា . . . | ២៥ |
| | ទសកថាវត្ថូនិ . . . | ៣១ |
| | អន្តេវាសូបទ្ទវោ . . . | ៣៣ |


## សង្ខេបមាតិកា

## សុញ្ញតវគ្គ

### ចូឡសុញ្ញតសូត្រ ទី ១


| | | លេខទំព័រ |
|---|---|---|
| សុញ្ញតវគ្គ ចូឡសុញ្ញតសូត្រ | អរញ្ញសញ្ញា . . . . | ៣ |
| | បឋវីសញ្ញា . . . . | ៤ |
| | វិញ្ញាណញ្ចាយតនសញ្ញា . . | ៧ |
| | អាកិញ្ចញ្ញាយតនសញ្ញា . . | ៩ |
| | នេវសញ្ញានាសញ្ញាយតនសញ្ញា . | ១០ |
| | អនិមិត្តចេតោសមាធិ . . . | ១៣ |
| | ការនៅដោយសុញ្ញតៈ . . . | ១៥ |


### មហាសុញ្ញតសូត្រ ទី ២


| | | |
|---|---|---|
| សុញ្ញតវគ្គ មហាសុញ្ញតសូត្រ | ពាក្យថាឋានៈនិងមិនមែនឋានៈ . . | ១៩ |
| | ការសម្រេចនូវសុញ្ញតផលសមាបត្តិ . | ២១ |
| | ការដើរច្រាសក្នុងហេតុនោះ . . | ២៣ |
| | កាមគុណប្រាំ . . . . | ២៥ |
| | កថាវត្ថុដប់ . . . . | ៣១ |
| | ឧបទ្រពសិស្ស . . . . | ៣៣ |

អង្កេ

សុញ្ញតវគ្គស្ស មហាសុញ្ញតសុត្តេ ព្រហ្មចារូបទ្ទវោ . . . ៣៥

មិត្តប្បដិបត្តិ . . . . ៣៧

## តតិយំ អច្ឆរិយព្ភុតធម្មសុត្តំ

សុញ្ញតវគ្គស្ស អច្ឆរិយព្ភុតធម្មសុត្តេ អត្តកថា . . . . ៤១

តុសិតកាយូបបត្តិ . . ៤៣

មាតុកុច្ឆោក្កន្តិ . . . ៤៥

មាតុកុច្ឆិនិក្ខមនំ . . . ៥១

ភាសិតាភិនន្ទនំ . . . ៥៧

## ចតុត្ថំ ពក្កុលត្ថេរច្ឆរិយព្ភុតសុត្តំ

សុញ្ញតវគ្គស្ស ពក្កុលត្ថេរច្ឆរិយព្ភុតសុត្តេ អច្ឆរិយតា . . . ៥៩

## បញ្ចមំ ទន្តភូមិសុត្តំ

សុញ្ញតវគ្គស្ស ទន្តភូមិសុត្តេ ភគវន្តូបសង្កមនំ . . . ៦៧

ហត្ថិទម្មូបមា . . . . ៦៩

មហាបព្វតូបមា . . ៧១

នាគោបមា . . . . ៧៥

ពុទ្ធគុណកថា . . . . ៧៩





លេខទំព័រ

សុញ្ញតវគ្គ មហាសុញ្ញតសូត្រ ឧបទ្រពព្រហ្មចារី . . . ៣៥

សេចក្តីប្រតិបត្តិជាមិត្ត . . . ៣៧

## អច្ឆរិយព្ភូតធម្មសូត្រ ទី ៣

សុញ្ញតវគ្គ អច្ឆរិយព្ភូតធម្មសូត្រ អត្តកថា . . . . . ៤១

ពោធិសត្វកើតក្នុងទីក្រុងទេវតាជាន់តុសិត ៤៣

ពោធិសត្វចុះកាន់ផ្ទៃមាតា . . ៤៥

ពោធិសត្វចេញចាកផ្ទៃមាតា . . ៥១

ការត្រេកអរចំពោះភាសិត . . ៥៧

## ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ ទី ៤

សុញ្ញតវគ្គ ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ សេចក្តីអស្ចារ្យ . . . ៥៩

## ទន្តភូមិសូត្រ ទី ៥

សុញ្ញតវគ្គ ទន្តភូមិសូត្រ អចិរវតសមណុទ្ទេស ចូលគាល់ព្រះ

មានព្រះភាគ . . . . ៦៧

ឧបមាដោយដំរីដែលគួរទូន្មាន . ៦៩

ឧបមាដោយភ្នំ . . . . ៧១

ឧបមាដោយដំរី . . . . ៧៥

ពោលអំពីពុទ្ធគុណ . . . ៧៩

អង្គ

សុញ្ញាគារវគ្គស្ស ទុតិយសុត្តំ ចតុសតិប្បដ្ឋានំ . . . . ៨១

អទន្តនាគោបមា . . . . ៨៧

ទន្តនាគោបមា . . . . . ៨៩

ឆដ្ឋំ ភូមិចលសុត្តំ

សុញ្ញាគារវគ្គស្ស ភូមិចលសុត្តំ ព្រហ្មចរិយចរណំ . . . . ៩១

ភគវន្តុបសង្កមនំ . . . . ៩៣

តេលត្ថិកោបមា . . . . ៩៧

ខីរត្ថិកោបមា . . . . . ៩៩

ផលាធិគមការណំ . . . . ១០១

តេលត្ថិកោបមា . . . . ១០៣

នវនីតោបមា . . . . . ១០៥

កាលកិរិយាខន្ធំ . . . . ១០៧

សត្តមំ អនុរុទ្ធសុត្តំ

សុញ្ញាគារវគ្គស្ស អនុរុទ្ធសុត្តំ អនុរុទ្ធុបសង្កមនំ . . . . ១០៩

បោរាណមុត្តិវិសជ្ជនំ . . . . ១១១

បត្តវិបត្តិ . . . . . ១១៥

ទោសាភាសព្យាករណំ . . . . ១១៧

ចបនីយកាលការេ . . . . ១២៧





លេខទំព័រ

សុញ្ញាគារវគ្គ ទុតិយសូត្រ ធម៌មានសតិប្បដ្ឋានបួនជាដើម . . ៨១

ឧបមាដោយដំរីមិនទាន់ទូន្មាន . . ៨៧

ឧបមាដោយដំរីដែលទូន្មានហើយ . . ៨៩

ភូមិចលសូត្រ ទី ៦

សុញ្ញាគារវគ្គ ភូមិចលសូត្រ ការប្រព្រឹត្តព្រហ្មចរិយៈ . . . ៩១

ការចូលទៅគាល់ព្រះមានព្រះភាគ . ៩៣

ឧបមាដោយបុរសអ្នកត្រូវការដោយប្រេង ៩៧

ឧបមាដោយបុរសអ្នកត្រូវការទឹកដោះស្រស់ ៩៩

ការពោលកិរិយាត្រាស់ដឹងនូវផល . . . ១០១

ឧបមាដោយបុរសអ្នកត្រូវការប្រេង . ១០៣

ឧបមាដោយបុរសអ្នកត្រូវការទឹកដោះខាប់ ១០៥

សេចក្ដីកំណត់យកចំពោះកាលសំរេច . . ១០៧

អនុរុទ្ធសូត្រ ទី ៧

សុញ្ញាគារវគ្គ អនុរុទ្ធសូត្រ បុរសម្នាក់ចូលទៅរកព្រះអនុរុទ្ធ . . ១០៩

សេចក្ដីដោះស្រាយនូវបោរាណមុត្ត . . ១១១

កិរិយាកើតកត្តរិកតាំងបួន . . . ១១៥

ព្យាករណ៍នូវសេចក្ដីទោស . . . ១១៧

ការៈនៃតាក្សន . . . . . ១២៧

អង្កេ

## អដ្ឋមំ ឧបក្កិលេសសុត្តំ

សុត្តន្តស្ស ឧបក្កិលេសសុត្ត កោសម្ពកា ភណ្ឌនំ . . . ១៣១
ភណ្ឌនមាតុកថា . . ១៣៣
ពាយពាលស្ស ភណ្ឌំ . . ១៣៧
ឯកចិត្តកាលេ . . . . ១៣៩
អប្បមត្តកាលេ . . . ១៤៣
អទ្ធានមគ្គប្បដិបន្នូបមា . . ១៤៧
អច្ចារទ្ធវីរិយកាលេ . . . ១៤៩
អភិជ្ឈាបច្ចុប្បន្នា . . . ១៥១
បរិតុត្តប្បច្ចេក . . . ១៥៣
តិវិធភាវនា . . . . ១៥៩

## នវមំ ពាលបណ្ឌិតសុត្តំ

សុត្តន្តស្ស ពាលបណ្ឌិតសុត្ត ពាលទុក្ខទោមនស្សំ . . ១៦៣
សត្តិហតូបមា . . . ១៦៩
បញ្ចវិធគុណ . . . . ១៧១
និរយកថា . . . . ១៧៣
តិរច្ឆានកថា . . . ១៧៥
កាណកច្ឆបោបមា . . . ១៧៩



លេខទំព័រ

## ឧបក្កិលេសសូត្រ ទី ៨

សេចក្តីផ្តើម ឧបក្កិលេសសូត្រ ព្រះមានព្រះភាគទ្រង់ឃាត់ភិក្ខុ . ១៣១
គាថាប្រកាសទោសនៃការជេរគ្នា . . . . ១៣៣
ពួកភិក្ខុហាមឃាត់ព្រះមានព្រះភាគ . ១៣៧
ការនៃបុគ្គលមានចិត្តជាមួយគ្នា . . . ១៣៩
ការនៃបុគ្គលមិនធ្វេសប្រហែស . . . ១៤៣
ឧបមាដោយបុរសដើរផ្លូវឆ្ងាយ . . . ១៤៧
ការនៃបុគ្គលមានសេចក្តីព្យាយាមក្លាពេក . ១៤៩
ការកើតឡើងនៃសេចក្តីប្រាថ្នាហួសពេក . . ១៥១
ការកើតឡើងនៃសេចក្តីក្រអឺត . . . ១៥៣
ភាវនា ៣ ប្រការ . . . . . ១៥៩

## ពាលបណ្ឌិតសូត្រ ទី ៩

សេចក្តីផ្តើម ពាលបណ្ឌិតសូត្រ ទុក្ខនិងទោមនស្សរបស់បុគ្គលពាល . ១៦៣
ឧបមាដោយបុរសត្រូវលំពែង . . . ១៦៩
កំណត់ប្រាំប្រការ . . . . . . ១៧១
និយាយអំពីនរក . . . . . . ១៧៣
និយាយអំពីកំណើតសត្វតិរច្ឆាន . . . ១៧៥
ឧបមាដោយអណ្តើកខ្វាក់ . . . . ១៧៩

អង្ក

សុត្តន្តស្ស ពាលបណ្ឌិតសុត្តេ ពាលភូមិ . . . . ១៨១
បណ្ឌិតទិដ្ឋធម្មសុខំ . . . ១៨៣
ចក្ករតនំ . . . . . ១៩១
អស្សរតនំ . . . . ១៩៥
ឥត្ថីរតនំ . . . . . ១៩៧
គហបតិរតនំ . . . . ១៩៩
ចក្កវត្តិសុខំ . . . . ២០១
បណ្ឌិតសុខំ . . . . ២០៥

## ទសមំ ទេវទូតសុត្តំ

សុត្តន្តស្ស ទេវទូតសុត្តេ បឋមទេវទូតោ . . . ២០៩
ទុតិយទេវទូតោ . . . ២១៣
តតិយទេវទូតោ . . . ២១៥
ចតុត្ថទេវទូតោ . . . ២១៧
បញ្ចមទេវទូតោ . . . ២១៩
មហានិរយោ . . . ២២៣
គូថកុក្កុលនិរយោ . . . ២២៧
ខារោទកា នទី . . . ២២៩
និគមគាថា . . . . ២៣១



លេខទំព័រ

សុត្តន្ត ពាលបណ្ឌិតសូត្រ ពាលភូមិ . . . . . ១៨១
សុខក្នុងបច្ចុប្បន្នរបស់បណ្ឌិត . . ១៨៣
ចក្ករ័តន៍ . . . . . . ១៩១
អស្សរ័តន៍ . . . . . . ១៩៥
ឥត្ថីរ័តន៍ . . . . . . . ១៩៧
គហបតិរ័តន៍ . . . . . . ១៩៩
សេចក្តីសុខរបស់ស្តេចចក្រពត្តិ . . ២០១
សេចក្តីសុខរបស់បណ្ឌិត . . . . ២០៥

## ទេវទូតសូត្រ ទី ១០

សុត្តន្ត ទេវទូតសូត្រ ទេវទូតទីមួយ . . . . . ២០៩
ទេវទូតទីពីរ . . . . . ២១៣
ទេវទូតទីបី . . . . . ២១៥
ទេវទូតទីបួន . . . . . ២១៧
ទេវទូតទីប្រាំ . . . . . ២១៩
មហានរក . . . . . ២២៣
គូថនរកនិងកុក្កុលនរក . . . ២២៧
ស្ទឹងទឹកប្រៃ . . . . . ២២៩
និគមគាថា . . . . . ២៣១

## វិរុទ្ធាវិរុទ្ធបត្ត

| វិរុទ្ធាចារ | អវិរុទ្ធាចារ | អង្គ | បន្ទាត់លេខ |
|---|---|---|---|
| ទ័រេ | ទ័រស្ស | ៩៩ | ៩ |
| ព្រហ្ម | ព្រហ្ម- | " | ១៤ |
| អាយោនិរេសា | អាយោនិរេសា | ១០៦ | ២ |
| កូម៉ផស្សេក្ត | កូម៉ផស្សេក្ត | ១០៣ | ១ |
| ការយស្ស | ការយស្ស | ១១៧ | ១៨ |
| យោ តាយ | យោ តាយំ | ១៦០ | ១១ |
| ទេវនិកាយ | ទេវនិកាយំ | ១៦៣ | ១៤ |
| កហុមុទមំ | កហុមុទម្ង | ១៦៤ | ៣ |
| ពុ | ពុ- | ១៧៤ | ៨ |
| បក្កក្តិស | បក្កក្តិស្ស | ១៩៨ | ៤ |
| - | - | ១៩៨ | ១១ |
| បរិក្ខា | បរិក្ខា | ២០៤ | ៨ |
| កិបក្តិ | កិបក្តិ | ២០៩ | ១៨ |

## វិរុទ្ធាវិរុទ្ធបត្ត

| វិរុទ្ធាចារ | អវិរុទ្ធាចារ | អង្គ | បន្ទាត់លេខ |
|---|---|---|---|
| ជាតាកិយៅ | ជាតាកិ យេ | ១៤ | ៧ |
| អរិយ្ហាសរិ | អរិយ្ហាសរិ បរិច្ច | ១៤ | ៩ |
| វិហារក្តិ(១) | វិហារក្តិ | ១២ | ៧ |
| និពេ | និពេ- | ២៧ | ៦ |
| ហាតំ | ហាតិ | ៣១ | ៨ |
| កាបត្តិ | កាបត្តិ | ៣៣ | ៤ |
| មុក្កាយ | មុក្កាវកាយ | ៣៦ | ១០ |
| កាយូបបត្តិ | កាយូបបត្តិ | ៤៣ | ១ |
| អញ្ញោប | អញ្ញោប | ៤៦ | ៩ |
| អច្ចាយក្កាមស្សេក្ត | អច្ចាយក្កាតមស្សេក្ត | ៨៧ | ១១ |
| នាកិជាម៉ | នាកិជាតាម៉ | ២៤ | ១៣ |
| បរិយត្តិ | បរិយត្តិ | ២៧ | ៨ |
| លក្ខាយំ | លក្ខា យំ | ២៨ | ១២ |
| ម៉ញ្ញាចិត្ត នោ | ម៉ញ្ញាចិត្តនោ | ៩៦ | ១០ |
| ទេសំនា- | ទេសំ-នា- | ៩៩ | ៦ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| សិប់ ជឿ | ជឿសិប់ | ៦ | ៨ |
| ខ្ញុំជាសការៈ | ខ្ញុំសការៈ | ១៤ | ៤ |
| ទេមថ | ទេមក | ១៧ | ៥ |
| សញាក | សុញ្ញាក | ៤៨ | ១ |
| ឈរពេជាយ | ឈរៈជាយ | " | ៤ |
| ក្រហ្មពារ្យ | ក្រហ្មពារី | ៣៤ | ១១ |
| " | " | ៣៨ | ១ |
| " | " | " | ១៨ |
| " | " | ៣៦ | ៦ |
| " | " | " | ៤ |
| អនីយ | អនិយ | ៤១ | ១៣ |
| ខ្ញុំកាំពោះ | ខ្ញុំកែពោះ | ៤៥ | ១៤ |
| អច្ច័យមុគធម៌ | អច្ច័យពុគធម៌ | ៨១ | ១៦ |
| កំពុងចំពាស៊ីកាម | ដែលកាមវិតក្កៈកំពុង | | |
| វិតក្កៈ | ចំពាស៊ី | ៦៥ | ៣ |
| " | " | ៧០ | ១១ |
| " | - | ៧៣ | ៨ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ញុំកី | ញុំញី | ៧៨ | ៨ |
| ទោះ | នេះ | ៧៥ | ១០ |
| ដោយកាម | ដោយកាយ | ៨៣ | ៤ |
| ផលធ្វើ | ផែលធ្វើ | ៨៥ | " |
| កពាន: | កញ្ញាន: | ១០៥ | ៣ |
| សុក្កខបង្កៈ | សុគ្គខបង្ក | ១៤៨ | ១ |
| មជ្ឈិមនិកាយស | មជ្ឈិមនិកាយ | " | " |
| សាល់ឮស់ | ស្គាល់ឮស់ | ១៨៨ | ៥ |
| ឃើញរូប | ឃើញរូប | " | ១៨ |
| ខ្ញុំកេ | ខ្ញុំកេ | ១៦៧ | ១១ |
| ដែលគធ្វើ | ដែលគេធ្វើ | ១៨៧ | ៣ |
| មជមនិកាយ | មជ្ឈិមនិកាយ | ១៩៦ | ១ |
| មិនមន | មិនមែន | ៤០១ | ១៤ |
| ជាពស្មុគាន | ជាពស្មុគាន | ៤៤១ | ១១ |